ទស្សនាវដ្ដី

# រាជបណ្ឌិត្យសភាកម្ពុជា

Royal Academy of Cambodia Review

Revue de l’Académie Royale du Cambodge

លេខ ៥ ខែ ធ្នូ ឆ្នាំ ២០១៣ | Issue 5 December 2013






រក្សាសិទ្ធិគ្រប់យ៉ាង

**នាយកការផ្សាយ**

| | |
|---|---|
| បណ្ឌិតសភាចារ្យ | ជា ណេង |

**និពន្ធនាយក**

| | |
|---|---|
| បណ្ឌិត | អ៊ិម បុណ្ណា |

**លេខាធិការ**

| | |
|---|---|
| បណ្ឌិត | ជួ ច័ន្ទដារី |
| បណ្ឌិត | ធុយ ចាន់ធួន |
| បណ្ឌិត | ម៉ុង ស៊ាងជីម |
| បណ្ឌិត | សុង ស៊ីណា |
| បណ្ឌិត | តាំង ស៊ិន |

**ហេរញ្ញិក**

| | |
|---|---|
| បណ្ឌិត | អ៊ុំ ប៉ុម |
| បេក្ខជនបណ្ឌិត | លី សុធីរ័ត្ន |
| បេក្ខជនបណ្ឌិត | គឹម ឧទ្ធី |
| បេក្ខជនបណ្ឌិត | ហួត រ៉ា |

**បច្ចេកទេសកុំព្យូទ័រ**

| | |
|---|---|
| បេក្ខជនបណ្ឌិត | សុខ ឧស្សាហ៍ |
| បេក្ខជនបណ្ឌិត | លឹម សេងឌី |
| បេក្ខជនបណ្ឌិត | យិន ពោ |
| បេក្ខជនបណ្ឌិត | ផឿន សុត្ថា |

**អក្ខរាវិរុទ្ធ**

| | |
|---|---|
| បណ្ឌិត | ជួរ តារី |
| បណ្ឌិត | មាឃ បូរ៉ា |
| បេក្ខជនបណ្ឌិត | ប៉ាង ចាន់ថា |
| បេក្ខជនបណ្ឌិត | យិន យ៉ង់ |

**ទីប្រឹក្សា**

| | |
|---|---|
| បណ្ឌិតសភាចារ្យ | ខ្លូត ធីតា |
| បណ្ឌិតសភាចារ្យ | រស់ ចន្ត្រាបុត្រ |
| បណ្ឌិតសភាចារ្យ | ព្រុំ ម៉ល់ |
| បណ្ឌិតសភាចារ្យ | សំ សោភាន់ |
| បណ្ឌិតសភាចារ្យ | ស៊ុំ ឈុំប៊ុន |
| បណ្ឌិតសភាចារ្យ | សោម សុមុនី |

**គណៈកម្មការត្រួតពិនិត្យ**

| | |
|---|---|
| បណ្ឌិត | ច័ន្ទ សំណាញ |
| បណ្ឌិត | ស៊ុន សូត |
| បណ្ឌិត | នូ ចាន់សុភី |
| បណ្ឌិត | សុខ ទូច |

**បោះពុម្ព និង ចែកផ្សាយ**

| | |
|---|---|
| បណ្ឌិត | ព្រុំ ទេវី |
| បេក្ខជនបណ្ឌិត | កែវ សុជាតិ |
| បេក្ខជនបណ្ឌិត | ហេង ហុកវេន |
| បេក្ខជនបណ្ឌិត | ជួន សោរិទ្ធី |
| បេក្ខជនបណ្ឌិត | តាំង មុយគា |

# មាតិកា


១-សេង សំអឿន ៖ ការគ្រប់គ្រងសំណល់នៅរាជធានីភ្នំពេញ ២០០៩-២០១៥......................................១

២-មិន ប្រុសបញ្ញារិទ្ធិ៖ យន្តការសេវាសាធារណៈនៃការនាំអង្ករចេញពីប្រទេសកម្ពុជា(២០០៩-២០១២)..........៦

៣-ជា ប៊ុនធៀង ៖ សិក្សាលើដំណើរការអាជីវកម្មរបស់កំពង់ផែស្វយ័តភ្នំពេញ........................................១១

៤-មាឃ សារី ៖ ប្រវត្តិនៃការវិវត្តការអប់រំដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាព................................១៦

៥-ព្រុំ ធី ៖ ការគ្រប់គ្រងរដ្ឋបាលមូលដ្ឋានតាមប្រព័ន្ធវិមជ្ឈការនិងវិសហមជ្ឈការ..........................២៤

៦-ម៉ុង ស៊ាងងីម ៖ ផលិតភាពនិងគុណភាពនៃពូជដំណាំចំណីសត្វនៅព្រះរាជាណាចក្រកម្ពុជា................៣១

៧-ហ៊ិន សុទ្ធនា ៖ ការលូតលាស់របស់ជ្រូកកូនកាត់ក្នុងស្រុកដោយប្រើស្លឹកមននិងទងដំឡូងផ្ទាស្រស់ ជាប្រភពប្រូតេអ៊ីន............................................................................................៣៩

៨-ឈត ប៊ុនថង ៖ តួនាទីនៃស្ថាប័នព័ត៌មានក្នុងសង្គម.........................................................................៤៤

៩-តឹក មេង ៖ គោលនយោបាយសហរដ្ឋអាម៉េរិកចំពោះកម្ពុជា......................................................៤៧

១០-អ៊ុក វិបុល ៖ គ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជា.................................................................................៥០

១១-កែវ សុជាតិ ៖ ឥទ្ធិពលនៃទស្សនវិជ្ជាម៉ាក្សលេនីន មកលើការវិវត្តន៍នៃប្រទេសកម្ពុជាពីឆ្នាំ១៩៧៩........៦១

១២-សួង ម៉េងឡុង ៖ វិស័យឯកជន និង ការងារ..................................................................................៦៨

១៣-ចិន្តា បណ្ឌិត ៖ ការគ្រប់គ្រងការងារគយនៅទីស្នាក់ការគយនិងរដ្ឋករភ្នំដិន.......................................៧៦

១៤-សូ សុធីរ ៖ ផលវិបាកនិងដំណោះស្រាយនៃវិធីសាស្ត្របង្រៀនភាសាខ្មែរនៅបឋមសិក្សា..................៨២

១៥-សុខ បូរី ៖ របបសន្តិសុខសង្គមនៅក្នុងសហគ្រាសកាត់ដេរភ្នំពេញ.............................................៨៧

១៦-ជួន រក្សា ៖ កត្តាដែលនាំឱ្យការគ្រប់គ្រងរដ្ឋបាលមូលដ្ឋានមានប្រសិទ្ធភាព....................................៩១

# ការគ្រប់គ្រងសំណល់នៅរាជធានីភ្នំពេញ ២០០៩-២០១៥



សេង សំអឿន
បេក្ខជនបណ្ឌិត ផ្នែកភូមិវិទ្យា
នៃរាជបណ្ឌិត្យសភាកម្ពុជា

## សេចក្តីផ្តើម

បច្ចុប្បន្នកំណើនបរិមាណសំណល់រឹងរាវកំពុងតែក្លាយជាបញ្ហាប្រឈមលើសុខភាពមនុស្សសត្វ និងបរិស្ថានដែលបញ្ហាសំណល់រឹងនេះក្លាយជាបញ្ហាចម្បងទី៣នៃបញ្ហាបរិស្ថានដែលសហគមន៍អន្តរជាតិកំពុងដោះស្រាយ។ តាមរយៈការព្រួយបារម្ភជាសកលលើកត្តាដែលធ្វើឱ្យមានការបញ្ចេញឧស្ម័នផ្ទះកញ្ចក់យ៉ាងច្រើនសន្ធឹកសន្ធាប់ចូលទៅក្នុងបរិយាកាសធ្វើឱ្យមានការប្រែប្រួលអាកាសធាតុនិងការកើនឡើងកម្តៅផែនដីនោះ កត្តាសំណល់រឹងក៏ជាប្រភពមួយដ៏សំខាន់ដែលចូលរួមបញ្ចេញបរិមាណឧស្ម័នផ្ទះកញ្ចក់នេះដែរជាពិសេសឧស្ម័នមេតាន។ ផលប៉ះពាល់នៃការផ្លាស់ប្តូរអាកាសធាតុមិនបញ្ឈប់ត្រឹមព្រំដែនប្រទេសទេ ពោលគឺទាំងប្រទេសជឿនលឿននិងប្រទេសកំពុងតែអភិវឌ្ឍសុទ្ធតែទទួលរងគ្រោះដូចគ្នា។ នេះជាបញ្ហាចម្បងដែលត្រូវចាត់វិធានការដោះស្រាយជាបន្ទាន់។ ទីក្រុងទីប្រជុំជនជាច្រើន ជាពិសេសនៅរាជធានីភ្នំពេញកំពុងជួបប្រទះនឹងបញ្ហាទុកដាក់សំណល់រឹងយ៉ាងធ្ងន់ធ្ងរផងដែរ។

យ៉ាងណាមិញ ប្រទេសកម្ពុជាបន្ទាប់ពីការបង្កើតទីផ្សារសេរីធ្វើឱ្យសេដ្ឋកិច្ចរីកចម្រើនយ៉ាងឆាប់រហ័សដែលជាបុព្វហេតុធ្វើឱ្យមានការបម្លាស់ទីពីជនបទមកកាន់ទីក្រុងយ៉ាងច្រើនសន្ធឹកសន្ធាប់។ ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានធ្វើឱ្យប្រទេសកម្ពុជាឈានឆ្ពោះទៅមុខយ៉ាងរឹងមាំប្រកបដោយភាពសុទិដ្ឋិនិយមនិងការប្តេជ្ញាខ្ពស់ក្នុងការអភិវឌ្ឍប្រទេសជាតិដើម្បីកែប្រែមុខមាត់ថ្មីនិងលើកស្ទួយកិត្តិសព្ទប្រទេសកម្ពុជាឱ្យបានល្អប្រពៃដូចសម័យអង្គរដ៏រុងរឿងដែលកូនខ្មែរគ្រប់ៗរូបមិនអាចបំភ្លេចបានដើម្បីជំរុញការអភិវឌ្ឍប្រទេសឱ្យបានជឿនលឿនប្រមុខរាជរដ្ឋាភិបាលគឺបានចេញយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដើម្បីលើកទឹកចិត្តដល់វិស័យឯកជនក្នុងការទាក់ទាញវិនិយោគទាំងក្នុងនិងក្រៅប្រទេស។

## ក.ស្ថានភាពគ្រប់គ្រងសំណល់រឹង

### ១.ទីតាំងភូមិសាស្ត្ររាជធានីភ្នំពេញ

ប្រទេសកម្ពុជាស្ថិតនៅភូមិភាគអាស៊ីអាគ្នេយ៍ចន្លោះខ្សែស្របទី១០និងទី១៥នៃរយៈទទឹងខាងជើង និងនៅខ្សែបណ្តោយទី១០២និង១០៨នៃរយៈបណ្តោយខាងកើត។ ប្រទេសកម្ពុជាមានផ្ទៃដី១៨១.០៣៥គ.ម$^{២}$។ ប្រទេសកម្ពុជាមានទំនាបនៅចំកណ្តាលដែលព័ទ្ធជុំវិញទៅដោយភ្នំនិងខ្ពង់រាបនៅតាមព្រំប្រទល់ជាមួយថៃលាវនិងវៀតណាម។ ប្រទេសកម្ពុជាស្ថិតនៅតំបន់ត្រូពិចក្តៅហើយសើមស្ថិតនៅក្បែរអេក្វាទ័រ។ សីតុណ្ហភាពជាមធ្យម គឺជុំវិញ២៦$^{0}$ ᶜហើយមិនសូវខុសគ្នាប៉ុន្មានទេពីរដូវមួយទៅរដូវមួយ។ កម្ពស់ទឹកភ្លៀងប្រចាំឆ្នាំលើសពី ២.០០០ម.ម.។ គេហៅអាកាសធាតុតំបន់ដែលមានរដូវពីរផ្សេងគ្នា ពោលគឺរដូវប្រាំងនិងរដូវវស្សាថា អាកាស-ធាតុស្ទើរត្រូពិច។ អាកាសធាតុនេះគឺងាយទទួលជំងឺឆ្លងផ្សេងៗតាមរយៈការបំពុលនូវសំណល់រឹងនិងសំណល់រាវដែលមនុស្សបានបោះចោលឬបញ្ចេញចោលមិនបានគ្រប់គ្រងត្រឹមត្រូវ។

រាជធានីភ្នំពេញមានខណ្ឌចំនួន៩ សង្កាត់មានចំនួន៨៩ ភូមិមានចំនួន៦៣៧ និងប្រជាជនសរុប ១-៤៩៧ ២៤៦នាក់ បានបែងចែកដូចតទៅ ១-ដូនពេញ ២-ទួលគោក ៣-៧មករា ៤-ឫស្សីកែវ ៥-ចំការមន ៦-សែនសុខ ៧-មានជ័យ ៨-ដង្កោ ៩-ពោធិ៍សែនជ័យ។

**១.១.សណ្ឋានដី**

រាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅរយៈបណ្តោយខាងកើតទី១០៤° ៦០′ និងរយៈទទឹងខាងជើងទី១១° ៨០′ ដែលមានរយៈកម្ពស់៤-១៧ម៉ែត្រពីនីវ៉ូសមុទ្រ។ ភ្នំពេញស្ថិតនៅចន្លោះទន្លេមេគង្គ និងទន្លេសាបដែលមានរាងជ្រុងទ្រវែង។ ប្រវែងពីជើងទៅត្បូងមានប្រវែង២៨គ.ម.និងពីលិចទៅកើតមានប្រវែង ២១គ.ម.។ នៅផ្នែកខាងកើតមានទន្លេចតុមុខ គឺទន្លេមេគង្គលើ ទន្លេមេគង្គក្រោម ទន្លេសាបនិងទន្លេបាសាក់ប្រសព្វគ្នា។

**១.២.អាកាសធាតុ**

ជាទូទៅរាជធានីនិងតំបន់ដទៃទៀត នៅក្នុងប្រទេសកម្ពុជាទាំងមូល គឺទទួលរបបខ្យល់មូសុងត្រូពិច ដែលមានលក្ខណៈក្តៅហើយសើមពេញមួយឆ្នាំ ក៏ប៉ុន្តែសីតុណ្ហភាពមានសភាពត្រជាក់បន្តិចនៅចន្លោះ ខែវិច្ឆិកា រហូតដល់ខែមករា។ ខែដែលក្តៅជាងគេគឺខែមេសា ដែលសីតុណ្ហភាពអាចឡើងពី៣៤$^{0}$C ទៅដល់៣៨*C។ រដូវភ្លៀងចាប់ផ្តើមពីខែមិថុនាដល់ខែតុលា ដោយនាំមកជាមួយនូវខ្យល់ សំណើមនិងភ្លៀងខ្លាំងទិន្នន័យអំពីកម្ពស់ទឹកភ្លៀងសីតុណ្ហភាពពន្លឺព្រះអាទិត្យ រំហួតនិងសំពាធត្រូវវាស់វែងដោយស្ថានីយ៍ឧតុនិយមពោធិ៍ចិនតុងភាគខាងលិចរាជធានីភ្នំពេញ។

**១.៣.កម្ពស់ទឹកភ្លៀង**

ជាមធ្យមកម្ពស់ទឹកភ្លៀងពីឆ្នាំ២០១០-២០១១ គឺមាន ១៤១🗎 ០២ម.ម. ចំណែកអប្បបរមាគឺមាន ១៤៩🗎៣៧ម.ម.និងអតិបរមាគឺ១៦១🗎 ៥៦ម.ម. ខែដែលមានកម្ពស់ទឹកភ្លៀងខ្ពស់បំផុតគឺខែកញ្ញាដែលមានកម្ពស់ជាមធ្យម២៦៤🗎 ៣២ម.ម. បន្ទាប់មកខែសីហាមានភ្លៀងធ្លាក់ច្រើនផងដែរគឺមានកម្ពស់ទឹកភ្លៀងជាមធ្យម២៦០🗎 ៧៤ម.ម. ខែមានកម្ពស់ទឹកភ្លៀងតិចជាងគេគឺខែកុម្ភៈមានកម្ពស់មធ្យមត្រឹមតែ២🗎 ៤៥ម.ម. ប៉ុណ្ណោះ។

**១.៤.សីតុណ្ហភាព**

តាមការសិក្សាអំពីសីតុណ្ហភាពបានឱ្យដឹងថាសីតុណ្ហភាពអប្បបរមាគិតជាមធ្យមក្នុងរយៈពេលប្រាំឆ្នាំ គឺ២៤🗎 ៤៥*C ចំពោះខែមានសីតុណ្ហភាពត្រជាក់ជាងគេ គឺខែធ្នូនិងមករាមានសីតុណ្ហភាពរហូតដល់២២🗎 ៨៣*C និង២២🗎 ២៦*C ចំណែកឯសីតុណ្ហភាពអតិបរមាគិតជាមធ្យមក្នុងរយៈពេលប្រាំឆ្នាំ គឺ៣៣🗎 ១៥*C ហើយខែមានសីតុណ្ហភាពក្តៅខ្លាំងជាងគេគឺខែមេសានិងឧសភាមានសីតុណ្ហភាពមធ្យមជាអតិបរមា ៣៥🗎 ៦២*C នៅខែមេសានិង៣៥🗎០៦*C នៅខែឧសភា។ ជាធម្មតាថ្ងៃរះនៅម៉ោង៥.៥២នាទីព្រឹកនិងលិចនៅម៉ោង ៥.៣៦នាទីល្ងាច។

## ២.ទីតាំងភូមិសាស្ត្រទីលានចាក់សំណល់

ទីលានចាក់សំណល់ថ្មី ស្ថិតក្នុងភូមិតាឡី សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ។ កន្លែងនេះជាទីតាំងថ្មីមួយសម្រាប់ដំណើរការទីលានចាក់សំណល់ដែលមានប្រព័ន្ធបច្ចេកទេសសម្រាប់គ្រប់គ្រងសំណល់ដូចជាប្រព័ន្ធគ្រប់គ្រងទឹកលេចចេញឡដុតកម្តៅនិងការដំឡើងឡជីវឧស្ម័នទីតាំងចាក់សំណល់ថ្មីនេះមានផ្ទៃដីប្រមាណ

៣១ហ.ត. ហើយមានចម្ងាយប្រមាណ១៥គ.ម.ពីរាជធានីភ្នំពេញ។ ទីលានចាក់សំរាមនេះ ត្រូវចែកចេញជាផ្នែកគឺ ផ្នែកA មានផ្ទៃប្រមាណ១២ហ.ត. និងផ្នែកB មានផ្ទៃប្រមាណ១៩ហ.ត.។

**២.១.បច្ចេកទេសគ្រប់គ្រងទីលាន**

ទីលានមានផ្ទៃដីសរុបទំហំ ៣១ហ.ត. ចែកចេញជាពីរដំណាក់កាលក្នុងការប្រតិបត្តិគឺដំណាក់កាលទី១ប្រើប្រាស់ផ្ទៃដីទំហំ ១២ហ.ត. (បច្ចុប្បន្ន) ហើយដំណាក់កាលទី២ ប្រើប្រាស់ផ្ទៃដីទំហំ ១៩ហ.ត. (ក្នុងអនាគត) ក្នុងដំណាក់កាលទី១តំបន់ចាក់សំរាមត្រូវបានបែងចែកជា២ គឺតំបន់Aនិងតំបន់B ដែលតំបន់A គឺកំពុងតែដំណើរការចាក់សំរាមនាពេលបច្ចុប្បន្ននេះ រីឯតំបន់Bគឺនៅមិនទាន់បានប្រើប្រាស់នៅឡើយទេ។ តំបន់ទាំង២នេះមានជម្រៅប្រមាណ៩ម៉ែត្រដូចគ្នា ហើយក្រាលបាតដោយឥដ្ឋមានកម្រាស់ប្រមាណ២ម៉ែត្រ ម្យ៉ាងទៀតទីតាំងសំខាន់ៗមួយចំនួនដូចជា កន្លែងធ្វើកំប៉ុស្តិ៍ ឡដុតកម្ដៅ រោងជាងនិងឡជីវឧស្ម័នគឺជាផ្នែកសំខាន់ក្នុងការគ្រប់គ្រងទីលានផងដែរបច្ចុប្បន្នទីលានស្ថិតក្នុងដំណាក់កាលជាទីលានត្រួតពិនិត្យ (Controlled Landfill) នៅឡើយ តែក្នុងពេលអនាគតគណៈគ្រប់គ្រងទីលាននឹងប្រឹងប្រែងដើម្បីឱ្យទីលាននេះប្រែក្លាយទៅជាទីលានចាក់សំរាមសុវត្ថិភាពមួយនិងសមស្របទាក់ទិននឹងបច្ចេកទេសក្នុងការគ្រប់គ្រងទីលានវិញ។ ទីលានចាក់សំរាមដង្កោមានប្រព័ន្ធសំខាន់ៗពីរគឺប្រព័ន្ធចម្បងគ្រប់គ្រងក្នុងទីលាននិងប្រព័ន្ធការពារបរិស្ថានក្នុងទីលាន។

**២.២.ក្រុមហ៊ុនទទួលសេវាសំរាម**

ស៊ិនទ្រី គឺជាសាខារបស់ក្រុមហ៊ុន CINTRI មួយដែលមាននៅប្រទេសកម្ពុជា បានផ្ដល់នៅកិច្ចសហការជាមួយសាលារាជធានីភ្នំពេញនៅក្នុងឆ្នាំ២០០២ ក្នុងគោលបំណងផ្ដល់សេវាកម្មប្រមូលសំរាមសម្រាប់រយៈពេល៤៩ឆ្នាំ។ នៅពេលនោះដែរ ក្រុមហ៊ុនក៏បានទទួលយកលក្ខខណ្ឌនៃកិច្ចការសហប្រតិបត្តិការជាមួយនឹងអគ្គិសនីកម្ពុជា(EDC)។ (សូមបញ្ជាក់ដែរថា មានក្រុមហ៊ុនចំនួន៦រួចមកហើយបានទទួលកិច្ចការនេះតែបោះបង់ចោល) ក្នុងការប្រមូលសំរាមរបស់ស៊ិនទ្រី (CINTRI) បានផ្ដល់ការចែកចាយយ៉ាងល្អទូទាំងតំបន់របស់ក្រុមហ៊ុន។ ក្រុមហ៊ុនបានបែងចែកតាមក្រុមការងារដែលមានបុគ្គលិក ១ ១៩០នាក់បានធ្វើការនៅពេលយប់និងពេលថ្ងៃ ក្រុមហ៊ុនមានអ្នកបើកបរចំនួន១៤០នាក់ សម្រាប់បើកត្រាក់ទ័រ១៣៨គ្រឿងមាន៖ ត្រាក់ទ័រសម្រាប់កម្ទេចនិងត្រាក់ទ័របញ្ជាដោយដៃ រួមជាមួយរទេះរុញចំនួន៣៥០ដែលអាចសម្អាតនិងដឹកជញ្ជូនសំរាមនៅគ្រប់តំបន់ការងារទាំងអស់។ ប្រព័ន្ធដឹកជញ្ជូននេះគឺជាប្រព័ន្ធឌីណាមិចមួយដែលអាចផ្ទុកសំរាមបានប្រហែល ១-២០០តោនក្នុងមួយថ្ងៃ ហើយអាចយកទៅចោលនៅកន្លែងចាក់សំរាមដែលមានចម្ងាយជាង ១៥ គ.ម. ពីរាជ-ធានីភ្នំពេញ។ បច្ចុប្បន្នក្រុមហ៊ុនមានអ្នកគ្រប់គ្រងរួមមាន៣រូប គឺ៖ ១-ឧកញ៉ា សេង សារី ជានាយក (នាយកប្រតិបត្តិ) ២-ឯកឧត្តម សេង ចំរើន ជាអនុប្រធាន ៣-លោក ជំទាវ សេង សុរីដា ជាអនុប្រធានទទួលបន្ទុកទំនាក់ទំនងអតិថិជន រដ្ឋបាល ហិរញ្ញវត្ថុនិងព័ត៌មានវិទ្យា។

**២.៣.ការកំណត់តម្លៃសេវាសំរាម**

ការបង់ថ្លៃលើសេវាកម្មប្រមូលសំរាមគេបានបែងចែកជាច្រើនប្រភេទនិងមានតម្លៃខុសៗគ្នាគឺ៖

១.សំរាមតាមលំនៅដ្ឋានរបស់ប្រជាពលរដ្ឋតម្លៃ១ដុល្លារ

២.សំរាមនៅតាមភូមិគ្រឹះតម្លៃ៥ដុល្លារ

៣.សំរាមនៅតាមភោជនីយដ្ឋានតម្លៃ២០ដុល្លារ

៤.សំរាមនៅតាមសណ្ឋាគារ ផ្ទះសំណាក់តម្លៃ២០ដុល្លារ

៥.សំរាមនៅតាមវង្គសាល ខារ៉ាអូខេ តម្លៃ២០ដុល្លារ

៦.សំរាមនៅតាមសាលារៀនឯកជនតម្លៃ៥ដុល្លារ

៧.សំរាមនៅតាមលំនៅដ្ឋានចាប់ពីជាន់ទី១ឡើងទៅតម្លៃ០.៨ដុល្លារ

៨.សំរាមនៅតាមសាលារៀនរដ្ឋ ទីវត្តអារាម ទីសាធារណៈមិនត្រូវបានបង់ថ្លៃនោះទេ។

## ៣-ការទាញយកផលប្រយោជន៍ពីសំរាម

### ៣.១.ការអនុវត្តយន្តការ3Rs

យន្តការការប្រើប្រាស់ឡើងវិញការកាត់បន្ថយនិងកែច្នៃឡើងវិញ បានផ្ដើមអនុវត្តជាផ្លូវការឆ្នាំ២០០៥ ក្នុងសន្និសីទ គណៈរដ្ឋមន្ត្រីក្នុងប្រទេសជប៉ុនដើម្បីលើកកម្ពស់ការអនុវត្តយន្តការ 3Rs ជុំវិញពិភពលោក។ យន្តការការប្រើប្រាស់ឡើងវិញ ការកាត់បន្ថយនិងការកែច្នៃជាយុទ្ធសាស្ត្រមួយដើម្បីសម្រេចបានការគ្រប់គ្រងសំណល់រឹងបែបចម្រុះ។ 3Rs បានឱ្យនិយមន័យថា ជាគោលការណ៍កាត់បន្ថយបរិមាណសំណល់ការប្រើប្រាស់ឡើងវិញនិងការកែច្នៃធនធានដែលបានប្រើប្រាស់រួចនិងផលិតផលក្នុងគោលដៅធានានូវនិរន្តភាពបរិស្ថាន។

**១.ការកាត់បន្ថយ (Reduce)**

ជាការជ្រើសរើសប្រើប្រាស់ផលិតផល ឬធនធានដោយគិតគូរពីការកាត់បន្ថយបរិមាណសំណល់ ឬបង្ការសំណល់ដែលនឹងត្រូវបង្កើតតាមរយៈការកែប្រែផលិតផល ការវេចខ្ចប់ផលិតផល ការផ្លាស់ប្តូរបែបបទនៃការប្រើប្រាស់និងការផលិតនិងមានន័យថា យើងគួរតែកាត់បន្ថយនៃការប្រើប្រាស់។

**២.ការប្រើឡើងវិញ (Reuse)**

មានន័យថាការប្រើប្រាស់សាជាថ្មីនូវផលិតផល ឬផ្នែកណាមួយនៃផលិតផលច្រើនដង ដោយពុំមានឆ្លងកាត់ដំណើរការផលិត។ ការប្រើប្រាស់ឡើងវិញអាចជួយកាត់បន្ថយទាំងបរិមាណនៃសំណល់និងទំហំសំណល់ដែលត្រូវបញ្ចេញចោលក្នុងធុងសំរាម ម្យ៉ាងទៀត ការប្រើប្រាស់ឡើងវិញអាចជាយន្តការដែលផ្តល់ផលចំណេញផ្នែកសេដ្ឋកិច្ចដំណើរការសាមញ្ញនិងអាចអនុវត្តបានសម្រាប់មនុស្សទូទៅ។

**៣.ការច្នៃឡើងវិញ (Recycling)**

ជាដំណើរការផ្លាស់ប្តូរសំណល់ឱ្យក្លាយជាផលិតផលសម្រាប់អ្នកប្រើប្រាស់ ឬឧស្សាហកម្ម ហើយផលិតផលិតផលថ្មីអាចស្ថិតក្នុងរូបភាពដើមឬប្តូររូបរាងថ្មី ការកែច្នៃឡើងវិញធ្វើឡើងក្នុងគោលបំណងបំប្លែងសំណល់ជាផលិតផលថ្មីមួយដែលអាចប្រើប្រាស់បាន។

# សន្និដ្ឋាននិងអនុសាសន៍

## ១.សន្និដ្ឋាន

ជាការពិតណាស់សំណលរឹងជាផ្នែកមួយសំខាន់ណាស់ដែលមនុស្សគ្រប់រូបត្រូវយកចិត្តទុកដាក់បែងចែកនិងគ្រប់គ្រងឱ្យបានត្រឹមត្រូវ ព្រោះសំណល់ទាំងនេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយសុខភាពមនុស្ស សត្វ រុក្ខជាតិ ដូចនេះយើងគ្រប់គ្នាត្រូវមានវិធានការទៅលើបញ្ហាសំណល់។ ការគ្រប់គ្រងសំណល់រឹង ការថែរក្សាគ្រប់ទីកន្លែងដោយឧស្សាហ៍សម្អាត លុបកប់ឬប្រមូលវេចខ្ចប់ទុកដាក់ ឱ្យបានត្រឹមត្រូវនោះសំណល់មិនបង្កគ្រោះថ្នាក់ដល់សុខភាពនិងរក្សាសោភណភាពរាជធានីភ្នំពេញទៀតផង។

## ២.អនុសាសន៍

១-ពង្រឹងកម្មវិធីឃោសនា អប់រំ ការញែកសំណល់នៅតាមប្រភេទសំណល់នានាឱ្យបានទូលំទូលាយ

២-លើកទឹកចិត្តដល់វិស័យសាធារណៈឬវិស័យឯកជនចំពោះសកម្មភាព 3Rs

៣-ចៀសវាងចាក់សំណល់រឹងចូលទៅក្នុងប្រភពទឹកឬគរសំណល់នៅក្បែរលូ ប្រឡាយបង្ហូរទឹកសំអុយ

៤-គ្រប់ទីសាធារណៈត្រូវមានធុងដាក់សំរាមតាមប្រភេទសំរាម

៥-គួរកាត់បន្ថយការប្រើប្រាស់របស់របរដែលបង្កជាសំរាមច្រើន

៦-ក្រុមហ៊ុនត្រូវជ្រើសរើសឡានដឹកសំរាមមានគុណភាពល្អ មិនត្រូវដឹកហួសទម្ងន់កំណត់ និង មានសំណាញ់គ្របពីលើឡាន

៧-ផ្តល់អាទិភាពនិងសេវាកម្មសុខភាពត្រឹមត្រូវចំពោះកម្មករ អ្នកបើកបរដែលបម្រើសេវាសំណល់។

## គន្ថនិទ្ទេស


១.អ៊ូ វ៉ន៉ៈ ទស្សនវិជ្ជាភូមិវិទ្យា ភ្នំពេញឆ្នាំ២០០៨ សម្រាប់បណ្តុះបណ្តាលនិស្សិតថ្នាក់បណ្ឌិត

២.ប៉េង ហុងសុជាតិខេមរ៉ូ បណ្ឌិត ឌី ខាល ឡាទីនីសៈ បុព្វកថា ចំពោះការរៀបចំគ្រប់គ្រងធនធានវប្បធម៌ ខែមករា បោះពុម្ព ឆ្នាំ២០០២

៣.សៀវភៅជំនួយស្មារតីបរិស្ថានៈ បោះពុម្ពដោយក្រសួងបរិស្ថាន ឆ្នាំ២០០០

៤.យុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល  នីតិកាលទី៣ នៃរដ្ឋសភា

៥.ក្រសួងបរិស្ថានៈ ការប្រែប្រួលអាកាសធាតុនិងយន្តការអភិវឌ្ឍស្អាត ឆ្នាំ២០០៤

៦.ឯកសារ និងCDដែលផ្តល់ដោយស្ថានីយ៍ទូរទស្សន៍ជាតិកម្ពុជា ក្នុងកម្មវិធីសមធម៌ ចាក់ផ្សាយថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ២០១០

៧.ហ៊ុន សែន សុន្ទរកថា ស្តីអំពីយុទ្ធសាស្រ្តចតុកោណ (ដំណាក់កាលទី២)

៨.ក្រសួងបរិស្ថានៈ ការប្រែប្រួលអាកាសធាតុ និងយន្តការអភិវឌ្ឍស្អាត ឆ្នាំ២០០៤

៩.Nuptiality . Phnom Penh , NIS, Ministry of Planning, 1999.

១០.Global Disaster Situation and Global Warming from Plan Philippines.

១១.Sarin,C Urban Solid WesteDisposal,A case study of the City of Phnom Penh.

១២.WWW.Cintri  com.Kh/

១៣.Phnompenhpost.Com/City/distric/boeung trabekCommun.

១៤.www.phnom penh.gov.kh\distrct.php

១៥.song khat in khan Duan Penh

# យន្តការសេវាសាធារណៈនៃការនាំអង្ករចេញពីប្រទេសកម្ពុជា(២០០៩-២០១២)

មិន ប្រុសបញ្ញារិទ្ធិ
បេក្ខជនបណ្ឌិត ផ្នែកគ្រប់គ្រងសាធារណៈ
នៃរាជបណ្ឌិត្យសភាកម្ពុជា



## សេចក្តីផ្តើម

ចាប់តាំងពីសម័យបុរាណរហូតមកដល់សតវត្សរ៍ទី២១នេះការគ្រប់គ្រងនៅតែដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើជំនួញទាំងកម្រិតជាតិតំបន់និងពិភពលោក។ ប្រទេសកម្ពុជាមានទីតាំងភូមិសាស្ត្រអំណោយផលដល់ផ្នែកកសិកម្ម ជាពិសេសដំណាំស្រូវបាននិងកំពុងកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំក្នុងកាលៈទេសៈដែលប្រភពថាមពល ពិសេសប្រេងឥន្ធនៈ ស្បៀងអាហារនៅទីផ្សារអន្តរជាតិបានដំឡើងថ្លៃស្របពេលដែលប្រជាជនពិភពលោកកើនឡើងជាង**៧០០០**លាននាក់[១]ផងនោះ តម្រូវការស្បៀងអាហារពិតជាមិនអាចខ្វះបានទេ នៅលើទីផ្សារអន្តរជាតិ។ ឆ្លៀតឱកាសដ៏ល្អនេះ ប្រទេសកម្ពុជាត្រូវតែបង្ហាញពីសក្តានុពលរបស់ខ្លួននៅលើទីផ្សារអន្តរ-ជាតិតាមរយៈការនាំចេញអង្ករដែលអាចចាត់ទុកថាជា**មាសស**របស់កម្ពុជាផងដែរ។ ការនាំចេញអង្ករពីប្រទេសកម្ពុជាវាមិនគ្រាន់តែធ្វើឱ្យអន្តរជាតិស្គាល់អត្តសញ្ញាណនិងរសជាតិផលិតផលខ្មែរប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងនាំមកនូវថវិកាដ៏ច្រើនសន្ធឹកសន្ធាប់សម្រាប់ទ្រទ្រង់ប្រទេសជាតិនិងអភិវឌ្ឍន៍នូវហេដ្ឋារចនាសម្ព័ន្ធ យន្តការគ្រប់គ្រង ការធ្វើទំនាក់ទំនងអន្តរជាតិ បើកចំហទីផ្សារសេរីឱ្យកាន់តែធំទូលាយមានស្ថិរភាពនយោបាយនាំមកនូវវិបុលភាពសង្គមកម្ពុជានាសម័យសាកលូបនីយកម្មនេះ។ តាមរយៈអង្គការស្បៀងអាហារពិភពលោក ក្នុងឆ្នាំ២០០៩និង២០១០ បរិមាណអង្ករដែលត្រូវនាំចេញទៅទីផ្សារអន្តរជាតិមានការកើនឡើងពី **២៩,៧លាន-តោនដល់៣១,៣លានតោន**[២] នៅឆ្នាំ២០១១ បរិមាណអង្ករនាំចេញទៅកាន់ទីផ្សារអន្តរជាតិកើនដល់ **៣៤,៧៨-លានតោន**[៣]។ បរិមាណអង្ករកើនឡើងបែបនេះ គឺជាឱកាសដ៏ល្អសម្រាប់បណ្តាប្រទេសផលិតស្រូវក្នុងនោះកម្ពុជាក៏ជាប្រទេសមួយដែលផលិតស្រូវផងដែរបាននិងកំពុងយកចិត្តទុកដាក់លើការនាំចេញអង្ករទៅកាន់ទីផ្សារអន្តរជាតិ។ តើមានទ្រឹស្តី-គោលការណ៍និងយន្តការអ្វីខ្លះដែលអាចជំរុញដល់ការនាំចេញអង្ករពីប្រទេសកម្ពុជា ?

## ១.ទ្រឹស្តីទូទៅនៃការគ្រប់គ្រងតាមប្រព័ន្ធសេដ្ឋកិច្ចនិងគោលការណ៍ជំរុញការនាំចេញ

### ១.១-ទ្រឹស្តីគ្រប់គ្រងតាមប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី

សេដ្ឋវិទូបានអះអាងថា ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី គឺមានប្រសិទ្ធភាពក្នុងការបែងចែកធនធានសេដ្ឋ-កិច្ច ពីព្រោះការប្រកួតប្រជែងក្នុងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរីបង្ខំឱ្យបញ្ជូនធនធានសេដ្ឋកិច្ចទៅក្នុងផលិតកម្មដែលផលិតនិងសេវាសម្រាប់តម្រូវការសង្គម[៤]។ ការប្រកួតប្រជែងបង្ខំឱ្យមានការប្រើប្រាស់វិធីសាស្ត្រដែលមានប្រសិទ្ធភាពក្នុងការចាត់ចែងធនធានសម្រាប់ដំណើរការផលិតនិងសុក្រឹតភាពបច្ចេកវិទ្យាទំនើប។ ជាពិសេស

---

[១] http://www.en.m.wikipedia,*the world population is the sum total of all living humans on earth. As of today, it is estimated to number 7.035 billion bythe United States Census Bureau.* The United States Bureau estimates that the world population exceeded 7 billion on March/12/2012

[២] រាជរដ្ឋាភិបាលកម្ពុជា៖ ឯកសារ គោលនយោបាយស្តីពី*ការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ* ២០១០ ទំព័រ ៤០

[៣] http://www.oryza.com/..FAO *Global Rice Exports estimates 2011 and 2012.*

[៤] ហ៊ាន សាហ៊ីប៖ *គ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* ភ្នំពេញ ២០០៦ ទំព័រ ១៩

សុក្រឹតភាពការប្រើប្រាស់ធនធាននានាដើម្បីឱ្យមានស្ថិរភាពយូរអង្វែង។ សរុបមកក្នុងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ "ដៃអរូប" គ្រប់គ្រងអត្ថប្រយោជន៍បុគ្គលសម្រាប់ជំរុញឱ្យមានការផ្គត់ផ្គង់ទំនិញនិងសេវាចាំបាច់សម្រាប់សង្គម។ ការងារសំខាន់របស់**អាដាមស្មីត**នៅក្នុងស្នាដៃដ៏ល្បីល្បាញដែលមានចំណងជើងថា "ភោគទ្រព្យប្រជាជាតិ" គឺត្រូវអភិវឌ្ឍរចនាសម្ព័ន្ធមួយជាយន្តការដែលងាយយល់តាមរយៈការបង្ហាញឱ្យឃើញពីសកម្មភាពអ៊ូអរកងរំពងនៃពាណិជ្ជកម្មប្រចាំថ្ងៃជាការពិតនេះជាលទ្ធផលតាមទម្លាប់។ ប្រវត្តិរបស់**អាដាមស្មីត**ក្នុងទ្រឹស្តីធម្មជាតិបាននាំគាត់ឱ្យសម្រេចពាណិជ្ជកម្មក្នុងទីផ្សារសេរីដែលអាចពង្រីកភោគទ្រព្យប្រជាជាតិឱ្យកាន់តែច្រើនឡើងៗ[៥]។

### ១.២-ទ្រឹស្តីគ្រប់គ្រងតាមប្រព័ន្ធសេដ្ឋកិច្ចផែនការ

ប្រព័ន្ធសេដ្ឋកិច្ចផែនការជួនកាលអាចហៅបានម្យ៉ាងទៀតថា "**ប្រព័ន្ធសេដ្ឋកិច្ចបញ្ជា**» សេដ្ឋកិច្ច មជ្ឈការរដ្ឋមានកម្មសិទ្ធិលើធនធាននិងកត្តាផលិតកម្មស្ទើរតែទាំងអស់ រីឯយន្តការគ្រប់គ្រងនិងសម្របសម្រួលផ្អែកលើមូលដ្ឋានផែនការរបស់រដ្ឋមានន័យថាផលិតកម្មស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋស្ទើរតែទាំងស្រុង។ ដំណោះស្រាយបញ្ហាធំៗទាក់ទងនឹងផលិតកម្មការប្រើប្រាស់បែងចែកត្រូវស្ថិតនៅក្រោមការកំណត់របស់រដ្ឋ។ សហគ្រាសជាកម្មសិទ្ធិរបស់រដ្ឋដូច្នេះសកម្មភាពរបស់ភ្នាក់ងារសេដ្ឋកិច្ចទាំងក្នុងផលិតកម្មការបែងចែក ព្រមទាំងការផ្លាស់ប្តូរទំនិញនិងសេវាត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យនិងអនុវត្តតាមផែនការរបស់រដ្ឋ[៦]។

### ១.៣-ទ្រឹស្តីគ្រប់គ្រងតាមប្រព័ន្ធសេដ្ឋកិច្ចចម្រុះ

ក្នុងប្រព័ន្ធសេដ្ឋកិច្ចចម្រុះយន្តការរដ្ឋនិងយន្តការទីផ្សារមានតួនាទីសំខាន់ណាស់ក្នុងការដោះស្រាយបញ្ហាជាមូលដ្ឋានសេដ្ឋកិច្ចថាតើត្រូវផលិតអ្វី? ផលិតយ៉ាងដូចម្តេច? ផលិតសម្រាប់អ្នកណា? ម្យ៉ាងទៀតប្រព័ន្ធសេដ្ឋកិច្ចនីមួយៗច្រើននៅចន្លោះឬមួយសេដ្ឋកិច្ចទីផ្សារសេរីឬមួយសេដ្ឋកិច្ចផែនការ។ ដូចក្នុងករណីសេដ្ឋកិច្ចអាម៉េរិកជាសេដ្ឋកិច្ចទីផ្សារសេរី ប៉ុន្តែមានលក្ខណៈពិសេសត្រង់រដ្ឋមានតួនាទីយ៉ាងសកម្មក្នុងការប្រើប្រាស់ឧបករណ៍ម៉ាក្រូសេដ្ឋកិច្ចដែលមានក្នុងដៃសម្រាប់ចូលរួមសម្របសម្រួលក្នុងដំណើរការអភិវឌ្ឍសេដ្ឋកិច្ចដូចជាការអនុវត្តគោលនយោបាយសារពើពន្ធដើម្បីផ្គត់ផ្គង់ស្ថិរភាពនិងជំរុញកំណើនសេដ្ឋកិច្ច ព្រមទាំងផ្តល់ទំនិញនិងសេវាដែលអវត្តមានក្នុងទីផ្សារឬមានពុំគ្រប់គ្រាន់ជាដើម។ តាមរយៈការធ្វើអន្តរាគមន៍របស់រដ្ឋអាចកែសម្រួលនិងបំពេញចន្លោះនូវភាពខ្វះខាតរបស់យន្តការទីផ្សារនិងដើម្បីផ្ទេរសកម្មភាពទាំងនេះឱ្យក្លាយទៅជាសកម្មភាពមានប្រយោជន៍សម្រាប់សង្គមជាតិទាំងមូល[៧]។ ផ្ទុយពីសេដ្ឋកិច្ចអាម៉េរិកសេដ្ឋកិច្ចអតីតសហភាពសូវៀតនិងបណ្តាប្រទេសនៅអឺរ៉ុបខាងកើតមានលក្ខណៈជាសេដ្ឋកិច្ចផែនការ ប៉ុន្តែជៀសមិនផុតក្នុងស្ថានភាពណាមួយប្រើយន្តការសេដ្ឋកិច្ចទីផ្សារនិងនៅតែមានសេសសល់កម្មសិទ្ធិឯកជន។ បច្ចុប្បន្ននេះ មានតែប្រទេសកូរ៉េខាងជើងនិងប្រទេសគុយបាដែលអាចចាត់ទុកថាជាប្រទេសដែលមានសេដ្ឋកិច្ចចម្រុះបែបបញ្ជា។

### ១.៤-ទ្រឹស្តីនិងគោលការណ៍សម្រាប់ការនាំចេញ

ក្នុងវិស័យពាណិជ្ជកម្មអន្តរជាតិ**ដាវីដរីកាដូ**[៨]បានលើកឡើងអំពីច្បាប់នៃតម្លៃប្រៀបធៀបដែលត្រូវគេរិះគន់យ៉ាងខ្លាំងហើយជជែកគ្នាច្រើនពីទ្រឹស្តីនេះដែលបង្ហាញការដោះដូរថាសេរីគឺមានអត្ថប្រយោជន៍ជានិច្ច។ ទ្រឹស្តី

---

[៥] David N. Hyman, *Microeconomics*, the United States of America, Von Hoffmann Press Inc., 1996, p. 18

[៦] ហ៊ាន សាហ៊ីបៈ *គ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* ដ.ឯ.ម. ទំព័រ ៣៦

[៧] -ដ- ទំព័រ ៣៧-៣៨

[8] Claude MOUCHOt, *Political Economy*, Paris, 1999, p. 221-222.

**ដារីដរីកាដូ** អំពីតម្លៃនិងការបែងចែកយើងគួររំលឹកថា**អាដាមស្មីត**បានបញ្ចូលនូវភាពខុសគ្នារវាងតម្លៃប្រើប្រាស់និងតម្លៃប្តូរដែលត្រូវបានទទួលយកយ៉ាងពេញលេញដោយសេដ្ឋវិទូទាំងអស់។ ទ្រឹស្តីនៃតម្លៃ គឺជាទ្រឹស្តីនៃតម្លៃប្តូរ ពីព្រោះវាតែមួយគត់ដែលអាចវាស់វែងបានយ៉ាងច្បាស់លាស់ក្នុងការដោះដូរ ៖ តម្លៃប្តូរនៃទ្រព្យធនមួយគឺជាបរិមាណនៃទ្រព្យធននោះដែលត្រូវឱ្យបានត្រឡប់មកវិញនូវបរិមាណណាមួយនៃទ្រព្យធនមួយផ្សេងទៀត[៩]។ ដូច្នេះការនាំចេញអង្ករពិតជាអាចដំណើរការទៅបានស្របទៅតាមទ្រឹស្តីសេដ្ឋវិទូ ព្រមទាំងទទួលបាននូវថវិកាដ៏ច្រើនសម្រាប់ជាតិ។

### ១.៥-គោលការណ៍សេវាសាធារណៈ

ក្នុងការអនុវត្តប្រភេទសេវាសាធារណៈត្រូវប្រមូលផ្តុំជា៧ប្រភេទ[១០] ទៅតាមវិស័យដូចខាងក្រោម ៖ (១) **សេវាពាក់ព័ន្ធនឹងអធិបតេយ្យរបស់រដ្ឋ៖** សេវានេះជាសេវាដែលផ្តល់ផ្តាច់មុខដោយរដ្ឋ អង្គភាពរដ្ឋ ឬដោយនីតិបុគ្គលនៃនីតិសាធារណៈដែលរដ្ឋបានប្រគល់សិទ្ធិអំណាចដើម្បីអនុវត្ត (២) **សេវាពាក់ព័ន្ធនឹងផ្នែកសន្តិសុខសណ្តាប់ធ្នាប់សាធារណៈនិងសុវត្ថិភាពសង្គម៖** សន្តិសុខជាសេវាដ៏ចាំបាច់និងមិនអាចខ្វះបាន ដើម្បីធានាដល់បរិយាកាសល្អដល់ការអភិវឌ្ឍសង្គមជាតិភាពសុខសាន្តរបស់ប្រជាពលរដ្ឋ។ (៣) **សេវាជួញដូរ និងអាជ្ញាកណ្តាល៖** អធិករណ៍ដែលកើតឡើងរវាងប្រជាពលរដ្ឋនិងប្រជាពលរដ្ឋឬប្រជាពលរដ្ឋនិងអ្នករាជការឬរវាងប្រជាពលរដ្ឋនិងផ្នែកឯកជន។ សេវាដោះស្រាយវិវាទនេះតាមរូបភាពពីរយ៉ាងគឺតាមរយៈក្រុមប្រឹក្សាអាជ្ញាកណ្តាលនិងតាមរយៈតុលាការ។ (៤) **សេវាពាក់ព័ន្ធនឹងការលើកកម្ពស់ពាណិជ្ជកម្មសហគ្រាសធុនតូចនិងមធ្យមបរិស្ថានវិនិយោគនិងការចូលរួមរបស់ផ្នែកឯកជនក្នុងការកសាងនិងការថែទាំហេដ្ឋារចនាសម្ព័ន្ធ៖** វិស័យឯកជនជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ចដូច្នេះដើម្បីធ្វើឱ្យបរិស្ថានធុរកិច្ចកាន់តែប្រសើរសម្រាប់វិស័យឯកជនត្រូវ៖ កាត់បន្ថយបែបបទស្មុគស្មាញនៅតាមក្រសួងស្ថាប័នដែលពាក់ព័ន្ធដល់ការនាំចេញ[១១]នាំចូលនិងបែបបទនៃការចុះបញ្ជីបង្កើតក្រុមហ៊ុន។ (៥) **សេវាសង្គមកិច្ចវប្បធម៌និងកិច្ចការនារី៖** មានដូចជាសេវាអប់រំលើកកម្ពស់គុណភាព សេវាអប់រំសម្រាប់ទាំងអស់គ្នាសម្ភារសិក្សាគ្រប់គ្រាន់និងសិទ្ធិទទួលបាននូវសេវាអប់រំគ្រប់កម្រិតសិក្សា សេវាសុខភាព អនាម័យនិងការចូលរួមរបស់ស្ត្រីក្នុងការអភិវឌ្ឍសេដ្ឋកិច្ច។ (៦) **សេវាពាក់ព័ន្ធនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត៖** គឺការកសាងប្រព័ន្ធគមនាគមន៍ដឹកជញ្ជូន គ្រប់ប្រភេទរួមមាន៖ ផ្លូវថ្នល់ ស្ពាន ផ្លូវដែក ផ្លូវទឹក កំពង់ផែ អាកាសយានដ្ឋានដែលតភ្ជាប់ទីក្រុងនិងជនបទ គ្រប់ទីកន្លែងទូទាំងប្រទេសកសាងមន្ទីរពេទ្យសាលារៀនអណ្តូងទឹកប្រព័ន្ធទឹកស្អាតប្រព័ន្ធធារាសាស្ត្រអគ្គិសនីបច្ចេកវិទ្យាព័ត៌មាន។ល។ (៧) **សេវាពាក់ព័ន្ធនឹងការប្រមូលចំណូលនិងការបើកផ្តល់៖** កែលម្អការគ្រប់គ្រងចំណូលនិងការបើកផ្តល់ឱ្យមានតម្លាភាពប្រសិទ្ធភាពកាត់បន្ថយការលំបាករបស់អ្នកប្រើប្រាស់សេវា។

### ១.៦-គោលការណ៍នៃការកែលម្អសេវាសាធារណៈ

ការកែលម្អការផ្តល់សេវាដែលត្រូវធ្វើតាមសភាពជាក់ស្តែងនិងជាជំហានៗគឺដើម្បីកែប្រែសេវាសាធា-រណៈឱ្យមាន៖ (១) **គុណភាព៖** សំដៅលើការពេញចិត្តរបស់អ្នកប្រើប្រាស់សេវានៅពេលដែលសេវាត្រូវផ្តល់

---

[៩] ibid. p. 29.

[១០] វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ៖ *រដ្ឋបាលសាធារណៈ* ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ២០១១ ទំព័រ ៨-៩

[១១] Merlinda D. Ingco and John D. Nash, *Agriculture and the WTO : Export Competition Policies,* the World Bank,Washington D.C., 2004, p.43.

ជូនទៅតាមលក្ខខណ្ឌកំណត់។ (២) **តម្លៃថោក៖** តម្លៃសេវាដែលត្រូវបង់ត្រូវមានកម្រិតមួយសមរម្យ ស្របតាមទីកន្លែងនិងលទ្ធភាពរបស់អ្នកប្រើប្រាស់។ (៣) **ខ្លី៖** សំដៅលើនីតិវិធីនៃការផ្តល់សេវាតាមរចនាសម្ព័ន្ធប្រតិបត្តិ គឺលុបបំបាត់ការិយាធិបតេយ្យមិនចាំបាច់។ (៤) **សាមញ្ញ៖** មានន័យថា លក្ខខណ្ឌផ្សេងៗដែលអ្នកប្រើប្រាស់សេវាត្រូវបំពេញដើម្បីទទួលបានសេវាយកទៅប្រើប្រាស់មានលក្ខណៈងាយយល់ទាំងទម្រង់បែបបទនិងនីតិវិធី។ (៥) **អាចជឿទុកចិត្តបាន៖** ការផ្តល់សេវាត្រូវផ្តល់ទៅតាមនីតិវិធីនិងបទដ្ឋានដែលបានកំណត់ទុកជាមុននិងមានការដឹងឮជាទូទៅ។ (៦) **ឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការ៖** ប្រភេទសេវា នីតិវិធីនិងពេលវេលានៃការផ្តល់សេវាបានកំណត់ដោយឈរលើមូលដ្ឋាននៃតម្រូវការរបស់អ្នកប្រើប្រាស់ជាអាទិភាព។ (៧) **បង្កលក្ខណៈងាយស្រួល៖** អ្នកផ្តល់សេវាសម្រួលដល់អ្នកប្រើប្រាស់ទាំងការងារទំនាក់ទំនង ការបំពេញបែបបទនិងការទទួលសេវាត្រឡប់ទៅវិញ។

### ១.៧-គោលការណ៍សម្រាប់ច្រកចេញចូលតែមួយ

គឺជាយន្តការនៃការផ្តល់សេវាសាធារណៈតាមបែបទំនើបដោយមានការប្រមូលផ្តុំចង្កោមសេវាសាធារណៈមួយចំនួន**កន្លែងសុំ**និង**កន្លែងទទួល**សេវាមកនៅ**កន្លែងតែមួយ**ដោយកំណត់ពេលវេលាប្រគល់និងទទួលសេវារវាងអ្នកផ្តល់សេវានិងអតិថិជននិងកំណត់តម្លៃយ៉ាងច្បាស់លាស់នៃសេវានោះ ដើម្បីបង្កភាពងាយស្រួលដល់ការផ្តល់សេវាជូនប្រជាពលរដ្ឋនិងអតិថិជនតាមនីតិវិធីសាមញ្ញតម្លាភាព ប្រសិទ្ធភាព យកចិត្តទុកដាក់ចំពោះចំណាប់អារម្មណ៍របស់អតិថិជន[១២]។ អនុវត្តយន្តការច្រកចេញចូលតែមួយដើម្បីបំពេញបែបបទនាំចេញនិងសម្រាប់ការបំពេញនីតិវិធីគយព្រមទាំងវិញ្ញាបនបត្រផ្សេងៗដូចជាវិញ្ញាបនបត្រអនាម័យនិងវិញ្ញាបនបត្រភូតគាមអនាម័យ វិញ្ញាបនបត្រធូបនកម្ម វិញ្ញាបនបត្របញ្ជាក់អំពីគុណភាពបរិមាណនិងទម្ងន់ព្រមទាំងវិញ្ញាបនបត្រគយ[១៣]។

## សន្និដ្ឋាន

សរុបសេចក្តីមកមូលដ្ឋានទ្រឹស្តីនិងគោលការណ៍ទាក់ទងនឹងការជំរុញការនាំចេញអង្ករ គឺជាប្រភពចម្បងក្នុងការតម្រង់ទិសដើម្បីឆ្ពោះទៅកំណត់ទស្សនវិស័យក្នុងការជំរុញនិងសម្របសម្រួលការនាំចេញអង្ករឱ្យបានយ៉ាងតិច១លានតោនចាប់ពីឆ្នាំ២០១៥។ ពីឆ្នាំ២០០១ដល់២០១ បរិមាណស្រូវដែលទទួលបានពី ៤-០៩៩ ០១៦តោន ក្រោយពីប្រើប្រាស់ក្នុងស្រុករួចសល់ជាអង្ករ០,៨៨៤លានតោនរហូតដល់៩ ៣០៩ ០០០-តោន ប្រើប្រាស់ក្នុងស្រុករួចរាល់សល់ជាអង្ករ៤,៥១លានតោន។ សូចនាករទាំងនេះអាចប៉ាន់ស្មានបានថាប្រទេសកម្ពុជាពិតជានឹងអាចនាំអង្ករចេញបានយ៉ាងតិច១លានតោនមុនឆ្នាំ គោលកំណត់ទៅទៀត។ ដើម្បីសម្រេចគោលដៅនេះប្រទេសកម្ពុជាត្រូវជំរុញយន្តការស្ថាប័នសម្រាប់អនុវត្តគោលនយោបាយស្តីពី ការនាំចេញអង្ករឱ្យធ្វើទំនាក់ទំនងប្រទាក់ក្រឡាគ្នាជាប្រចាំនិងត្រូវខិតខំបន្ថែមក្នុងការពង្រីកទីផ្សារនិងរក្សាទីផ្សារតាមរយៈការចុះអនុសារណនាំចេញអង្ករពីប្រទេសកម្ពុជាជាមួយបណ្តាប្រទេសនាំចូលអង្ករមួយចំនួនទៀតនៅក្នុងពិភពលោក។

---

[១២] រាជរដ្ឋាភិបាលកម្ពុជា៖ *ឯកសារគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ* ដ.ឯ.ម. ទំព័រ ១១

[១៣] Merlinda D. Ingco and John D. Nash,*Agriculture and the WTO : Export Competition Policies,* op. cit., p. 345

# គន្ថនិទ្ទេស


## ជាភាសាខ្មែរ

១.ក្រសួងពាណិជ្ជកម្ម៖ ***ស្ថិតិនាំចេញនៃព្រះរាជាណាចក្រកម្ពុជាតាមមុខទំនិញ*** ភ្នំពេញ ឆ្នាំ២០១០

២.ច័ន្ទ សារុន៖ ***យុទ្ធសាស្ត្របង្កើនផលិតកម្មដំណាំស្រូវប្រកបដោយចីរភាព*** ភ្នំពេញ ឆ្នាំ២០០៦

៣.ម៉ែន សារុម៖ ***ដំណាំស្រូវនៅកម្ពុជា*** វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា ឆ្នាំ២០០៧

៤.រាជរដ្ឋាភិបាល៖ ឯកសារគោលនយោបាយស្តីពី ***ការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ*** អនុម័តដោយគណៈរដ្ឋមន្ត្រី ភ្នំពេញ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១០

៥.វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ៖ រដ្ឋបាលសាធារណៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ភ្នំពេញ ឆ្នាំ២០១១

៦.ហ៊ាន សាហ៊ីប៖ ***គ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*** វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ភ្នំពេញ ឆ្នាំ២០០៦

## ជាភាសាបរទេស

៧.Claude MOUCHOT, *Political Economy*, Paris 1999.

៨.David N. Hyman, *Microeconomics,* the United States of America, Von Hoffmann Press Inc., 1996.

៩.http://www.oryza.com/..FAO,*Global Rice exports estimates 2011 and 2012.*

១០.http://www.en.m.wikipedia, *the world population*is the sum total of all living humans on earth.

១១.Merlinda D. Ingco and John D.Nash, *Agriculture and the WTO Creating a Trading System for Development,* World Bank and Oxford University Press, 2008.

១២.United Nations :*Trade Facilitation Beyond the Multilateral Trade Negotiations: Regional Practices, Custom Valuation and Other Emerging Issues,* New York, 2007.

១៣.Adam Smith, *An Inquiry into the Nature and Causes of the Wealth of Nations,* Fifth edition, London : Methuen and Co., Ltd., ed. EwinCannan, 1904.

១៤.Robert Frank & Ben Bernanke, *Principle of Economics,* New York, Quebecor World/Hawkins, 2001.

# **សិក្សាលើដំណើរការអាជីវកម្មរបស់កំពង់ផែស្វយ័តភ្នំពេញ**

ជា ប៊ុនធៀង

បេក្ខជនបណ្ឌិតជំនាន់ទី១ ផ្នែកគ្រប់គ្រង

នៃសាកលវិទ្យាល័យឯកទេសនៃកម្ពុជា



## **១-សេចក្តីផ្តើម**

កំពង់ផែស្វយ័តភ្នំពេញ បានចាប់បដិសន្ធិឡើងក្នុងសម័យសង្គមរាស្ត្រនិយម ដោយបានបំពេញតួនាទីរបស់ខ្លួនយ៉ាងសកម្មខាងផ្នែកដឹកជញ្ជូននូវរាល់ទំនិញដែលបានចេញចូលតាមមាត់ទ្វារកំពង់ផែ។ សកម្មភាពទាំងនេះប្រព្រឹត្តទៅបានក៏ដោយសារមានការចូលរួមពីបណ្តាការដឹកជញ្ជូនតាមផ្លូវទឹក ***មានការចូលរួមពីបណ្តាបុគ្គលិក-កម្មករនៅតាមផ្នែកផ្សេងៗ*** ដែលរួមសហការណ៍គ្នាយ៉ាងស្អិតរមួត ដើម្បីឱ្យដំណើរការការងារនៅក្នុងកំពង់ផែប្រព្រឹត្តទៅបានល្អ។ នៅក្នុងការបំពេញភារកិច្ចរបស់ខ្លួន កំពង់ផែស្វយ័តភ្នំពេញ ដែលជាអង្គភាពមួយកំពុងតែបោះជំហានទៅមុខក្នុងការអភិវឌ្ឍនិងស្តារសេដ្ឋកិច្ចជាតិ ចាំបាច់ត្រូវរៀបចំនូវផែនការអាជីវកម្មរបស់ខ្លួនឱ្យមានលក្ខណៈល្អប្រសើរ តាំងពីស្ថានភាពទូទៅនៃការគ្រប់គ្រងអាជីវកម្ម សហប្រតិបត្តិការអាជីកម្មនិងបរត្តិបរិមាណទំនិញឆ្លងកាត់ផែ ការរៀបចំជ្រើសរើសនិងអភិវឌ្ឍន៍ធនធានមនុស្ស និងកត្តាផ្សេងៗទៀតដែលទាក់ទងនឹងដំណើរការរបស់ខ្លួននិងត្រូវតែគិតអំពីលក្ខណៈអន់ថយមួយចំនួន ដែលជាចំណុចខ្វះខាតរបស់អង្គភាព។

## **២-វិធីសាស្ត្រស្រាវជ្រាវ**

### **២.១-ការជ្រើសរើសសំណាក**

ការសិក្សានេះ ប្រើវិធីសាស្ត្រស្រាវជ្រាវបែបអង្កេតស្រាវជ្រាវ (Survey research) ដោយបានធ្វើសម្ភាសន៍ អ្នកត្រួតការ-អ្នកគ្រប់គ្រងចំនួន៨នាក់ និង បុគ្គលិក-កម្មករចំនួន១៦៨នាក់ ក្នុងការិយាល័យចំនួន៤ អំពីដំណើរការគ្រប់គ្រងអាជីវកម្ម។ ការគណនាទំហំសំណាកគំរូមានការពាក់ព័ន្ធទៅនឹងប៉ារ៉ាមែត្រកំណត់ទំហំសំណាកគំរូចំនួន (N) ដូចដែលបានសន្មតយកមកសិក្សាស្រាវជ្រាវយកតម្លៃស្តង់ដាកម្រិតលម្អៀង តម្លៃផលធៀប និងការគណនាទំហំសំណាកដូចរូបមន្តខាងក្រោម ៖

(Yamane, 1967)[១៤]

Where

- n = ទំហំសំណាកគំរូ ដែលត្រូវសម្ភាស
- N = ចំនួន អ្នកត្រួតការ-អ្នកគ្រប់គ្រង និង បុគ្គលិក-កម្មករ សរុបទាំងអស់
- e = កម្រិតលម្អៀង ១..........១២ %

n=៤៤២/១+ ៤៤២ (០,០៥៨) ២=១៧៦នាក់

ការជ្រើសរើសយកទំហំសំណាក អាស្រ័យដោយចំនួនអ្នកត្រួតការ-អ្នកគ្រប់គ្រង និង បុគ្គលិក-កម្មករជាអ្នកធ្វើការជូនកំពង់ផែស្វយ័តភ្នំពេញ មានចំនួនសរុប៤៤២នាក់ ដែលមានកម្រិតលម្អៀង០.០៥៨%។

---

[៩] YamaneTaro. 1967 WWW. Google.com

ជាលទ្ធផលយើងទទួលបានទំហំសំណាកត្រឹមតែ ១៧៦នាក់ ប្រហែល ៤០ភាគរយ សម្រាប់ធ្វើសម្ភាសន៍អ្នកត្រួតការ-អ្នកគ្រប់គ្រង និង បុគ្គលិក-កម្មករ ជាអ្នកធ្វើការជូនកំពង់ផែស្វយ័តភ្នំពេញ។

**២.២-ការប្រមូលទិន្នន័យទី២** ( Secondary Data )

ទិន្នន័យទី២ ៖ ជាទិន្នន័យដែលបានដកស្រង់ពីឯកសារដែលមានស្រាប់ ជាពិសេស និក្ខេបបទ, អត្ថបទវិទ្យាសាស្ត្រ, សៀវភៅពុម្ព, ស្ថិតិតាមអង្គភាពនានា។ល។

**២.៣-វិធីសាស្ត្រវិភាគ**

ទិន្នន័យដែលប្រមូលបានត្រូវធ្វើវិភាគតាមបែបគុណភាពនិងគុណភាពតាម Chi-square-Test. ANOVA នៃកម្មវិធី SPSS ( Statistic Package of Social Science )។

## ៣-លទ្ធផលនៃការស្រាវជ្រាវនិងការពិភាក្សា

### ៣.១.សកម្មភាពនៃអាជីវកម្ម

ស្ថិតិដឹកជញ្ជូនទំនិញឆ្លងកាត់កំពង់ផែស្វយ័តភ្នំពេញ ឆ្នាំ១៩៥៤-១៩៦០ បានបង្ហាញតាមក្រាហ្វិកលេខ ៤.២ ឱ្យឃើញថា ក្រោយទទួលឯករាជ្យចាប់ពីឆ្នាំ១៩៥៤ ប្រទេសកម្ពុជាមានការរីកចម្រើនជឿនលឿនគួរឱ្យកត់សម្គាល់ពីមួយឆ្នាំទៅមួយឆ្នាំយើងឃើញថា កំណើននាវានិងទំនិញឆ្លងកាត់កំពង់ផែកើនឡើងជារៀងរហូតដូចក្នុងឆ្នាំ១៩៥៤ នាវាចេញ-ចូលឆ្លងកាត់កំពង់ផែស្វយ័តភ្នំពេញមានចំនួនសរុប៥៧៩ គ្រឿងនិងបរិមាណទំនិញនាំចូល-នាំចេញសរុបចំនួន២៩៤ ៨០០តោន ដល់ឆ្នាំ១៩៦០ នាវាចេញ-ចូល ឆ្លងកាត់កំពង់ផែស្វយ័តភ្នំពេញមានចំនួនសរុប១ ១២៩គ្រឿងនិងបរិមាណទំនិញនាំចូល-នាំចេញសរុបចំនួន៨៩៧ ៧៣៧តោន គិតជាភាគរយរបស់នាវាកើនឡើងស្មើប្រហែល១៩៥% និងភាគរយទំនិញនាំចូល-នាំចេញកើនឡើងស្មើប្រហែល៣០៥%។




ក្រាហ្វិកទី ៣.១ ៖ ក្រាហ្វិកតាងបរិមាណទំនិញ (តោន) ទំនិញឆ្លងកាត់កំពង់ផែឆ្នាំ១៩៥៤-១៩៦០

ស្ថិតិដឹកជញ្ជូនទំនិញឆ្លងកាត់កំពង់ផែស្វយ័តភ្នំពេញឆ្នាំ១៩៦១-១៩៧០ បានបង្ហាញឱ្យឃើញថាក្នុងទសវត្សរ៍ ឆ្នាំ១៩៦០ ស្ថិតិដឹកជញ្ជូនទំនិញឆ្លងកាត់កំពង់ផែមានទំហំកើនឡើងយ៉ាងខ្លាំងដែលបញ្ជាក់ពីការរីកចម្រើននៃការនាំចូលទំនិញប្រើប្រាស់និងនាំចេញទំនិញជាកសិផល។ ឆ្នាំ១៩៦២ នាវានាំចេញ-នាំចូលឆ្លងកាត់កំពង់ផែមានចំនួនសរុប៦២៥គ្រឿង ឆ្នាំ១៩៦៣ ទំនិញឆ្លងកាត់មានរហូតដល់៩៦២ ០០០តោន ហើយមានការធ្លាក់ចុះចាប់ពីឆ្នាំ១៩៦៩-១៩៧០ ដែលជាឆ្នាំចាប់ផ្តើមសង្គ្រាមក្នុងស្រុក។

ស្ថិតិដឹកជញ្ជូនទំនិញឆ្លងកាត់កំពង់ផែស្វយ័តភ្នំពេញឆ្នាំ១៩៧៩-១៩៩០ បានបង្ហាញតាមក្រាហ្វិក លេខ ៣.២ ឱ្យឃើញថា ក្រោយថ្ងៃរំដោះ ៧មករា ឆ្នាំ១៩៧៩ ចាប់ពីឆ្នាំ១៩៧៩ ប្រទេសកម្ពុជាមានការរីកចម្រើនជឿនលឿនគួរឱ្យកត់សម្គាល់ពីមួយឆ្នាំទៅមួយឆ្នាំ យើងឃើញថា កំណើននាវានិងទំនិញឆ្លងកាត់កំពង់ផែកើនឡើងជារៀងរហូតដូចក្នុងឆ្នាំ១៩៧៩ នាវាចេញ-ចូលឆ្លងកាត់កំពង់ផែស្វយ័តភ្នំពេញមានចំនួនសរុប ៨០គ្រឿងនិងបរិមាណ ទំនិញនាំចូល-នាំចេញសរុបចំនួន៦០ ៨៧៤តោន ដល់ឆ្នាំ១៩៩០ នាវាចេញ-ចូលឆ្លងកាត់កំពង់ផែស្វាយ័តភ្នំពេញ មានចំនួនសរុប៥៥០គ្រឿងនិងបរិមាណទំនិញនាំចូល-នាំចេញសរុបចំនួន ៣៦៩ ០០០តោនគិតជាភាគរយរបស់នាវាកើនឡើងស្មើប្រហែល ៦៨៨% និងភាគរយទំនិញនាំចូល នាំចេញកើនឡើងស្មើប្រហែល ៦០៦%។




**ក្រាហ្វិកទី ៣.២ ៖ ក្រាហ្វិកតាងចំនួននាវា (តោន) ដឹកជញ្ជូនឆ្លងកាត់កំពង់ផែ ឆ្នាំ១៩៧៩-១៩៩០**

ស្ថិតិដឹកជញ្ជូនទំនិញឆ្លងកាត់កំពង់ផែស្វយ័តភ្នំពេញ ឆ្នាំ១៩៩១-១៩៩៨ បានបង្ហាញតាមក្រាហ្វិក លេខ ៣.៣ ឱ្យឃើញថា កំណើននាវានិងទំនិញឆ្លងកាត់កំពង់ផែកើនឡើងជារៀងរហូតក្នុងនោះ ទំនិញនាំចូល និងប្រេងឥន្ធនៈនាំចូលច្រើនជាងនាំចេញ។ ការកើននៃបរិមាណទំនិញឆ្លងកាត់ដែលមានទំហំច្រើននេះ គឺអាស្រ័យដោយផ្លូវភ្នំពេញ ក្រុងព្រះសីហនុកំពុងជួសជុលហើយសន្តិសុខតាមផ្លូវពុំទាន់មានសុវត្ថិភាព ហើយអតិថិជនបាននាំចេញ-នាំចូលទំនិញឆ្លងកាត់តែតាមកំពង់ផែស្វយ័តភ្នំពេញ។ ដូចក្នុងឆ្នាំ១៩៩១ នាវាចេញ-ចូលឆ្លងកាត់កំពង់ផែស្វយ័តភ្នំពេញមានចំនួនសរុប៥៥២គ្រឿងនិងបរិមាណទំនិញនាំចូល-នាំចេញសរុបចំនួន ៤២៩ ៣៨៧តោន ដល់ឆ្នាំ១៩៩៨ នាវាចេញ-ចូលឆ្លងកាត់កំពង់ផែស្វយ័តភ្នំពេញមានចំនួនសរុប១ ០៦៩គ្រឿងនិងបរិមាណទំនិញនាំចូល-នាំចេញសរុបចំនួន៦៥៨៣៩៤តោនគិតជាភាគរយរបស់នាវាកើនឡើងស្មើប្រហែល១៩៤% និងភាគរយទំនិញនាំចូល-នាំចេញកើនឡើងស្មើប្រហែល ១៥៣%។




ក្រាហ្វិកទី ៣.៣ ៖ ក្រាហ្វិកតាងចំនួនកប៉ាល់ (គ្រឿង ) ដឹកជញ្ជូនទំនិញឆ្លងកាត់កំពង់ផែ ឆ្នាំ១៩៩១-១៩៩៨

តារាងទី ៣.១ ប្រៀបធៀបមធ្យមភាគទម្ងន់នាំចូលនិងចេញ ១៩៩១-១៩៩៨ (ANOVA)

| លក្ខណៈ | ទំនិញឆ្លងកាត | ទំនិញនាំចូល | ទំនិញនាំចេញ | ប្រេងឥន្ធនៈ | ទំនិញក្នុងស្រុក | F-value | p. |
|---|---|---|---|---|---|---|---|
| N | 8 | 8 | 8 | 8 | 8 | | |
| X | 568506.6[a] | 119828[c] | 83154.4[c] | 342955.3[b] | 22574.0[d] | 115.85 | <0.001 |
| S± | 69991.1 | 68332.5 | 53330.9 | 71886.1 | 553.8 | | |

លទ្ធផលតាមតារាងទី៣.១ ខាងលើនេះបានបញ្ជាក់ឱ្យដឹងថាបរិមាណទំនិញឆ្លងកាត់មានចំនួនច្រើនជាងទំនិញដទៃទៀតដោយ p.<0.001 រីឯប្រេងឥន្ធនៈក៏មានបរិមាណខ្ពស់ដែរ ចំណែកឯទំនិញនាំចូល និងទំនិញនាំចេញមានបរិមាណប្រហាក់ប្រហែលគ្នាដោយឡែកទំនិញក្នុងស្រុកមានបរិមាណទាបជាងគេ។

តារាងទី ៣.២ ប្រៀបធៀបមធ្យមភាគទម្ងន់នាំចូលនិង ចេញ ១៩៩៩២០០១-

| លក្ខណៈ | ទំនិញឆ្លងកាត់ | ទំនិញនាំចូល | ទំនិញនាំចេញ | ប្រេងឥន្ធនៈ | ទំនិញក្នុងស្រុក | F-value | p. |
|---|---|---|---|---|---|---|---|
| N | 3 | 3 | 3 | 3 | 3 | | |
| X | 476666.0[a] | 54265.3[c] | 47520.0[c] | 365845.3[b] | 9035.3[d] | 402.42 | <0.001 |
| S± | 23546.6 | 6737.3 | 12413.9 | 31032.8 | 1708.2 | | |

លទ្ធផលតាមតារាងទី៣.២ ខាងលើនេះបានបញ្ជាក់ឱ្យដឹងថា បរិមាណទំនិញឆ្លងកាត់មានចំនួនច្រើនជាងទំនិញដទៃទៀត ដោយ p.<0.001 រីឯប្រេងឥន្ធនៈក៏មានបរិមាណខ្ពស់ដែរ ចំណែកឯទំនិញនាំចូលនិងទំនិញនាំចេញមានបរិមាណប្រហាក់ប្រហែលគ្នាដោយឡែកទំនិញក្នុងស្រុកមានបរិមាណទាបជាងគេ។




ក្រាហ្វិកទី៣.៤ ៖ ក្រាហ្វិកតាងបរិមាណទំនិញ (តោន) ដឹកជញ្ជូនទំនិញឆ្លងកាត់កំពង់ផែឆ្នាំ២០០២-២០០៣

ក្រាហ្វិក លេខ ៤.២២ ឱ្យឃើញថាកំណើននាវានិងទំនិញឆ្លងកាត់កំពង់ផែកើនឡើងជារៀងរហូត។ ដូចក្នុងឆ្នាំ២០០២ នាវាចេញ-ចូលឆ្លងកាត់កំពង់ផែស្វយ័តភ្នំពេញមានចំនួនសរុប ៨៣១គ្រឿងនិងបរិមាណទំនិញនាំចូល-នាំចេញសរុបចំនួន៤២៧ ៣៦៨តោន ដល់ឆ្នាំ២០០៣ នាវាចេញ-ចូលឆ្លងកាត់កំពង់ផែស្វាយ័តភ្នំពេញមានចំនួនសរុប១ ០៧៣គ្រឿងនិងបរិមាណទំនិញនាំចូល-នាំចេញសរុបចំនួន៥៣៣ ៦៥៩តោនគិតជាភាគរយរបស់នាវាកើនឡើងស្មើប្រហែល ១២៩%និងភាគរយទំនិញនាំចូល-នាំចេញកើនឡើងស្មើប្រហែល ១២៥%។

តារាងទី៣.៣ ប្រៀបធៀបមធ្យមភាគទម្ងន់នាំចូលនិងចេញ ១៩៩៩-២០០១ (ANOVA)

| លក្ខណៈ | ទំនិញឆ្លងកាត់ | ទំនិញនាំចូល | ទំនិញនាំចេញ | ទំនិញក្នុងស្រុក | F-value | p. |
|---|---|---|---|---|---|---|
| N | 3 | 3 | 3 | 3 | | |
| X | 480513.5[a] | 449929.0[a] | 19633.0[b] | 10951.5[b] | 54.32 | <0.001 |
| S± | 75159.1 | 64869.9 | 10210.6 | 78.5 | | |

លទ្ធផលតាមតារាងទី៣.៣ ខាងលើនេះបានបញ្ជាក់ឱ្យដឹងថា បរិមាណទំនិញឆ្លងកាត់និងទំនិញនាំចូលមានចំនួនច្រើនជាងទំនិញដទៃទៀត ដោយ p.<0.001 រីឯទំនិញនាំចេញនិងទំនិញក្នុងស្រុកមានបរិមាណប្រហាក់ប្រហែលគ្នា។

តារាងទី៣.៤ ប្រៀបធៀបមធ្យមភាគទម្ងន់នាំចូល និងចេញ ២០០៤-២០០៨ (ANOVA)

| លក្ខណៈ | ទំនិញឆ្លងកាត់ | ទំនិញនាំចូល | ទំនិញនាំចេញ | ទំនិញក្នុងស្រុក | ប្រេងឥន្ធនៈ | F-value | p. |
|---|---|---|---|---|---|---|---|
| N | 5 | 5 | 5 | 5 | 5 | | |
| X | 694900.0[a] | 204400.0[c] | 97900.0[d] | 15000.0[e] | 377600.0[b] | 402.42 | <0.001 |
| S± | 36909.3 | 18297.5 | 8443.9 | 2061.5 | 8264.3 | | |

លទ្ធផលតាមតារាងទី៣.៤ ខាងលើនេះបានបញ្ជាក់ឱ្យដឹងថា បរិមាណទំនិញឆ្លងកាត់មានចំនួនច្រើនជាងទំនិញដទៃទៀត ដោយ p.<0.001 រីឯប្រេងឥន្ធនៈក៏មានបរិមាណខ្ពស់ដែរចំណែកឯបរិមាណទំនិញនាំចូលខ្ពស់ទំនិញនាំចេញដោយឡែកទំនិញក្នុងស្រុកមានបរិមាណទាបជាងគេ។

## ៤-សន្និដ្ឋាន

លទ្ធផលទំនិញឆ្នាំ១៩៩១-១៩៩៨មាន បរិមាណទំនិញឆ្លងកាត់ ដោយ p.<0.001 រីឯប្រេងឥន្ធនៈក៏មានបរិមាណខ្ពស់ដែរ ដោយឡែកទំនិញក្នុងស្រុកមានបរិមាណទាបជាងគេ។ ចំណែកឯលទ្ធផលទំនិញឆ្នាំ ១៩៩៩-២០០១ មានបរិមាណទំនិញឆ្លងកាត់ 476 666.0 etaneRcInCagTMnijTMnijnaMcUl 54 265.3 etannigTMnijnaMecj 47 520. 0etan ដោយ p.<0.001 រីឯប្រេងឥន្ធនៈ ក៏មានបរិមាណខ្ពស់ដែរ ដោយឡែកទំនិញក្នុងស្រុកមាន **បរិមាណទាបជាងគេ។** រីឯលទ្ធផលទំនិញឆ្នាំ២០០៤-២០០៨ ក៏មានបរិមាណទំនិញឆ្លងកាត់ 694 900.0etan ច្រើនជាងទំនិញទំនិញនាំ **ចូល** 204 400.0etan**nigTMnijnaMecj** 97 900.0 etaneday p.<0.001 រីឯប្រេងឥន្ធនៈ ក៏មានបរិមាណខ្ពស់ ដែរដោយឡែកទំនិញក្នុងស្រុកមានបរិមាណទាបជាងគេ។ **ចំណែកឯបរិមាណទំនិញនាំចូលនូវមានកម្រិតនិងពុំសូវ** ទៀងទាត់ពេលខ្លះតិចពេលខ្លះច្រើនជាហេតុតម្រូវឱ្យត្រូវចំណាយថវិកាច្រើន។ សរុបមកកំពង់ផែប្រទេសកម្ពុជា ពុំទាន់មានលក្ខណៈប្រកួតប្រជែងជាខ្នាតអន្តរជាតិឱ្យបានទូលំទូលាយនៅឡើយទេ ដោយមានការខ្វះខាតធនធានមនុស្សផ្នែកជំនាញ, សម្ភារៈ បរិក្ខារ និងថវិកា។ល។

## គន្ថនិទ្ទេស


L' Economie des Transports maritimes et les contrats du Transport maritime par Jean FrancoisMe'rillon : 1954-1960

Phnom Penh Port Authority: 1979-1990, 1991-1998, 2002-2003, 2004-2008

Rapport d'une missiond'inspection faite du 15 au 22 juillet 1971

# ប្រវត្តិនៃការវិវត្តការអប់រំដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាព



មាឃ សារី

បេក្ខជនបណ្ឌិត ផ្នែកវិទ្យាសាស្ត្រអប់រំ

នៃរាជបណ្ឌិត្យសភាកម្ពុជា

## ១.សាវតារ

ប្រសិនបើយើងនិយាយពីការប្រែប្រួលនៃកំណើនប្រជាជននៅលើផែនដីយើងវិញគឺមានការខុសប្លែកគ្នារវាង១០០ឆ្នាំមុននិង១០០ឆ្នាំក្រោយគឺ១៦៥០លាននាក់នៅនាឆ្នាំ១៩០០ និង នៅឆ្នាំ២០០៩ ប្រហែលជា ៦៨០០លាននាក់ដែលចំនួននេះមានការកើនឡើង២.២%ក្នុងមួយឆ្នាំ។ តាមការប៉ាន់ស្មានទៅលើការជំរឿនប្រជាជនគេពិនិត្យឃើញថាប្រជាជនពិភពលោកនឹងកើនដល់៩០០០លាននាក់នៅឆ្នាំ២០៤០[១៥]។ កំណើនប្រជាជននេះនាំឱ្យមានកំណើននូវតម្រូវការម្ហូបអាហារនិងអ្វីៗផ្សេងៗទៀត។

ដើម្បីបំពេញនូវតម្រូវការនេះពិភពលោកទាមទារនូវការគិតគូរទៅលើគ្រប់ផ្នែកគ្រប់វិស័យជាពិសេសលើការអភិវឌ្ឍផ្នែកសេដ្ឋកិច្ចហើយការអភិវឌ្ឍលើវិស័យនេះក៏មានតម្រូវទៅលើការប្រើប្រាស់ធនធានធម្មជាតិដែលមាននៅលើផែនដីស្ទើរតែនឹងបាត់ទាំងស្រុងអស់ប្រសិនបើមិនមានការការពារនិងទប់ស្កាត់ទេនោះ។*ប្រព័ន្ធអេកូឡូស៊ីនិងធនធានដទៃទៀតដែលគាំទ្រដល់ជីវិតមនុស្សនិងជីវិតដទៃទៀតនៅលើផែនដីបាននិងកំពុងទទួលនូវការគំរាមកំហែង*[១៦]។

សហគមន៍អន្តរជាតិនានាក៏បានបង្កើតឡើងនូវច្បាប់បរិស្ថានដែលបង្កើតឡើងក្នុងគោលដៅពីរៈទីមួយត្រួតពិនិត្យការបំពុលនិងលុបបំបាត់ការបំពុលនានានិងទីពីរសំដៅលើការថែរក្សាធនធាននិងគ្រប់គ្រងបរិស្ថាន។ ច្បាប់នេះស្ថិតនៅក្នុងច្បាប់អន្តរជាតិដែលយកចិត្តទុកដាក់ទៅលើខ្យល់ទឹកលើដីនិងក្រោមដីក៏ដូចជាទឹកសមុទ្រ។ចំណែកការថែរក្សាគ្រប់គ្រងក៏ផ្តោតទៅលើធនធានធម្មជាតិព្រៃឈើនិងធនធានរ៉ែនៅក្នុងផែនដី[១៧]។ ក្រៅពីច្បាប់បរិស្ថានក៏មានច្បាប់សាមញ្ញនានាស្តីពីបរិស្ថានសន្ធិសញ្ញាកិច្ចព្រមព្រៀងនានានិងច្បាប់អន្តរជាតិដទៃទៀតដែលផ្តោតទៅលើការការពារនិងថែរក្សាបរិស្ថានពិភពលោកដែរ។

ការធ្វើឱ្យមានការយល់ដឹងអំពីបញ្ហាបរិស្ថានគឺធ្វើឡើងតាមគោលវិធីថ្មីដែលគេហៅថាគោលវិធីសីលធម៌ថ្មី(New Ethical Approach)[១៨]។ នៅក្នុងទសវត្សរ៍ទី៦នៃសតវត្សរ៍ទី២០មានកើតឡើងនូវសីលធម៌ ស្តីពីបរិស្ថានដែលធ្វើឱ្យមនុស្សពិចារណានិងយល់ដឹងអំពីសារៈសំខាន់នៃបរិស្ថាននិងនាំទៅដល់ការទប់ស្កាត់ការបំផ្លាញ បរិស្ថានដោយសកម្មភាពឥតព្រំដែនដើម្បីថែរក្សានិងការពារបរិស្ថានធម្មជាតិសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព[១៩]។ តាមទស្សនៈព្រះពុទ្ធសាសនាផងដែរលោក Donald Swearer បានធ្វើចំណាត់ថ្នាក់ពិសេស ទៅលើទស្សនៈពុទ្ធនិយមដែលជាប់ពាក់ព័ន្ធទៅនឹងប្រព័ន្ធអេកូឡូស៊ីជា៥កម្រិតដើម្បីទាញបញ្ជាក់ពីហេតុផលនានា

---

[១៥] Cf., *World population*, retrieved from, http://en.wikipedia.org/wiki/World_population p., 1.

[១៦] Robbie Henderson, (2009), *Education for Sustainable Development Teacher Training Manual*, nzaid, p., 2.

[១៧] Cf., Environmental law, Retrieved from Wikipedia, page., 2.

[១៨] Jackson Yvette. (2006), *Evolutionary Spiral in the Development of Environmental Ethics*, Mg JICEL vol.3, p.,

[១៩] Cf., Ibid, p. 120.

ថា ទស្សនៈពុទ្ធនិយមបានរួមចំណែកឱ្យមានការការពារនិងថែរក្សាបរិស្ថានប្រព័ន្ធអេកូឡូស៊ីរួមមាន៖ ទីមួយសំដៅលើក្រុមអ្នកខមាទេសនិយម-អេកូឡូស៊ី ទីពីរគឺក្រុមអ្នករិះគន់ស្ថាបនានិយម-អេកូឡូស៊ី ទីបីក្រុមអ្នកស្ថាបនានិយម-អេកូឡូស៊ី ទីបួនក្រុមអ្នកសីលធម៌ និយម-អេកូឡូស៊ី និងទីប្រាំក្រុមអ្នកបរិការណ៍និយម-អេកូឡូស៊ី[២០] ដែលទាំងនេះក៏ជាការចូលរួមចំណែកថែរក្សាប្រព័ន្ធបរិស្ថានឱ្យមាននិរន្តរភាព។ នៅក្នុងចំណុចនេះដែរ សម្រាប់ប្រទេសកម្ពុជាយើងគឺប្រជាជនមានជំនឿ និង គោរពចំពោះដើមឈើពិសេសដើមឈើធំៗដែលគេចាត់ទុកថាមានម្ចាស់កាន់កាប់ឬស្នាក់នៅ ដូចជាទេវតា និង អ្នកតាជាដើមនេះមានន័យថាគាត់មិនហ៊ានកាប់ឬទន្ទ្រានតាមចិត្តចង់ឡើយ ជាពិសេសបងប្អូនជនជាតិដើម ភាគតិចមុននឹងកាប់ឆ្ការព្រៃធ្វើចម្ការគាត់តែងធ្វើពិធីបន់ស្រន់ជាមុន ហើយការធ្វើស្រែចម្ការរបស់គាត់ជារបៀប វិលជុំដែលមិនធ្វើឱ្យប៉ះពាល់ដល់បរិស្ថានឡើយ។

## ២. ការវិវត្តនៃការអប់រំដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាព

កំណើនមនុស្សនៅលើផែនដីការរីកចម្រើនសេដ្ឋកិច្ចក៏ដូចជាតម្រូវការនានាដែលទាំងអស់នេះសុទ្ធតែពឹងផ្អែកលើធម្មជាតិបរិស្ថាននៃផែនដីដោយឡែកការគ្រប់គ្រងនិងការប្រើប្រាស់មិនត្រឹមត្រូវអំពីបរិស្ថានធម្មជាតិទាំងអស់នេះធ្វើឱ្យមានការបាត់បង់ធនធានធម្មជាតិនិងកើតឡើងនូវការប្រែប្រួលអាកាសធាតុជាដើម ដោយសារមនុស្សច្រើនជាងអ្វីផ្សេងទៀតដូចការពោលរៀបរាប់នៅផ្នែកខាងដើមតើមានអ្វីដែលដោះស្រាយបញ្ហាទាំងអស់នេះបាន? តាមរយៈសហគមន៍អន្តរជាតិជាពិសេសអង្គការសហប្រជាជាតិបានលើកឡើងថា មានតែការអប់រំនៅគ្រប់កម្រិតទាំងអស់អាចកំណត់រូបរាងរបស់ពិភពលោកនៅពេលអនាគតដែលជាការផ្ដល់ដល់បុគ្គលនិងសង្គមដែលមានជំនាញទស្សនៈចំណេះដឹងតម្លៃដើម្បីរស់នៅនិងធ្វើការនៅក្នុងលក្ខណៈនិរន្តរភាពគឺការអប់រំដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ នៅក្នុងជំពូកទី៣៦នៃរបៀបវារៈទី២១បានបញ្ជាក់ថា*ការអប់រំគឺជាប្រការសំខាន់សម្រាប់ធ្វើឱ្យមានវឌ្ឍនភាពឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយនិរន្តរភាពនិងលើកកម្ពស់សមត្ថភាពប្រជាជនដែលបាញ់ឆ្ពោះទៅនឹងបញ្ហាបរិស្ថាននិងការអភិវឌ្ឍ*[២១]។ ជាទូទៅគ្រប់សកម្មភាពក៏ដូចជាផលិតផលនានានៅក្នុងសង្គមតែងមានប្រវត្តិនៃការអភិវឌ្ឍរបស់ខ្លួនដោយឡែកសម្រាប់ការអប់រំដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាពដែលរួមមានសមាភាពជាសសរស្តម្ភសំខាន់ចំនួនបីគឺសង្គមបរិស្ថាននិងសេដ្ឋកិច្ចហើយបច្ចុប្បន្នសហគមន៍អន្តរជាតិបានបញ្ចូលផ្នែកវប្បធម៌មួយទៀត។ ទាក់ទងទៅនឹងការការពារបរិស្ថានយើងឃើញមានការជួបជុំគ្នាជាលក្ខណៈអន្តរជាតិនៅអាម៉េរិកខាងជើងនៅក្នុងអំឡុងទសវត្សរ៍ឆ្នាំទី១៩៦០ ដែលបង្ហាញពីបញ្ហាបរិ-ស្ថាននិងព្រះពុទ្ធសាសនានិយម។ ការជួបជុំនេះបានលើកយកទស្សនៈព្រះពុទ្ធសាសនាមកការពារបរិស្ថានដោយយល់ថា មនុស្សត្រូវរស់ដោយឯករាជជាមួយបរិស្ថាន[២២]។

ក្រោយមកនៅអំឡុងទសវត្សរ៍ឆ្នាំទី១៩៧០ក្នុងសេចក្ដីប្រកាស Stockholm ឆ្នាំ១៩៧២ បានលើកអនុសាសន៍ដើម្បីធ្វើឱ្យមានសកម្មភាពរួមគ្នាក្នុងការការពារបរិស្ថានពិភពលោក។ សន្និសីទអន្តរជាតិនេះដែរអំពីការអភិវឌ្ឍនានារបស់សហគមន៍អន្តរជាតិត្រូវយកចិត្តទុកដាក់ទៅដល់បរិស្ថានដោយមានចែងនៅក្នុងគោលការណ៍ទី២៤ គឺសំដៅឱ្យគ្រប់រដ្ឋាភិបាលត្រូវធ្វើសហប្រតិបត្តិការរួមគ្នាក្នុងភាពជាពហុភាគីឬទ្វេភាគី ដើម្បីត្រួតពិនិត្យ

[៦] Cf., Ibid, p., 8.

[៧] Cf., Haruhiko Tanaka, (2009) ***Education for Sustainable Development in Japan***, ESD Research Center, Rikkyo University, p., 7.

[៨] Cf., Edelglass William. (2006), *Moral Pluralism, Skillful Means, and Environmental Ethics*, Volume 3, Fall p., 8.

ការបាត់បង់បរិស្ថាននិងកាត់បន្ថយការបំផ្លាញបរិស្ថានក្នុងបរិបទជាតិតំបន់និងអន្តរជាតិ។ ក្នុងគោលការណ៍ទី២១ សេចក្តីប្រកាស Stockholm នេះដែររដ្ឋនីមួយៗត្រូវមានគោលនយោបាយបរិស្ថាននិងទទួលខុសត្រូវខ្លួនឯងនូវការបាត់បង់បរិស្ថានដែលគោរពទៅតាមច្បាប់អន្តរជាតិនានាដែលពាក់ព័ន្ធទៅនឹងបញ្ហាបរិស្ថាន[២៣]។

ការបាត់បង់ធនធានធម្មជាតិប្រព័ន្ធបរិស្ថានអេកូឡូស៊ីនៅលើផែនដីនៅតែកើតមានជាបន្តក្នុងនោះមានការអភិវឌ្ឍសហគមន៍ប្រកបដោយនិរន្តរភាពក៏មានការលើកឡើងនៅក្នុងគណៈកម្មការពិភពលោកស្តីពីបរិស្ថាននិងការអភិវឌ្ឍឆ្នាំ១៩៨៧បានលើកឡើងពីការអភិវឌ្ឍប្រកបដោយនិរន្តរភាពដែលមានន័យថា៖ *ការអភិវឌ្ឍដែលឆ្លើយតបទៅនឹងតម្រូវការបច្ចុប្បន្នដោយមិនប៉ះពាល់ដល់លទ្ធភាពកូនចៅជំនាន់ក្រោយក្នុងការបំពេញតម្រូវការរបស់ពួកគេ*[២៤]។

នៅក្នុងសន្និសីទកំពូលរបស់អង្គការសហប្រជាជាតិអំពីបរិស្ថាននិងការអភិវឌ្ឍដែលប្រព្រឹត្តទៅនៅក្នុងទីក្រុង Rio de Janeiro ឆ្នាំ១៩៩២ គំនិតនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាពបានទទួលស្គាល់ជាអន្តរជាតិហើយបានចុះក្នុងទិនានុលេខន៍២១ដែលតម្រូវឱ្យមានផែនការសកម្មភាពជាពិសេសសម្រាប់កម្មវិធីនេះ។ ជារួមនៅក្នុងទសវត្សរ៍ឆ្នាំទី១៩៩០ក្នុងកិច្ចប្រជុំលំដាប់ពិភពលោកមានការរៀបចំនិងអនុម័តជាបន្តបន្ទាប់ទៅលើការអភិវឌ្ឍប្រកបដោយនិរន្តរភាពលើប្រធានបទខុសគ្នាដូចជានៅក្នុង៖

-សន្និសីទកំពូលពិភពលោកលើកទីពីរស្តីពី*សិទ្ធិមនុស្ស* នៅទីក្រុង Vienna ឆ្នាំ១៩៩៣

-សន្និសីទអន្តរជាតិស្តីពី*ប្រជាជននិងការអភិវឌ្ឍ* នៅទីក្រុង Cairo ឆ្នាំ១៩៩៤

-ជំនួបកំពូលពិភពលោកស្តីពី*ការអភិវឌ្ឍសង្គម* នៅទីក្រុង Copenhagen ឆ្នាំ១៩៩៥

-សន្និសីទអន្តរជាតិលើកទីបួនស្តីពី*ស្ត្រី* នៅទីក្រុង Beijing ឆ្នាំ១៩៩៥ និងសន្និសីទអង្គការសហប្រជាជាតិលើកទីពីរស្តីពី*ការតាំងលំនៅដ្ឋានរបស់មនុស្សជាតិ* នៅទីក្រុង Istanbul ឆ្នាំ១៩៩៦[២៥]។ នៅក្នុងសន្និសីទរបស់អង្គការសហប្រជាជាតិក៏ដូចជាពិភពលោកទាំងមូលដែលបានរៀបរាប់ខាងលើនេះគឺរាល់កិច្ចពិភាក្សាឬដំណោះស្រាយនានាសុទ្ធសឹងតែផ្តោតទៅលើកំណើននៃប្រជាជនការកាត់បន្ថយភាពក្រីក្របញ្ហាបរិស្ថានបញ្ហាយែនឌ័រការសាងសង់លំនៅដ្ឋានសិទ្ធិមនុស្សនិងការអប់រំជាពិសេសកុមារនិងស្ត្រី។

## ៣. ការអប់រំដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាព

ទោះបីការទទួលបានជាទូទៅនៃការអប់រំមូលដ្ឋានបានកើនឡើងយ៉ាងខ្លាំងនៅក្នុងកំលុងពេលនៃទសវត្សរ៍មុនក៏ដោយក៏អ្នកក្រនៅតែមានលទ្ធភាពតិចក្នុងការចូលរៀននិងងាយនឹងរៀនត្រួតថ្នាក់ហើយមានគុណភាពអប់រំទាបជាងអ្នកមានចំណូលខ្ពស់ជាង។ នៅឆ្នាំ២០០០ កុមារប្រហែល៣២៥លាននាក់មិនបានចូលរៀននិងមនុស្សពេញវ័យច្រើនជាង៨៥០លាននាក់មិនចេះអក្សរដែលប្រហែលពីរភាគបីនៃពួកគេគឺជាស្ត្រី[២៦]។ អត្រាចុះ

---

[៩] Trondalen J. Martin. and Munasingher Mohan, (2004), *Water and Ethics: Ethic and Water Resources Conflicts*, UNESCO, p., 8.

[១០] Matsuura Koïchiro, **(២០០៦) នៅក្នុង** Monique Perroi Lenaud, and others, **យូណេស្កូនិងការអភិវឌ្ឍដែលមានចីរភាព ៖ បកប្រែដោយ ជិន ចាន់រិទ្ធី យូណេស្កូ ភ្នំពេញ ២០០៦ ទំព័រ ១**

[១១] Cf., Tanaka Haruhiko. (2009), *Education for Sustainable Development and Development Education in Japan*, ESDRC, p., 5

[១២] **UNDP, (2002)** *Human Development (New York ៖* UNDP).

ឈ្មោះចូលរៀនក្នុងចំណោមអ្នកក្រទាបដោយសារមូលហេតុជាច្រើនមាន៖ ចម្ងាយផ្លូវទៅកាន់សាលារៀនឆ្ងាយ ថ្លៃសិក្សា (ឧទាហរណ៍ ថ្លៃសាលា សៀវភៅ មធ្យោបាយធ្វើដំណើរ) ការទទួលខុសត្រូវផ្តល់ការថែទាំ មានការថែទាំសមាជិកគ្រួសារដែលមានមេរោគហ៊ីវ/ជំងឺអេដស៍និងតម្លៃឱកាសដទៃទៀត (ការខាតបង់ពលកម្មនៃផលិតកម្មនៅផ្ទះការងារកសិកម្មសហគ្រាសគ្រួសារ។ល។ដែលទាំងនេះជាបញ្ហារាំងស្ទះដល់ការអភិវឌ្ឍនានា។

ចាប់តាំងពីពេលដែលការអភិវឌ្ឍប្រកបដោយនិរន្តរភាពត្រូវបានគាំទ្រជាលើកដំបូងនៅឯមហាសន្និ-បាតអ.ស.ប.ក្នុងឆ្នាំ១៩៨៧ បញ្ញត្តិនៃការអប់រំដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាពក៏ត្រូវគេរាវរកផងដែរ។ សន្និសីទ អ.ស.ប. ស្តីពី បរិស្ថាននិងការអភិវឌ្ឍនៅទីក្រុង Rio de Janeiro កាលពីឆ្នាំ១៩៩២ បាននាំមកចូលរួមជាមួយគ្នានូវអ្នកតំណាងរដ្ឋាភិបាលអង្គការអន្តរជាតិនិងអង្គការមិនមែនរដ្ឋាភិបាល (NGOs) និងសង្គមស៊ីវិលដើម្បីពិភាក្សាអំពីបញ្ហាប្រឈមរបស់សតវត្សរ៍បន្ទាប់និងដើម្បីអនុវត្តតាមផែនការសកម្មភាពជាសាកលដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនេះ។ ផែនការសកម្មភាពដែលត្រូវបានដឹងថាជារបៀបវារៈទី២១ បានផ្តល់នូវគំរូគោលការណ៍យ៉ាងធំទូលំទូលាយមួយដើម្បីជួយរដ្ឋាភិបាលនិងស្ថាប័នផ្សេងៗនៅក្នុងការអនុវត្តគោលនយោបាយនិងកម្មវិធីការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ ជំពូកទី៣៦នៃរបៀបវារៈទី២១ បានបញ្ជាក់ថាការអប់រំគឺជាប្រការសំខាន់សម្រាប់ធ្វើឱ្យមានវឌ្ឍនភាពឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ ការអប់រំដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាព {Education for Sustainable Development (ESD)} *គឺជាទស្សនវិស័យនៃការអប់រំដែលស្វែងរកនូវការធ្វើឱ្យមានតុល្យភាពនៃសុខុមាលភាពសេដ្ឋកិច្ចនិងមនុស្សដោយមានទាំងទំនៀមទម្លាប់ប្រពៃណីវប្បធម៌និងការគោរពចំពោះធនធានធម្មជាតិរបស់ផែនដី*[១៧]។ ESD ប្រើប្រាស់វិធីសាស្ត្រនិងគោលវិធីផ្នែកអប់រំដោយអន្តរវិស័យដើម្បីបង្កើតសុជីវធម៌សម្រាប់ការសិក្សាពេញមួយជីវិត។ ESD ជំរុញឱ្យមាននូវការគោរពចំពោះតម្រូវការមនុស្សដែលស្របគ្នានឹងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាពនិងតម្រូវការរបស់ភពផែនដី។ ESD នឹងថែរក្សាអត្ថន័យនៃសាមគ្គីភាពជាសាកល។

និយមន័យដទៃទៀតនៃ *ការអប់រំដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាព* (ESD)[១៨] ទី១ *គឺជាការអប់រំដែលក្នុងនេះគេត្រូវអនុញ្ញាតឱ្យអ្នកសិក្សាទទួលបាននូវជំនាញសមត្ថភាពតម្លៃនិងចំណេះដឹងដែលជាតម្រូវការសម្រាប់ធានាឱ្យមានការអភិវឌ្ឍប្រកបដោយនិរន្តរភាព*។ ទី២គឺ *ការអប់រំដែលគេត្រូវអនុវត្តទៅក្នុងគ្រប់កម្រិតនិងគ្រប់បរិបទសង្គម (គ្រួសារសាលារៀនកន្លែងធ្វើការសហគមន៍)*។ ទី៣ *គឺការអប់រំទាំងឡាយណាដែលបណ្តុះពលរដ្ឋឱ្យមានការទទួលខុសត្រូវនិងលើកកម្ពស់លទ្ធិប្រជាធិបតេយ្យដោយអនុញ្ញាតឱ្យបុគ្គលនិងសហគមន៍នានាពេញចិត្តនឹងសិទ្ធិនិងបំពេញការទទួលខុសត្រូវរបស់ខ្លួន។ទីបួនការអប់រំដែលផ្អែកទៅលើគោលការណ៍សិក្សាពេញមួយជីវិត* ក្នុងនេះត្រូវរៀបចំឱ្យមនុស្សគ្រប់រូបបានការអប់រំជាប់ជាប្រចាំ។ ទីប្រាំគឺ *សំដៅលើការអប់រំដែលបណ្តុះការអភិវឌ្ឍដើម្បីធ្វើឱ្យមានលំនឹងសម្រាប់បុគ្គលនានាលើគ្រប់ផ្នែកនៃការរស់នៅទាំងទៅលើផ្នែកបរិស្ថានវប្បធម៌និងសេដ្ឋកិច្ច*។

យើងមាននិយមន័យមួយទៀតដែលបង្ហាញអំពីអត្ថន័យប្រហែលគ្នានេះដែរ ESD *គឺជាថាមពលនិងដ៏ទូលំទូលាយនៃកិច្ចការដែលជាការគ្រោងទុកជាមុននៃពិភពលោកហើយមនុស្សម្នាក់ៗត្រូវតែមានសំណាងទទួល*

---

[១៧] UNESCO-APEID (2004), *Education Innovation for Sustainable Development*, NIER, p., 17

[១៨] UNESCO (2003) *យូណេស្កូនិងការអភិវឌ្ឍដែលមានចីរភាព*

*បានផលប្រយោជន៍អំពីកាលានុវត្តភាពនៃការអប់រំដើម្បីរៀនពីរបៀបរស់នៅរៀនអំពីអាកប្បកិរិយានិងតម្លៃចាំបាច់ទៅអនាគតប្រកបដោយនិរន្តរភាព*[១៥]។ ហេតុដូច្នេះហើយ ESD គឺបង្កើតឡើងសម្រាប់មនុស្សគ្រប់ៗគ្នា នៅគ្រប់ស្រទាប់នៃជីវិតនិងនៅគ្រប់បរិបទនៃលទ្ធភាពសិក្សាដែលដូចគ្នាទៅនឹងការអប់រំសម្រាប់ទាំងអស់គ្នាផងដែរ ESD ត្រូវមានការចូលរួមពីពហុផ្នែកនិងអ្នកមានការពាក់ព័ន្ធឬអ្នកចូលរួមដទៃទៀត (Stakeholders) ដើម្បីធ្វើឱ្យសកម្មភាពនេះប្រព្រឹត្តតាមបំណងប្រាថ្នា។ ESD គឺយកចិត្តទុកដាក់សំខាន់ទៅលើសសរស្តម្ភបីក្នុងការធ្វើឱ្យមានការអភិវឌ្ឍប្រកបដោយនិរន្តរភាពមាន៖ សង្គម (Society) បរិស្ថាន (Environment) និងសេដ្ឋកិច្ច (Economic)។ ក្នុងនេះគេក៏រាប់បញ្ចូលនូវវប្បធម៌ផងដែរដែលជាទំហំមួយដ៏មានសារៈសំខាន់សម្រាប់ ESD។

## ៤.ទសវត្សរ៍នៃការអប់រំដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាព

### ៤-១.និន្នាការនៃទសវត្សរ៍នៃការអប់រំដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាព

សន្និសីទសកលសំខាន់ៗមួយចំនួននៅក្នុងទសវត្សរ៍ថ្មីៗនេះបានធ្វើឡើងដើម្បីបង្កើតយុទ្ធសាស្ត្រជាក់ស្តែងអំពីបញ្ហាអភិវឌ្ឍសំខាន់ៗមានការអភិវឌ្ឍប្រកបដោយនិរន្តរភាពនិងទំនាក់ទំនងរវាងភាពក្រីក្របរិស្ថាននិងការប្រើប្រាស់ធនធានធម្មជាតិ។ អនុសាសន៍ដែលបានមកពីសន្និសីទទាំងនេះបានបង្កើតមូលដ្ឋានគោលដៅអភិវឌ្ឍន៍សន្និសីទកំពូលពិភពលោកស្តីពី *ការអភិវឌ្ឍប្រកបដោយនិរន្តរភាព* (WSSD) នៅឆ្នាំ២០០២ បានកំណត់គោលដៅសំខាន់ៗអំពីការលុបបំបាត់ភាពក្រីក្រដោយមានការបន្ថយពាក់កណ្តាលនៅឆ្នាំ២០១៥ នូវសមភាគនៃប្រជាជនពិភពលោកប្រកបដោយចំណូលតិចជាងមួយដុល្លារក្នុងមួយថ្ងៃនិងសមភាគនៃប្រជាជនដែលរងគ្រោះដោយគ្រោះអត់ឃ្លាន។ កាត់បន្ថយពាក់កណ្តាលនៅឆ្នាំ២០១៥ នូវសមភាគនៃប្រជាជនដែលមិនអាចទទួលបានទឹកផឹកមានសុវត្ថិភាពនិងសមភាគនៃប្រជាជនដែលមិនអាចទទួលបានអនាម័យមូលដ្ឋានរួមទាំងការសម្រេចនូវការកែលម្អជាសំខាន់នៃជីវភាពប្រជាជនដែលរស់នៅតំបន់តោកយ៉ាកក្នុងទីក្រុងយ៉ាងតិច១០០លាននាក់នៅឆ្នាំ២០២០។

ម្យ៉ាងទៀតដើម្បីសម្រេចគោលដៅខាងលើនេះនិងគោលដៅ MDGs ទាំងប្រាំបីសហគមន៍អន្តរជាតិនឹងត្រូវតែអនុវត្តយុទ្ធសាស្ត្រដែលមិនត្រឹមតែទាក់ទងនឹងវិធានការសេដ្ឋកិច្ច ប៉ុន្តែថែមទាំងទាក់ទងនឹងលទ្ធផលសុខភាពការទទួលបានការអប់រំប្រកបដោយគុណភាពជម្រកស្នាក់នៅសមភាពយេនឌ័រនិងការការពារបរិស្ថានទៀតផង។

ថ្មីៗនេះតាមរយៈមហាសន្និបាតអង្គការសហប្រជាជាតិនៅ Johannesburg នាឆ្នាំ២០០២ បានលើកទិសនិងកំណត់នយោបាយអប់រំស្តីពី "ទសវត្សរ៍នៃការអប់រំដើម្បីអភិវឌ្ឍប្រកបដោយនិរន្តរភាព" ដោយគិតចាប់ពីឆ្នាំ២០០៥-២០១៤ ក្នុងនេះគឺផ្តោតជាសំខាន់ទៅលើការផ្តល់កាលានុវត្តនភាពក្នុងការបើកទូលាយនូវការប្រតិបត្តិជាលក្ខណៈពិភពលោកដើម្បីការអប់រំនិងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ ដំណាក់កាលនីមួយៗនៃសន្និសីទខ្នាតពិភពលោកទាំងនេះជាបន្តបន្ទាប់បានបង្កើតឱ្យមាននូវការអប់រំដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាពនេះឡើង។

### ៤-២.បញ្ហាប្រឈមថ្មីៗនៃការអប់រំដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាព នៅលើពិភពលោក

[១៥] Cf., UNDESD, (2005), *United Nations Decade of Education for Sustainable Development, 2005-2014*, Asia-Pacific Region.

ចាប់តាំងពីឆ្នាំ១៩៨៥មក អ.ស.ប.បានបង្កើតទសវត្សរ៍ជាបន្តបន្ទាប់ដើម្បីទាក់ទាញចំណាប់អារម្មណ៍អំពីបញ្ហាសំខាន់ៗនិងដើម្បីជំរុញសកម្មភាពអន្តរជាតិដោះស្រាយបញ្ហាដែលមានសារៈសំខាន់ចំពោះពិភពលោក។ អនុសាសន៍សម្រាប់ DESD បានគាំទ្រនៅឯសន្និសីទកំពូលពិភពលោកសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរ-ភាព (WSSD) នៅទីក្រុង Bali ប្រទេសឥណ្ឌូណេស៊ីនៅខែមិថុនា ឆ្នាំ២០០២ និងបានអនុម័តនៅកម្រិតនយោបាយខ្ពស់បំផុតនៅឯ WSSD នៅឯទីក្រុង Johannesburg ប្រទេសអាហ្រ្វិកខាងត្បូង នៅខែកញ្ញា ឆ្នាំ២០០២។ ផែនការអនុវត្តនៃ WSSD បានគូសបញ្ជាក់អំពីសារៈសំខាន់នៃការអប់រំដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាពនិងផ្ដល់អនុសាសន៍ថាមហាសន្និបាតអ.ស.ប. "គួរតែពិចារណាអនុម័តទសវត្សរ៍នៃការអប់រំដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាពដោយចាប់ផ្ដើមនៅឆ្នាំ២០០៥។ បីខែក្រោយមកពង្រាងដំណោះស្រាយ A/C.2/57/L.71 បានដាក់ជូនមហាសន្និបាតដោយរដ្ឋាភិបាលជប៉ុនដោយមានការគាំទ្រពីប្រទេសដទៃទៀតជាច្រើន។ ដំណោះស្រាយនេះត្រូវបានអនុម័តជាឯកច្ឆន្ទដោយគណៈកម្មការហើយ DESD បានប្រកាសចាប់ផ្ដើមដំណើរការនៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៥។

បណ្ដាប្រទេសនៅតំបន់អាស៊ីបាស៊ីហ្វិកនិងអង្គការយូណេស្កូបានយកចិត្តទុកដាក់ពង្រឹងនិងពង្រីកការអនុវត្តនិងសម្រេចឱ្យបានក្នុងរយៈពេល១ទសវត្សរ៍លើផែនការ DESD ដើម្បីរួមគ្នាដោះស្រាយបញ្ហាដែលមាន ១១ចំណុចនៃបញ្ហាជាមូលដ្ឋានដូចខាងក្រោម[៣០]៖

១-ព័ត៌មាននិងការយល់ដឹង (Information and Awareness)៖ ក្នុងនេះការអប់រំត្រូវផ្ដល់ឬកើតឡើងពីបណ្ដាញព័ត៌មានសេដ្ឋកិច្ចបណ្ដាញព័ត៌មានពីអគ្គរកម្មនិងបច្ចេកទេសទំនាក់ទំនងព័ត៌មានវិទ្យា។

២-ប្រព័ន្ធចំណេះដឹង (Knowledge Systems): គឺជាការរួមបញ្ចូលជាមួយនឹងកម្មវិធីសិក្សាតាមកម្រិតសិក្សានីមួយៗត្រូវសិក្សារៀនសូត្របន្ថែមពីចំណេះដឹងក្នុងតំបន់និងពីជនជាតិដើមភាគតិច ព្រមទាំងសមាហរណបន្ថែមដែរនូវទំនៀមទម្លាប់ប្រពៃណីនិងបច្ចេកទេសទំនើបនៅក្នុងការអប់រំគ្រប់ផ្នែកនិងគ្រប់កម្រិត។

៣-ការគ្រប់គ្រងនិងការពារបរិស្ថាន (Environmental Protection and Management): ចំណុចនេះត្រូវអប់រំដល់មនុស្សទាំងអស់គ្នាឱ្យបានយល់ដឹងចេះគ្រប់គ្រងនិងការការពារថែរក្សាបរិស្ថានឱ្យបានល្អដែលរួមមានផ្នែកជីវៈចម្រុះ (Biodiversity) ការផ្លាស់ប្ដូរអាកាសធាតុឬបរិយាកាសនិងធនធានធម្មជាតិជាដើម។

៤-សន្តិភាពនិងសមធម៌ (Peace and Equity): ក្នុងនេះត្រូវដោះស្រាយទំនាស់ផ្សេងៗទៅតាមលក្ខណៈសន្តិភាពសមធម៌ការអភិវឌ្ឍសមស្របនិងប្រកបដោយលក្ខណៈប្រជាធិបតេយ្យ។

៥-បរិបទតំបន់ (Local Context): ដែលចំណុចនេះមានន័យថាការអប់រំត្រូវតែធ្វើឡើងដើម្បីអភិវឌ្ឍសហគមន៍ហើយនៅក្នុងចំណុចនេះត្រូវផ្ដល់អំណាចទៅដល់សហគមន៍ដើម្បីធ្វើឱ្យសហគមន៍មានការអភិវឌ្ឍដោយខ្លួនឯងដោយពឹងផ្អែកទៅលើអ្វីដែលសហគមន៍មាននិងជំនួយពីខាងក្រៅ (ដូចជាបច្ចេកទេស សម្ភារៈថវិកា...ជាដើម)។

៦-ការផ្លាស់ប្ដូរ (Transformation): បញ្ហានេះយើងត្រូវធ្វើឱ្យមានការផ្លាស់ប្ដូរនិងប្រែប្រួលអភិវឌ្ឍនៅគ្រប់ទីកន្លែងក្នុងនេះរួមមានការផ្លាស់ប្ដូរមុខមាត់ជនបទការធ្វើជាទីក្រុងនីយកម្មការរៀបចំលំនៅដ្ឋានប្រកបដោយនិរន្តរភាពទឹកស្អាតអនាម័យនិងហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាដើម។

[៣០] UNESCO, (2005) *Working Paper, Asia-Pacific Regional Strategy for ESD*, p., 4.

៧-វប្បធម៌ (Culture)៖ អត្ថន័យនៃចំណុចនេះគឺសង្កត់ធ្ងន់ទៅលើការយល់ដឹងពីភាពទីទៃពីគ្នានៃវប្បធម៌នីមួយៗពីអន្តរវប្បធម៌និងអន្តរសាសនា (Interfaith) ផងដែរ។

៨-ប្រធានបទនិងបញ្ហាឆ្លងគ្នា (Cross Cutting Issues and Themes)៖ ចំណុចនេះគឺផ្តោតទៅលើសិទ្ធិមនុស្សភាពជាពលរដ្ឋល្អសមភាពយេនឌ័រអនាគតប្រកបដោយនិរន្តរភាពការបង្កើតថ្មីនិងភាពជាដៃគូល្អ។ ផលិតនិងប្រើប្រាស់ផលិតផលប្រកបដោយនិរន្តរភាពនិងការដឹកនាំល្អ។

៩-សុខភាព (Health)៖ គឺជាការយកចិត្តទុកដាក់ថែរក្សានិងទប់ស្កាត់នូវជំងឺខ្លះ ដែលសំខាន់ៗដូចជាអ្នកផ្ទុកវីរុស HIV អ្នកកើតជំងឺអេដស៏និងជំងឺគ្រុនចាញ់។ល។

១០-អប់រំផ្នែកបរិស្ថាន (Environmental Education)៖ ផ្នែកនេះត្រូវសមាហរណនូវការគ្រប់គ្រងឱ្យបាននូវជំងឺផ្សេងៗការយល់ដឹងពីបរិស្ថាននិងការកែច្នៃឡើងវិញនូវកម្មវិធីសហគមន៍។

១១-ការសន្យាចូលរួមពីអ្នកដឹកនាំ (Engagement of Leaders)៖ការសន្យានេះធ្វើឡើងដើម្បីធានាឱ្យមានការបណ្តុះបណ្តាលវិជ្ជាជីវៈនីតិប្រតិបត្តិអប់រំភាពជាដៃគូល្អនិងបណ្តាញការងារល្អ។

**៥.សន្និដ្ឋាន**

ដើម្បីរក្សាបាននូវធនធានធម្មជាតិបរិស្ថានល្អនៅក្នុងការអភិវឌ្ឍសម្រាប់អនាគតជនជំនាន់ក្រោយអ្នកជំនាន់មុនគួរគិតគូរទៅលើគ្រប់ទិដ្ឋភាពនៃការអភិវឌ្ឍឱ្យបានគ្រប់ជ្រុងជ្រោយជាពិសេសការប្រើប្រាស់ធនធានធម្មជាតិនៅលើផែនដីយើងនេះ។ ជាការពិតណាស់ពិភពលោកយើងនេះបានគិតគូរអំពីផលប៉ះពាល់នានានៃការអភិវឌ្ឍនៅលើផែនដីយើងទាំងមូល ប៉ុន្តែភាគច្រើនគឺស្ថិតនៅត្រឹមទ្រឹស្តីព្រោះថាប្រទេសខ្លះបានអនុវត្តតាមគោលនយោបាយរួមរបស់អន្តរជាតិដែលមានច្បាប់ សន្ធិសញ្ញា ក្រមសីលធម៌អន្តរជាតិជាដើម ហើយប្រទេសខ្លះមិនបានអនុវត្តតាមទិសដៅអន្តរជាតិទាំងនេះទេ។ ដោយឡែកសម្រាប់ប្រទេសមួយៗវិញក៏មានវិធានការច្បាប់ វិន័យ សារាចរណែនាំនិងក្រមសីលធម៌របស់ខ្លួនផងដែរ ប៉ុន្តែរូបភាពបាត់បង់ធនធានធម្មជាតិរបស់ប្រទេសនោះ នៅតែរីចរេលដដែលទោះបីមានអន្តរាគមន៍ទាំងខាងក្នុងនិងខាងក្រៅក៏ដោយ។ ហេតុដូច្នេះហើយមធ្យោបាយបច្ចុប្បន្នដែលពិភពលោកកំពុងតែធ្វើគឺ*ការអប់រំដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាព* ដែលជាផ្លូវមួយនាំយើងទាំងអស់គ្នាទៅកាន់ការថែរក្សាបាននូវធនធានធម្មជាតិក្នុងការអភិវឌ្ឍបានយូរអង្វែងសម្រាប់ជនជំនាន់ក្រោយដើម្បីធ្វើឱ្យជនទាំងនោះមានការផ្លាស់ប្តូរទៅលើចំណេះដឹងថ្មីអាកប្បកិរិយាថ្មី ឥរិយាបថថ្មីឬការអនុវត្តថ្មីសម្រាប់អនាគតរបស់ពួកគេនិងជនជំនាន់ក្រោយបន្តបន្ទាប់ទៀត។

# គន្ថនិទ្ទេស

-Matsuura Koïchiro, (២០០៦) នៅក្នុង Monique Perroi Lenaud, and others, យូណេស្កូនិងការអភិវឌ្ឍដែលមានចីរភាព ៖ បកប្រែដោយ ជិន ចាន់រិទ្ធី យូណេស្កូ ភ្នំពេញ ២០០៦។

-Edelglass William. (2006), *Moral Pluralism, Skillful Means, and Environmental Ethics*, Volume 3, Fall.

-Environmental law, Retrieved from Wikipedia.

-Jackson Yvette, (2006), *Evolutionary Spiral in the Development of Environmental Ethics*, Mg JICEL, vol.3.

-Haruhiko Tanaka, (2009) *Education for Sustainable Development in Japan*, ESD Research Center, Rikkyo University.

-Trondalen J. Martin. and Munasingher Mohan, (2004), *Water and Ethics: Ethic and Water Resources Conflicts*, UNESCO.

-UNESCO, (2005) *Working Paper, Asia-Pacific Regional Strategy for ESD.*

-UNESCO-APEID (2004), *Education Innovation for Sustainable Development*, NIER.

-UNDESD, (2005), *United Nations Decade of Education for Sustainable Development, 2005-2014*, Asia-Pacific Region.

-**UNESCO (2003)** *យូណេស្កូនិងការអភិវឌ្ឍដែលមានចីរភាព។*

-**UNDP. (2002)** *Human Development (New York :* UNDP)។

-World population, retrieved from, http://en.wikipedia.org/wiki/World_population

-Zhu Dajian, (2004), *Towards a Closed-Loop Materials Economy* in: *Chinese Journal of Population Resources and Environment,* Vol. 2 No. 1

# ការគ្រប់គ្រងរដ្ឋបាលមូលដ្ឋានតាមប្រព័ន្ធវិមជ្ឈការនិងវិសហមជ្ឈការ នៅស្រុកកំចាយមារ



**ព្រុំ ធី**
បេក្ខជនបណ្ឌិតជំនាន់ទី១ ផ្នែកគ្រប់គ្រង
នៃសាកលវិទ្យាល័យឯកទេសនៃកម្ពុជា

## ១-សេចក្តីផ្តើម

ការគ្រប់គ្រងរដ្ឋបាលមូលដ្ឋានតាមប្រព័ន្ធវិមជ្ឈការនិងវិសហមជ្ឈការគឺជាមូលដ្ឋានគ្រឹះនៃលទ្ធិប្រជាធិបតេយ្យដែលតម្រូវឱ្យប្រជាពលរដ្ឋចូលរួមចំណែកផ្ទាល់ ឬ តាមរយៈតំណាងរបស់ខ្លួនក្នុងការធ្វើសេចក្តីសម្រេចចិត្តនានា ពាក់ព័ន្ធទៅនឹងការធ្វើផែនការអភិវឌ្ឍន៍មូលដ្ឋាន។

តាមវចនានុក្រមរបស់ខ្មែរ «ប្រជាធិបតេយ្យ» មានន័យថា ភាពនៃប្រទេសដែលមានប្រជារាស្ត្រជាអធិបតីគឺប្រទេសឬរដ្ឋបាលដែលមានប្រជាជនជាធំក្នុងការរើសតំណាងរបស់ខ្លួនជាអ្នកសម្រេចកិច្ចការក្នុងប្រទេស។

***វិមជ្ឈការ ៖*** *គឺរាជរដ្ឋាភិបាលប្រគល់ឱ្យក្រុមប្រឹក្សានូវភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច និង ធនធាន ដើម្បីឆ្លើយតបតម្រូវការរបស់មូលដ្ឋាន។ ក្រុមប្រឹក្សាត្រូវមានការទទួលខុសត្រូវចំពោះប្រជាពលរដ្ឋនៅមូលដ្ឋានលើបញ្ហានេះ។ ក្រុមប្រឹក្សាឃុំ-សង្កាត់កើតឡើងដោយការបោះឆ្នោតជ្រើសតាំងពីប្រជាពលរដ្ឋ។ ឃុំ-សង្កាត់ទទួលបានអំណាចទទួលខុសត្រូវមួយចំនួនដែលប្រគល់ឱ្យដោយច្បាប់ និង មានមធ្យោបាយមួយចំនួនគឺថវិការបស់ឃុំ-សង្កាត់ផ្ទាល់ឬក៏ធនធានដែលមាននៅក្នុងឃុំ-សង្កាត់។ ក្រោយមកក៏មានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។*

***វិសហមជ្ឈការ ៖*** *រាជរដ្ឋាភិបាល ឬ ក្រសួង ស្ថាប័នធ្វើប្រតិភូកម្មមុខងារ សិទ្ធិអំណាចនិងធនធានទៅឱ្យអង្គភាពក្រោមបង្គាប់ឬទៅក្រុមប្រឹក្សាប្រភេទណាមួយដើម្បីអនុវត្តក្នុងនាមរាជរដ្ឋាភិបាល ឬ ក្រសួង ស្ថាប័ន។ អង្គភាពឬក្រុមប្រឹក្សានោះត្រូវមានការទទួលខុសត្រូវចំពោះរាជរដ្ឋាភិបាល ឬ ក្រសួង ស្ថាប័ន។* គោលការណ៍សំខាន់ៗទាំងពីរខាងលើនេះត្រូវរាជរដ្ឋាភិបាលយកទៅអនុវត្តនៅថ្នាក់មូលដ្ឋាន ជាពិសេសក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់លើកទី១ នៅឆ្នាំ២០០២។ ប៉ុន្តែសព្វថ្ងៃ ការអនុវត្តគោលនយោបាយទាំងនេះនៅមានកម្រិតទាប ដោយសារមូលហេតុផ្សេងៗ ហេតុដូចនេះ ទើបប្រធានបទខាងលើត្រូវជ្រើសរើសយកមកសិក្សា។

## ២-គោលបំណងនៃការសិក្សា

១-សិក្សាលើដំណើរការគ្រប់គ្រងមូលដ្ឋានតាមប្រព័ន្ធវិមជ្ឈការនិងវិសហមជ្ឈការ

២-ស្វែងយល់ពីការគ្រប់គ្រងសេដ្ឋកិច្ចនៅមូលដ្ឋាន

៣-វិភាគលើប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធវិមជ្ឈការនិងវិសហមជ្ឈការ។

## ៣-វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីឱ្យសមស្របតាមគោលបំណងនិងពេលវេលានៃការសិក្សា អ្នកស្រាវជ្រាវបានកំណត់គោលដៅនៃការសម្ភាសចំនួន៤០០គ្រួសារ ដោយគណនារូបមន្ត Yamane Taro:

$$n = \frac{N}{1+Ne^2}$$ n = ចំនួនគ្រួសារដែលត្រូវសម្ភាសន៍ N = ចំនួនគ្រួសារសរុប

e = កម្រិតលម្អៀង, ដោយកំណត់យក e =5%/ N = 18.699 គ្រួសារ

$$n = \frac{18699}{1+18699(0{,}05)^2} = \frac{18699}{1+46{,}7475} = \frac{18699}{47{,}7475} =$$ 391RKYsar

បន្ថែមសមាជិកក្រុមប្រឹក្សាស្រុកនិងមន្ត្រីរាជការ ០៩រូប

| ខេត្ត | ស្រុក | ឃុំ | ភូមិ | ចំនួនគ្រួសារ | ទំហំសំណាក |
|---|---|---|---|---|---|
| **ព្រៃវែង** | **ស្វាយអន្ទរ** | -ជាខ្លាង<br>២.២៣៧គ្រួសារ | -ជ្រៃសីម៉ា<br>-ផ្ទង់<br>-ឆ្កែកូន | ២៧៨ គ្រួសារ<br>៤២២ គ្រួសារ<br>៤០៤ គ្រួសារ | ១៩ គ្រួសារ<br>២៩ គ្រួសារ<br>២៨ គ្រួសារ |
| | | -ជ្រៃ<br>៣.១៦២គ្រួសារ | -ស្វាយអាត់<br>-ក្រសាំងគយ<br>-ព្រៃតាណាន់ | ១៧២ គ្រួសារ<br>២១៦ គ្រួសារ<br>១៤១ គ្រួសារ | ១២ គ្រួសារ<br>១៥ គ្រួសារ<br>១០ គ្រួសារ |
| | **ពារាំង** | -រាប<br>២.៧៦២គ្រួសារ | -ចុងក្រូច<br>-វៃវេត<br>-ជ្រៃ | ៥៣១ គ្រួសារ<br>៤៤៥ គ្រួសារ<br>១៦២ គ្រួសារ | ៣៩ គ្រួសារ<br>៣១ គ្រួសារ<br>១១គ្រួសារ |
| | | -រកា<br>៣.៦២៨គ្រួសារ | -ស្វាយពល<br>-ត្រកៀត<br>-ត្នោត | ៧៨១ គ្រួសារ<br>៣១៩ គ្រួសារ<br>៤១៦ គ្រួសារ | ៥៤ គ្រួសារ<br>២២ គ្រួសារ<br>២៩ គ្រួសារ |
| | **កំចាយមារ** | -ស្មោងជើង<br>៣.៨៦៥គ្រួសារ | -ថ្នល់កែង<br>-ព្រៃស្នួរ<br>-តាម៉ិញ | ៣៧៣ គ្រួសារ<br>២៧៩ គ្រួសារ<br>១៨៦ គ្រួសារ | ២៦ គ្រួសារ<br>១៩ គ្រួសារ<br>១៣ គ្រួសារ |
| | | -ស្មោងត្បូង<br>៣.០៤៥គ្រួសារ | -ព្រៃធំ<br>-ព្រឹក្សាទី ១<br>-ព្រឹក្សាទី ២ | ៣០២ គ្រួសារ<br>៩៥ គ្រួសារ<br>១៨៨ គ្រួសារ | ២១ គ្រួសារ<br>០៦ គ្រួសារ<br>១៣ គ្រួសារ |
| | | | **សរុប** | **១៨៦៩៩. គ្រួសារ** | **៣៩១ គ្រួសារ** |

## ៤-លទ្ធផលនៃការស្រាវជ្រាវនិងពិភាក្សា

### ក-ទីតាំងភូមិសាស្ត្រស្រុកកំចាយមារ

ស្រុកកំចាយមារ ស្ថិតភូមិជោរ៍ ឃុំក្រញូង នៅតាមបណ្តោយផ្លូវជាតិលេខ ៨ មានចម្ងាយ ៤៥គីឡូម៉ែត្រ ពីទីរួមខេត្តព្រៃវែង។ ព្រំប្រទល់ខាងជើងទល់នឹងស្រុកកញ្ជ្រៀច ខេត្តព្រៃវែង និងស្រុកពញាក្រែក ខេត្តកំពង់-ចាម។ ខាងត្បូងទល់នឹងស្រុករមាសហែក ខេត្តស្វាយរៀង និងស្រុកមេសាង ខេត្តព្រៃវែង។ ខាងលិចទល់នឹងស្រុកស្វាយអន្ទរ និងស្រុកកញ្ជ្រៀច ខេត្តព្រៃវែង។ ផ្ទៃដីសរុប ៣៥.១៨៣ហិចតា, ផ្ទៃដីបង្កបង្កើនផល ២៣.០៦០ហិចតា, ដីលំនៅដ្ឋាន ៥.៣០៨ហិចតា, ដីដាំដំណាំ មានចំនួន៦.៨១៥ហិចតា។ ប្រជាពលរដ្ឋសរុប ៨៧.៧៣៥នាក់ ស្មើនឹង ២០.០៣១គ្រួសារ។ ដង់ស៊ីតេមធ្យម ២៦១ នាក់/គម$^2$។

ស្រុកកំចាយមារ មាន៨ ឃុំគឺ ឃុំជាច, ឃុំស៊ាងឃ្វាង, ឃុំដូនកឹង, ឃុំស្មោងជើង, ឃុំក្រញូង, ឃុំក្របៅ, ឃុំស្មោងត្បូង, ឃុំត្របែក។ មានភូមិចំនួន១២៩ភូមិ។

ស្រុកកំចាយមារ បានគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ( គ.អ.ជ.ខ.) សម្រេចជ្រើសរើសជាស្រុកគោលដៅសម្រាប់អនុវត្តកម្មវិធីសាកល្បងពង្រឹងតួនាទីថ្នាក់ស្រុក ក្រុង ក្រោមលក្ខខណ្ឌជាស្រុកដែលក្រីក្រជាងគេ។ ឆ្នាំ២០១០ ថវិកាវិភាជន៍សម្រាប់ការអនុវត្តកម្មវិធីមានចំនួន៣០,០០០ដុល្លារ។ ថវិកាចំនួន១៩,១៩៩.៩៩ដុល្លារ ផ្សេងទៀតជាថវិកាជាប់កិច្ចសន្យាគម្រោងជួសជុលផ្លូវលំ ២ខ្សែ ប្រវែង ៥.៧៤៨គីឡូម៉ែត្រ ឆ្នាំ២០០៩ ដែលនឹងបន្តទូទាត់ នៅឆ្នាំ២០១០។ ដូច្នេះថវិកាសរុបទាំងអស់របស់ស្រុកកំចាយមារមានចំនួន៤៩,១៩៩.៩៩-ដុល្លារ ដែលត្រូវរ៉ាប់រងចំណាយប្រតិបត្តិការនិងគម្រោងវិនិយោគដែលជាអាទិភាពរបស់ស្រុក។ ថវិកាទាំងនេះបានផ្តល់ឱកាសឱ្យសុកកំចាយមារមានលទ្ធភាពអនុវត្តទាំងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងអរូបវន្ត។ ហេដ្ឋា-រចនាសម្ព័ន្ធរូបវន្តដើម្បីកសាងផ្លូវថ្មល់ក្រាលគ្រួសក្រហម ផ្លូវលំ ការស្តារប្រឡាយទឹក ការជីកអណ្តូង។ល។ រីឯគម្រោងហេដ្ឋារចនាសម្ព័ន្ធអរូបវន្តវិញយកចិត្តទុកដាក់ ចំពោះវគ្គបណ្តុះបណ្តាលស្តីពីការដាំដំណាំស្រូវ, ផ្សព្វ-ផ្សាយច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ, ផ្សព្វផ្សាយច្បាប់ចរាចរផ្លូវគោក, វគ្គបណ្តុះបណ្តាលបច្ចេកទេសធ្វើជីកំប៉ុស្តនិងប្រើជីគីមី, ផ្សព្វផ្សាយពីសារប្រយោជន៍នៃការចុះអត្រានុកូលដ្ឋាន, អប់រំសុខភាពអនាម័យ, សារប្រយោជន៍និងផលប៉ះពាល់នៃការប្រើប្រាស់ថ្នាំពុលកសិកម្ម។ ក្រៅពីនោះស្រុកបានគ្រោងថវិកា ១០ភាគរយនៃថវិកាវិភាជន៍សរុបសម្រាប់កិច្ចការរដ្ឋបាលនិងការពង្រឹងសមត្ថភាពដល់ក្រុមការងាររបស់ស្រុក។

+ស្រុកកំចាយមារមានភព្វសំណាងបានទទួលអំណោយដ៏ថ្លៃថ្លារបស់ ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងលោកជំទាវក្នុងការកសាងសមិទ្ធផលផ្សេងៗដូចជា ៖

-សាកលវិទ្យាល័យ **ជា ស៊ីម កំចាយមារ ៖**

ក-អគារសិក្សាធំកម្ពស់ ៤ជាន់ មានទទឹង ១៤ម៉ែត្រ បណ្តោយ ១៧៧ម៉ែត្រ។

ខ-អគារសិក្សា ១ខ្នង កម្ពស់ ២ជាន់ មានទទឹង ៩ម៉ែត្រ បណ្តោយ ៥០ម៉ែត្រ។

គ-អគារបណ្ណាល័យកម្ពស់ ២ជាន់ មានទទឹង ៣០ ម៉ែត្រ បណ្តោយ ៥៤ ម៉ែត្រ។

ឃ-អគារអន្តេវាសិកដ្ឋាន មានទទឹង ១១ម៉ែត្រ បណ្តោយ ៤២ម៉ែត្រ សរុប ២៦ខ្នង។

ច-សាលប្រជុំដែលបានសាងសង់ផ្ទាល់ដីអាចផ្ទុកសមាជិកបាន ១.០០០នាក់។

-វិទ្យាល័យ ហ៊ុន សែន **កំចាយមារ ៖**

-អគារសិក្សាកម្ពស់ ៣ជាន់ ចំនួន៣ខ្នង និងអគារកាត់ដេរចំនួន ១ខ្នង កម្ពស់ ២ជាន់។

**ខ-ការវិភាគអំពីលទ្ធផលនៃការសម្ភាសន៍**

តារាងទី១ ថវិកាអភិវឌ្ឍន៍ឃុំ-សង្កាត់បានមកពីប្រភពណា?

| រាជរដ្ឋាភិបាល | | អង្គការក្រៅរដ្ឋាភិបាល | | សប្បុរសជន | | ប្រជាពលរដ្ឋ | | Chi-square | p. |
|---|---|---|---|---|---|---|---|---|---|
| ដឹង | មិនដឹង | ដឹង | មិនដឹង | ដឹង | មិនដឹង | ដឹង | មិនដឹង | | |
| ៤០០ | ០ | ៣៦០ | ៤០ | ២៥០ | ១៥០ | ៣៧០ | ៣០ | ២៥៦ | <0,00១ |

តារាងទី១ បញ្ជាក់ថា ជាទូទៅប្រជាពលរដ្ឋដឹងពីប្រភពថវិកាសម្រាប់អភិវឌ្ឍន៍ដែលឃុំ-សង្កាត់ទទួលបានពីប្រភពផ្សេងៗដូចជា ការធ្វើវិភាជពីរាជរដ្ឋាភិបាល, អង្គការក្រៅរដ្ឋាភិបាល, សប្បុរសជន និងការចូលរួមរបស់ប្រជាពលរដ្ឋ p.<0,00១។

តារាងទី២ អំពីដំណើរការរដ្ឋបាលនៅថ្នាក់ឃុំ-សង្កាត់ ?

| លំបាក | មិនលំបាក | *មិនមានចម្លើយ* | Chi-square | p. |
|---|---|---|---|---|
| ៣៤៣ | ៥១ | ០៦ | ៥០២,១៤ | <0,00១ |

តារាងទី២ បញ្ជាក់ថា ដំណើរការរដ្ឋបាលនៅថ្នាក់ឃុំ-សង្កាត់មានការលំបាកដោយសមត្ថភាព និងការយល់ដឹងរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់នៅមានកម្រិតទាប p. <0,00១។

តារាងទី៣ ថវិកាអភិវឌ្ឍន៍ឃុំ-សង្កាត់បានជួយអ្វីខ្លះដល់មូលដ្ឋាននាពេលកន្លងមក ?

| កសាងផ្លូវថ្នល់ | | *ប្រឡាយទឹក* | | *លូកាត់ផ្លូវ* | | Chi-square | p. |
|---|---|---|---|---|---|---|---|
| ដឹង | មិនដឹង | ដឹង | មិនដឹង | ដឹង | មិនដឹង | | |
| ៣៩០ | ១០ | *៣៧៥* | *២៥* | *២០៧* | *១៩៣* | ៣៦១,0 | <0,00១ |

តារាងទី៣ បញ្ជាក់ដឹងថា ជាទូទៅប្រជាពលរដ្ឋដឹងពីប្រភពថវិកាសម្រាប់កសាងផ្លូវថ្នល់ ប្រឡាយទឹក លូកាត់ផ្លូវ ដោយការយល់ដឹងមានកម្រិតខ្ពស់ p.<0,00១។

តារាងទី៤ តើសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់អាចឆ្លើយតបទៅនឹងតួនាទី ភារកិច្ច និង ការទទួលខុសត្រូវដែរឬទេ ?

| *ខ្ពស់* | *មធ្យម* | *ខ្សោយ* | Chi-square | p. |
|---|---|---|---|---|
| *៨៦* | *២២៤* | *៩០* | ៩២,៥៤ | <0,00១ |

តារាងទី៤ បញ្ជាក់ថា សមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់អាចឆ្លើយតបទៅនឹងតួនាទីភារកិច្ច បានមធ្យម **p.** <0,00១។

តារាងទី៥ ការគ្រប់គ្រងប្រព័ន្ធរដ្ឋបាលនៅថ្នាក់ឃុំ-សង្កាត់

| *បែបបទរដ្ឋបាល* | *ទាប* | *មធ្យម* | *ខ្ពស់* | Chi-square | p. |
|---|---|---|---|---|---|
| កម្រិតនៃការសរសេរលិខិត-បែបបទរដ្ឋបាល | ១៨៥ | ២១៣ | ០២ | ១៩៨,៩៨ | **<0,00១** |
| ការសរសេរកិច្ចសន្យា | ១៨០ | ២១៦ | ០៤ | ១៩៣,០៤ | **<0,00១** |
| ការធ្វើរបាយការណ៍ | ១៩៨ | ១៩០ | ១២ | ១៦៥,៨៦ | **<0,00១** |
| ការយល់ដឹងពីច្បាប់គ្រប់គ្រងឃុំ-សង្កាត់ | ១១១ | ២៦៨ | ២១ | ២៣៤,៣៩ | **<0,00១** |
| ការយល់ដឹងពីច្បាប់អគ្រានុកូលដ្ឋាន | ៨៩ | ២២៣ | ៨៨ | ៩០.៤៥ | **<0,00១** |

តារាងទី៥ បញ្ជាក់ថា សមត្ថភាពនៃការគ្រប់គ្រងប្រព័ន្ធរដ្ឋបាលនៅថ្នាក់ឃុំ-សង្កាត់មានកម្រិតមធ្យម **p.** <0,00១។

តារាងទី៦ ការគ្រប់គ្រងផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់

| *ផែនការអភិវឌ្ឍន៍* | *ទាប* | *មធ្យម* | *ខ្ពស់* | Chi-square | p. |
|---|---|---|---|---|---|
| ការសរសេរស្នើសុំគម្រោងតូចៗ | ២០៣ | ១៩៣ | ០៤ | ១៨៨,៥៥ | **<0,00១** |
| ការត្រួតពិនិត្យនិងវាយតម្លៃសមិទ្ធផលគម្រោង | ២០៥ | ១៨៩ | ០៦ | ១៨៣,៣៦ | **<0,00១** |
| ការរៀបចំកសាងផែនការអភិវឌ្ឍន៍មូលដ្ឋាន | ១១៥ | ២៣៤ | ៥១ | ១២៩,៣៦ | **<0,00១** |

តារាងទី៦ បញ្ជាក់ថា ការគ្រប់គ្រងផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់នៅមានកំរិតទាបនៅឡើយ **p.** <0,00១។

តារាងទី៧ ការគ្រប់គ្រងចំណូលថវិការបស់ឃុំ-សង្កាត់

| ការគ្រប់គ្រងចំណូលថវិការបស់ឃុំ-សង្កាត់មានតម្លាភាពឬទេ? | | Chi-square | p. |
|---|---|---|---|
| មានតម្លាភាព | មិនមានតម្លាភាព | | |
| *២០៧* | ***១៩៣*** | **0,៤៨** | **>0,0៥** |

តារាងទី៧ បញ្ជាក់ថា ការគ្រប់គ្រងចំណូលថវិការបស់ឃុំ-សង្កាត់មិនសូវមានតម្លាភាព **p.** >0,0៥។

តារាងទី៨ កត្តាដែលនាំអោយប៉ះពាល់ដល់ការអភិវឌ្ឍន៍ឃុំ-សង្កាត់

| កត្តាដែលនាំឱ្យការងាររដ្ឋបាលមានប្រសិទ្ធភាព | | | កត្តាដែលជាគុណវិបត្តិចំពោះការងាររដ្ឋបាល | | កត្តាលំបាកក្នុងការរៀបចំផែនការអភិវឌ្ឍន៍ | | | Chi-square | p. |
|---|---|---|---|---|---|---|---|---|---|
| *ត្រូវមានថវិកាគ្រប់គ្រាន់* | *បើកវគ្គបណ្តុះបណ្តាល* | *កត្តាសាមគ្គីផ្ទៃក្នុង* | *គោរពម៉ោងធ្វើការ* | *មិនគោរពម៉ោងធ្វើការ* | យល់ដឹងខ្ពស់ | យល់ដឹងមធ្យម | យល់ដឹងទាប | | |
| *៩៣* | *២២៤* | *៨៣* | *៩៥* | *៣០៥* | ៩២ | ៨០ | ២២៨ | **១២០,៧៣** | <0,00១ |

***តារាងទី៨ បញ្ជាក់ថា កត្តាដែលនាំឱ្យការងាររដ្ឋបាលមានប្រសិទ្ធភាពចាំបាច់ត្រូវបើកវគ្គបណ្តុះបណ្តាល រីឯគុណវិបត្តិ គឺការមិនគោរពពេលម៉ោងធ្វើការ កត្តាលំបាកក្នុងការរៀបចំផែនការអភិវឌ្ឍន៍ គឺការយល់ដឹងនៅមានកម្រិតទាប p. <0,00១។***

តារាងទី៩ ការគ្រប់គ្រងហិរញ្ញវត្ថុឃុំ-សង្កាត់

| កត្តាដែលជួបប្រទះក្នុងការគ្រប់គ្រងហិរញ្ញវត្ថុឃុំ-សង្កាត់ | | **Chi-square** | **p.** |
|---|---|---|---|
| ការផ្តល់ថវិកាទាន់ពេលវេលា | យឺតយ៉ាវ | | |
| ៣៥ | ៣៦៥ | **២៧២,២៥** | **<0,00១** |

តារាងទី៩ បញ្ជាក់ថា ការផ្តត់ផ្គង់ហិរញ្ញវត្ថុសម្រាប់អភិវឌ្ឍន៍ឃុំ-សង្កាត់មានការយឺតយ៉ាវ **p.** <0,00១។

តារាងទី១០ ទស្សនៈប្រជាពលរដ្ឋលើការអនុវត្តប្រព័ន្ធវិមជ្ឈការនៅថ្នាក់ឃុំ-សង្កាត់

| **ឃុំ-សង្កាត់ លើការអនុវត្តគោលនយោបាយវិមជ្ឈការ** | | | Chi-square | p. |
|---|---|---|---|---|
| **ពេញចិត្តខ្លាំង** | **ពេញចិត្តមធ្យម** | **មិនពេញចិត្ត** | | |
| ៣៤៥ | ៥៤ | ០១ | ៥១៤,៥៦ | **<0,00១** |

តារាងទី១០ បញ្ជាក់ថា ប្រជាពលរដ្ឋពេញចិត្តយ៉ាងខ្លាំងលើគោលនយោបាយវិមជ្ឈការនៅថ្នាក់ឃុំ-សង្កាត់ **p.** <0,00១។

តារាងទី១១ ឃុំ-សង្កាត់បានជួយការងារអ្វីខ្លះដល់ប្រជាពលរដ្ឋ?

| ឃុំ -សង្កាត់បានជួយការងារដល់ប្រជាពលរដ្ឋ | | | Chi-square | p. |
|---|---|---|---|---|
| ជួយប្រជាពលរដ្ឋច្រើន | ជួយប្រជាពលរដ្ឋមធ្យម | ជួយប្រជាពលរដ្ឋតិចតួច | | |
| ៣៧២ | ២១ | ០៧ | ៦៤១,៥៥ | **<0,00១** |

តារាងទី១១ បញ្ជាក់ថា គោលនយោបាយវិមជ្ឈការនៅថ្នាក់ឃុំ-សង្កាត់បានជួយដល់ប្រជាពលរដ្ឋច្រើន p. <0,00១។

**គ-ការចូលរួមបដិភាគរបស់ប្រជាពលរដ្ឋក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត**

តារាងទី១២ ប្រៀបធៀបវិភាគទានរវាងឃុំនិងប្រជាពលរដ្ឋក្នុងស្រុកកំចាយមារ

| លក្ខណៈ | ថវិកាឃុំ | ថវិកាប្រជាពលរដ្ឋ | t-Value | p. |
|---|---|---|---|---|
| **ឃុំស្មោងជើង** | | | | |
| N | 5 | 6 | | |
| X | 23.105.460,00** | 1.145.480,00 | 3.006 | <0.01 |
| S± | 16.327.620,32 | 473.940,32 | | |
| **ឃុំស្មោងត្បូង** | | | | |
| N | 9 | 8 | | <0.001 |
| X | 51.204.333,33*** | 1.449.300 | 9.306 | |
| S± | 15.047.131,69 | 816.250,26 | | |

តារាងទី ១២ បញ្ជាក់ថាថវិកាសម្រាប់កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅឃុំស្មោងជើង មានចំនួនច្រើនជាងថវិកាដែលចូលរួមដោយប្រជាពលរដ្ឋ p.<0,0១។ រីឯថវិកានៅឃុំស្មោងត្បូងវិញមានគម្លាតឆ្ងាយខ្លាំងពីថវិកាដែលចូលរួមដោយប្រជាពលរដ្ឋ p. <0,00១។

## ៥-សន្និដ្ឋាន

លទ្ធផលនៃការសិក្សាស្រាវជ្រាវបង្ហាញឱ្យឃើញថា ការគ្រប់គ្រងរដ្ឋបាលមូលដ្ឋានតាមប្រព័ន្ធវិមជ្ឈការនិងវិសហមជ្ឈការនៅខេត្តព្រៃវែងជាការសមស្របទៅតាមបំណងប្រាថ្នារបស់ប្រជាពលរដ្ឋ។

ចំណាប់អារម្មណ៍របស់អង្គការសង្គមស៊ីវិលគឺ សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ខ្លះគ្មានការងារធ្វើជាបញ្ហាមួយបណ្ដាលមកពីការការពារបក្សរៀងខ្លួន ឬ ទំនាស់ផ្ទៃក្នុងដោយសារប្រព័ន្ធបោះឆ្នោត សមាមាត្រដែលនាំឱ្យក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវចំណុះបក្សខ្លួនឯង។

សមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់នៅមានកម្រិតទាបបណ្ដាលឱ្យជួបការលំបាកក្នុងការធ្វើសេចក្ដីសម្រេចចិត្តចំពោះការងារដែលថ្នាក់កណ្ដាលប្រគល់ឱ្យ។

ការផ្ដល់ថវិកាពីរាជរដ្ឋាភិបាលសម្រាប់អភិវឌ្ឍន៍មូលដ្ឋានកាន់តែធ្លាក់ចុះទុនបដិភាគពីប្រជាពលរដ្ឋកាន់តែមានចំនួនតិច ធ្វើឱ្យការកសាងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗមានការយឺតយ៉ាវ។

ដើម្បីឱ្យលទ្ធិប្រជាធិបតេយ្យកាន់តែរឹងមាំ រាជរដ្ឋាភិបាលត្រូវវិភាជន៍ថវិកាជូនអាជ្ញាធរមូលដ្ឋានឱ្យបានទាន់ពេលវេលា និង តាមគម្រោងផែនការដែលបានអនុម័តរួច។

ក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក និង ឃុំ សង្កាត់គួរជ្រើសរើសមនុស្សមានសមត្ថភាព ហើយកំណត់ក្នុងច្បាប់ និង រៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព។ ត្រូវមានបទពិសោធន៍ការងារយ៉ាងតិច៥ឆ្នាំ អាយុចាប់ពី៣០ឆ្នាំឡើងមានសញ្ញាប័ត្រចាប់ពីបរិញ្ញាប័ត្រឡើងទៅ មានសីលធម៌និងទំនាក់ទំនងសាធារណៈល្អ។

## គន្ថនិទ្ទេស


-របាយការណ៍របស់សាលាស្រុកកំចាយមារ ឆ្នាំ២០១០

-សារព័ត៌មានស្តីពីស្ថានភាពខេត្តព្រៃវែង ឆ្នាំ២០០៨

-របាយការណ៍បូកសរុបការងារ ឆ្នាំ២០០៩ របស់ខេត្តព្រៃវែង

-ផែនការសកម្មភាព និងថវិកាឆ្នាំ២០១០ របស់ខេត្តព្រៃវែង

-Yamane Taro, Statistic: Introductory Analysis 2nd Edition, University of Florida, NewYork, 1967

-Yamane Taro, Statistic: Introductory Analysis 3nd Edition, University of Florida, NewYork, 1973

# ផលិតភាពនិងគុណភាពនៃពូជដំណាំចំណីសត្វនៅព្រះរាជាណាចក្រកម្ពុជា

ម៉ុង ស៊ាងងីម
បេក្ខជនបណ្ឌិតវគ្គទី១ ផ្នែកវិទ្យាសាស្ត្រកសិកម្ម
នៃរាជបណ្ឌិត្យសភាកម្ពុជា



## ១-សេចក្តីផ្តើម

ប្រទេសកម្ពុជាជាប្រទេសកំពុងអភិវឌ្ឍន៍ដែលយកវិស័យកសិកម្មជាគោលមានប្រជាជនប្រមាណ៨០% ជាកសិករ។ វិស័យកសិកម្មជារចនាសម្ព័ន្ធស្នូលនៃខឿនសេដ្ឋកិច្ចជាតិមានផលិតផលជាតិសរុបប្រមាណ៣០% ក្នុងនោះវិស័យផលិតកម្មសត្វមាន១៥,៦% ក្នុងឆ្នាំ២០០៧ (ច័ន្ទ សារុន, ២០០៨)។ គោលដៅសំខាន់របស់រាជរដ្ឋាភិបាលគឺសុវត្ថិភាពស្បៀង ដូច្នេះដើម្បីធ្វើឱ្យមានតុល្យភាពស្បៀងអាហារគេត្រូវបង្កើនផលិតកម្មដំណាំស្រូវនិងផលិតផលសត្វ។ វិស័យចិញ្ចឹមសត្វបានដើរតួយ៉ាងសំខាន់ជាមធ្យោបាយបម្រើឱ្យការផលិតនិងជាប្រភពចំណូលរបស់ប្រជាជន។ផលិតកម្មសត្វគោក្របីជាសមាសភាគមួយដ៏សំខាន់បំផុតនៅក្នុងប្រព័ន្ធកសិកម្ម។ ជាទូទៅកសិករចិញ្ចឹមគោក្របីសម្រាប់ជួយការងារភ្ជួររាស់ការដឹកជញ្ជូន យកលាមកសម្រាប់ធ្វើជីនិងទុកសម្រាប់លក់ដូរ។

ជាទូទៅកសិករឱ្យសត្វគោក្របីស៊ីស្មៅតាមវាល។នៅពេលដែលចំនួនប្រជាជនចំនួនសត្វចិញ្ចឹមនិងផ្ទៃដីដាំដំណាំមានការកើនឡើងពេលនោះវាលស្មៅធម្មជាតិដែលមានពីមុនមក កាន់តែតិចទៅៗ(Stur and Peter, 2003)។ បច្ចុប្បន្នការងារចិញ្ចឹមសត្វនៅកម្ពុជាកំពុងជួបប្រទះផលលំបាកពីបញ្ហាកង្វះខាតចំណីសម្រាប់សត្វគោក្របី។ នៅរដូវវស្សា ដីទំនាបប្រមាណ៧៥%ត្រូវលិចទឹក ដីទួលប្រមាណ៥% ជាដីភូមិ និងផ្ទៃដីប្រមាណ ១៥% ជាដីចំការសម្រាប់ដំណាំរួមផ្សំឬដំណាំហូបផ្លែ ដូចនេះនៅសល់ផ្ទៃដីតិចតួចណាស់សម្រាប់ជាវាល ចំណីសត្វធម្មជាតិ។ ទោះបីនៅរដូវវស្សាដែលសម្បូរស្មៅធម្មជាតិ ក៏កសិករនៅតែត្រូវចំណាយពេលវេលាច្រើនក្នុងការប្រូតស្មៅយកមកឱ្យគោក្របីស៊ី។

នៅរដូវប្រាំងភាពរាំងស្ងួតមានរយៈពេលយូរចំណីសត្វនៅតាមវាលធម្មជាតិក្រៀមស្វិតចំណីជាសំខាន់សម្រាប់គោក្របីគឺចំបើងនិងគល់ជញ្ជ្រាំងដែលពុំមានតម្លៃជីវជាតិគ្រប់គ្រាន់។ យ៉ាងនេះហើយបានជានៅរដូវប្រាំងគេឃើញគោក្របីស្គមស្គាំង បាក់កម្លាំង ពន្យារពេលបន្តពូជ ងាយរងគ្រោះដោយជំងឺផ្សេងៗ ឬអាចបង្កឱ្យស្លាប់ក៏មាន។ កសិករត្រូវចំណាយពេលវេលាជាច្រើនដើម្បីស្វែងរកចំណីសម្រាប់សត្វចិញ្ចឹមឬត្រូវលែងសត្វឱ្យដើររកស៊ីនៅតាមតំបន់ឆ្ងាយៗឬបង្ខំកូនតូចៗឱ្យបោះបង់ការសិក្សាដើម្បីទៅរកស្មៅនៅទីឆ្ងាយៗពីលំនៅស្ថាន។ ពេលខ្លះពួកគាត់គិតថាតើត្រូវកាត់បន្ថយការចិញ្ចឹម ឈប់ចិញ្ចឹមឬត្រូវស្វែងរកប្រភពចំណីសត្វថ្មី។ ផលលំបាកនេះបានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ការសិក្សារបស់កុមារតូចៗនិងពេលវេលារបស់កសិករ។ ដើម្បី លើកស្ទួយស្ថានភាពចិញ្ចឹមសត្វនៅកម្ពុជាឱ្យមានលក្ខណៈល្អប្រសើរនិងកាត់បន្ថយផលលំបាកខាងលើការសិក្សាលើ «**គុណភាពនៃពូជដំណាំចំណីសត្វនាំចូល នៅព្រះរាជាណាចក្រកម្ពុជា**» ជាបញ្ហាគន្លឹះមួយក្នុងការដោះស្រាយបញ្ហា។

## ២-គោលបំណង

ការសិក្សាស្រាវជ្រាវនេះ មានគោលបំណងរកឱ្យឃើញគុណប្រយោជន៍នៃដំណាំចំណីសត្វពូជនាំចូល។

ដើម្បីសម្រេចគោលបំណងនេះ ការសិក្សាស្រាវជ្រាវនេះបានរៀបចំនូវវត្ថុបំណងបីយ៉ាងដូចខាងក្រោម៖

-សិក្សាពីបច្ចេកទេសដាំនិងការថែទាំដំណាំចំណីសត្វ

-សិក្សាពីការលូតលាស់និងទិន្នផលនៃដំណាំទាំងនេះ

-សិក្សាពីសមាសធាតុគីមីនៃដំណាំចំណីសត្វ

ការសិក្សានេះបានធ្វើឡើងនៅក្នុងខេត្តបីនៃព្រះរាជាណាចក្រកម្ពុជា គឺខេត្តកំពង់ចាម ខេត្តតាកែវ ខេត្តកណ្តាល និងនៅស្ថានីយ៍ចិញ្ចឹមគោពូជភ្នំតាម៉ៅ។

## ៣-សម្ភារៈស្រាវជ្រាវនិងវិធីសាស្ត្រពិសោធន៍

### ៣-១. សម្ភារៈស្រាវជ្រាវ

ពូជដំណាំចំណីសត្វទាំង៥ប្រភេទនេះ បាននាំចូលពីប្រទេសអូស្ត្រាលី តាមរយៈគម្រោងការអនុវត្តល្អប្រសើរលើការងារសុខភាពនិងផលិតកម្មគោក្របីនៅកម្ពុជា(Best Practice Health and husbandry of Cattle, Cambodia ACIAR, AH/2005/086) ដែលបានទទួលការឧបត្ថមដោយមជ្ឈមណ្ឌលអូស្ត្រាលីស្រាវជ្រាវកសិកម្មអន្តរជាតិ (Australian Center for International Agricultural research) ពូជទាំងនោះមាន៖Panicum maximum ហៅស៊ីមួង Brachiaria hybrid ហៅមូឡាតូ២ Brachiaria brizantha ហៅម៉ារ៉ាន់ឌូ Paspalum atratum ហៅតេរីណូស និង Stylosanthes gianensis ហៅស្តាយឡូ១៨៤។

### ៣-២. វិធីសាស្ត្រពិសោធន៍

#### ក.ពិសោធន៍ទី១ ៖ គុណភាពដាំដំណាំចំណីសត្វ

#### ការរៀបចំដី និង វិធីសាស្ត្រដាំ

ការរៀបចំដីគឺត្រូវបានរៀបចំភ្ជួរជាពីរលើកដោយលើកទី១ក្នុងគោលបំណងដើម្បីហាលដីនិងធ្វើឱ្យបាក់តេរីឬសត្វល្អិតមួយចំនួនដែលនៅក្នុងដីនិងស្មៅចង្រៃឬរុក្ខជាតិចង្រៃងាប់។ ការភ្ជួរលើកទី២គឺត្រូវធ្វើចន្លោះពេលការភ្ជួរលើកទី១រយៈពេល៣សប្តាហ៍។ ក្រោយពីការភ្ជួរលើកទី២ប្រមាណ១សប្តាហ៍ការរាស់ត្រូវបានចាប់ផ្តើមដើម្បីធ្វើយ៉ាងណាបំបែកដីឱ្យទៅជាដុំតូចៗម៉ត់ល្អនិងមានសភាពធូរល្អហើយធ្វើយ៉ាងណាប្រមូលឱ្យអស់នូវស្មៅឬរុក្ខជាតិចង្រៃនៅលើដី។

ការរៀបចំចម្ការពិសោធន៍ធ្វើឡើងតាមរបៀប <Split plot> ដែលមាន៣ចម្ការនៅក្នុងតំបន់នីមួយៗ។ នៅតំបន់ទាំងបីនៃពិសោធន៍ដំណាំចំណីសត្វទាំង៥ពូជបានដាំដោយគ្រាប់ពូជ។ វិធីសាស្ត្រដាំគឺធ្វើឡើងដូចៗគ្នាគឺស្ទូងកូនស្មៅតូចៗបន្ទាប់ពីបានសាបលើថ្នាលរយៈពេល១ខែ។ ការដាំត្រូវធ្វើដោយទុកចន្លោះជួរ០,៤ម.x០,៤ម. និងចន្លោះគុម្ព០,៥ម.x០,៥ម. សម្រាប់ពួកពូជស្មៅ (ស៊ីមួង មូឡាតូ២ ម៉ារ៉ាន់ឌូនិងតេរីណូស) ហើយសម្រាប់ពួកស្តាយឡូ១៨៤ទុកចន្លោះជួរ០,៤ម.x០,៤ម.។ ការស្ទូងមានតែ១ដើមប៉ុណ្ណោះក្នុងមួយគុម្ពៗដោយប្រើខ្សែអូសជាបន្ទាត់ជាជួរៗ។ ការដាំទាំង៥ពូជចូលគ្នាដោយជួរទី១ ដាំពូជស្មៅស៊ីមួង ជួរទី២ ដាំពូជស្មៅមូឡាតូ ២ ជួរទី៣ ដាំពូជស្មៅម៉ារ៉ាន់ឌូ ជួរទី៤ ដាំពូជស្មៅតេរីណូសនិងជួរទី៥ ដាំពូជលេហ្គឹមស្តាយឡូ១៨៤។ ការជួសកូនមិនដុះត្រូវធ្វើនៅកំលុងពេល១សប្តាហ៍ដំបូង។

**តារាងទី១៖ការរៀបចំពិសោធន៍ដំណាំចំណីសត្វនៃខេត្តទាំងបី**

| ពូជ | ស៊ីមួង | មូឡាតូ២ | ម៉ារ៉ាន់ឌូ | តេរីណូស | ស្តាយឡូ១៨៤ |
|---|---|---|---|---|---|
| ចន្លោះជួរ | ០,៤ម.x០,៤ម. | ០.៤ម.x០,៤ម. | ០,៤ម.x០,៤ម. | ០,៤ម.x០,៤ម. | ០,៤ម.x០,៤ម. |
| ចន្លោះគុម្ព | ០,៥ម.x០,៥ម. | ០,៥ម.x០,៥ម. | ០,៥ម.x០,៥ម. | ០,៥ម.x០,៥ម. | - |

**ការពិនិត្យលើការលូតលាស់និងទិន្នផល**

ការលូតលាស់ ត្រូវតាមដានរៀងរាល់ពីរសប្តាហ៍ម្តងបន្ទាប់ពីការស្ទូងដោយការវាស់កម្ពស់ (ដោយប្រើម៉ែត្រខ្នាត៣ម.)និងការរាប់ចំនួនដើមក្នុងមួយគុម្ពៗ ចំនួនបីគុម្ពក្នុងពូជនីមួយៗ/ក្នុងចម្ការនីមួយៗ។ ការវាស់កម្ពស់ត្រូវគិតជាស.ម. ដោយវាស់ពីដីរហូតដល់ចុងស្លឹក ដោយជ្រើសរើសយកដើមខ្លី ដើមមធ្យមនិងដើមដែលខ្ពស់ជាងគេក្នុងគុម្ពនីមួយៗ ហើយក្នុងមួយពូជត្រូវវាស់បីគុម្ពនៅក្នុងចម្ការនីមួយៗ។ ការប្រមូលទិន្នផលលើកទី១ ត្រូវប្រមូលនៅ២ខែក្រោយពីស្ទូង ឯការប្រមូលបន្ទាប់មកទៀតគឺប្រមូលក្នុងរយៈពេល១ខែម្តងដោយច្រូតកម្ពស់ចន្លោះពី៥-៧ស.ម.ពីដី ចំពោះពពួកស្មៅនិងច្រូតកម្ពស់ចន្លោះពី១៥-២០ស.ម.ពីដីចំពោះពពួកលេហ្គឹម ដោយប្រើកណ្តៀវនិងត្រូវថ្លឹងដោយប្រើជញ្ជីងខ្នាត៣០គ.ក្រ.។ ការច្រូតគិតជាគក្រ./ម² ដោយច្រូតបីម²ក្នុងពូជនីមួយៗ/ក្នុងចម្ការនីមួយៗ។

**ខ. ពិសោធន៍ទី២ ៖ សមាសធាតុគីមីដំណាំចំណីសត្វ**

ដំណាំចំណីសត្វទាំង៥ប្រភេទត្រូវច្រូតនៅរយៈពេលនៃការប្រមូលផលលើកទី២ គឺដំណាំចំណីសត្វមានអាយុមួយខែ ក្នុងបរិមាណមួយគក្រ./ពូជនីមួយៗ ដោយប្រកចូលក្នុងថង់ផ្លាស្ទីចរួចដាក់ក្នុងធុងទឹកកកដើម្បីបញ្ជូនមកទីពិសោធន៍។ សមាសធាតុគីមីយើងវិភាគតាមគោលការណ៍ Weede-Analysis (Hanneberg and Stohmann, 1862) ដូចជារូបធាតុសោះទឹក (DM) ផេះ (Ash) ប្រូតេអ៊ីន (CP) សារធាតុសរសៃ (CF) សារធាតុអេឌីអេហ្វ (ADF) សារធាតុអិនឌីអេហ្វ (NDF)។

## ៤. ការវិភាគទិន្នន័យ

ទិន្នន័យដែលបានមកពីការពិសោធន៍ទាំងអស់ត្រូវបានរក្សាទុកក្នុងកម្មវិធី Microsoft Excel និងវិភាគតាម One Way ANOVA ដោយប្រើកម្មវិធី SPSS Version 16.0។

## ៥-លទ្ធផលនិងការពិភាក្សា

### ពិសោធន៍ទី១ ៖ គុណភាពដំណាំចំណីសត្វ

**ការលូតលាស់**

**តារាងទី២៖** កម្ពស់**នៃពូជ**ដំណាំចំណីសត្វតាមអាយុ(**គិតជាស.ម.**)

| អាយុ | | ស៊ីមួង | មូឡាតូ២ | ម៉ារ៉ាន់ឌូ | តេវើណូស | ស្តាយឡូ | p |
|---|---|---|---|---|---|---|---|
| ១៥ ថ្ងៃ | X | ៣០,៣[a] | ១៣,៧[c] | ១៦,៩[bc] | ១៨,៤[b] | ៨,១០[d] | 0,00 |
| | S± | ១,៩៥ | 0,៨0 | ៣,៧៥ | 0,៨៦ | 0,៩៥ | |
| ៣០ ថ្ងៃ | X | ៦១,៣[a] | ២៩,៦[c] | ៣៣,៦[bc] | ៣៨,៣[b] | ១៥,២[d] | 0,00 |
| | S± | ៤,១០ | 0,១១ | ៥,១០ | ២,៥៣ | ១,៩៣ | |
| ៤៥ ថ្ងៃ | X | ៩១,៤[a] | ៤១,៦[bc] | ៥១,៤[b] | ៥១,៨[b] | ២៣,៤[c] | 0,00 |
| | S± | ៥,៩៥ | 0,៩៥ | ៩,0១ | ២,៦៧ | ៤,៦១ | |
| ៦០ ថ្ងៃ | X | ១១៩,៣[a] | ៥៩,៣[c] | ៦៩,២[bc] | ៧៣,៥[b] | ៣៥,២[d] | 0,00 |
| | S± | ៨,៨0 | ១,0៥ | ៩,៩៦ | ៣,៥0 | ៣,៦៣ | |

a>b>c>d: មធ្យមភាគនៃភាពខុសគ្នាផ្នែកស្ថិតិសាស្ត្រ ដោយp≤0,05

ក្រាភិច**ទី**១៖ កម្ពស់**នៃពូជស្មៅនីមួយៗ**តាមអាយុ (**គិតជាស.ម.**)




តាមតារាងទី២និងក្រាភិចទី១បង្ហាញថា ការវាស់កម្ពស់គ្រប់លើក ពូជស្មៅស៊ីមួងមានកម្ពស់ ខ្ពស់ជាងគេដោយតម្លៃ p<0,05។ ពូជស្មៅមានកម្ពស់បន្តបន្ទាប់គឺពូជស្មៅតេរីណូសម៉ារ៉ាន់ឌូមូឡាតូ២។ ឯលេហ្គីមស្តាយឡូ ១៨៤ មានកម្ពស់ទាបជាងគេ។

**តារាងទី**៣៖ ចំនួនដើមជាមធ្យមក្នុង១គុម្ព **នៃពូជស្មៅនីមួយៗ** តាមអាយុ

| អាយុ | | ស៊ីមួង | មូឡាតូ២ | ម៉ារ៉ាន់ឌូ | តេរីណូស | p |
|---|---|---|---|---|---|---|
| ១៥ ថ្ងៃ | X | ៨,៥៣ns | ៦,៦៣ | ៧,០០ | ៧,៣៦ | ០,៣២ |
| | S± | ១,៩៥ | ០,៥៧ | ០,៦២ | ១,២០ | |
| ៣០ ថ្ងៃ | X | ១៦,៣ns | ១២,៥ | ១៥,០៣ | ១៣,៥៦ | ០,១១ |
| | S± | ៣,១៥ | ១,០០ | ០,៤៧ | ០,៩០ | |
| ៤៥ ថ្ងៃ | X | ២២,១ | ១៩,៥ | ២៣,០ns | ២០,១ | ០,៥០ |
| | S± | ៥,១៧ | ២,១០ | ០,៥១ | ២,២៥ | |
| ៦០ ថ្ងៃ | X | ២៨,៩ | ៣០,០ns | ២៩,២ | ២៩,៥ | ០,៩៧ |
| | S± | ៣,៥៣ | ៤,៦៥ | ១,៥៩ | ១,៩០ | |

ns: non significant difference, p>0,05

តាមតារាងទី៣បង្ហាញថា ចំនួនដើមជាមធ្យមក្នុង១គុម្ពៗ នៃពូជស្មៅពិសោធន៍ គ្មានលក្ខណៈខុសគ្នាដោយតម្លៃ p>0,05។

**ទិន្នផល តារាងទី**៤៖ **ទិន្នផលជាមធ្យមនៃពូជ**ដំណាំចំណីសត្វ(គក្រ/ម$^{២}$)

| លើក | | ស៊ីមួង | មូឡាតូ២ | ម៉ារ៉ាន់ឌូ | តេរីណូស | ស្តាយឡូ១៨៤ | p |
|---|---|---|---|---|---|---|---|
| ១ | X | ៧,២៣a | ៦,៤៦a | ៦,២០a | ៧,១៤a | ៣,០៦b | ០,០០ |
| | S± | ០,៥៥ | ០,៧២ | ០,៦០ | ០,៥៦ | ០,១១ | |
| ២ | X | ៦,៤៣a | ៦,៥០a | ៦,៤៣a | ៦,៣៦a | ៣,១៦b | ០,០០ |
| | S± | ០,១១ | ១,០០ | ០,៧៣ | ១,១៨ | ០,៧៦ | |
| ៣ | X | ៧,៤៣a | ៦,៦៣a | ៦,៨៦a | ៧,០៣a | ៣,៤b | ០,០០ |
| | S± | ០,៦០ | ០,៣២ | ០,៤០ | ០,៩៥ | ០,៣៦ | |
| មធ្យម | X | ៧,០៣a | ៦,៥៣a | ៦,៤៩a | ៦,៨៤a | ៣,២០b | ០,០០ |
| | S± | ០,៥៣ | ០,០៨ | ០,៣៣ | ០,៤២ | ០,១៧ | |

a>b: មធ្យមភាគនៃភាពខុសគ្នាផ្នែកស្ថិតិសាស្រ្ត ដោយ p≤0,05

លទ្ធផលនៃការពិសោធបានបង្ហាញថា ពពួកស្មៅទាំងអស់ដាំនៅ៣ខេត្តក្នុងប្រទេសកម្ពុជាមានទិន្នផលពី៦-៨គក្រ/ម$^{២}$ ដូចការពិសោធរបស់ Stur and Horne(2001)គឺបានទម្ងន់ពី៦-៨គក្រ./ម$^{២}$។ ពពួកលេហ្គឹមដាំនៅ៣ខេត្តក្នុងប្រទេសកម្ពុជាមានទិន្នផលពី៣,២-៤គក្រ./ម$^{២}$ខ្ពស់ជាងការពិសោធរបស់ Stur and Horne (2001)គឺបានទម្ងន់ពី២-៣គក្រ./ម$^{២}$និងខ្ពស់ជាងការពិសោធរបស់ Mannetje (1982)។ ពូជស្មៅម៉ារ៉ាន់ឌូដាំនៅក្នុងប្រទេសកម្ពុជាមានទិន្នផល៦,៥គក្រ./ម$^{២}$ តិចជាងការពិសោធរបស់Miles et al.,(1996) គឺបានទម្ងន់ពី៨-៩គក្រ./ម$^{២}$។ ពូជស្មៅមូឡាតូ២ មានទិន្នផល៦,៥គក្រ./ម$^{២}$ តិចជាងការពិសោធរបស់CIAT(2002) គឺបានទម្ងន់៩,២គក្រ./ម.$^{២}$។ ពូជស្មៅស៊ីមួងមានទិន្នផល៧,០៣គក្រ./ម$^{២}$ខ្ពស់ជាងការពិសោធរបស់ Harty et al.,(1982)គឺបានទម្ងន់៦គក្រ./ម$^{២}$។ ពូជស្មៅតេរីណ្ឌូសមានទិន្នផល៦,៨គក្រ./ម$^{២}$ តិចជាងការពិសោធរបស់ CIAT(2002)គឺបានទម្ងន់៧គក្រ./ម$^{២}$។

**ពិសោធន៍ទី២ ៖ សមាសធាតុគីមីដំណាំចំណីសត្វ**

**តារាងទី៥៖ សមាសជាតុគីមីនៃពូជដំណាំចំណីសត្វដាំនៅកម្ពុជា**(គិតជា%)

| ពូជ | | រូបធាតុសោះទឹក | ផេះ | រូបធាតុសរីរាង្គ | ប្រូតេអ៊ីន | សារធាតុសរសៃ | សារធាតុអេឌីអេហ្វ | សារធាតុអិនឌីអេហ្វ |
|---|---|---|---|---|---|---|---|---|
| Si | X | ២១,៥$^{ns}$ | ៧,០៣$^{bc}$ | ៩២,៩៧$^{ab}$ | ១១,៧$^{c}$ | ២៧,២$^{b}$ | ៤២,៤$^{b}$ | ៧១,៤$^{a}$ |
| | S± | ១,២ | ០,២ | ០,២០ | ០,៣២ | ២,០១ | ១,០៥ | ០,៩៦ |
| Mu | X | ២១,៦ | ៧,៤៦$^{b}$ | ៩២,៥៤$^{b}$ | ១៥,៩$^{b}$ | ២៧,២$^{b}$ | ៤៦,៦$^{a}$ | ៦៨,៨$^{b}$ |
| | S± | ៤,៤៩ | ០,១៩ | ០,១៩ | ១,២៧ | ០,៦៦ | ១,៨៨ | ០,៩០ |
| Ma | X | ២៣,៥ | ៨,២៣$^{a}$ | ៩១,៧៧$^{c}$ | ១២,៦$^{c}$ | ២៦,៤$^{b}$ | ៤៣,៨$^{b}$ | ៦៦,៧$^{c}$ |
| | S± | ៣,៥៥ | ០,៣០ | ០,៣០ | ០,២៥ | ២,៦៩ | ១,២៦ | ០,៨៥ |
| Te | X | ១៩,៨ | ៦,៨៥$^{c}$ | ៩៣,១៥$^{a}$ | ១២,៦$^{c}$ | ២៧,៦$^{b}$ | ៤៤,០$^{b}$ | ៦៧,៧$^{bc}$ |
| | S± | ១,០៦ | ០,២៧ | ០,២៧ | ១,២២ | ០,៧៧ | ១,០១ | ១,៤៥ |
| Sty | X | ២០,៤ | ៧,២១$^{bc}$ | ៩២,៧៩$^{ab}$ | ១៧,៨$^{a}$ | ៣៧,៩$^{a}$ | ៤៤,៦$^{ab}$ | ៦៩,៥$^{ab}$ |
| | S± | ០,៧៩ | ០,០៨ | ០,០៨ | ០,៧០ | ១,៦៨ | ០,៩៥ | ១,២០ |
| p | | ០,៥៤ | 0,00 | 0,00 | 0,00 | 0,00 | ០,0២ | 0,00 |

a>b>c: មធ្យមភាគនៃភាពខុសគ្នាផ្នែកស្ថិតិសាស្ត្រដោយ$p \leq 0,05$ ns: non significant difference, $p>0,05$

តាមតារាងទី៥ រូបជាតុសោះទឹក(DM)នៃស្មៅពិសោធន៍គ្មានលក្ខណៈខុសគ្នាដោយតម្លៃ p>0,0៥។ ផេះ(Ash) មានលក្ខណៈខុសគ្នាដោយតម្លៃ p<0,0៥ ក្នុងនោះពូជស្មៅម៉ារ៉ាន់ឌូមានភាគរយផេះច្រើនជាងគេ ដោយឡែកពូជស្មៅដែលមានភាគរយផេះតិចជាងគេគឺតេរីណ្ឌូស។ ប្រូតេអ៊ីន (CP) មានលក្ខណៈខុសគ្នាដោយតម្លៃ p<0,0៥ ក្នុងនោះពូជលេហ្គឹមស្តាយឡូ១៨៤មានភាគរយប្រូតេអ៊ីនច្រើនជាងគេ ដោយឡែកពូជស្មៅដែលមានភាគរយប្រូតេអ៊ីនតិចជាងគេគឺស៊ីមួង។

ចំពោះពូជស្មៅស៊ីមួងមានកម្រិតប្រូតេអ៊ីន១១,៤% គឺខ្ពស់ជាងការបង្ហាញរបស់Johnson et al.,(1968) គឺមានកម្រិតប្រូតេអ៊ីនចន្លោះពី៦,៦-៩,៨% និងការបង្ហាញរបស់ Odedire and Babayemi (2008) គឺមានកម្រិតប្រូតេអ៊ីន ៩,៣៦% តែផ្ទុយទៅវិញលទ្ធផលនេះទាបជាងការបង្ហាញរបស់ Meissner and Esterhuyse (1993) គឺមានកម្រិតប្រូតេអ៊ីនចន្លោះពី១៣,១-១៦,២% តែវាស្របនឹងការបង្ហាញរបស់ Aganga and Thwenyane(2004) គឺមានកម្រិតប្រូតេអ៊ីន ១១,៧%។ ចំពោះកម្រិតសារជាតុសរសៃ

២៩,១% លទ្ធផលនេះទាបជាងការបង្ហាញរបស់Johnson et al., (1968) គឺមានកម្រិតសារជាតុសរសៃចន្លោះ ពី ៣២,១-៣៩,៤% និងទាបជាងការបង្ហាញរបស់ Aganga and Thwenyane (2004) គឺមានកម្រិតសារជាតុសរសៃ ៣០,៩%។ ចំពោះកម្រិតសារជាតុអេឌីអេហ្វ ៤២,៤% សារជាតុអិនឌីអេហ្វ ៧២,៤% លទ្ធ-ផល នេះខ្ពស់ជាងការបង្ហាញរបស់ Meissnerand Esterhuyse(1993) គឺមានកម្រិតសារជាតុអេឌីអេហ្វ ២៦-៣១% សារជាតុអិនឌីអេហ្វ ៥១-៥៥% ហើយខ្ពស់ជាងការបង្ហាញរបស់ Aganga and Thwenyane (2004) គឺមានកម្រិតសារជាតុអេឌីអេហ្វ ២៧,១% សារជាតុអិនឌីអេហ្វ ៥២,៥% ហើយនៅតែខ្ពស់ជាងការបង្ហាញរបស់ Odedire and Babayemi (2008) គឺមានកម្រិតសារជាតុអេឌីអេហ្វ៣៨% សារជាតុអិនឌីអេហ្វ ៦០%។ កម្រិតភាគរយសារជាតុ អិនឌីអេហ្វខ្ពស់ជាងលទ្ធផលរបស់ Bamikole et al., (1998) គឺមានកម្រិតសារជាតុអិនឌីអេហ្វ ៦៩,៤៣%។ ចំពោះកម្រិតផេះ ៧,១% ទាបជាងការបង្ហាញរបស់ Meissner and Esterhuyse (1993) គឺមានកម្រិតផេះចន្លោះពី៨,៩-៩,៥% ហើយនៅតែទាបជាងការបង្ហាញរបស់ Odedire and Babayemi (2008) គឺមានកម្រិតផេះ ១៣% ចំណែកការបង្ហាញរបស់ Aganga and Thwenyane (2004) ដែលបង្ហាញថាពូជស្មៅស៊ីមួងមានកម្រិតផេះ១២%ផងដែរ។ ចំពោះកម្រិតរូបជាតុសោះទឹក២១,៧% ទាបជាងការបង្ហាញរបស់ Odedire and Babayemi (2008) គឺមានកម្រិតរូបជាតុសោះទឹក ២៦% និងទាបជាងការបង្ហាញរបស់ Aganga and Thwenyane (2004) គឺមានកម្រិតរូបជាតុសោះទឹក២៣%។

ពូជស្មៅម៉ារ៉ាន់ឌូមានកម្រិតប្រូតេអ៊ីន ១២,៦% ស្របនឹងការបង្ហាញរបស់Miles et al., (1996) គឺមានកម្រិតប្រូតេអ៊ីនចន្លោះពី ៧-១៦%។

ពូជស្មៅមូឡាតូ២មានកម្រិតប្រូតេអ៊ីន ១៥,៦% ស្របនឹងការបង្ហាញរបស់ Pedro et al., (1996) គឺមានកម្រិតប្រូតេអ៊ីនចន្លោះពី ៩-១៦% តែលទ្ធផលនេះខ្ពស់ជាងការរកឃើញ Libardo and Federico (2005) គឺមានកម្រិតប្រូតេអ៊ីនចន្លោះពី១២-១៥%។

ពូជស្មៅតេរីណូសមានកម្រិតរូបជាតុសោះទឹក ១៨,៦% ប្រូតេអ៊ីន ១១,៧% ស្របគ្នានឹងការបង្ហាញរបស់ Ngugen et al., (2009) គឺមានកម្រិតរូបជាតុសោះទឹក១៨,៥% និងប្រូតេអ៊ីន១១,៩%។ ចំពោះសាជាតុអេឌីអេហ្វ ៤៣,៨% និងសារជាតុអិនឌីអេហ្វ ៦៩,១% ខ្ពស់ជាងការបង្ហាញរបស់ Ngugen et al., (2009) គឺមានកម្រិតសារជាតុអេឌីអេហ្វ៣៥%និងសារជាតុអិនឌីអេហ្វ ៦៥,៩%។

រីឯសមាសជាតុគីមីលេហ្គីមស្តាយឡូ១៨៤មានកម្រិតរូបជាតុសោះទឹក ២១,៣% ទាបជាងការបង្ហាញរបស់ Bounlieng et al., (2009) គឺមានកម្រិតរូបជាតុសោះទឹក២៣%។ ចំពោះកម្រិតប្រូតេអ៊ីន១៧,១% ទាបជាងការបង្ហាញរបស់ Bounlieng (2009) គឺមានប្រូតេអ៊ីនចន្លោះពី ១៧,៨-១៨,៨% និងទាបជាងការរកឃើញ Bounlieng et al., (2009) គឺមានកម្រិតប្រូតេអ៊ីន១៩,១%។ ចំពោះកម្រិតសារជាតុអេឌីអេហ្វ ៤៥,៦% និងសារជាតុអិនឌីអេហ្វ ៧០,៨% ខ្ពស់ជាងការបង្ហាញរបស់Bounlieng (2009) គឺមានសារជាតុ អេឌីអេហ្វចន្លោះពី៥៥,៨-៦៣,៣% និងមានសារជាតុអិនឌីអេហ្វចន្លោះពី ៤៥,៥-៤៧ និងខ្ពស់ជាងការរកឃើញ Bounlieng et al., (2009) គឺមានសារជាតុអេឌីអេហ្វ២៨,៨% និងមានសារជាតុអិនឌីអេហ្វ ៤០,៤%។

## ៦. សន្និដ្ឋាន

**តាមលទ្ធផលនៃការពិសោធនខាងលើយើងអាចសន្និដ្ឋានថា ៖**

-**ការលូតលាស់និងទិន្នផលនៃពូជស្មៅ**ពិសោធន៍**មានលក្ខណៈខុសគ្នានៅ**តាមតំបន់**ពិសោធន៍គឺពូជស្មៅ**ស៊ីម្លួង**និងពូជស្មៅ**តេរីណ្ឌូស**មានការលូតលាស់លឿននិងផ្តល់ទិន្នផលខ្ពស់ជាងពូជស្មៅ**ម៉ាំាន់ឌូ**និងពូជស្មៅ**មូឡាតូ២ដោយ p<0,05។ **ចំណែកលេហ្គីមស្តាយឡូ**១៨៤**មានការលូតលាស់យឺតនិង**មាន**ទិន្នផលទាបបើប្រៀបធៀបនឹងពូជស្មៅទាំង៤ប្រភេទ**ដោយតម្លៃ p<0,05។

-រូបធាតុសោះទឹក(DM)នៃស្មៅពិសោធន៍គ្មានលក្ខណៈខុសគ្នាដោយតម្លៃ p>0,05។ ផេះ (Ash) មានលក្ខណៈខុសគ្នាដោយតម្លៃ p<0,05 ក្នុងនោះពូជស្មៅម៉ាំាន់ឌូមានភាគរយផេះច្រើនជាងគេ (៨,២៣) ដោយឡែកពូជស្មៅដែលមានភាគរយផេះតិចជាងគេគឺតេរីណ្ឌូស(៦,៨៥) ដោយតម្លៃ p<0,05។ ប្រូតេអ៊ីន (CP) មានលក្ខណៈខុសគ្នាដោយតម្លៃ p<0,05 ក្នុងនោះពូជលេហ្គីមស្តាយឡូ១៨៤មានភាគរយប្រូតេអ៊ីនច្រើនជាងគេ (១៧,៨) ដោយឡែកពូជស្មៅដែលមានភាគរយប្រូតេអ៊ីនតិចជាងគេគឺស៊ីម្លួង (១១,៧) ដោយតម្លៃ p<0,05។

## គន្ថនិទ្ទេស


-**ច័ន្ទ សារុន, ២០០៨៖ ការអភិវឌ្ឍកសិកម្មនិងជនបទ៖ គន្លឹះឈានទៅរកដំណាក់កាលបន្តនៃការអភិវឌ្ឍប្រទេសកម្ពុជាប្រកបដោយចីរភាព. ភ្នំពេញ។**

-Werner W. Stur and Peter M. Horner.2003 ៖ **ការដោះស្រាយបញ្ហាកសិកម្មដែលកំពុងអភិវឌ្ឍន៍ជាមួយកសិករខ្នាតតូច៖របៀបក្នុងការចាប់ផ្តើមដំណើរការវិនិច្ឆ័យដោយមានការចូលរួម.** ACIAR និង CIAT ។

-Werner W. Stur and Peter M. Horner.2001៖ **បច្ចេកវិទ្យាស្មៅចំណីសត្វដែលកំពុងអភិវឌ្ឍន៍ជាមួយកសិករខ្នាតតូច៖ របៀបដាំថែទាំនិងប្រើប្រាស់ស្មៅចំណីសត្វ.** ACIARនិង CIAT ។

-Werner W. Stur and Peter M. Horner. 1999៖ **បច្ចេកវិទ្យាស្មៅចំណីសត្វដែលកំពុងអភិវឌ្ឍន៍ជាមួយកសិករ៖ ត្រូវជ្រើសរើសពូជស្មៅដែលល្អៗដើម្បីផ្តល់ឱ្យកសិករនៅតំបន់អាស៊ីអាគ្នេយ៍ដោយរបៀបណា?** ACIAR&CIAT ។

-Associate of Official Analytical Chemists (AOAC). 1990. Official method of analysis. Arlington. VA.

-Mannetje. L. (1992) *Stylosanthes guianensis*(Aublet) Swartz. In: 't mannetje. L. and Jones. R.M. (eds) *Plant Resources of South-East Asia No. 4. Forages*. pp. 211-213. (Pudoc Scientific Publishers. Wageningen.the Netherlands).

-Aganga A.A and Shwenyane S.T (2004) *Potential of Panicum maximum as Forage Crop in Livestock Production.*Pakistan Journal of Nutrition-Bogdan.A.V. (1977) *Tropical Pasture and Fodder Plants (Grasses and Legumes).* pp. 181-191. (Longមាន: London and New York)

-Chakraborty S. (ed.) (2004) High-yielding anthracnose-resistant *Stylosanthes* for agricultural systems.*ACIAR Monograph No 111* .(Australian Centre for International Agricultural Research. Canberra).

-Bondi.(1987) *Animal Nutrition.*Wiley and Sons.New york.-Bounlieng Khoutsavang (1996) *Use of fresh Stylo184 and cassava foliage (Manihot eseulanta. Crantz)as a protein source for crossbred pigs.* Livestock Research Center National Agriculture and Forestry Research Institute.Ministry of Agriculture and Forestry. P.O. Box 811. Vientiane. Lao PDR.

-Bounlieng Khoutsavang. Bounlieng bouahom and Brian Ogle (1996) *Effect of including fresh Stylo 184 and cassava foliage (Manihot eseulanta. Crantz.).fed separately or in a mixture on digestibility. intake and N retention in growing pigs.* Livestock Research Center National Agriculture and Forestry Research Institute.Ministry of Agriculture and Forestry. P.O. Box 811. Vientiane. Lao PDR.

-Chakraborty S.(ed.)(2004) *High-Yielding anthracnose-resistant Stylosanthes for agricultural systems.* ACIAR Monograph No111.(Australian Centre for International Agricultural Research. Canberra).

-Chen. C.P. and Hutton.E.M. (1992) *Panicum maximum*Jacq. InIn: 't Mannetje. L. and Jones. R.M. (eds) *Plant Resources of South-East Asia No. 4. Forages* . pp. 172-174. (Pudoc Scientific Publishers. Wageningen.the Netherlands).

-CIAT (1992) *Pastures for the Tropical Lowlands* .CIAT. Cali. Colombia.-CIAT (2002) Variety: 'Mulato'. Application no: 2001/174. *Plant Varieties Journal.***15**. 20–21.-Clayton. W.D. and Renvoize.S.A. (1982) Gramineae (Part 3). In: R.M. Polhill (ed.) *Flora of tropical East Africa.* A.A. Balkema on behalf of the East African Governments. Rotterdam. Netherlands.

-Cullison. A.E..and Lowrey R.S (1987) *Feeds and Feeding General use of Pasture in Livestock Feeding.*Fourth edition. pp 436-442

-Gibbs Russell. G.E.. Watson. L.. Koekemoer. M.. Smook. L.. Barker. N.P.. Anderson. H.M. and Dallwitz.M.J. (1990) `Grasses of Southern Africa.'*Memoirs of the Botanical Survey of South Africa No. 58* . Botanical Research Institute: Pretoria.

-Grof. B. and Harding. W.A.T. (1970) Dry matter yields and animal production of guinea grass( *Panicum maximum*) on the humid tropical coast of North Queensland. *Tropical Grasslands.***4**. 85-95.

-Guyer. P.Q. and Owen. F.G (1980)*Composition of feed in Ration to Cattle Nutrient.*Fill G476 Under beef. A.30 feeding &Nutrient.

# ការលូតលាស់របស់ជ្រូកកូនកាត់ក្នុងស្រុកដោយប្រើស្លឹកមននិង ទងដំឡូងផ្វាស្រស់ជាប្រភពប្រូតេអ៊ីន



ហ៊ិន សុទ្ធនា
បេក្ខជនបណ្ឌិតវគ្គទី១ ផ្នែកវិទ្យាសាស្ត្រកសិកម្ម
នៃរាជបណ្ឌិត្យសភាកម្ពុជា

## ១-សេចក្តីផ្តើម

ចំណីអាហារគឺជាកត្តាចម្បងមួយដែលកំណត់នូវការលូតលាស់របស់សត្វ។ ចំណីសម្រាប់សត្វជ្រូកភាគច្រើនមានតម្លៃថ្លៃដូចជា សណ្តែកសៀង ត្រី ដែលជាប្រភពប្រូតេអ៊ីន និងចំណីផ្តល់ថាមពលខ្លះទៀត ដូចជាពោត ចុងអង្ករ។ល។ ដោយសារតម្លៃនេះហើយដែលចោទជាបញ្ហាមិនអាចផ្តល់លទ្ធភាពដល់កសិករអភិវឌ្ឍន៍ការចិញ្ចឹមជ្រូកនេះបានល្អនិងទាញយកផលឱ្យអស់លទ្ធភាពនោះឡើយ ដូច្នេះគួរតែប្រើប្រាស់ឱ្យអស់លទ្ធភាពនូវធនធានចំណីក្នុងស្រុកដែលមានស្រាប់និងមានតម្លៃថោក។ ដំឡូងផ្វាព្រមទាំងធញ្ញជាតិផ្សេងៗទៀតជាច្រើនត្រូវប្រើជាចំណីក្នុងផលិតកម្មសត្វដែលពឹងផ្អែកលើចំណីមើមដែលគេប្រើប្រាស់វាជាប្រភពថាមពល និងស្លឹកជាប្រភពប្រូតេអ៊ីនហើយទាំងស្លឹកទាំងមើមអាចប្រើប្រាស់ស្រស់និងស្ងួត ឬ ផ្អាប់បាន (Peter, 2004)។ ថ្មីៗនេះទងដំឡូងផ្វាស្រស់ត្រូវបានគេយកមកប្រើប្រាស់ជាចំណីសត្វនិងអាចផ្តល់ជាចំណីជ្រូកក្នុងដំណាក់កាលលូតលាស់ និងវគ្គបញ្ចប់ក្នុងកម្រិត ២៧%នៃសារធាតុសោះទឹក និង៥០%នៃប្រូតេអ៊ីនសរុប (Hoang Nghia Duyet et al., 2003)។

សក្តានុពលផលិតកម្មដំណាំដំឡូងផ្វា មានពី២៤-៣៦តោនក្នុងមួយហិចតានៃមើមស្រស់ និងពី៤,៣-៦តោនក្នុងមួយហិចតានៃស្លឹកគិតជារូបធាតុសោះទឹក (FAO, 1997 និង Morales,1980)Domiguezនិង Ly (1997)បានវិភាគសមាសធាតុគីមីនៃទងដំឡូងផ្វាហើយជាលទ្ធផលគឺវាមានជាតិសែលុយឡូស២៣,៤% NDF ៤០,៣% ប្រូតេអ៊ីន១៨,៣% ផេះ ២,៦% និងថាមពល១៥,៨MJ/Kg នៃរូបធាតុសោះទឹក។

## ២-សម្ភារៈនិងវិធីសាស្ត្រស្រាវជ្រាវ

**-ជ្រូក** ៖ ក្នុងការពិសោធនេះយើងជ្រើសរើសយកតែជ្រូកឈ្មោលដែលក្រៀវរួចចំនួនសរុប៣០ក្បាលជាពូជកូនកាត់ (Large White X Local)។ មុននឹងយកមកពិសោធជ្រូកទាំងអស់ត្រូវបានចាក់ថ្នាំទម្លាក់ បរា-សិតនិងវ៉ាក់សាំងការពារជំងឺមួយចំនួនដូចជាជំងឺ ប៉េស្ត សាម៉ូណែឡានិងសាទឹក។ ជ្រូកពិសោធន៍ត្រូវនាំមកកាន់ទ្រុងពិសោធន៍រយៈពេល១៥ថ្ងៃមុននឹងចាប់ផ្តើមពិសោធដើម្បីឱ្យវាស៊ាំជាមួយទ្រុងនិងបង្ហាត់វាឱ្យចេះស៊ីចំណីពិសោធន៍។

**-ជញ្ជីង ៖** មានពីរគឺជញ្ជីងសម្រាប់ថ្លឹងចំណីផ្តល់ឱ្យសត្វស៊ី និងថ្លឹងចំណីសល់ជារៀងរាល់ព្រឹក និងជញ្ជីងសម្រាប់ថ្លឹងទម្ងន់ជ្រូកជារៀងរាល់១០ថ្ងៃ ។

**-ទ្រុង** ៖ ទ្រុងត្រូវបានសាងសង់ឡើងបណ្តោយថ្ងៃដែលអាចទទួលពន្លឺនិងកម្តៅថ្ងៃចូលបានគ្រប់គ្រាន់ និងមានលក្ខណៈបច្ចេកទេសត្រឹមត្រូវ។

**-ចំណីនិងការផ្តល់ចំណី** ៖ ចំណី ដែលបានផ្តល់ឱ្យជ្រូកស៊ី រួមមានស្លឹកមន ទងដំឡូងជ្វា និងចុងអង្ករប្រេមិច និងអំបិល។

**-ស្លឹកមន** ៖ ស្លឹកមនដែលយកមកប្រើប្រាស់ក្នុងការពិសោធនេះគឺបានប្រមូលបេះនៅក្នុងមជ្ឈមណ្ឌលអភិវឌ្ឍន៍ការចិញ្ចឹមសត្វនិងកសិកម្ម (CelAgrid) ដែលដាំសម្រាប់កាត់យកស្លឹកមកពិសោធទៅលើសត្វតែប៉ុណ្ណោះ។ ស្លឹកមនដែលកាត់យកមកប្រើប្រាស់មានរយៈពេលដាំដុះ៦០ថ្ងៃបន្ទាប់ពីកាត់លើកទីមួយ ហើយត្រូវប្រមូលផលជារៀងរាល់ថ្ងៃដោយប្រឡេះយកតែស្លឹកប៉ុណ្ណោះ ប៉ុន្តែត្រូវហាន់វាមុននឹងផ្តល់ឱ្យសត្វស៊ីបន្ទាប់ពីប្រមូលផលភ្លាម។

**-ទងដំឡូងជ្វា** ៖ ទងដំឡូងជ្វាដែលយកមកប្រើប្រាស់ក្នុងការពិសោធត្រូវដាំនិងប្រមូលផលនៅក្នុងមជ្ឈមណ្ឌល (CelAgrid) ទងដំឡូងជ្វាស្រស់ត្រូវបានកាត់ប្រវែងប្រហែល២៥-៣០សង់ទីម៉ែត្រ ជារៀងរាល់ថ្ងៃបន្ទាប់ពីដាំរយៈពេលបីខែ ប៉ុន្តែត្រូវហាន់វាឱ្យសត្វស៊ីបន្ទាប់ពីប្រមូលផលភ្លាម។

ចំណីដែលយកមកពិសោធនេះមាន ទងដំឡូងជ្វាស្រស់ ស្លឹកមនស្រស់ ប្រេមិច ចុងអង្ករ និង អំបិល។ រូបធាតុដើមទាំងនេះត្រូវយកទៅវិភាគរករូបធាតុសោះទឹក(DM)តាម Undersandeer et al., (1993) និង អាសូត (N) តាម AOAC (1990) នៅមន្ទីរពិសោធន៍ចំណីក្នុងមជ្ឈមណ្ឌលអភិវឌ្ឍន៍ការចិញ្ចឹមសត្វ និងកសិកម្ម (CelAgrid) ។

តារាងទី១ : សមាសធាតុគីមីចំណីពិសោធ

| សមាសធាតុគីមី / រូបធាតុដើម | រូបធាតុសោះទឹក (DM%) | ប្រូតេអ៊ីន (CP %) | ថាមពល (Kcal/Kg) | សែលុយឡូស (CF %) | កាល់ស្យូម (Ca %) | ផូស្វរ (P %) |
|---|---|---|---|---|---|---|
| ស្លឹកមន | ២១,៣២ [a] | ២២,៣៦ [a] | ២៧០០,៧ [f] | ១៦ [b] | ០,៥ [e] | ០,៦ [e] |
| ទងដំឡូងជ្វា | ១១,៦៨ [a] | ២៣,៤១ [a] | ៣៤៤១,៦ [g] | ១៤,៩ [b] | ១,១៥ [c] | ០,៤២ [c] |
| ចុងអង្ករ | ៨៧,៣៤ [a] | ៨,១២ [a] | ៣៣០០ [d] | ១,៨៨ [b] | ០,២ [d] | ០,៤ [d] |

ប្រភព a : Labor celAgrid 2008 ,b : ChivPhiny, 2007

c : Hoang HoungGiang et al (2004), d : NIAH, 1995

e :Jayal and Kehar, 1962, f : Makkar and Becker, 1996, g : Dominguez (1992)

## ៣-លទ្ធផល

ឆ្លងតាមការពិសោធអស់រយៈពេល១២០ថ្ងៃទៅលើការលូតលាស់របស់ជ្រូកកូនកាត់ដោយប្រើស្លឹកមន និង ទងដំឡូងផ្វាស្រស់ជាប្រភពប្រូតេអ៊ីនទទួលបានលទ្ធផលដូចខាងក្រោមៈ

### ៣.១-បរិមាណនៃការស៊ីចំណី

តារាងទី២ : បរិមាណនៃការស៊ីចំណីតាមក្រុមរបស់ជ្រូកពី០ទៅ១២០ថ្ងៃ

| ក្រុម / ចំណី(ក្រ/ថ្ងៃ/ក្បា) | $T_1$ | $T_2$ | $T_3$ | SE | P |
|---|---|---|---|---|---|
| ស្លឹកមន | ៤៥២,៥៥ | 0 | 0 | - | - |
| ទងដំឡូងផ្វា | 0 | ៧៣៧,០១ | 0 | - | - |
| ស្លឹកមន+ទងដំឡូងផ្វា | 0 | 0 | ៦១៨,០១ | - | - |
| ចុងអង្ករ | ៦៧៤,៩៧$^{c}$ | ៧៨៦,៨៥$^{a}$ | ៧១៦,៩៨$^{b}$ | ៥,៤៩ | 0,00១ |
| សរុប(DM)ស៊ី | ១១៣៤,១៨$^{c}$ | ១៥៣១,៥៤$^{a}$ | ១៣៤២,១៩$^{b}$ | ១៣,១៥ | 0,00១ |
| ប្រូតេអ៊ីន | ១៥៦,៩៩$^{c}$ | ២៦០,៥៦$^{a}$ | ១៩៦,៦៩$^{b}$ | ២,៦៥ | 0,00១ |

a, b, c តំណាងតម្លៃនៃការប្រៀបធៀបដែលកំណត់ដោយ a>b>c ( P≤00៥,)

តាមលទ្ធផលនៃការពិសោធអស់រយៈពេល៤ខែកន្លងមក យើងឃើញថា បរិមាណនៃការស៊ីចំណី របស់ក្រុម $T_1$=១១៣៤,១៨ក្រ. (ស្លឹកមន ៤៥២,៥៥ក្រ. ចុងអង្ករ ៦៧៤,៩៧ក្រ.) $T_2$=១៥១៣,៥៤ក្រ. (ទងដំឡូងផ្វា ៧៣៧,០១ក្រ.និងចុងអង្ករ ៧៨៦,៨៥ក្រ.) និង $T_3$ =១៣៤២,១៩ក្រ. (ស្លឹកមននិង ទងដំឡូងផ្វា ៦១៨,០១ក្រ. ចុងអង្ករ ៧១៦,៩៨ក្រ.) រវាងក្រុមទាំង៣នេះ យើងសង្កេតឃើញថា ក្រុម $T_2$ មានបរិមាណនៃការស៊ីចំណីច្រើនជាងគេ តែបើប្រៀបធៀបក្រុម $T_1$ និង $T_3$ គឺ $T_3$ មានបរិមាណនៃការស៊ី ចំណីល្អជាង $T_1$ ដោយ (P≤0,00១)។ តាមតារាងបានបង្ហាញថាបរិមាណនៃការស៊ីចំណីផ្តល់ប្រូតេអ៊ីន គឺ ស្លឹកមន ទងដំឡូងផ្វានិងការរួមបញ្ចូលគ្នារវាងស្លឹកមននិងទងដំឡូងផ្វាពិតជាមានភាពខុសគ្នា ព្រោះថាបរិមាណ នៃការស៊ីស្លឹកមនសម្រាប់ $T_1$ បានតិចជាងការស៊ីស្លឹកមនរបស់ក្រុម $T_2$ និង $T_3$ ដែលស៊ីស្លឹកមនលាយជាមួយ ទងដំឡូងផ្វា។

### ៣.២-ការឡើនទម្ងន់

ជាលទ្ធផលសរុបក្នុងរយៈពេលពិសោធន៍ ១២០ថ្ងៃ ដែលបានបង្ហាញឱ្យយើងឃើញពីការកើនឡើង ខុសៗគ្នា រវាងក្រុមទាំងបី ដែលប្រើចំណីខុសគ្នា ថាតើក្រុមមួយណាដែលកើនទម្ងន់បានល្អជាងគេក្នុងចំណោម ក្រុមទាំងបីនេះ។ បើយើងសង្កេតមើលនៅក្នុងតារាងឃើញថា ក្រុម $T_1$ $T_2$ និង$T_3$ ទម្ងន់នៅពេលចាប់ផ្តើមពុំមាន ការខុសគ្នាទេ ប៉ុន្តែនៅទីបញ្ចប់នៃការពិសោធយើងឃើញថាទម្ងន់ដែលបានទទួលសម្រាប់ក្រុម $T_1$ ទាបជាង គេទៅវិញគឺ៥៦,១៣គ.ក្រ.តែប៉ុណ្ណោះ ចំណែកឯក្រុមដែលប្រើចំណីទងដំឡូងផ្វាស្រស់ជាមួយចុងអង្ករធ្វើឱ្យ

សត្វជ្រូកកើនទម្ងន់បានល្អជាងក្រុមដែលប្រើចំណីទងដំឡូងផ្វាលាយជាមួយស្លឹកមននិងចុងអង្ករនិងចំណីដែលផ្តល់តែ ស្លឹកមននិងចុងអង្ករ។

តារាងទី៣: កំណើនទម្ងន់ជ្រូកតាមក្រុមពី ០ទៅ១២០ថ្ងៃ

| ក្រុម / ទម្ងន់ (គ.ក្រ.) | $T_1$ | $T_2$ | $T_3$ | SE | P |
|---|---|---|---|---|---|
| ចាប់ផ្តើម | ២៨,២ | ២៧,៩ | ២៧,៨ | ០,៣៥ | ០,៧ |
| បញ្ចប់ | ៥៦,១៣ $^{c}$ | ៧៣,៨ $^{a}$ | ៦៣,៥២ $^{b}$ | ៣,១៤ | ០,០០៧ |
| កំណើន ក្រាម/ថ្ងៃ | ២២៤,៥៦ $^{c}$ | ៣៩០,៣៧ $^{a}$ | ២៩២,១៥ $^{b}$ | ២៤,៨២ | ០,០០១ |

a, b, c តំណាងឱ្យតម្លៃនៃការប្រៀបធៀបដែលកំណត់ដោយ a>b>c ( P≤០០៥,)

**៣.៣-សន្ទស្សន៍នៃការស៊ីចំណី**

តារាងទី៤ : សន្ទស្សន៍នៃការស៊ីចំណីរបស់ជ្រូកតាមក្រុម

| ក្រុម / ដំណាក់កាល | $T_1$ | $T_2$ | $T_3$ | SE | P |
|---|---|---|---|---|---|
| ០-៣០ | ៤,៩២ | ៣,៦៨ | ៣,៩៩ | ០,៤ | ០,១ |
| ៣០-៦០ | ៦,២៣ $^{c}$ | ៣,៨៩ $^{a}$ | ៣,៩៩ $^{b}$ | ០,៤ | ០,០០១ |
| ៦០-៩០ | ៥,៤៧ $^{c}$ | ៣,៦៤ $^{a}$ | ៤,៦៨ $^{b}$ | ០,៣៣ | ០,០០៦ |
| ៩០-១២០ | ៦,១៦ $^{c}$ | ៤,៦៤ $^{a}$ | ៥,៥៨ $^{b}$ | ០,៣ | ០,០១ |
| ០-១២០ | ៥,៨៥ $^{c}$ | ៣,៦៧ $^{a}$ | ៤,៦៨ $^{b}$ | ០,៣២ | ០,០០១ |

a, b, c តំណាងតម្លៃនៃការប្រៀបធៀបដែលកំណត់ដោយ a>b>c ( P≤០០៥,)

សរុបលទ្ធផលនៃការពិសោធគិតជាមធ្យមទៅលើសន្ទស្សន៍នៃការស៊ីចំណីរបស់ក្រុមទាំងបីក្នុងរយៈពេល១២០ថ្ងៃកន្លងមកឃើញថា លទ្ធផលនៅក្នុងដំណាក់កាលនេះគឺមានលក្ខណៈខុសគ្នាគួរឱ្យកត់សម្គាល់ដោយ (P≤០,០០១) $T_2$=៣,៦៧គ.ក្រ. ដើម្បីបានសាច់មួយគីឡូក្រាមគឺវាស៊ីចំណីអស់តិចជាងក្រុមផ្សេងៗទៀតដែល $T_1$=៥,៨៥គក្រនិង$T_3$=៤,៦៨.គក្រ. ដើម្បីបានសាច់មួយគីឡូក្រាម។ យើងឃើញថា $T_2$ ដែលប្រើទងដំឡូងផ្វាស្រស់លាយជាមួយចុងអង្ករពិតជាមានសន្ទស្សន៍នៃការស៊ីចំណីល្អជាងគេ ព្រោះទងដំឡូងផ្វាជាចំណី ដែលសត្វចូលចិត្តស៊ីហើយវាគ្មានជាតិចត់ដូចជាស្លឹកមនដែលធ្វើឱ្យក្រុម $T_1$ មានសន្ទស្សន៍នៃការស៊ីចំណីខ្ពស់ជាង $T_3$ ទៅទៀតដោយហេតុថា $T_3$ មានស្លឹកមនលាយជាមួយទងដំឡូងផ្វាធ្វើឱ្យជាតិចត់នៅក្នុងចំណីត្រូវ

កាត់បន្ថយដែលធ្វើឱ្យជ្រូកស៊ីបានច្រើននិងស្រូបយកទៅចិញ្ចឹមសារពាង្គកាយក៏បានច្រើនជាង $T_1$ សន្ទស្សន៍នៃការស៊ីចំណីក៏បានល្អ។

## ៤-សន្និដ្ឋាន

ចំពោះលទ្ធផលនៃការពិសោធលើការលូតលាស់បានបង្ហាញឱ្យឃើញថា បរិមាណនៃការស៊ីចំណីនិងប្រូតេអ៊ីនរបស់ក្រុមទាំងបីគឺមានលក្ខណៈខុសគ្នាពិតប្រាកដមែនពោលគឺក្រុម $T_2$=១៥៣១,៥៤ក្រ; ២៦០,៥៦ក្រ. ខ្ពស់ជាក្រុម $T_1$=១១៣៤,១៨ក្រ.; ១៥៦,៩៩ក្រ. និង $T_3$=១៣៤២,១៩ក្រ.; ១៩៦,៦៩ក្រ./ថ្ងៃ (P≤0,00១)។ ចំពោះកំណើនទម្ងន់វិញក៏មានលក្ខណៈមិនខុសពីបរិមាណនៃការស៊ីចំណីដែរគឺថា ក្រុម $T_2$=៣៩០,៣៧ក្រ./ថ្ងៃ កើនទម្ងន់បានខ្ពស់ជាង $T_1$=២២៤,៥៦ក្រ./ថ្ងៃ និង$T_3$=២៩២,១៥ក្រ./ថ្ងៃ (P≤0,00១)។ រីឯសន្ទស្សន៍នៃការស៊ីចំណីក៏បង្ហាញលក្ខណៈខុសគ្នាផងដែរ រវាងក្រុមទាំងបីនេះគឺក្រុម $T_2$=SPVBR=៣,៦៧គ.ក្រ. ដែលផ្តល់ទងដំឡូងផ្ទាស្រស់លាយជាមួយចុងអង្ករដែលជាចំណីផ្តល់ថាមពលបានបង្ហាញឱ្យឃើញថា មានលក្ខណៈល្អជាងក្រុម $T_1$=៥,៨៥គ.ក្រ. និង$T_3$=៤,៦៨គ.ក្រ.(P≤0,00១) វាចំណាយចំណីតិចដើម្បីបានសាច់មួយគីឡូក្រាម។

សរុបមក ការប្រើប្រាស់ទងដំឡូងផ្ទាស្រស់លាយជាមួយចុងអង្ករជាប្រភពថាមពលបានបង្ហាញឱ្យឃើញថា បរិមាណនៃការស៊ីចំណីបានច្រើន កំណើនទម្ងន់បានខ្ពស់ ហើយនិងសន្ទស្សន៍នៃការស៊ីចំណីល្អជាងក្រុមផ្សេងៗទៀត។ លទ្ធផលទាំងពីរខាងលើនេះបានបង្ហាញឱ្យឃើញថាការប្រើប្រាស់ទងដំឡូងផ្ទាស្រស់សម្រាប់ជ្រូកពិតជាចំណីល្អទាំងលើភាពរលាយនៃអាហារនិងការលូតលាស់។

## គន្ថនិទ្ទេស


១.Dominguez, P.L. and J. Ly 1997.An approach to the nutritional value for pig of sweet potato vine (Ipomoea batatas(L)Lam). Livestock Research for rural development, volume9, number2.

២.FAO 1997. Feeding Pigs in the tropics.Chapter5, Root, tubers banana and plantains.htpp//www.fao.org/ag/AGA/AGAP/PRG/APH132/Chap5.htm

៣.Hoang HoungGiang, Leviet Ly and Brian Ogle, 2004. Evaluation of ensiling methods to preserve sweet potato roots and vine as pig feed. Developments of Animal nutrition and management, Swedish university of agriculture science.

៤.Morales , A., 1980. El clondelboniato CEMSA74-228 centro de mejoramiento de semillas

៥.Peter D.,2004.Use of Sweet potato in pig production in Asia .Agricultural and Socieconomic aspects. International Center for Tropical Agriculture(CIAT).Hanoi,Vietnam.

# តួនាទីនៃស្ថាប័នព័ត៌មានក្នុងសង្គម



ឈត ប៊ុនថង
បេក្ខជនបណ្ឌិតវគ្គ ២ ផ្នែកទស្សនវិជ្ជា
នៃរាជបណ្ឌិត្យសភាកម្ពុជា

ប្រព័ន្ធផ្សព្វផ្សាយគឺជាមធ្យោបាយមួយដែលមានតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ដំណឹងព័ត៌មាន ហេតុការណ៍ ព្រឹត្តិការណ៍ និងផ្តល់ពុទ្ធិជាច្រើនទៀតដល់សង្គមមនុស្ស។ ប្រព័ន្ធផ្សព្វផ្សាយនេះអាចជួយសង្គមបានច្រើនយ៉ាងណាស់ជាពិសេសជំនួយខាងផ្នែកស្មារតីដែលជាកត្តាចម្បងអាចជំរុញឱ្យការប្រតិបត្តិការងារផ្សេងៗបានល្អប្រសើរនិងឈានទៅអភិវឌ្ឍបុគ្គលនិងអភិវឌ្ឍសង្គមទាំងមូល។ នៅប្រទេសកម្ពុជាក៏ដូចជាប្រទេសនានាទៅទាំងពិភពលោកដែរ ប្រព័ន្ធផ្សព្វផ្សាយតែងតែដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ដំណឹងព័ត៌មានហេតុការណ៍និងព្រឹត្តិការណ៍នានាទាក់ទងប្រពៃណីទំនៀមទម្លាប់ សាសនា វប្បធម៌ សិល្បៈ នយោបាយ សេដ្ឋកិច្ច ពាណិជ្ជកម្ម សន្តិសុខ សង្គ្រាម ភេរវកម្ម ការធ្វើដំណើរ អាកាសធាតុ ឧតុនិយមនិងគ្រោះធម្មជាតិ។ល។ ដែលទាំងអស់នោះគឺជាអ្វីដែលមនុស្សត្រូវតែដឹងជាចាំបាច់ ពីព្រោះវាតែងតែជះឥទ្ធិពលដោយផ្ទាល់ ឬមិនផ្ទាល់មកលើជីវិតនិងការរស់នៅរបស់ពួកគេ។ ក្រៅពីនេះ ប្រព័ន្ធផ្សព្វផ្សាយ ក៏បានផ្តល់ចំណេះដឹង បទពិសោធន៍ជីវិតនិងព័ត៌មាន ស្តីពីការបង្កើតថ្មីនិងរបកគំហើញខាងវិទ្យាសាស្ត្រផងដែរ។

ដើម្បីបំពេញបាននូវតួនាទីដ៏ធំធេងនិងប្រកបដោយសារៈសំខាន់នេះប្រព័ន្ធផ្សព្វផ្សាយទាំងអស់មានដូចជា វិទ្យុ ទូរទស្សន៍ កាសែត ទស្សនាវដ្តី ប្រព័ណ្ឌអ៊ីនធឺរណិត។ល។ ត្រូវតែផ្សព្វផ្សាយដោយឈរលើគោលជំហរមួយដែលស្ថិតនៅក្នុងក្របខ័ណ្ឌច្បាប់សារព័ត៌មានក្រមសីលធម៌វិជ្ជាជីវៈនិងផ្អែកលើផលប្រយោជន៍រួមរបស់មនុស្សជាតិ។ បើពុំដូច្នេះទេវាពុំបានផ្តល់ផលប្រយោជន៍វិជ្ជមានសម្រាប់សង្គមឡើយ។

ថ្វីបើអ្នកសារព័ត៌មានមានសេរីភាពទូលំទូលាយក៏ដោយ ក៏គេមិនអាចធ្វើអ្វីៗបានតាមចិត្តដែលគេចង់ធ្វើនោះដែរសូម្បីតែនៅក្នុងប្រទេសនានាដែលកាន់លទ្ធិប្រជាធិបតេយ្យសេរីក៏ដោយ។ សេរីភាពសារព័ត៌មានត្រូវផ្សារភ្ជាប់ជាមួយទំនួលខុសត្រូវ ទោះស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ។ តាមពិត "នៅក្នុងពិភពលោកគ្មានប្រទេសណាមួយដែលអ្នកសារព័ត៌មានមានសេរីភាពដាច់ខាតនោះទេ។ សេរីភាពក្នុងការបញ្ចេញមតិយោបល់ (ឬសេរីភាពសារព័ត៌មាន)អាចត្រូវបានកំណត់និងត្រូវកំណត់ព្រំដែនដោយៈ

- ក.ការចាប់ពិរុទ្ធរបស់រដ្ឋាភិបាលក្នុងរដ្ឋផ្តាច់ការ
- ខ.ផលប្រយោជន៍និងគោលនយោបាយរបស់ជាតិ
- គ.គណបក្សនយោបាយ
- ឃ.ផលប្រយោជន៍របស់ថៅកែ (ប្រធានក្រុមហ៊ុន)និងសមាជិកភាគហ៊ុន
- ង.អ្នកឃោសនាឬអ្នកផ្សព្វផ្សាយពាណិជ្ជកម្ម
- ច.ភ្នាក់ងារយកព័ត៌មាន

ទាំងអស់នេះគ្រាន់តែជាចំណុចខ្លះៗប៉ុណ្ណោះនៅមានកាត្តាជាច្រើនទៀតដែលរួមចំណែកទប់ស្កាត់ធ្វើយ៉ាងណាឱ្យប្រព័ន្ធផ្សព្វផ្សាយបម្រើផលប្រយោជន៍រួមនិងនិយាយការណ៍ពិត។ ប្រសិនបើគ្មានកត្តាទាំងនេះរួមផ្សំជាមួយច្បាប់សារព័ត៌មាននិងសីលធម៌វិជ្ជាជីវៈទេ ប្រព័ន្ធផ្សព្វផ្សាយសារព័ត៌មានអាចផ្សព្វផ្សាយនិងបោះពុម្ព

ផ្សាយនូវអ្វីដែលខុសពីភាពដើមសច្ចភាពលម្អៀងឬផ្សព្វផ្សាយដំណឹងឬព័ត៌មានលាបពណ៌ដែលអាចធ្វើឱ្យខូចផលប្រយោជន៍រួមរបស់ជាតិឬអាចបង្កចភាពចលាចលធ្វើឱ្យខ្វះសណ្តាប់ធ្នាប់និងបង្កទំនាស់ផ្សេងៗនៅក្នុងសង្គមទាំងកម្រិតជាតិនិងអន្តរជាតិ។ ទន្ទឹមនឹងការទប់ស្កាត់នេះ រដ្ឋាភិបាលនៃរដ្ឋនីមួយៗក៏គួរតែផ្តល់សិទ្ធិផ្តល់ឱកាសគ្រប់គ្រាន់និងបង្កលក្ខណៈងាយស្រួល ព្រមទាំងការពារនិងលើកទឹកចិត្តចំពោះប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននិងអ្នកសារព័ត៌មានទាំងឡាយណាដែលបានបំពេញកាតព្វកិច្ចរបស់ខ្លួនដោយអនុលោមទៅតាមច្បាប់សារព័ត៌មាននិងក្រមសីលធម៌វិជ្ជាជីវៈ។

នៅក្នុងព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្នភាពលម្អៀងការលាបពណ៌ឱ្យដំណឹងឬព័ត៌មាននិងការផ្សព្វផ្សាយខុសភាពដើមនៃហេតុការណ៍ឬព្រឹត្តិការណ៍ក៏កំពុងមានអត្ថិភាពដែរនៅក្នុងប្រព័ន្ធផ្សព្វផ្សាយរបស់ខ្លួន។ អ្នកសារព័ត៌មានមួយចំនួនបានគោរពមនសិការវិជ្ជាជីវៈ គោរពច្បាប់សារព័ត៌មាននិងគោរពក្រមសីលធម៌វិជ្ជា-ជីវៈបានត្រឹមត្រូវគួរឱ្យកោតសរសើរ។ ប៉ុន្តែនៅមានអ្នកសារព័ត៌មានមួយចំនួនទៀតពុំស័ក្តិសមជាអ្នកសារព័ត៌-មានពិតប្រាកដទេ ពួកនេះតែងតែផ្សព្វផ្សាយព័ត៌មានបំផ្លើសការណ៍ពិត បំប៉ោងសភាពការណ៍ ប្រើប្រាស់ពាក្យពេចន៍អសុរោះ អុជអាលបង្កឱ្យមានទំនាស់រវាងបុគ្គលនិងបុគ្គលទំនាស់រវាងក្រុមមួយនិងក្រុមមួយ ទំនាស់រវាងគណបក្សនិងគណបក្ស ទំនាស់រវាងក្រុមហ៊ុនមួយនិងក្រុមហ៊ុនមួយ និងទំនាស់រវាងប្រជាជាតិមួយនិងប្រជា-ជាតិមួយជាដើម។ អ្នកសារព័ត៌មានប្រភេទនេះ ពួកគេពុំបានគិតគូរដល់តម្លៃសីលធម៌ទេ គេគិតតែធ្វើយ៉ាងណាឱ្យព័ត៌មានរបស់ខ្លួនលក់ដាច់និងទទួលបានការចាប់អារម្មណ៍ពីអ្នកអាន អ្នកមើលនិងអ្នកស្តាប់របស់គេតែប៉ុណ្ណោះ។

ក្រៅពីការបំប៉ោងការណ៍ពិតនិងផ្សព្វផ្សាយដំណឹងអគតិដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីគាំទ្រ ឬប្រឆាំងក្រុមណាមួយ ឬក៏លម្អៀងទៅតាមបុរេនិច្ច័យរបស់ខ្លួន យើងក៏សង្កេតឃើញកាសែតនិងទស្សនាវដ្តីខ្លះបានចុះផ្សាយនូវរូបភាពអាសអាភាស រឿងអាសអាភាស។ល។ ដែលអាចធ្វើឱ្យខូចប្រពៃណីខ្មែរនិងអាចអូសទាញយុវជនដែលជាអនាគតអ្នកបន្តវេនគ្រប់គ្រងថែរក្សាទឹកដី វប្បធម៌និងអរិយធម៌ខ្មែរឱ្យធ្លាក់ទៅក្នុងភាពពាលាអាវ៉ាសែភ្លេចអស់ការសិក្សានិងអាចឈានទៅប្រព្រឹត្តបទល្មើសផ្សេងៗទៀតផង។

ដើម្បីអាចទប់ស្កាត់នូវផ្នែកអវិជ្ជមាននៃប្រព័ន្ធផ្សព្វផ្សាយនេះ លុះត្រាតែយើងទាំងអស់គ្នាទាំងប្រជាពលរដ្ឋទាំងសង្គមស៊ីវិល ជាពិសេស សមាគមអ្នកសារព័ត៌មាននិងរាជរដ្ឋាភិបាលត្រូវរិះរកគ្រប់វិធីធ្វើយ៉ាងណាដើម្បីឱ្យអ្នកសារព័ត៌មានទាំងអស់ក្លាយទៅជាអ្នកសារព័ត៌មានល្អគោរពច្បាប់សារព័ត៌មាននិងគោរពក្រមសីលធម៌វិជ្ជា-ជីវៈដែលអាចធ្វើឱ្យពួកគេក្លាយទៅជាមនុស្សដែលមិនគ្រាន់តែមានប្រយោជន៍ចំពោះខ្លួនឯងនិងគ្រួសាររបស់គេប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាមនុស្សដែលបានគិតគូរនិងបានផ្តល់ផលប្រយោជន៍រួមដល់សង្គមផងដែរ។ សារ-ព័ត៌មានល្អគឺជាសារព័ត៌មានដែលគោរពសច្ចភាពនិយាយការណ៍ពិតមានទស្សនៈ វិភាគខ្ពស់មានគោលដៅបម្រើឧត្តមប្រយោជន៍រួមរបស់ជាតិនិងមនុស្សជាតិ ជាងផលប្រយោជន៍បុគ្គលនិងបក្សពួករបស់ខ្លួន មានជំហរឯក-រាជ្យ យុត្តិធម៌ គោរពតម្លៃសីលធម៌ គ្មានការរុកគួន ការឈ្នានីស បន្តុះបង្អាប់ និង គ្មានការញុះញង់ដែលធ្វើឱ្យបាត់បង់ស្ថិរភាពនយោបាយបាត់បង់សណ្តាប់ធ្នាប់សង្គមបាត់បង់ផលប្រយោជន៍រួមរបស់ជាតិនិងធ្វើឱ្យបែកបាក់សាមគ្គីផ្ទៃក្នុងរបស់ជាតិ ក៏ដូចជាសុខដុមនីយកម្មអន្តរជាតិផងដែរ។

តាមពិតចំពោះអ្នកដែលធ្វើការនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ យើងផ្តល់សេរីភាពឱ្យពួកគេធ្វើរបាយការណ៍ពីព្រោះតែយើងចង់ដឹងការណ៍ពិត ដូច្នេះយើងផ្តល់ឱ្យពួកគេនូវអំណាចតាមឃ្លាំមើលបុគ្គលនានារដ្ឋាភិបាល ឬ

ស្ថាប័នផ្សេងៗទៀតក្នុងបំណងការពារច្បាប់និងគោលការណ៍សីលធម៌។ ទោះបីជាយ៉ាងនេះក៏ដោយក៏ពួកគេមិនមែនឈរនៅពីលើសីលធម៌ដែរផ្ទុយទៅវិញពួកគេត្រូវមានកាតព្វកិច្ចគោរពសេចក្តីថ្លៃថ្នូររបស់មនុស្ស សិទ្ធិមនុស្សនិងតម្លៃមូលដ្ឋានរបស់មនុស្ស។ ពួកគេត្រូវចងដោយកាតព្វកិច្ចឱ្យគោរពបរានុម័ត្តិភាព ភាពត្រឹមត្រូវនិងការការពារសេចក្តីថ្លៃថ្នូររបស់មនុស្ស។ អ្នកដែលធ្វើការនៅក្នុងប្រព័ន្ធផ្សព្វផ្សាយមិនមានសិទ្ធិរំលោភឬជ្រៀតជ្រែកចូលរឿងឯកជនរបស់បុគ្គលបំភាន់មតិសាធារណៈឬបំប៉ោងតថភាព(បំភ្លៃការណ៍ពិត)ឡើយ។ បើពុំដូច្នោះទេ ពួកគេនឹងត្រូវទទួលការស្តីបន្ទោសពីសាធារណជននិងទទួលរងការវិនិច្ឆ័យខាងសីលធម៌និងច្បាប់។ ក្នុងករណីធ្ងន់ធ្ងរពួកគេអាចត្រូវប្រឈមមុខនឹងការពិន័យជាប្រាក់ ឬដាក់ពន្ធនាគារ។

# គោលនយោបាយសហរដ្ឋអាមេរិកចំពោះកម្ពុជា



តឹក មេង
បេក្ខជនបណ្ឌិតវគ្គទី១ ផ្នែកប្រវត្តិវិទ្យា
នៃរាជបណ្ឌិត្យសភាកម្ពុជា

## សេចក្តីផ្តើម

ទំនាក់ទំនងកម្ពុជា-សហរដ្ឋអាម៉េរិកបានចាប់បដិសន្ធិឡើងដំបូងនៅចុងសតវត្សរ៍ទី១៩ ហើយក្រោយមកលោក ហ្សាល់ ទ្រីឡែត (ជហារលសេ Trewlett) ដែលជាពាណិជ្ជករ និងជាតំណាងស្ថានកុងស៊ុល សហរដ្ឋអាម៉េរិក ប្រចាំទីក្រុងព្រៃនគរ បានផ្តួចផ្តើមគំនិតស្ថាបនាទំនាក់ទំនងរវាងកម្ពុជានិងសហរដ្ឋអាម៉េរិក។ ទំនាក់ទំនងដំបូងនេះ មានរូបភាពជាផ្នែកពាណិជ្ជកម្មប៉ុណ្ណោះ ពីព្រោះសហរដ្ឋអាម៉េរិកត្រូវការពង្រីកពាណិជ្ជកម្មជាពិសេស គឺ ពាណិជ្ជកម្មប្រេងឥន្ធនៈ កេរ៉ូសែន ( Kerosene) មកកាន់ប្រទេសទាំងឡាយនៅឥណ្ឌូចិន។

មូលហេតុចម្បងនៃទំនាក់ទំនងនេះ គឺអាស្រ័យដោយសហរដ្ឋអាម៉េរិក មានគោលបំណងពង្រីកវិស័យពាណិជ្ជកម្មប្រេងឥន្ធនៈមកកាន់ប្រទេសនៅឥណ្ឌូចិន។ ហេតុដូច្នេះហើយ ទើបនៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៨៨៩ រដ្ឋាភិបាលសហរដ្ឋអាម៉េរិក បានតែងតាំងលោក អេមី ហ្វ្រង់សា ឡែស (Fonsales) ធ្វើជាភ្នាក់ងារទទួលបន្ទុកផ្នែកពាណិជ្ជកម្មប្រចាំឥណ្ឌូចិន។ បន្ទាប់មកទៀត នៅខែមិថុនា ឆ្នាំ១៩០៦ សហរដ្ឋអាម៉េរិក បានបើកស្ថានកុងស៊ុលរបស់ខ្លួននៅទីក្រុងសៃហ្គន ដោយបានតែងតាំងលោក ភើលី ស៊ី ហ៊ីល (C Heald) ជាប្រធាន[៣១]។

នៅក្នុងរជ្ជកាលព្រះបាទ ស៊ីសុវត្ថិ (១៩០៤-១៩២៧) ទំនាក់ទំនងកម្ពុជា-សហរដ្ឋអាម៉េរិកបានធ្វើឡើងជាលក្ខណៈទំនាក់ទំនងផ្នែកការទូត ហើយចាប់ផ្តើមមានទស្សនកិច្ចមកកាន់ប្រទេសកម្ពុជានូវឥស្សរជនសំខាន់ៗនៃសហរដ្ឋអាម៉េរិក។ ជាក់ស្តែងនៅឆ្នាំ១៩០៨ លោក ខនណើនិងសមាជិករបស់ លោកបានធ្វើដំណើរមកកាន់ប្រទេសកម្ពុជា នេះគឺជាវត្តមានអ្នកការទូតសហរដ្ឋអាម៉េរិកនៅលើទឹកដីកម្ពុជាជា លើកដំបូង។ ក្រោយមកទៀតនៅឆ្នាំ១៩១៥ គេសង្កេតឃើញមានទស្សនកិច្ចរបស់មន្ត្រីសហរដ្ឋអាម៉េរិក មកកាន់ទីក្រុងភ្នំពេញ តាមមហាវិថីមួយដែលភ្ជាប់ពីទីក្រុងព្រៃនគរមកកាន់ទីក្រុងភ្នំពេញ។ ម្យ៉ាងទៀតនៅ ឆ្នាំ១៩២៥ លោក ហ៊ីតតុន ទ្រីតវេត ( Treadway) ដែលជាសមាជិកសភាសហរដ្ឋអាម៉េរិក លើកដំបូងបានធ្វើដំណើរមកបំពេញទស្សនកិច្ចជាផ្លូវការនៅទីក្រុងភ្នំពេញ។ លោក ហ៊ីតតុន ទ្រីតវេត ក៏បានចូលគាល់ព្រះមហាក្សត្រកម្ពុជា ព្រមទាំងបានថ្វាយសារតាំងដល់ ព្រះមហាក្សត្រទៀតផង។

## ១-ប្រវត្តិទំនាក់ទំនងសង្ខេប

នៅចុងសម័យកាលគ្រប់គ្រងរបស់អាណានិគមបារាំងឃើញថា បើទោះជាប្រទេសក្នុងឥណ្ឌូចិនកំពុងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រទេសបារាំងក៏ដោយ ក៏សហរដ្ឋអាម៉េរិកនៅតែព្យាយាមធ្វើទំនាក់ទំនងការទូតជាមួយប្រទេសទាំងនោះដែរ។ ជាពិសេស នៅឆ្នាំ១៩៥០ សហរដ្ឋអាម៉េរិកបានធ្វើទំនាក់ទំនងការទូតដោយផ្ទាល់ជាមួយកម្ពុជា ហើយនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៥២ ទំនាក់ទំនងនេះកាន់តែប្រសើរឡើងរហូតដល់មានបើកទីស្នាក់ការទូតនិងមានមន្ត្រីទូតឈ្មោះ រ៉ូបែត ម៉ាកគ្លីនថក (Mc Clintock) ជាអគ្គរដ្ឋទូត

[៣១] អ៊ុំ ប៉ុម ទំនាក់ទំនងកម្ពុជា-សហរដ្ឋអាម៉េរិក ឆ្នាំ១៩៥០-១៩៧០ សារណាបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ ឆ្នាំ២០០២ ទំព័រ ទី ១៣

ប្រចាំព្រះរាជាណាចក្រកម្ពុជា[៣២]។ បើផ្អែកតាមទស្សនៈរបស់លោក គ្រីតហ្គ័រី ( Lawless) បានបង្ហាញថា "សហរដ្ឋអាម៉េរិកមានទំនាក់ទំនងការទូតផ្លូវការដំបូងជាមួយកម្ពុជានៅឆ្នាំ១៩៥៥ ហើយទំនាក់ទំនងនេះត្រូវប្រេះឆារទៅវិញពីឆ្នាំ១៩៦៥-៦៩"[៣៣]។ បន្ទាប់ពីមានទំនាក់ទំនងការទូតនោះមក យើងសង្កេតឃើញថា ចាប់ពីឆ្នាំ១៩៥៥ សហរដ្ឋអាម៉េរិកបានចាប់ផ្តើមផ្តល់កម្មវិធីជំនួយជាច្រើនដល់កម្ពុជា ដែលមានទឹកប្រាក់ប្រមាណជាង៥០លានដុល្លារក្នុង១ឆ្នាំ[៣៤]។ ដោយសារសហរដ្ឋអាម៉េរិក ឃុបឃិតជាមួយ សម្ព័ន្ធមិត្ត ដូចជា វៀតណាមខាងត្បូង និងប្រទេសថៃ រៀបចំផែនការនៅក្នុងស្ថានទូតអាម៉េរិក ប្រចាំភ្នំពេញ គ្រោងធ្វើរដ្ឋប្រហារទម្លាក់ព្រះបាទសម្តេច នរោត្តម សីហនុ តែត្រូវបរាជ័យទៅវិញ គឺជាដើមចមជំរុញស្ថានភាព ទំនាក់ទំនងរវាងកម្ពុជា និង សហរដ្ឋអាម៉េរិក ឈានទៅរកការផ្តាច់ទំនាក់ទំនងទូតទាំងស្រុងនៅថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៦៥[៣៥]។ ចាប់ពីដំណើរ ទស្សនកិច្ចពីថ្ងៃទី២ដល់ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៦៧ របស់លោក ជំទាវ ចេកឃ័រលីន ខេនណឺឌី ( Kennedy) មកទីក្រុងភ្នំពេញ ដែលមានការទទួល ស្វាគមន៍ ពីសម្តេចព្រះបាទ នរោត្តម សីហនុ ទំនាក់ទំនងនៃ ប្រទេសទាំងពីរផ្តើមមានចំណងល្អនឹងគ្នាឡើង វិញរហូតដល់មានការបើកស្ថានទូតអាម៉េរិកឡើងវិញ នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៦៩[៣៦]។ បន្ទាប់ពីការ ធ្វើរដ្ឋប្រហារទម្លាក់ព្រះបាទ នរោត្តម សីហនុ ដោយសេនាប្រមុខ លន់ នល់ សហរដ្ឋអាម៉េរិកបន្តជំនួយ យ៉ាងច្រើនដល់រដ្ឋាភិបាល លន់ នល់ តាំងពីឆ្នាំ១៩៧០-១៩៧៥។ ចាប់ពីឆ្នាំ១៩៧៥ មក ទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរត្រូវផ្តាច់ទាំងស្រុង។

បេសកកម្មសហរដ្ឋអាម៉េរិកនៅទីក្រុងភ្នំពេញ បានចាប់ផ្តើមឡើងវិញនាថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៩១ យោងតាមស្មារតីកិច្ចព្រមព្រៀងទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ សហរដ្ឋអាម៉េរិកបានរក្សានូវវត្តមានរូបវន្តរបស់ខ្លួនក្នុងប្រទេសកម្ពុជា។ ទំនាក់ទំនងការទូតពេញលេញក៏បានបង្កើតឡើងបន្ទាន់ផងដែរ ក្រោយប្រទេសកម្ពុជាបានរៀបចំការបោះឆ្នោតដោយសេរីនិងយុត្តិធម៌ ហើយបានរៀបចំរាជរដ្ឋាភិបាល នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។ នៅឆ្នាំ១៩៩៤ ឯកអគ្គរដ្ឋទូតដំបូងរបស់សហរដ្ឋអាម៉េរិក ក៏បានមកធ្វើការនៅកម្ពុជាផងដែរ ( Charles H. Twining)។

## ២-គោលនយោបាយសំខាន់ៗ សហរដ្ឋអាម៉េរិកចំពោះកម្ពុជា

បេសកកម្មសហរដ្ឋអាម៉េរិកនៅទីក្រុងភ្នំពេញ បានចាប់ផ្តើមឡើងវិញនាថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៩១ ដោយយោងតាមស្មារតីកិច្ចព្រមព្រៀងទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ សហរដ្ឋអាម៉េរិកបានរក្សានូវវត្តមានរូបវន្តរបស់ខ្លួនក្នុងប្រទេសកម្ពុជា។ ទំនាក់ទំនងការទូតពេញលេញក៏បានបង្កើតឡើងបន្ទាន់ផងដែរ ក្រោយប្រទេសកម្ពុជាបានរៀបចំការបោះឆ្នោតដោយសេរីនិងយុត្តិធម៌ ហើយបានរៀបចំរាជរដ្ឋាភិបាល នៅ

---

[៣២] សុខ ទូច, ប៊ុន ធឿន "ទំនាក់ទំនងអន្តរជាតិរវាងកម្ពុជា សហរដ្ឋអាម៉េរិក ចិន និងវៀតណាម" វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា ២០០៧, ទំព័រទី ៣៤។

[៣៣] Gregory Lawless, "**U.S. foreign Policy toward contemporary Cambodia**" February 19, 2008 at the Royal Academy of Cambodia, page 1.

[៣៤] សុខ ទូច, "ទំនាក់ទំនងអន្តរជាតិ រវាង កម្ពុជា សហរដ្ឋអាម៉េរិក ចិន និងវៀតណាម" ដ-ឯ-ម- ទំព័រទី ៣៤។

[៣៥] -ដ- ទំព័រទី ៤០។

[៣៦] សុខ ទូច, "ទំនាក់ទំនងអន្តរជាតិ រវាងកម្ពុជា សហរដ្ឋអាម៉េរិក ចិន និងវៀតណាម" ដ-ឯ-ម- ទំព័រទី ៤៤។

ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។ នៅឆ្នាំ១៩៩៤ ឯកអគ្គរដ្ឋទូតដំបូងរបស់សហរដ្ឋអាម៉េរិក ក៏បានមកធ្វើការនៅកម្ពុជាផងដែរ។

ចាប់ពីឆ្នាំ១៩៩៤ មកដល់បច្ចុប្បន្ន សហរដ្ឋអាម៉េរិកបានចាត់តាំងឯកអគ្គរដ្ឋទូតចំនួន០៦រូប មកបំពេញបេសកកម្មការទូតនៅកម្ពុជា ហើយបេសកកម្មទូតទាំងនោះ ផ្តោតជាពិសេសទៅលើគោលដៅនៃគោលនយោបាយការបរទេសរបស់សរដ្ឋអាម៉េរិកដូចៗគ្នា ពោលគឺ ការពារទឹកដីសហរដ្ឋអាម៉េរិកនិងពលរដ្ឋអាម៉េរិកនៅបរទេស។ សហរដ្ឋអាម៉េរិកចង់មានទំនាក់ទំនងជាមួយកម្ពុជាដោយសន្តិវិធីនិងអភិវឌ្ឍន៍ក្នុងបំណងសម្រេចឱ្យបាននូវសន្តិសុខ ក្នុងតំបន់ និងពិភពលោក។

គោលបំណងសំខាន់របស់សហរដ្ឋអាម៉េរិក នៅក្នុងប្រទេសកម្ពុជាមិនមានលក្ខណៈធំដុំទេ ប៉ុន្តែជាប្រទេសសំខាន់ផ្នែកយុទ្ធសាស្ត្រសម្រាប់សហរដ្ឋអាម៉េរិក ពិសេស ការជំរុញនីតិរដ្ឋ, ប្រជាធិបតេយ្យ, សិទ្ធិមនុស្ស, ទប់ស្កាត់អំពើភេរវកម្ម, ការសម្របសម្រួលពាណិជ្ជកម្ម និងការនាំយកអតីតអ្នកដឹកនាំជាន់ខ្ពស់ សម័យខ្មែរក្រហមទៅកាត់ទោស។ គោលបំណងនេះ ក៏មិនខុសពីគោលបំណងរបស់សហរដ្ឋអាម៉េរិក ចំពោះតំបន់អាស៊ីទាំងមូលដែរ ពោលគឺ ទី១ សន្តិសុខ តាមរយៈការគោរពតាមនីតិរដ្ឋនិងការប្រយុទ្ធប្រឆាំងការគំរាមកំហែងអន្តរជាតិ ដូចជា ភេរវកម្ម គ្រឿង ញៀន ជំងឺអេដស៍ និងជំងឺគ្រុនផ្តាសាយបក្សី។ ទី២ ភាពសម្បូររុងរឿងតាមរយៈសេរីភាពខាងធ្វើពាណិជ្ជកម្មនិងការអភិវឌ្ឍសេដ្ឋកិច្ច។ ទីបី ការគាំទ្រលទ្ធិប្រជាធិបតេយ្យនិងសិទ្ធមនុស្ស[៣៧]។ ទាំងអស់នេះក៏បានឆ្លើយតបនឹងគោលនយោបាយអភិវឌ្ឍន៍សហរដ្ឋអាម៉េរិក ចំពោះពិភពលោកទាំងមូលដែលមាន ១-ការបង្កើនជំនួយផ្នែកហិរញ្ញវត្ថុដល់បណ្តាប្រទេសដែលក្រីក្រ ២-ផ្តល់នូវជំនួយបន្ថែមទៀតនិងការកែទម្រង់ការផ្តល់ជំនួយ ៣-កំណត់នូវលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងផ្តល់ជំនួយឱ្យបានយ៉ាងហ្មត់ចត់ និង៤-កំណត់គោលដៅកិច្ចគាំទ្រដល់បណ្តាប្រទេសនានាដែលមាន យុទ្ធសាស្ត្រនៃការលូតលាស់ជាមុន"[៣៨]។

ចំណែកឯគោលដៅ នៃគោលនយោបាយការបរទេសស្នូលរបស់សហរដ្ឋអាម៉េរិក ចំពោះកម្ពុជានាសហសម័យនេះមាន ៥ចំណុចសំខាន់[៣៩] ៖

១- ការរក្សាឱ្យមានស្ថិរភាព និងសន្តិភាព

២- ការរក្សាសុវត្ថិភាព

៣- ការជំរុញឱ្យមានការរីកចម្រើន

៤- ផ្តោតលើការគំរាកំហែង ដូចជា អំពើភេរវកម្ម

៥- ជំរុញលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស

ដូច្នេះឃើញថា គោលនយោបាយទាំងនេះ កំពុងឆ្លើយតបនឹងបច្ចុប្បន្នភាពនៃកម្ពុជា ដែលរាជរដ្ឋាភិបាលកំពុងរៀបចំបទដ្ឋានគតិយុត្តឱ្យប្រទេសនេះមាននីតិរដ្ឋ ក្នុងបំណងអភិវឌ្ឍប្រទេសឱ្យរីកចម្រើនលឿន។

ម្យ៉ាងទៀត យើងសូមបង្ហាញនូវសកម្មភាព នៃគោលនយោបាយការបរទេសសហរដ្ឋអាម៉េរិកចំពោះកម្ពុជា ដូចខាងក្រោម ៖

---

[៣៧] JosephA. Mossomelli បទឧទ្ទេសនាម ស្តីពី គោលនយោបាយសហរដ្ឋអាម៉េរិកនាពេលអនាគត ចំពោះតំបន់អាស៊ី សណ្ឋាគារភ្នំពេញ ថ្ងៃទី៦ ខែមេសា ឆ្នាំ២០០៦។

[៣៨] -ដ-

[៣៩] Gregory Lawless, "U.S. foreign Policy toward contemporary Cambodia" op.cit, page 2.

ចាប់ពីខែកុម្ភៈ ឆ្នាំ២០០៧ រដ្ឋាភិបាលសហរដ្ឋអាម៉េរិកនឹងផ្តល់ជំនួយរយៈពេល១០ឆ្នាំ ដោយផ្ទាល់ដល់រាជរដ្ឋាភិបាលកម្ពុជា។ ទាំងអស់នេះ គឺជាសញ្ញានៃទំនាក់ទំនងល្អរវាងប្រទេសទាំងពីរ។ ចាប់តាំងពីឆ្នាំ១៩៩៨ មក សហរដ្ឋអាម៉េរិកគ្មានការលាក់លៀមរាល់រូបភាពជំនួយទៅឱ្យរដ្ឋាភិបាលកម្ពុជា ដើម្បីឆ្លើយតបនឹងការគ្រប់គ្រងរបស់សម្តេច ហ៊ុន សែន នាឆ្នាំ១៩៩៧។ សហរដ្ឋអាម៉េរិកនឹងមិនផ្តល់ជំនួយផងដែរ ដល់សាលាជំនុំជម្រះក្តីខ្មែរក្រហម ប្រសិនបើបទដ្ឋានសាលានេះមិនមានលក្ខណៈ ឯករាជ្យ និង យុត្តិធម៌។ បើទោះបីជា មានភាពតានតឹងយ៉ាងនេះក្តី ក៏ប្រទេសកម្ពុជានៅតែជាអ្នកទទួលជំនួយបរទេសដ៏ធំទីបីពីសហរដ្ឋអាម៉េរិក ក្នុងតំបន់អាស៊ីអាគ្នេយ៍ បន្ទាប់ពីប្រទេសឥណ្ឌូណេស៊ីនិងហ្វីលីពីន។ ភាគច្រើននៃជំនួយនេះបានផ្តល់តាមរយៈអង្គការមិនមែនរដ្ឋាភិបាល។ សហរដ្ឋអាម៉េរិកគឺជាទីផ្សារបរទេសដ៏ធំជាងគេ សម្រាប់ទំនិញកម្ពុជា ជាពិសេស សម្លៀកបំពាក់ និងប្រដាប់ប្រដាតែងកាយ។ ប្រទេសកម្ពុជានិងប្រទេសដែលមានការអភិវឌ្ឍទាបច្រើនទៀត កំពុងមានការទទូចសុំឱ្យសហរដ្ឋអាម៉េរិកទទួលយកផលិតផលកាត់ដេររបស់ខ្លួន។ កម្ពុជាក៏បានធ្វើឱ្យប្រសើរឡើង ចំពោះបញ្ហាជាច្រើនដែលទាក់ទងនឹងប្រយោជន៍សហរដ្ឋអាម៉េរិក ក្នុងនោះមានការត្រួតពិនិត្យនៃការរីករាលដាលជំងឺឆ្លង ដូចជា (ជំងឺអេដស៍ និង ជំងឺគ្រុនផ្តាសសាយបក្សី), វិធានការប្រឆាំងនឹងការជួញដូរមនុស្ស, ការអភិវឌ្ឍសង្គមស៊ីវិល, ការជំរុញច្បាប់ការងារ, កិច្ចប្រឹងប្រែងប្រឆាំងភេរវកម្ម និងគោលការណ៍សារពើពន្ធ។ ទាក់ទងនឹងការអភិវឌ្ឍកម្ពុជា សហរដ្ឋអាម៉េរិកបានផ្តល់មូលនិធិប្រមាណ ៧០លានដុល្លារ ដោយផ្តោតលើវិស័យនានា ដូចជា សុខភាព សន្តិភាព និង សុវត្ថិភាព អភិបាលកិច្ចល្អ សិក្សាអប់រំ សិទ្ធិមនុស្ស កំណើនសេដ្ឋកិច្ច និង ការអភិវឌ្ឍ។ល។ ការជំរុញនូវលទ្ធិប្រជាធិបតេយ្យនិងសិទ្ធិមនុស្ស រដ្ឋាភិបាលសហរដ្ឋអាម៉េរិកយកចិត្តទុកដាក់ជា សំខាន់ទៅលើបញ្ហា "នីតិរដ្ឋ" នៅក្នុងប្រទេសកម្ពុជា ដូច្នេះហើយបានជាគាំទ្រខាងផ្នែកហិរញ្ញវត្ថុសម្រាប់ការបោះឆ្នោត ដោយផ្តល់ថវិការាប់រយពាន់ដុល្លារសម្រាប់សកម្មភាពមួយចំនួនដូចជា ការបណ្តុះបណ្តាល ដល់អ្នកឃ្លាំមើលហិបឆ្នោតរបស់គណបក្សនយោបាយ ការរៀបចំកិច្ចពិភាក្សារបស់បេក្ខជនឈរឈ្មោះ វេទិកាស្ត្រីក្នុងភាពជាអ្នកដឹកនាំនិងគាំទ្របេសសម្ព័ន្ធអង្គការជាតិ អន្តរជាតិក្នុងការតាមដានឃ្លាំមើលការបោះឆ្នោត។ លើសពីនេះទៀត មន្ត្រីស្ថានទូតសហរដ្ឋអាម៉េរិកបានចុះធ្វើការងារនៅទូទាំងប្រទេសកម្ពុជា ដើម្បីអង្កេត តាមស្ថានីយ៍បោះឆ្នោតដែលបានប្រព្រឹត្តទៅនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨។ ក្រៅពីនេះភាពប្រសើរឡើងយ៉ាងឆាប់រហ័សរវាងទំនាក់ទំនងកិច្ចសហប្រតិបត្តិការកម្ពុជា-សហរដ្ឋអាម៉េរិក មានការកើនឡើងស្ទើរគ្រប់វិស័យ ធ្វើឱ្យទំនាក់ទំនងទ្វេភាគី រវាងប្រទេសទាំងពីរឆ្ពោះទៅមុខជានិច្ច ដូចជា នៅឆ្នាំ២០០៧ កម្ពុជាបានស្វាគមន៍នាវាសហរដ្ឋអាម៉េរិកពីរគ្រឿង ហើយដែលការទទួលស្វាគមន៍លើកទី១ មានតាំងពីជាង៣០ឆ្នាំ កន្លងមកម្ល៉េះ។ នាពេលនេះ មានការសម្ពោធកម្មវិធីអង្គសន្តិភាព (Peace Corps Program). ដោយមានការជំរុញលើកទឹកចិត្ត និង ការផ្តល់ជំនួយពីសហរដ្ឋអាម៉េរិក កម្ពុជាមានជំហរទទួលខុសត្រូវលើឆាកអន្តរជាតិ ដូចជា ការបញ្ជូនក្រុមដោះមីនទៅប្រទេសស៊ូដង់ (Sudan) ក្នុងនាមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហ-ប្រជាជាតិ។

ទំនាក់ទំនងទ្វេភាគីរវាងប្រទេសទាំងពីរកាន់តែមានភាពប្រសើរឡើងយ៉ាងឆាប់រហ័ស ជាពិសេសនៅក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ។ ទោះបីជាសហរដ្ឋអាម៉េរិកយល់ឃើញថា ប្រទេសកម្ពុជាមានការលំបាកនៅក្នុងដំណើរការរដ្ឋាភិបាលប្រជាធិបតេយ្យក៏ដោយ ក៏សហរដ្ឋអាម៉េរិកមើលឃើញថា កម្ពុជាមានការអភិវឌ្ឍជាវិជ្ជមាននៅលើវិស័យជាច្រើន ដូចជាការពង្រឹងសង្គមស៊ីវិលនិងដំណើរការលទ្ធិប្រជាធិបតេយ្យ កំណើន

សេដ្ឋកិច្ចយ៉ាងលឿន ភាពប្រសើរឡើងក្នុងកិច្ចការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សនិងការកើនឡើងនូវការអធ្យាស្រ័យខាងផ្នែកសាសនា។ ក្នុងជំនាន់ថ្មីនេះ គឺជាដំណាក់កាលនៃដំណោះស្រាយក្នុងការប្រឈមមុខនឹងគ្នាបែបការទូត តាម រយៈការពឹងផ្អែកទៅលើបទដ្ឋានថ្មីនៃការយោគយល់គ្នាជាលក្ខណៈរួមរបស់កិច្ចការពិភពលោកទាំងមូល។

## សន្និដ្ឋាន

ទំនាក់រវាងប្រទេសមួយនិងប្រទេសមួយ គឺជាការចាំបាច់ណាស់សម្រាប់ប្រទេសនីមួយៗ ក្នុងសម័យសាកលូបនីយកម្ម ប៉ុន្តែ លទ្ធផលឬផលប៉ះពាល់អវិជ្ជមានក៏កើតមានច្រើនដែរ ចំពោះប្រទេសកំពុងអភិវឌ្ឍឬការអភិវឌ្ឍនៅមានភាពទន់ខ្សោយ។ ទំនាក់ទំនងអន្តរជាតិជំរុញឱ្យប្រទេសមួយងាយធ្វើសមាហរណកម្មក្នុងតំបន់និងពិភពលោកដែលជាកត្តាចម្បងក្នុងការជំរុញអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ជាក់ស្តែង ទំនាក់ទំនងកម្ពុជា-សហរដ្ឋអាម៉េរិក ដែលធ្វើឱ្យសហរដ្ឋអាម៉េរិកផ្តល់ជំនួយដោយផ្ទាល់ដល់រដ្ឋាភិបាលកម្ពុជា ដើម្បីឆ្លើយតបឱ្យចំគោលនយោបាយការបរទេសរបស់ខ្លួន ចំពោះប្រទេសកម្ពុជា។ ជាមួយនេះផងដែរ ក៏គួរនាំគ្នាគិតថា សហរដ្ឋអាម៉េរិក មានមហិច្ឆតាធំណាស់ មិនមែនសម្រាប់តែកម្ពុជាទេ។ ដើម្បីសម្រេចគោលនយោបាយការបរទេសរបស់ខ្លួនក្នុងពិភពលោកនិងតំបន់អាស៊ី ពិសេស តំបន់អាស៊ីអាគ្នេយ៍ អាម៉េរិកបានយកកម្ពុជាជាទីតាំងយុទ្ធសាស្ត្រដើម្បីទប់ទល់អំពើភេរវកម្មក្នុងតំបន់អាស៊ាន, ពង្រឹងលទ្ធិប្រជាធិបតេយ្យនិងសិទ្ធិមនុស្ស ទីផ្សារសេដ្ឋកិច្ច និងដើម្បីបង្ហាញនូវមោទកភាពអាម៉េរិកក្នុងឆាកអន្តរជាតិផងដែរ ដូចប្រសាសន៍របស់លោក ចូសេដ មូសូមេលី Joseph A. Mossomelli ឯកអគ្គរដ្ឋទូតសហរដ្ឋអាម៉េរិក ប្រចាំប្រទេសកម្ពុជាថា "នៅលើបញ្ហាសន្តិសុខតំបន់ និងកិច្ចសហប្រតិបត្តិការជាមួយអាស៊ាន គឺតំបន់អាស៊ីអាគ្នេយ៍បន្តទៅធ្វើឱ្យក្លាយកន្លែងមួយដែលគួរឱ្យទាក់ទាញនៃកិច្ចប្រតិបត្តិការប្រឆាំងអង្គការភេរវករ ដូចជា ជីម៉ាស់អ៊ីស្លាមីយ៉ាស់ និង ក្រុមអាប៊ូសៃយ៉ាហ្វ។ សហគមន៍អាស៊ានបានគាំទ្រយ៉ាងខ្លាំងក្លានូវការពង្រីកនៃសមត្ថភាពប្រឆាំងភេរវកម្មនៅក្នុងតំបន់។ សហរដ្ឋអាម៉េរិកបានចាប់អារម្មណ៍ ចំពោះកិច្ចសហប្រតិបត្តិការប្រឆាំងភេរវកម្មដ៏ល្អប្រសើររបស់រដ្ឋាភិបាលកម្ពុជា ហើយសូមកោតសរសើរយ៉ាងខ្លាំងចំពោះភាពជាដៃគូបែបនេះ។ គោលបំណងចុងក្រោយរបស់សហរដ្ឋអាម៉េរិក គឺធ្វើឱ្យខូចខាតនូវចំណុចសំខាន់នៃភាពអង់អាចរបស់ភេរវករ លុបបំបាត់ចោលកន្លែងជ្រកកោន កិច្ចសហប្រតិបត្តិការតំបន់ដែលបង្កើតឡើងនិងលុបបំបាត់ចោលភាពរីកចម្រើន ដោយធ្វើឱ្យអន់ថយនូវកត្តាចូលរួមនានា ព្រមទាំងលុបបំបាត់ចោលនូវអំពើអយុត្តិធម៌ ភាពក្រីក្រ ភាពអត់ការងារធ្វើ ការអប់រំទន់ខ្សោយ និងអំពើពុករលួយ[៤០]។ ត្រង់នេះបញ្ជាក់ឱ្យឃើញថា បើគ្មានប្រយោជន៍អ្វី សហរដ្ឋអាម៉េរិកមិនងាយបញ្ចេញប្រាក់របស់ខ្លួនដល់ប្រទេសណាមួយទេ។ ដូច្នេះ បញ្ហាធំ គឺគ្មានអ្វីក្រៅពីការខំប្រឹងដោយខ្លួនឯង ទើបអាចជួយកិត្តិយសខ្លួនឯងបានក្នុងឆាកអន្តរជាតិ។

តែទោះបីជាយ៉ាងណាក៏ដោយ អ្វីដែលអាចធ្វើឱ្យប្រទេសមួយនឹងប្រទេសមួយ ប្រជាជាតិនិងប្រជាជាតិ មានចំណងអនុស្សាវរីយ៍នឹងគ្នានោះ គឺការបន្សល់ទុកនូវទំនាក់ទំនងល្អរវាងប្រទេសទាំងពីរ ឱ្យស្ថិតស្ថេរយូរអង្វែង។ នៅទីបំផុតនោះ ដើម្បីឱ្យគោលនយោបាយនៃប្រទេសទាំងពីរ ឈានទៅដល់គោលដៅរួមជាមូលដ្ឋាន គឺទំនាក់ទំនងទ្វេរភាគីដែលស្តែងចេញឱ្យឃើញនូវមិត្តភាព ការយោគយល់គ្នា ចិត្តបុណ្យ មេត្តាករុណា និងមានបំណងល្អនឹងគ្នា ស្មើមុខគ្នានិងជួយគ្នាទៅវិញទៅមក។

---

[៤០] JosephA. Mossomelli បទឧទ្ទេសនាម ស្តីពី គោលនយោបាយសហរដ្ឋអាម៉េរិកនាពេលអនាគត ចំពោះតំបន់អាស៊ី ជ-ឯ-ម-។

# គ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជា



អ៊ុក វិបុល
បេក្ខជនបណ្ឌិតវគ្គទី២ ផ្នែកវិទ្យាសាស្ត្រអប់រំ
នៃរាជបណ្ឌិត្យសភាកម្ពុជា

## ១- បញ្ហាប្រឈមសំខាន់ៗនៅតាមគ្រឹះស្ថានឧត្តមសិក្សា

ការវិភាគលើលទ្ធផលនៃការចុះវាយតម្លៃថ្នាក់ឆ្នាំសិក្សាមូលដ្ឋានមានសារៈសំខាន់ណាស់ ពីព្រោះការវិភាគនេះបានបង្ហាញឱ្យឃើញនូវចំណុចខ្វះខាតដែលកើនមានឡើង នៅក្នុងការបណ្តុះបណ្តាលថ្នាក់ឆ្នាំសិក្សាមូលដ្ឋាននៅតាមគ្រឹះស្ថានឧត្តមសិក្សា ហើយចំណុចទាំងអស់នេះវាឆ្លុះបញ្ចាំងឱ្យឃើញពីបញ្ហាដែលកើនមានឡើងនៅក្នុងការបណ្តុះបណ្តាលជំនាញទេសចរណ៍ នៅតាមគ្រឹះស្ថានឧត្តមសិក្សាផងដែរ ពីព្រោះ *ការបណ្តុះបណ្តាលគ្រប់មុខជំនាញទាំងអស់នៅក្នុងឆ្នាំទីមួយនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋានទាំងការរៀបចំផែនការយុទ្ធសាស្ត្រ សម្រាប់ការបណ្តុះបណ្តាល, ការប្រើប្រាស់សម្ភារៈបរិក្ខារអប់រំ, ការជ្រើសរើសគ្រូបង្រៀន, ថ្នាក់រៀន, បណ្ណាល័យ និង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្មវិធីសិក្សា មិនបានបែងចែកឱ្យដាច់ចេញពីមហាវិទ្យាល័យនីមួយៗដោយឡែកពីគ្នានោះទេ។* ដូច្នេះការវិភាគទៅលើលទ្ធផលនៃការចុះវាយតម្លៃនេះ ពិតជាឆ្លុះបញ្ចាំងឱ្យឃើញពីចំណុចខ្វះខាត ក្នុងការបណ្តុះបណ្តាលជំនាញទេសចរណ៍ពិតប្រាដកមែន។ ការវិភាគនេះត្រូវរៀបចំឡើងតាមវិធីសាស្ត្របែបបរិមាណវិស័យ ដើម្បីចង់ដឹងអំពីបញ្ហាអ្វីខ្លះដែលប្រឈមខ្លាំងជាងគេនៅក្នុងការបណ្តុះបណ្តាលថ្នាក់ឆ្នាំសិក្សាមូលដ្ឋាននៅតាមគ្រឹះស្ថានអប់រំឧត្តមសិក្សាសាធារណៈនិងឯកជន នាពេលបច្ចុប្បន្ននេះ និង ចង់ដឹងអំពីបញ្ហាអ្វីខ្លះ ដែលកើតមានឡើងច្រើនជាងគេ នៅក្នុងលក្ខណៈវិនិច្ឆ័យនីមួយៗនៃថ្នាក់ឆ្នាំសិក្សាមូលដ្ឋានគឺ រចនាសម្ព័ន្ធគ្រប់គ្រងថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ការរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ការបណ្តុះបណ្តាល ការអភិវឌ្ឍកម្មវិធីសិក្សា ធនធានគ្រូបង្រៀន សម្ភារៈបរិក្ខារអប់រំ និង ការជ្រើសរើសនិស្សិតឱ្យចូលរៀន។

### ១.១- បញ្ហាប្រឈមសំខាន់ៗនៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ

តាមលទ្ធផលនៃការចុះវាយតម្លៃ ឆ្នាំសិក្សា ២០០៩-២០១០ លើគ្រឹះស្ថានឧត្តមសិក្សាសាធារណៈដែលមានការបណ្តុះបណ្តាលថ្នាក់ឆ្នាំសិក្សាមូលដ្ឋានចំនួន១០ បានបង្ហាញឃើញថា បញ្ហាប្រឈមនៅតាមគ្រឹះស្ថានឧត្តមសិក្សាទាំងអស់ចំនួន១០៤ចំណុច ក្នុងនោះមានដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន១១ចំណុច ត្រូវនឹង ១០.៥៧% ផែនការយុទ្ធសាស្ត្រនៃថ្នាក់ឆ្នាំសិក្សាមូលដ្ឋានចំនួន១៥ចំណុច ត្រូវនឹង ១៤.៤២% កម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋានចំនួន២៧ចំណុច ត្រូវនឹង ២៥.៩៦% ធនធានគ្រូបង្រៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋានចំនួន២៣ចំណុច ត្រូវនឹង ២២.១១% សម្ភារៈរូបវន្ត និងធនធានសិក្សា ចំនួន២៤ចំណុច ត្រូវនឹង ២៣.០៧% និងការជ្រើសរើសនិស្សិតឱ្យចូលរៀនចំនួន៤ចំណុច ត្រូវនឹង ៣.៨៤%។ ដូច្នេះ តាមរយៈក្រាបសសរនៃការចុះវាយតម្លៃខាងក្រោមបានបង្ហាញឱ្យឃើញថា គ្រឹះស្ថានឧត្តមសិក្សាមានចំណុចខ្វះខាតចម្បងៗលើការបណ្តុះបណ្តាលរបស់ខ្លួនចំនួន៣គឺ កម្មវិធីសិក្សា, ធនធានគ្រូបង្រៀននិងសម្ភារូបវន្ត ហើយចំណុចនីមួយៗមានចំណុចខ្វះខាតដូចខាងក្រោមនេះ ៖

១. បញ្ហាប្រឈមនៅក្នុងដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋានមានដូចជា ការអនុវត្តន៍តួនាទីភារកិច្ចរបស់មន្ត្រីទទួលបន្ទុកថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន មន្ត្រីទទួលបន្ទុកថ្នាក់ឆ្នាំសិក្សាថ្នាក់មូលដ្ឋានមិនគ្រប់គ្រាន់ ការិ-

យាល័យ ថ្នាក់ឆ្នាំសិក្សាមូលដ្ឋានតូចចង្អៀត នីតិវិធី និងលក្ខខណ្ឌជ្រើសរើសមន្ត្រីដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន រចនាសម្ព័ន្ធគ្រប់គ្រង និង ការកំណត់តួនាទីភារកិច្ច ការរៀបចំទុកដាក់ឯកសាររបស់និស្សិត និងការតែងតាំង។

២. បញ្ហាប្រឈមនៅក្នុងផែនការយុទ្ធសាស្ត្រមានដូចជា ផែនការសកម្មភាពមិនច្បាស់លាស់ ការផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រ ការរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពមិនច្បាស់លាស់ មិនបានអនុវត្តផែនការសកម្មភាព និងខ្វះយន្តការតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រ។

៣. បញ្ហាប្រឈមនៅក្នុងកម្មវិធីសិក្សារួមមានដូចជាក្រុមប្រឹក្សាអភិវឌ្ឍន៍កម្មវិធីសិក្សា (គោលការណ៍គុណវុឌ្ឍិសិក្សា ការជ្រើសរើស តួនាទីភារកិច្ច ) ការបង្រៀនមិនស្របតាមកម្មវិធីសិក្សាដែលមាន ការវាយតម្លៃលើការសិក្សារបស់និស្សិត, វិធីនៃការបង្រៀន, ការសិក្សា និងការស្រាវជ្រាវ, កម្មវិធីសិក្សាមិនបានបញ្ចូលបញ្ហាប្រឈមរបស់សង្គម, លទ្ធផលនៃការសិក្សារបស់និស្សិត។

៤. បញ្ហាប្រឈមនៅក្នុងធនធានគ្រូបង្រៀនរួមមានដូចជា ការវាយតម្លៃគ្រូបង្រៀន ការអភិវឌ្ឍគ្រូបង្រៀន, កិច្ចសន្យាជាមួយគ្រូបង្រៀន, ប្លង់មេរៀន, ការវាយតម្លៃគ្រូបង្រៀន, ការបង្រៀនខុសជំនាញ, បទពិសោធន៍និងគុណវុឌ្ឍិគ្រូបង្រៀន, ការជ្រើសរើសគ្រូបង្រៀន ផលធៀបគ្រូនិងនិស្សិត, ប្រាក់ម៉ោងបង្រៀន។

៥. បញ្ហាប្រឈមនៅក្នុងសម្ភារបរិក្ខារអប់រំមានដូចជា បន្ទប់សិក្សា, កុំព្យូទ័រ, អ៊ីនធឺណិត, បន្ទប់ស្តាប់ភាសា, ការចូលអនុវត្តកុំព្យូទ័រ, ទស្សនាវដ្តីក្នុងបណ្ណាល័យ, សៀវភៅនិងឯកសារចងក្រងនៃមុខវិជ្ជានីមួយៗ, បណ្ណាល័យតូចចង្អៀត, សៀវភៅ និងឯកសារយោងនៅក្នុងបណ្ណាល័យ, បណ្ណារក្ស, បរិយាកាសក្នុងបណ្ណាល័យ សម្ភារៈប្រើប្រាស់ក្នុងបន្ទប់ពិសោធន៍, សេវាបណ្ណាល័យ។

៦. បញ្ហាប្រឈមនៅក្នុងការជ្រើសរើសនិស្សិតមានដូចជា ការផ្សព្វផ្សាយគោលការណ៍ផ្ទេរ និងទទួលនិស្សិត គោលការណ៍ជ្រើសរើសនិស្សិតចូលរៀន និងគោលការណ៍ផ្ទេរ និងទទួលនិស្សិតមិនច្បាស់លាស់។

តាមលទ្ធផលនៃការចុះវាយតម្លៃ និងតាមការចង្អុលបង្ហាញរបស់ក្រាបសសរខាងក្រោមបានបង្ហាញឱ្យឃើញថាគ្រឹះស្ថានឧត្តមសិក្សាសាធារណៈកំពុងប្រឈមនឹងបញ្ហា ក្នុងការបណ្តុះបណ្តាលថ្នាក់ឆ្នាំសិក្សាមូល-ដ្ឋានចំនួន៦សំខាន់ៗ គឺ ការគ្រប់គ្រងដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ការរៀបចំផែនការយុទ្ធសាស្ត្រ កម្ម-វិធីសិក្សា ធនធានគ្រូបង្រៀន ហេដ្ឋារចនាសម្ព័ន្ធបរិក្ខារអប់រំ និង ការជ្រើសរើសនិស្សិតចូលរៀន។ ប៉ុន្តែក្នុងចំណោមបញ្ហាទាំង៦នេះ បញ្ហាដែលសំខាន់ជាងគេគឺ កម្មវិធីសិក្សាដែលមានចំណុចខ្វះខាតចំនួន២៧ ត្រូវនឹង ២៥.៩៦% បញ្ហាទី២គឺ ហេដ្ឋារចនាសម្ព័ន្ធបរិក្ខារអប់រំមានចំណុចខ្វះខាតចំនួន២៤ ត្រូវនឹង ២៣.០៧% បញ្ហាទី៣គឺ ធនធានគ្រូបង្រៀន មានចំណុចខ្វះខាតចំនួន២៣ ត្រូវនឹង ២២.១១% បញ្ហាទី៤គឺ ការរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ការបណ្តុះបណ្តាលមានចំណុចខ្វះខាតចំនួន១៥ ត្រូវនឹង ១៤.៤២% បញ្ហាទី៥គឺ ការគ្រប់គ្រងដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន មានចំណុចខ្វះខាតចំនួន១១ ត្រូវនឹង ១០.៥៧% និង បញ្ហាទី៦ គឺ ការជ្រើសរើសនិស្សិតចូលរៀន មានចំណុចខ្វះខាតចំនួន៤ ត្រូវនឹង ៣.៨៤%។

ដូច្នេះ បញ្ហាទាំង៦ខាងលើនេះ ជាបញ្ហាចម្បងសម្រាប់គ្រឹះស្ថានឧត្តមសិក្សាសាធារណៈទាំងអស់ត្រូវកែលម្អ ដើម្បីពង្រឹងគុណភាពអប់រំនៅក្នុងគ្រឹះស្ថានរបស់ខ្លួនឱ្យកាន់តែល្អប្រសើរឡើង។ តាមលទ្ធផលវិភាគ

ខាងលើគ្រឹះស្ថានឧត្តមសិក្សាត្រូវយកចិត្តទុកដាក់ឱ្យបានខ្លាំងទៅលើការកែលម្អកម្មវិធីសិក្សា ហេដ្ឋារចនាសម្ព័ន្ធបរិក្ខារអប់រំ និងធនធានគ្រូបង្រៀនជាមុនសិន និងបន្ទាប់មកទៀតត្រូវយកចិត្តទុកដាក់ទៅលើការរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ការបណ្តុះបណ្តាល ការគ្រប់គ្រង និងការជ្រើសរើសនិស្សិតឱ្យចូលរៀន។ ចំណុចខ្វះ-ខាតលម្អិតៗនៅក្នុងបញ្ហាទាំង៦នេះ ខ្ញុំនឹងព្យាយាមបង្ហាញនៅក្នុងទំព័រខាងក្រោមបន្ថែមទៀត។

**ក្រាបសរសេរស្តីពីបញ្ហាប្រឈមសំខាន់ៗនៅតាមគ្រឹះស្ថានសាធារណៈ**




## ១.២- បញ្ហាប្រឈមសំខាន់ៗនៅតាមគ្រឹះស្ថានឧត្តមសិក្សាឯកជន

តាមលទ្ធផលនៃការចុះវាយតម្លៃ ឆ្នាំសិក្សា២០០៩-២០១០ ចំពោះគ្រឹះស្ថានឧត្តមសិក្សាឯកជនដែលមានការបណ្តុះបណ្តាលថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ចំនួន៤៣ បានបង្ហាញឃើញថាបញ្ហាប្រឈមនៅតាមគ្រឹះ-ស្ថានឧត្តមសិក្សាទាំងអស់ចំនួន៣៥៩ចំណុចក្នុងនោះមានការគ្រប់គ្រងដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន៤៣ ចំណុច ត្រូវនឹង ១២.៧៤%, ការរៀបចំផែនការយុទ្ធសាស្ត្រនៃថ្នាក់ឆ្នាំសិក្សាមូលដ្ឋានចំនួន៥៣ចំណុច ត្រូវនឹង ១៤.៧៦%, កម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋានចំនួន៨៦ចំណុច ត្រូវនឹង ២៣.៩៥%, ធនធានគ្រូបង្រៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋានចំនួន៧០ចំណុច ត្រូវនឹង ១៩.៤៩%, សម្ភារៈរូបវន្ត និងធនធានសិក្សា ចំនួន៨៩ចំណុច ត្រូវនឹង ២៤.៧៩%, និងការជ្រើសរើសនិស្សិតចូលសិក្សាចំនួន១៨ចំណុច ត្រូវនឹង ៥.០១%។ ដូច្នេះតាមរយៈដ្យាក្រាមនៃការចុះវាយតម្លៃខាងក្រោមនេះបានបង្ហាញឃើញថាគ្រឹះស្ថានឧត្តមសិក្សាមានចំណុចខ្វះខាតចម្បងៗលើការបណ្តុះបណ្តាលរបស់ខ្លួនចំនួន៣គឺ កម្មវិធីសិក្សា, ធនធានគ្រូបង្រៀននិងសម្ភាររូបវន្តដូចសាធារណៈផងដែរ ហើយចំណុចនីមួយៗមានចំណុចខ្វះខាតដូចខាងក្រោមនេះ ៖

១. បញ្ហាប្រឈមនៅក្នុងដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋានមាន ដូចជា រចនាសម្ព័ន្ធថ្នាក់ឆ្នាំសិក្សាមូលដ្ឋានមិនច្បាស់លាស់, ការកំណត់តួនាទីភារកិច្ចរបស់មន្ត្រីទទួលបន្ទុកថ្នាក់ឆ្នាំសិក្សាមូលដ្ឋានមិនច្បាស់

លាស់, មន្ត្រីទទួលបន្ទុកថ្នាក់ឆ្នាំសិក្សាមូលដ្ឋានខ្វះបទពិសោធន៍និងមានគុណវុឌ្ឍិសិក្សាទាប, មិនទាន់មានការតែងតាំងមន្ត្រីទទួលបន្ទុកថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន គោលការណ៍ និងនីតិវិធីជ្រើសរើសមន្ត្រីទទួលបន្ទុកថ្នាក់ឆ្នាំសិក្សាមូលដ្ឋានមិនទាន់ច្បាស់លាស់, បទពិសោធន៍ប្រធានដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋានមិនសមស្រប, មន្ត្រីទទួលបន្ទុកថ្នាក់ឆ្នាំសិក្សាមូលដ្ឋានមិនគ្រប់គ្រាន់, ខ្វះយន្តការវាយតម្លៃតាមការអនុវត្តតួនាទីភារកិច្ចរបស់មន្ត្រីទទួលបន្ទុកថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន, ខ្វះការរៀបចំទុកដាក់ឯកសារព័ត៌មានរបស់និស្សិតឱ្យបានត្រឹមត្រូវ, សមត្ថភាពរបស់មន្ត្រីទទួលបន្ទុកថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន, ការិយាល័យតូចចង្អៀតគ្មានស្លាកសញ្ញាសម្រាប់សម្គាល់ដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន។

២. បញ្ហាប្រឈមនៅក្នុងផែនការយុទ្ធសាស្ត្រមានដូចជា ការកំណត់បេសកកម្ម គោលដៅ និងវត្ថុបំណងមិនបានច្បាស់លាស់, ការកំណត់សកម្មភាពដើម្បីសម្រេចគោលដៅរបស់គ្រឹះស្ថានឧត្តមសិក្សា, មិនបានផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រ, ខ្វះយន្តការវាយតម្លៃលើការអនុវត្តផែនការសកម្មភាព, មានផែនការយុទ្ធសាស្ត្រតែមិនមានផែនការសកម្មភាពប្រចាំឆ្នាំនីមួយៗ, របៀបបង្កើតផែនការយុទ្ធសាស្ត្រមិនបានបង្ហាញលទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រ, មានផែនការសកម្មភាពតែមិនបានអនុវត្តទៅតាមផែនការនោះ, មិនទាន់ចេះបង្កើតផែនការយុទ្ធសាស្ត្រ។

៣. បញ្ហាប្រឈមនៅក្នុងកម្មវិធីសិក្សាមានដូចជា គោលការណ៍ នីតិវិធី និងវិធីសាស្ត្រនៃការបង្រៀនមិនច្បាស់លាស់, ខ្វះការផ្សព្វផ្សាយកម្មវិធីសិក្សា, ការវាយតម្លៃលើការសិក្សាមិនស្របគ្នា, សៀវភៅសិក្សាមិនស្របនឹងកម្មវិធីសិក្សា, ខ្វះគោលការណ៍ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្មវិធីសិក្សា, នៅក្នុងថ្នាក់រៀនមានចំនួននិស្សិតច្រើន, សៀវភៅសិក្សាមិនមានលក្ខណៈត្រឹមត្រូវ, ការផ្សព្វផ្សាយលទ្ធផលនៃការវាយតម្លៃលើការសិក្សារបស់និស្សិតមិនទាន់ពេលវេលា, ខ្វះការផ្តល់ប្លង់មេរៀនឱ្យនិស្សិតមុននឹងបង្រៀន, ខ្វះយន្តការតាមដានវត្តមានរបស់និស្សិត, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្មវិធីសិក្សាមិនបានអនុវត្តតាមតួនាទីភារកិច្ចរបស់ខ្លួនដែលបានកំណត់, កម្មវិធីសិក្សាមិនបានបញ្ចូលបញ្ហាប្រឈមរបស់សង្គមនាពេលបច្ចុប្បន្ន, មិនបានកំណត់ម៉ោងសិក្សាទ្រឹស្តីនិងម៉ោងសិក្សាប្រតិបត្តិ, សមាសភាពក្រុមប្រឹក្សាអភិវឌ្ឍន៍កម្មវិធីសិក្សាមិនសមស្រប។

៤. បញ្ហាប្រឈមនៅក្នុងធនធានគ្រូបង្រៀនមានដូចជា ខ្វះការវាយតម្លៃលើការបង្រៀនរបស់គ្រូបង្រៀន, ខ្វះកម្មវិធីអភិវឌ្ឍន៍គ្រូបង្រៀន, កិច្ចសន្យាមិនមានលក្ខណៈច្បាស់លាស់, ខ្វះគ្រូបង្រៀន, ខ្វះគោល-ការណ៍ដំឡើងប្រាក់ឈ្នួលដល់គ្រូបង្រៀន, ខ្វះយន្តការជ្រើសរើសគ្រូ គ្រូបង្រៀនខ្វះបទពិសោធន៍ និងគុណវុឌ្ឍិសិក្សាមិនសមស្រប, ផលធៀបគ្រូនិងនិស្សិតមិនសមស្រប, បង្រៀនខុសមុខជំនាញ, ខ្វះគរុកោសល្យក្នុងការបង្រៀន។

៥. បញ្ហាប្រឈមនៅក្នុងធនធានគ្រូបង្រៀនមានដូចជា កុំព្យូទ័រមានល្បឿនយឺតហើយចាស់ៗ, ខ្វះកុំព្យូទ័រ និង LCD នៅក្នុងថ្នាក់រៀន, នៅក្នុងបណ្ណាល័យមានសៀវភៅតិចតួច, ខ្វះបន្ទប់ពិសោធន៍សម្រាប់មុខវិជ្ជាវិទ្យាសាស្ត្រ, ខ្វះសៀវភៅ និងឯកសារយោង, អ៊ីនធឺណិតមានល្បឿនយឺត និងមិនគ្រប់គ្រាន់សម្រាប់និស្សិតប្រើប្រាស់, បណ្ណាល័យមានទំហំតូច, ខ្វះបន្ទប់ស្តាប់ភាសា, មានកុំព្យូទ័រមិនគ្រប់គ្រាន់សម្រាប់និស្សិតសិក្សាអនុវត្ត, បណ្ណារក្សគ្មានជំនាញផ្នែកបណ្ណាល័យ, បន្ទប់ស្តាប់ភាសានៅជាមួយបន្ទប់កុំព្យូទ័រ ឬ បណ្ណា-ល័យ, គ្មានបញ្ជាផ្ទៃក្នុងសម្រាប់ប្រើប្រាស់បណ្ណាល័យ, ខ្វះការគ្រប់គ្រងសៀវភៅ និងឯកសារសិក្សានៅក្នុងបណ្ណាល័យជាប្រព័ន្ធ, បន្ទប់សិក្សាមិនត្រូវនឹងនិយាមគរុកោសល្យ។

៦. បញ្ហាប្រឈមនៅក្នុងការជ្រើសរើសនិស្សិតមានដូចជា ការផ្សព្វផ្សាយគោលការណ៍ផ្ទេរ និងទទួលនិស្សិតមានកម្រិតទាប, គោលការណ៍ផ្ទេរ និងទទួលនិស្សិតមិនច្បាស់លាស់ ការប្រឡងចូលរៀនមិនច្បាស់លាស់, ខ្វះការធ្វើតេស្តវាស់ស្ទង់កម្រិតយល់ដឹងរបស់និស្សិតដើម្បីចូលរៀន។

ដូច្នេះ បញ្ហាទាំង៦ខាងលើនេះ ជាបញ្ហាចម្បងសម្រាប់គ្រឹះស្ថានឧត្តមសិក្សាឯកជនទាំងអស់ត្រូវកែលម្អ ដើម្បីពង្រឹងគុណភាពអប់រំនៅក្នុងគ្រឹះស្ថានរបស់ខ្លួនឱ្យកាន់តែល្អប្រសើរឡើង។ តាមលទ្ធផលវិភាគខាងលើគ្រឹះស្ថានឧត្តមសិក្សាត្រូវយកចិត្តទុកដាក់ឱ្យបានខ្លាំង ជាដំបូងទៅលើការកែលម្អហេដ្ឋារចនាសម្ព័ន្ធបរិក្ខារអប់រំ, កម្មវិធីសិក្សា និងធនធានគ្រូបង្រៀនជាមុនសិន និងបន្ទាប់មកទៀតត្រូវយកចិត្តទុកដាក់ទៅលើការរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ការបណ្តុះបណ្តាល ការគ្រប់គ្រង និងការជ្រើសរើសនិស្សិតឱ្យចូលរៀន។ ចំណុចខ្វះខាតលម្អិតៗនៅក្នុងបញ្ហាទាំង៦នេះ ខ្ញុំនឹងព្យាយាមបង្ហាញនៅក្នុងទំព័រខាងក្រោមបន្ថែមទៀត។

**ក្រាបសសរស្តីពីបញ្ហាប្រឈមសំខាន់ៗនៅក្នុងគ្រឹះស្ថានឧត្តមសិក្សាឯកជន**




ដូច្នេះ គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជនបច្ចុប្បន្នកំពុងប្រឈមនឹងបញ្ហាសំខាន់ៗនៅក្នុងដំណើរការបណ្តុះបណ្តាលថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន(ឆ្នាំទី១)ចំនួន៦គឺ ការគ្រប់គ្រងដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ការរៀបចំផែនការយុទ្ធសាស្ត្រ ការអភិវឌ្ឍកម្មវិធីសិក្សា ធនធានគ្រូបង្រៀន ហេដ្ឋារចនាសម្ព័ន្ធ បរិក្ខារអប់រំ និងការជ្រើសរើសនិស្សិតចូលរៀន។ ខាងក្រោមនេះជាចំណុចខ្វះខាតដែលកើតមានឡើងនៅក្នុងបញ្ហាប្រឈមទាំង៦ខាងលើនេះ។

### ១.៣- បញ្ហាប្រឈមនៅក្នុងការអភិវឌ្ឍកម្មវិធីសិក្សា

តាមលទ្ធផលនៃការចុះវាយតម្លៃលើកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ឆ្នាំ២០០៩-២០១០ របស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា លើគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជនចំនួន

៥៣ ដែលផ្តោតទៅលើចំណុចសំខាន់ៗចំនួនប្រាំមួយនិងបានបង្ហាញឱ្យឃើញថា គ្រឹះស្ថានឧត្តមសិក្សាមានបញ្ហាប្រឈមនៅក្នុងការរៀបចំ និងការអនុវត្តកម្មវិធីសិក្សាចំនួន១២០ចំណុច ដូចជាក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ម-វិធីសិក្សាចំនួន១៥ចំណុច ត្រូវនឹង ១២.៥០% ការអនុវត្តកម្មវិធីសិក្សាចំនួន៣៨ចំណុច ត្រូវនឹង ៣១.៧០% ចំនួនម៉ោងនៃមុខវិជ្ជានីមួយៗចំនួន៤ចំណុច ត្រូវនឹង ៣.៣០% វិធីសាស្ត្រនៃការបង្រៀនចំនួន៣៥ចំណុច ត្រូវនឹង ២៩.២០% ការផ្សព្វផ្សាយចំនួន៩ចំណុច ត្រូវនឹង៧.៥០% ការធ្វើសិក្ខាសាលាចំនួន១៣ចំណុច ត្រូវនឹង ១០.៨០% និងផ្សេងៗចំនួន៦ចំណុច ត្រូវនឹង ៥.០០%។ តាមការវិភាគទិន្នន័យតាមក្រាបសសរនៃលទ្ធផលចុះវាយតម្លៃខាងក្រោមបានបង្ហាញឱ្យឃើញថា បញ្ហាប្រឈមសំខាន់ៗជាងគេ នៅក្នុងការរៀបចំផែនការយុទ្ធសាស្ត្រមានចំនួន២ ហើយចំណុចនីមួយៗមានចំណុចខ្វះខាតដូចខាងក្រោមនេះ ៖

១.បញ្ហាប្រឈមទី១គឺ ការអនុវត្តកម្មវិធីសិក្សាដែលគ្រឹះស្ថានឧត្តមសិក្សា នៅមានចំណុចខ្វះខាតដូចជាការបង្រៀនខុសពីកម្មវិធីសិក្សាដែលមានការយល់ព្រមពីគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ការវាយតម្លៃការសិក្សារបស់និស្សិតមិនស្របតាមកម្មវិធីសិក្សា មិនបានផ្តល់ព័ត៌មានអំពីគោលបំណង ប្លង់មេរៀន លទ្ធផលរំពឹងទុក និងវិធីសាស្ត្រវាយតម្លៃលើការសិក្សាដល់និស្សិត ខ្វះយន្តការតាមវត្តមាននិស្សិត ផ្សព្វផ្សាយលទ្ធផលប្រឡងយឺតយូរ ខ្លឹមសាររបស់សៀវភៅសិក្សាមិនស្របតាមកម្មវិធីសិក្សា បង្រៀនមេរៀនមិនចប់តាមកម្មវិធី មិនបានផ្តល់កិច្ចការប្រឡងដល់និស្សិត និងការបង្រៀនមិនស្របតាមម៉ោងទ្រឹស្តី និងម៉ោងប្រតិបត្តិ។

២.បញ្ហាប្រឈមទី២គឺ វិធីសាស្ត្រនៃការបង្រៀន ដែលគ្រឹះស្ថានឧត្តមសិក្សានៅមានចំណុចខ្វះខាតដូចជា ខ្វះគោលការណ៍សម្រាប់វាយតម្លៃលើការសិក្សាដោយផ្តោតលើលទ្ធផលសិក្សារបស់និស្សិត មិនបានផ្តល់ប្លង់មេរៀននៃមុខវិជ្ជានីមួយៗដល់និស្សិត គោលការណ៍បង្រៀនមិនច្បាស់លាស់ មិនបានផ្សព្វផ្សាយកម្មវិធីសិក្សាដល់និស្សិត និងគ្រូបង្រៀន វិធីសាស្ត្របង្រៀនមិនច្បាស់លាស់ ខ្វះយន្តការតាម ដានវត្តមានរបស់និស្សិត គ្រូបង្រៀនមិនបានយល់ដឹងអំពីវិធីសាស្ត្រនៃការបង្រៀននិងការស្រាវជ្រាវដោយផ្តោតលើលទ្ធផលការសិក្សារបស់និស្សិត។

៣.បញ្ហាប្រឈមទី៣ គឺ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្មវិធីសក្សា ដែលគ្រឹះស្ថានឧត្តមសិក្សា នៅមានចំណុចខ្វះខាតដូចជា ខ្វះគោលការណ៍ស្តីពីការប្រព្រឹត្តទៅ និងការរៀបចំក្រុមប្រឹក្សាអភិវឌ្ឍន៍កម្មវិធីសិក្សា ខ្វះបំណែងចែកតួនាទីភារកិច្ចរបស់សមាសភាពក្រុមប្រឹក្សាអភិវឌ្ឍន៍កម្មវិធីសិក្សា ខ្វះការកំណត់គុណវុឌ្ឍិសិក្សា និងជំនាញរបស់សមាសភាពក្រុមប្រឹក្សាអភិវឌ្ឍន៍កម្មវិធីសិក្សា ខ្វះរបាយការណ៍ស្តីពីការរៀបចំនិងកែលម្អកម្មវិធីសិក្សា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្មវិធីសិក្សាមិនដែលបានជួបប្រជុំពិភាក្សាគ្នាអំពីកម្មវិធីសិក្សា។

៤.បញ្ហាប្រឈមទី៤គឺ ការធ្វើសិក្ខាសាលា ដែលគ្រឹះស្ថានឧត្តមសិក្សានៅមានចំណុចខ្វះខាតដូចជាមិនបានធ្វើសិក្ខាសាលាបញ្ហាបញ្ហាប្រឈមនានា និងមុខវិជ្ជាចាំបាច់ដល់និស្សិត ។

៥.បញ្ហាប្រឈមទី៥គឺ ការផ្សព្វផ្សាយកម្មវិធីសិក្សា ដែលគ្រឹះស្ថានឧត្តមសិក្សានៅមានចំណុចខ្វះខាតដូចជា មិនបានផ្សព្វផ្សាយកម្មវិធីសិក្សាដល់និស្សិត និងអ្នកពាក់ព័ន្ធ។

៦.បញ្ហាប្រឈមទី៦គឺ ចំនួនម៉ោងនៃមុខវិជ្ជានីមួយៗ ដែលគ្រឹះស្ថានឧត្តមសិក្សានៅមានចំណុខ្វះខាតដូចជា មុខវិជ្ជាសំខាន់ៗខ្លះមានចំនួនម៉ោងតិចពេក។

តាមលទ្ធផលវិភាគខាងលើ បញ្ហាដែលកើតមានឡើងនៅក្នុងគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជនលើកម្មវិធីសិក្សាមានចំនួន៦ចំណុចគឺ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្មវិធីសិក្សា ការអនុវត្តកម្មវិធីសិក្សា ចំនួនម៉ោងនៃមុខវិជ្ជានីមួយៗ វិធីសាស្ត្រនៃការបង្រៀន ការផ្សព្វផ្សាយ និងការធ្វើសិក្ខាសាលា។ ប៉ុន្តែបញ្ហាដែលគ្រឹះស្ថានឧត្តមសិក្សាប្រឈមសំខាន់ជាងគេគឺ ការអនុវត្តកម្មវិធីសិក្សា និងវិធីសាស្ត្រនៃការបង្រៀន។ ដូច្នេះ គ្រឹះស្ថានឧត្តមសិក្សាត្រូវយកចិត្តទុកដាក់ឱ្យបានខ្លាំងទៅលើកែលម្អចំណុចខ្វះខាតខាងលើដើម្បីពង្រឹងគុណភាពអប់រំឱ្យកាន់ប្រសើរឡើង។

**ក្រាបសសរស្តីពីចំណុចខ្វះខាតនៅក្នុងកម្មវិធីសិក្សា**




**១.៤- បញ្ហាប្រឈមនៅក្នុងធនធានគ្រូបង្រៀន**

តាមលទ្ធផលនៃការចុះវាយតម្លៃលើធនធានគ្រូបង្រៀន នៅក្នុងឆ្នាំសិក្សា២០០៩-២០១០ របស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា លើគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជនចំនួន៥៣ដែលផ្តោតទៅលើចំណុចសំខាន់ៗចំនួនប្រាំ និងបានបង្ហាញឱ្យឃើញថា គ្រឹះស្ថានឧត្តមសិក្សាមានបញ្ហាប្រឈមនៅក្នុងធនធានគ្រូបង្រៀនចំនួន១០១ចំណុច ដូចជា កិច្ចសន្យាចំនួន៧ចំណុច ត្រូវនឹង ៧.៣៧% មុខវិជ្ជាបង្រៀនចំនួន៣ចំណុច ត្រូវនឹង ៣.១៦% ចំនួនម៉ោងបង្រៀនគ្មានត្រូវនឹង ០០% គុណវុឌ្ឍិ និងបទពិសោធន៍ចំនួន១១ចំណុច ត្រូវនឹង ១១.៥៨% ការជ្រើសរើសគ្រូបង្រៀនចំនួន៦ចំណុច ត្រូវនឹង ៦.៣២% ការវាយតម្លៃគ្រូបង្រៀនចំនួន១៤ចំណុច ត្រូវនឹង ១៤.៧៤% ប្រាក់ម៉ោងបង្រៀន និងលាភការផ្សេងៗចំនួន៩ ត្រូវនឹង ៩.៤៧% ការពង្រឹងសមត្ថភាពគ្រូបង្រៀនចំនួន២៤ ត្រូវនឹង ២៥.២៦% ផលធៀបគ្រូបង្រៀននិងនិស្សិតចំនួន ១៨ ត្រូវនឹង ១៨.៩៥% និងផ្សេងៗចំនួន០៣ចំណុច ត្រូវនឹង ៣.១៦%។ តាមការវិភាគទិន្នន័យតាមក្រាបសសរនៃលទ្ធផលចុះវាយតម្លៃខាងក្រោមបានបង្ហាញឱ្យឃើញថា បញ្ហាប្រឈមសំខាន់ៗជាងគេនៅក្នុងធនធានគ្រូបង្រៀនមានចំនួន២ ហើយចំណុចនីមួយៗមានចំណុចខ្វះខាតដូចខាងក្រោមនេះ ៖

១.បញ្ហាប្រឈមទី១គឺ ការពង្រឹងសមត្ថភាពគ្រូបង្រៀន ដែលគ្រឹះស្ថានឧត្តមសិក្សានៅមានចំណុចខ្វះ

ខាតដូចជា មិនបានពង្រឹងសមត្ថភាពគ្រូបង្រៀនបន្ថែម គ្មានកម្មវិធីសម្រាប់អភិវឌ្ឍន៍គ្រូបង្រៀនច្បាស់លាស់។

២.បញ្ហាប្រឈមទី២ គឺ ផលធៀបគ្រូបង្រៀន និង និស្សិត ដែលគ្រឹះស្ថានឧត្តមសិក្សានៅមានចំណុចខ្វះខាតដូចជា ផលធៀបគ្រូ និង និស្សិតមិនស្របតាមការណែនាំរបស់ គ.ទ.ក. (វិស័យសិល្បៈ និង មនុស្សសាស្ត្រ ៖ ១:២៥ វិស័យគណិតសាស្ត្រ វិទ្យាសស្ត្រ និង កុំព្យូទ័រវិទ្យា៖ ១ :១៨ វិទ្យាសាស្ត្រសង្គម ៖ ១ :២៥ វិស័យ ភាសាបរទេស ៖ ១ :២០) ត្រូវជ្រើសគ្រូបង្រៀនបន្ថែម។

៣.បញ្ហាប្រឈមទី៣គឺការវាយតម្លៃគ្រូបង្រៀន ដែលគ្រឹះស្ថានឧត្តមសិក្សានៅមានចំណុចខ្វះខាតដូចជា មិនបានវាយតម្លៃលើការបង្រៀនរបស់គ្រូបង្រៀន គ្មានគោលការណ៍ និងនីតិវិធីវាយតម្លៃគ្រូបង្រៀនជាលាយលក្ខណ៍អក្សរច្បាស់លាស់ មានគោលការណ៍វាយតម្លៃគ្រូបង្រៀនតែមិនបានអនុវត្តនិស្សិតគ្មានឱកាសវាយតម្លៃគ្រូបង្រៀន មិនបានបូកសរុបលទ្ធផលវាយតម្លៃលើគ្រូបង្រៀន មានការវាយតម្លៃលើគ្រូបង្រៀនពីនិស្សិត ប៉ុន្តែ មិនមានការវាយតម្លៃពីគណៈគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា។

៤.បញ្ហាប្រឈមទី៤គឺ គុណវុឌ្ឍិ និងបទពិសោធន៍គ្រូបង្រៀន ដែលគ្រឹះស្ថានឧត្តមសិក្សានៅមានចំណុចខ្វះខាតដូចជា គុណវុឌ្ឍិ និងបទពិសោធន៍គ្រូបង្រៀនមិនស្របតាមគោលការណ៍ណែនាំរបស់ គ.ទ.ក. (គោលការណ៍ណែនាំ ៖ គ្រូបង្រៀនត្រូវមានគរុកោសល្យ និងមានសញ្ញាបត្រចាប់ពីកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅ។ គ្រូបង្រៀនដែលមានសញ្ញាបត្រកម្រិតបរិញ្ញាបត្រ ត្រូវមានបទពិសោធន៍បង្រៀននៅឧត្តមសិក្សាយ៉ាងតិច៣ឆ្នាំ)។

៥.បញ្ហាប្រឈមទី៥គឺ ប្រាក់ម៉ោងបង្រៀន និង លាភការផ្សេងៗ ដែលគ្រឹះស្ថានឧត្តមសិក្សានៅមានចំណុចខ្វះខាតដូចជា គ្មានគោលការណ៍ដំឡើងប្រាក់ឈ្នួលបៀវត្សរ៍ និង លាភការផ្សេងៗដល់គ្រូបង្រៀន មិនបានបើកប្រាក់ម៉ោងឱ្យគ្រូបង្រៀនទាន់ពេលវេលា និង ប្រាក់ម៉ោងបង្រៀនទាបពេក។

៦.បញ្ហាប្រឈមទី៦គឺ កិច្ចសន្យារបស់គ្រូបង្រៀនដែលគ្រឹះស្ថានឧត្តមសិក្សានៅមានចំណុចខ្វះខាតដូចជា មិនបានធ្វើកិច្ចសន្យាជាមួយគ្រូបងៀនមិនពេញម៉ោង កិច្ចសន្យារបស់គ្រូបង្រៀនហួសកាលកំណត់ កិច្ចសន្យាគ្មានកាលបរិច្ឆេទច្បាស់លាស់ និងទម្រង់កិច្ចសន្យាមិនច្បាស់លាស់។

៧.បញ្ហាប្រឈមទី៧គឺ ការជ្រើសរើសគ្រូបង្រៀន ដែលគ្រឹះស្ថានឧត្តមសិក្សានៅមានចំណុចខ្វះខាតដូចជា គ្មានគោលការណ៍ និង នីតិវិធីជ្រើសរើសគ្រូបង្រៀន មានគោលការណ៍ និង នីតិវិធីជ្រើសរើសគ្រូបង្រៀន ប៉ុន្តែមិនបានអនុវត្តតាមគោលការណ៍ជ្រើសរើសគ្រូបង្រៀន មិនស្របតាមគោលការណ៍របស់គ.ទ.ក.។

៨.បញ្ហាប្រឈមទី៨គឺ មុខវិជ្ជាបង្រៀន ដែលគ្រឹះស្ថានឧត្តមសិក្សានៅមានចំណុចខ្វះខាតដូចជាបង្រៀនមិនស្របតាមជំនាញឯកទេសរបស់ខ្លួន។

៩.បញ្ហាប្រឈមទី៩គឺ ចំនួនម៉ោងបង្រៀនរបស់គ្រូបង្រៀនម្នាក់ៗដែលគ្រឹះស្ថានឧត្តមសិក្សាពុំមានចំណុចខ្វះខាតអ្វីទេ ដោយសារមន្ត្រីវាយតម្លៃមានការលំបាកក្នុងការរកចំនួនម៉ោងនេះបាន ពីព្រោះគ្រូបង្រៀនម្នាក់បង្រៀននៅតាមគ្រឹះស្ថានឧត្តមសិក្សាច្រើន ឬបង្រៀននៅក្នុងឆ្នាំសិក្សាខុសៗគ្នា។ តាមការពិតគ្រូបង្រៀនភាគច្រើនបង្រៀនលើសចំនួនម៉ោងដែលគ.ទ.ក.បានកំណត់(២៤ម៉ោងក្នុងមួយសប្តាហ៍)។

១០.បញ្ហាប្រឈមទី១០គឺ ដែលគ្រឹះស្ថានឧត្តមសិក្សានៅមានចំណុចខ្វះខាតដូចជា មិនបានធ្វើកិច្ចសន្យាជាមួយគ្រូបង្រៀនមិនពេញម៉ោង កិច្ចសន្យារបស់គ្រូបង្រៀនហួសកាលកំណត់កិច្ចសន្យាគ្មានកាលបរិច្ឆេទច្បាស់លាស់ ទម្រង់កិច្ចសន្យាមិនច្បាស់លាស់ និងតាមតារាងទិន្នន័យ និងក្រាបសសរខាងក្រោមបានបង្ហាញថា *គ្រូបង្រៀនជំនាញទេសចរណ៍នៅតាមគ្រឹះស្ថានទាំងអស់មាន ចំនួនគ្រូបង្រៀនពេញម៉ោងចំនួន១៤នាក់ គ្រូបង្រៀនមិនពេញម៉ោងចំនួន៦៥នាក់ សញ្ញាបត្របណ្ឌិតចំនួន៤នាក់ បរិញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ចំនួន៥៧នាក់ និងបរិញ្ញាបត្រចំនួន១៣នាក់។*

តាមលទ្ធផលវិភាគខាងលើ បញ្ហាដែលកើតមានឡើងនៅក្នុងគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជនលើធនធានគ្រូបង្រៀនមានចំនួន៩ចំណុចគឺ កិច្ចសន្យា មុខវិជ្ជាបង្រៀន ចំនួនម៉ោងបង្រៀន គុណវុឌ្ឍិ និងបទពិសោធន៍ ការជ្រើសរើសគ្រូបង្រៀន ការវាយតម្លៃគ្រូបង្រៀន ប្រាក់ម៉ោងបង្រៀន និងលាភការផ្សេងៗ ការពង្រឹងសមត្ថភាពគ្រូបង្រៀន ផលធៀបគ្រូបង្រៀន និងនិស្សិត។ ប៉ុន្តែបញ្ហាដែលគ្រឹះស្ថានឧត្តមសិក្សាប្រឈមសំខាន់ជាងគេគឺ ពង្រឹងសមត្ថភាពគ្រូបង្រៀន ផលធៀបគ្រូបង្រៀន និងនិស្សិត ការវាយតម្លៃគ្រូបង្រៀន និងគុណវុឌ្ឍិ និងបទពិសោធន៍គ្រូបង្រៀន។ ដូច្នេះគ្រឹះស្ថានឧត្តមសិក្សាត្រូវយកចិត្តទុកដាក់ឱ្យបានខ្លាំងទៅលើការកែលម្អចំណុចខ្វះខាតខាងលើ ដើម្បីពង្រឹងគុណភាពអប់រំឱ្យកាន់ប្រសើរឡើង។ របៀបនៃការលើកកម្ពស់ធនធានគ្រូបង្រៀននៅតាមគ្រឹះស្ថានឧត្តមសិក្សា ដែលបណ្តុះបណ្តាលជំនាញទេសចរណ៍នឹងមានបង្ហាញជាលម្អិតនៅក្នុងជំពូក៣ បន្ថែមទៀត។

**ក្រាបសសរស្តីពីចំណុចខ្វះខាតនៅក្នុងធនធានគ្រូបង្រៀន**



# ឥទ្ធិពលនៃទស្សនវិជ្ជាម៉ាក្សលេនីន-មកលើការវិវត្តន៍ នៃប្រទេសកម្ពុជាពីឆ្នាំ១៩៧៩



កែវ សុជាតិ
បេក្ខជនបណ្ឌិតវគ្គទី១ ផ្នែកទស្សនវិជ្ជា
នៃរាជបណ្ឌិត្យសភាកម្ពុជា

## សេចក្តីផ្តើម

ឆ្នាំ១៩៧៩ ជាឆ្នាំមួយដែលប្រជាជនខ្មែរភាគច្រើនមិនអាចបំភ្លេចបានឡើយ ពីព្រោះជាពេលរស់ឡើងវិញរបស់ប្រជាជនខ្មែរ ក្រោយពីសេចក្តីស្លាប់ក្នុងរបប ប៉ុល ពត។ ក្រោមផ្លាករណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងមានការជួយឧបត្ថម្ភពីកងទ័ពស្ម័គ្រចិត្តវៀតណាម ប្រទេសកម្ពុជាបានរំដោះពីរបប ប៉ុល ពត នៅថ្ងៃ៧ មករា ១៩៧៩។ ការកសាងរបបថ្មីមួយមិនអាចផ្តាច់ចេញទាំងស្រុងពីអ្វីដែលនៅសេសសល់ពីរបបចាស់បានឡើយ ពីព្រោះ ត្រូវកសាងលើមូលដ្ឋានសង្គមមុនដូចជា ទឹកដី មនុស្ស ហេដ្ឋារចនាសម្ព័ន្ធសង្គម វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ ហើយរួមជាមួយអ្វីដែលជារបស់ថ្មី ដើម្បីបង្កើតរបបថ្មីមួយទៀតតាមការកំណត់របស់អ្នកនយោបាយ។ ចំពោះប្រទេសកម្ពុជា ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ បានចេញដំណើរពីមូលដ្ឋានសង្គមចាស់ដែលខ្ទេចខ្ទាំគ្រប់វិស័យរបស់សង្គម ជាពិសេសមនុស្សដែលជាកត្តាសំខាន់នៃការកសាងប្រទេសក៏ត្រូវទ្រុឌទ្រោមទាំងរាងកាយនិងស្មារតី។ ដូច្នេះបញ្ហាជាសារវន្តនាពេលនោះគឺថា តើកម្ពុជាត្រូវដើរតាមរបបណាដែលអាចស្រោចស្រង់ប្រជាជននិងប្រទេសជាតិឡើងវិញបានទាន់ពេលវេលា។

## ១-ស្ថានភាពប្រទេសកម្ពុជានៅឆ្នាំ១៩៧៩

នៅក្រោយថ្ងៃ ៧ មករា ១៩៧៩ ប្រទេសកម្ពុជា ត្រូវប្រឈមមុខនឹងផលវិបាកជាច្រើនដែលត្រូវដោះស្រាយគឺ ៖

- ប្រជាជនស្ថិតក្នុងស្ថានភាពច្របូកច្របល់ក្នុងការស្វែងរកគ្រួសារ ការវិលត្រឡប់ទៅស្រុកកំណើតវិញ ការជួបនឹងគ្រោះអត់ឃ្លាន ជំងឺតម្កាត់ ក្មេងកំព្រា និងការមិនបានបង្កបង្កើនផល បានក្លាយទៅជាបន្ទុកដ៏ធ្ងន់ធ្ងររបស់រដ្ឋាភិបាលដ៏ក្មេងខ្ចី។
- ម្យ៉ាងទៀត ពួក ប៉ុល ពត ទោះជាចាញ់ក៏ដោយ តែនៅមានគោលបំណងវិលត្រឡប់មកដណ្តើមរដ្ឋអំណាចវិញ ម្ល៉ោះហើយតែងលបចូលមកក្នុងភូមិប្រជាជន បង្កវិនាសកម្ម និងភាពភ័យខ្លាច។
- ការវាយផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យមានសភាពលឿនខ្លាំងពេក រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ពុំទាន់បានរៀបចំរចនាសម្ព័ន្ធអ្វីឱ្យបានច្បាស់លាស់គឺ ការត្រៀមលក្ខណសម្បត្តិដឹកនាំ និងគ្រប់គ្រងប្រទេសមិនទាន់បានល្អ ដួរកម្មាភិបាលមិនទាន់គ្រប់គ្រាន់ នៅពេលដែលចូលមកកាន់អំណាច។
- នៅក្រៅប្រទេស ប្រទេសចិនរួមជាមួយអាម៉េរិកបានអូសទាញបណ្តាប្រទេសនៅទ្វីបអឺរ៉ុប និងប្រទេសអាស៊ានឱ្យគាំទ្រនិងចូលរួមក្នុងការប្រឆាំងសាធារណរដ្ឋប្រជាមានិតកម្ពុជា និងវៀតណាមក្រោមលេសថា "កងទ័ពវៀតណាមឈ្លានពានកម្ពុជា"។ នាពេលនោះបណ្តាប្រទេសលោកសេរី និងប្រទេសចិនបាន គាំទ្រ និងឧបត្ថម្ភរបបកម្ពុជាប្រជាធិបតេយ្យរបស់ ប៉ុល ពត ដែលដួលរលំ និងកម្លាំងប្រឆាំងផ្សេងទៀតនៅតាមព្រំដែនកម្ពុជាថៃ- ហើយបែរជាដាក់ទណ្ឌកម្មសេដ្ឋកិច្ចមកលើរបប

ភ្នំពេញដែលមានប្រជាជនពោរពេញដោយការស្រេកឃ្លាន ខ្សត់ខ្សោយ មានជំងឺខាងរាងកាយ និង ស្មារតីដែលភ័យខ្លាច ការវិលត្រឡប់មកវិញនៃរបប ប៉ុល ពត។

ក្នុងស្ថានភាពបែបនេះ តម្រូវឱ្យប្រទេសកម្ពុជានាពេលនោះត្រូវជ្រើសរើសយករបបគ្រប់គ្រងមួយ ដែលសមស្របតាមសភាពការណ៍ជាក់ស្តែងរបស់ប្រទេស និង កម្លាំងជំនួយឧបត្ថម្ភដើម្បីគ្រប់គ្រងការពារ និង សង្គ្រោះប្រជាជាតិកម្ពុជាឱ្យចាកផុតពីភាពមរណា។ តាមទ្រឹស្តីភាវៈ ភាវៈទាំងឡាយវិវត្តទៅបានអាស្រ័យលើកត្តាពីរ គឺ កត្តាខាងក្នុងនិងកត្តាខាងក្រៅ។ កត្តាខាងក្នុង គឺពឹងផ្អែកលើសក្តានុពលរបស់ខ្លួនដែលជាអ្នកកំណត់នូវអំពើ (សកម្មភាព) រីឯកត្តាខាងក្រៅគឺ ភាវៈទាំងឡាយដែលមានទំនាក់ទំនងជាមួយភាវៈនោះ។ ហេតុនេះ ការកំណត់នូវរបបសង្គមមួយក៏អនុលោមទៅតាមសក្តានុពលដែលមានទាំងកត្តាខាងក្នុងសង្គម និងកត្តាខាងក្រៅសង្គមដែរ។ ចំពោះកម្ពុជា សក្តានុពលដែលកំណត់ជោគជ័យនាពេលនោះគឺ ៖

-កម្លាំងខាងក្នុងដែលជាកត្តាកំណត់ដល់ការងើបឡើងប្រឆាំងនឹងរបប ប៉ុល ពត ភាគច្រើនគឺជាកម្លាំងដែលដឹកនាំដោយកម្មាភិបាលបដិវត្តពីពេលមុន ហើយមានគោលដៅស្របគ្នាគឺផ្តួលរំលំរបប ប៉ុល ពត កសាងប្រទេសតាមមាគ៌ានៃលទ្ធិសង្គមនិយម[៦១]។

-កម្លាំងខាងក្រៅដែលជួយឧបត្ថម្ភចំពោះការតស៊ូផ្តួលរំលំរបប ប៉ុល ពត នាពេលនោះជាកម្លាំងបដិវត្តន៍វៀតណាម ដែលតំណាងឱ្យកម្លាំងបដិវត្តអន្តរជាតិ ក៏ដើរតាមលទ្ធិម៉ាក្សលេនីនដែរ។-

-ទ្រឹស្តីកុម្មុយនីស្ត និង លទ្ធិកុម្មុយនីស្តលើសកលលោកកំពុងជាកម្លាំងជឿនលឿននិងមានឥទ្ធិពល។

កត្តាទាំងអស់នេះ ដែលធ្វើឱ្យបក្ស និងរដ្ឋអំណាចថ្មីប្រកាន់យកទិសដៅឈានឡើងលទ្ធិសង្គមនិយម ដោយជឿថា របបនេះនឹងរកយុត្តិធម៌ជូនសង្គមកម្ពុជាបានល្អប្រសើរជាងរបបដទៃទៀត ដូចប្រសាសន៍របស់លោក ហេង សំរិន អគ្គលេខានៃគណៈកម្មាធិការមជ្ឈិមបក្សប្រជាជនបដិវត្តន៍កម្ពុជា និងជាប្រធានក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាថា "ជ័យជំនះជាប្រវត្តិសាស្ត្រ ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ គឺជាការបន្តពីជ័យជំនះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយបើកចេញនូវសករាជមួយថ្មីក្នុងប្រវត្តិសាស្ត្រជាតិ ៖ សករាជឯករាជ្យ សេរីភាពពិតប្រាកដ និងឈានជាជំហានៗឡើងលទ្ធិសង្គមនិយម"[៦២] ទោះបីជាមានប្រជាជនមួយចំនួនមិនពេញចិត្តនឹងលទ្ធិនេះ ដោយសារឥទ្ធិពលដ៏អាក្រក់នៃរបប ប៉ុល ពតក៏ដោយ។

ក្រោយពេលដណ្តើមបានរដ្ឋអំណាច ប្រទេសកម្ពុជាត្រូវចេញដំណើរពីចំណុចសូន្យឬពីបាតដៃទទេ ជាមួយនឹងការលំបាករាប់មិនអស់ ព្រោះគ្រប់ធាតុទាំងអស់នៃរចនាសម្ព័ន្ធសង្គមត្រូវកម្ទេចសឹងទាំងស្រុង ហើយបញ្ហាគ្រោះអត់ឃ្លានកំពុងគំរាមកំហែងនៅទូទាំងប្រទេស ព្រមទាំងគ្រោះថ្នាក់នៃការប៉ុនប៉ងវិលត្រឡប់មកវិញរបស់របប ប៉ុល ពត។ បញ្ហានេះ តម្រូវឱ្យរដ្ឋអំណាចថ្មីត្រូវដោះស្រាយជាបន្ទាន់នូវភារកិច្ចជាយុទ្ធសាស្ត្រពីរគឺ ការពារ ប្រទេស និងកសាងប្រទេស។

ភារកិច្ចការពារប្រទេសនៅពឹងផ្អែកលើកម្លាំងពីរគួបគ្នាគឺ កម្លាំងបដិវត្តន៍កម្ពុជា និង ការជួយឧបត្ថម្ភរបស់កងទ័ពវៀតណាម ព្រោះថាកម្លាំងបដិវត្តន៍កម្ពុជានៅទន់ខ្សោយគឺ កងកម្លាំងរណសិរ្សពេលវាយលុករំដោះប្រជាជនកម្ពុជាពីរបប ប៉ុល ពត មានចំនួនប្រមាណ ២០ ០០០នាក់ប៉ុណ្ណោះ រីឯកម្លាំងប្រជាជនខ្មែរ ដែលត្រូវរំដោះ មានសភាពទ្រុឌទ្រោម មានជំងឺ បាក់ស្មារតី ដែលមិនទាន់អាចបំពេញភារកិច្ចការពារប្រទេសបាន

[៦១] ហ៊ុន សែន, ១៣ ទសវត្សនៃដំណើរកម្ពុជា, កាសែតប្រជាជន,១៩៩១, ទំព័រ ២៥២-២៥៣

[៦២] ហេង សំរិន, បណ្តាជំណាក់អភិវឌ្ឍរបស់បដិវត្តន៍កម្ពុជា, រស្មីបដិវត្ត, ភ្នំពេញ, ១៩៨៦, ទំព័រ ២២

និងមួយចំនួនទៀតភ័យខ្លាចនឹងរបបកុម្មុយនីស្តហើយរកមធ្យោបាយចេញទៅបរទេស។ ប៉ុន្តែ កម្លាំងបដិវត្តន៍កម្ពុជាផ្ទាល់បានរីកចម្រើនជាបណ្តើរៗ រហូតដល់អាចរ៉ាប់រងភារកិច្ចការពារប្រទេសដោយខ្លួនឯង ហើយកងទ័ពស្ម័គ្រចិត្តវៀតណាម អាចដកទាំងស្រុងនៅខែកញ្ញា ឆ្នាំ១៩៨៩។

ភារកិច្ចស្តារនិងកសាងប្រទេសជាភារកិច្ចលំបាកបំផុតសម្រាប់បដិវត្តន៍កម្ពុជា ដោយសារលក្ខណៈពិសេសនៃស្ថានភាពសង្គមសេដ្ឋកិច្ចរបស់កម្ពុជា។ ការទាមទារជាបឋមនៃការបដិវត្តន៍គឺ កសាងរដ្ឋអំណាចបដិវត្តន៍ និង បង្កើតឡើងនូវបែបផែនផលិតកម្មថ្មី។

- ការរៀបចំស្ថាប័នរដ្ឋអំណាច ៖ តាមមហាសន្និបាតបក្សប្រជាជនបដិវត្តន៍កម្ពុជាលើកទី៤ ដែលប្រារព្ធឡើងនៅខែឧសភា ឆ្នាំ១៩៨១ ក្នុងទីក្រុងភ្នំពេញ បានកំណត់របបនយោបាយឯកបក្សនៅក្នុងនយោបាយពោលគឺ ស្ថាប័នរដ្ឋអំណាចត្រូវស្ថិតនៅក្រោមការដឹកនាំរបស់បក្សប្រជាជនបដិវត្តន៍កម្ពុជា ដែលដើរតាមលទ្ធិម៉ាក្ស-លេនីន។ ប៉ុន្តែ ចំណុចពិសេសនៃប្រទេសកម្ពុជាគឺបក្សប្រជាជនបដិវត្តកម្ពុជាត្រូវកសាងឡើងវិញ ក្រោយពីរបប ប៉ុល ពត បានបំផ្លាញបក្ស និងកំទេចបក្ខជនជើងចាស់អស់មួយចំនួនធំ ដូចជាក្នុងមហាសន្និបាតបក្សលើកទី៣ នៅសល់បក្ខជនតែជាង ២០០នាក់ប៉ុណ្ណោះ ដែលដឹកនាំបានតែនៅថ្នាក់មជ្ឈិម ថ្នាក់ខេត្ត/ក្រុង និងក្នុងជួរកងទ័ព ឯថ្នាក់ស្រុក និង ឃុំមិនទាន់មានបក្ខជននៅឡើយ។ ហេតុនេះ ក្រោយពេលរំដោះបក្សប្រជាជនបដិវត្តន៍កម្ពុជាបានចេញគោលការណ៍ចាំបាច់ និង បន្ទាន់បំផុតគឺ ការកសាងបក្ស និង ជួរកម្មាភិបាល គ្រប់ផ្នែក។ ការកសាងរចនាសម្ព័ន្ធសេដ្ឋកិច្ចសង្គម

ក្រោយថ្ងៃ ៧ មករា ១៩៧៩ ការស្តារនិងកសាងប្រទេសកម្ពុជា បានចាប់ផ្តើមពីស្ថានភាពសង្គមមួយដែលគ្មានរចនាសម្ព័ន្ធខាងសេដ្ឋកិច្ច គ្មានអ្នកជំនាញខាងសេដ្ឋកិច្ច និងភាពច្របូកច្របល់ដោយគ្រោះអត់ឃ្លានរបស់ប្រជាជន។ បញ្ហាចំពោះមុខ និងជាបន្ទាន់ដែលត្រូវដោះស្រាយគឺ សុខភាព និងការអត់ឃ្លានរបស់ប្រជាជន។ ក្នុងស្ថានភាពបែបនេះការគ្រប់គ្រងសេដ្ឋកិច្ចត្រូវរត់ទៅតាមសភាពការណ៍ជាក់ស្តែងក្នុងសង្គមគឺ ដើម្បីដោះស្រាយការអត់ឃ្លានចំពោះមុខរបស់ប្រជាជន រដ្ឋបានកំណត់ឱ្យមានតែសមាសភាពសេដ្ឋកិច្ចរដ្ឋ សេដ្ឋកិច្ចសមូហភាព និង សេដ្ឋកិច្ចគ្រួសារ ដោយហេតុថា ៖

+ របបប៉ុលពតបានកម្ទេចអស់នូវសេដ្ឋកិច្ចឯកជន ពោលគឺកម្មសិទ្ធិឯកជនលើមធ្យោបាយផលិតកម្មបាន ត្រូវបំបាត់រួចទៅហើយ ទាំងរោងចក្រ សិប្បកម្ម និងដីធ្លី ហើយដីស្រែចម្ការទៀតសោតក៏ត្រូវ របប ប៉ុល ពត ប្រមូលធ្វើជារបស់រួម តាមវិធីធ្វើប្រព័ន្ធភ្លឺស្រែ និង ប្រឡាយ ដូចជាដីមួយហិចតា ធ្វើស្រែតែមួយដីមួយគីឡូម៉ែត្របួនជ្រុងធ្វើប្រឡាយព័ទ្ធជុំវិញ ដូច្នេះត្រូវចាប់កសាងសេដ្ឋកិច្ចសង្គមនិយមតែម្តងដោយ បញ្ចូលជាសេដ្ឋកិច្ចរដ្ឋ។

+ ម្យ៉ាងទៀតក្នុងស្ថានភាពដែលខ្វះកម្លាំងអូសទាញ ខ្វះឧបករណ៍ ខ្វះពូជជារ ខ្វះកម្លាំងពលកម្មដោយនៅសេសសល់ភាគច្រើនជាស្ត្រី ជនចាស់ជរា និងកុមារកំព្រា ម្ល៉ោះហើយការដោះស្រាយ ចំពោះមុខនូវផលិតកម្មស្បៀងគឺ ការបង្កើតក្រុមសាមគ្គីបង្កបង្កើតផល ដើម្បីឱ្យប្រជាជនទាំងអស់ អាចចូលរួមក្នុងការផលិតស្បៀងអាហារបានទាន់ពេលវេលា។

+ ម្យ៉ាងវិញទៀត ប្រជាជនខ្មែរធ្លាប់មានប្រពៃណីល្អក្នុងការជួយគ្នាទៅវិញទៅមកក្នុងការធ្វើស្រែ ចម្ការដូចជាការធ្វើប្រវាស់ដៃគ្នាទៅវិញទៅមក ម្ល៉ោះហើយក្នុងពេលនោះមិនជាការលំបាកក្នុងការចូលរួមជាក្រុមសាមគ្គីបង្កបង្កើនផលឡើយ។ ទន្ទឹមនឹងនោះ ជំនឿលើពុទ្ធសាសនាក្នុងផ្នត់គំនិត ប្រជាជនខ្មែរ

បានរួមចំណែកយ៉ាងសំខាន់ដល់ស្មារតីជួយសង្គ្រោះគ្នាទៅវិញទៅមក ដើម្បីឱ្យក្មេងកំព្រា ជនគ្មានទីពំនាក់ដ៏ច្រើនបាន រស់រានមានជីវិតដែរ។

ដូច្នេះ កម្លាំងផលិតកម្មនាពេលនោះបានកំណត់ទំនាក់ទំនងផលិតកម្ម។ តាមក្រឹត្យក្រមសេដ្ឋកិច្ច ទំនាក់ទំនងផលិតកម្មត្រូវសមស្របនឹងកម្រិតនិងចរិតរបស់កម្លាំងផលិតកម្ម បើកម្លាំងផលិតកម្មមានលក្ខណៈសមូហភាពទាមទារត្រូវមានទំនាក់ទំនងផលិតកម្មមួយដែលសមស្របជាមួយវាគឺសមូហភាពដែរ ទើបអាចជំរុញកម្លាំងផលិតកម្មឱ្យរីកចម្រើនទៅបាន បើផ្ទុយទៅវិញ នោះនឹងរារាំងដល់ការរីកចម្រើនរបស់កម្លាំងផលិត-កម្ម។ ស្ថានភាពជាក់ស្តែងនាពេលនោះ កម្មាភិបាលមូលដ្ឋានមួយចំនួនធំមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការដឹកនាំគ្រប់គ្រងមូលដ្ឋាននៅឡើយ តែដោយសារស្មារតីជួយគ្នាទៅវិញទៅមក និងការរស់ឡើងវិញពីទុក្ខលំបាកពីសេចក្តីស្លាប់ និងការព្រាត់ប្រាស់គ្រួសារក្នុងរបប ប៉ុល ពត បានធ្វើឱ្យប្រជាជនខ្មែរនាពេលនោះយល់ថាជាការរស់នៅល្អប្រសើរជាងរបប ប៉ុល ពត ព្រមជាមួយនឹងការអប់រំផ្សព្វផ្សាយពីការកសាងសហគមន៍សមូហ-ភាពដោយការស្ម័គ្រចិត្តពីប្រជាជនផង "មិនបណ្តោយឱ្យមានការបង្ខិតបង្ខំប្រជាជនឱ្យចូលរួមក្នុងក្រុមសាមគ្គីសមូហភាពឡើយ។ គេត្រូវតែធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនឯង... ការគោរពដល់គោលការណ៍ដោយស្ម័គ្រចិត្ត ឆ្លើយតបទៅនឹងអត្ថប្រយោជន៍នៃការពង្រឹងបដិវត្តន៍"[៤៣]។ គោលនយោបាយនេះ សមស្របនឹងទ្រឹស្តីសង្គមនិយមរបស់ ម៉ាក្ស ចំពោះករណីវណ្ណៈ កសិករតូចតាច អង់ហ្គែល្ស បានប្រកាសនូវគោលគំនិតរបស់ម៉ាក្សថា "នៅពេលណាដែលយើងនឹងបានក្តោបក្តាប់រដ្ឋអំណាច យើងមិនអាចមានអារម្មណ៍ថា ត្រូវដកហូតកម្មសិទ្ធិរបស់កសិករតូចតាចដោយអាងកម្លាំង (ទោះការដកហូតកម្មសិទ្ធិនេះ ធ្វើដោយមាន ឬ ដោយគ្មានសំណងក៏ដោយ( ដូចដែលយើងមានអារម្មណ៍ថា នឹងត្រូវតែដកហូតកម្មសិទ្ធនេះ សម្រាប់តែនាយទុន ម្ចាស់ដីធំៗនោះឡើយ។ ករណីយកិច្ចរបស់យើងចំពោះកសិករ តូចតាចជាបឋមត្រូវតែកែប្រែផលិតកម្ម ឯកជនរបស់កសិករតូចតាចអោយទៅជាការបង្កបង្កើនផលសហករណ៍មិនមែនក្នុងករណីនេះត្រូវធ្វើដោយការបង្ខិតបង្ខំទេ ប៉ុន្តែតាមគំរូរបស់គេ ហើយឱ្យការបង្កបង្កើនផលនេះ មានរួមសហការពីសំណាក់សង្គមប៉ុណ្ណោះ។ ដូច្នេះ យើងមិនខ្វះមធ្យោបាយនឹងធ្វើឱ្យកសិករមើលឃើញនូវអត្ថប្រយោជន៍ជាក់ស្តែងដែលនឹងមានចំពោះខ្លួនគេចាប់តាំងពីពេលកែប្រែកម្មសិទ្ធិនេះទៅនោះទេ គឺអត្ថប្រយោជន៍ដែលនឹងបានចាប់ផ្តើមពន្យល់កសិករតាំងពីពេលនេះទៅ"[៤៤]។ លក្ខណសម្បត្តិទាំងអស់នេះបានធ្វើឱ្យប្រជាជនខ្មែរភាគច្រើនរស់នៅក្រោម ការដឹកនាំរបស់រដ្ឋអំណាចថ្មី ហើយដំណើរចងក្រងសហគមន៍សាមគ្គី សមូហភាពបានដំណើរការលឿនទៅមុខគឺ នៅឆ្នាំ១៩៧៩ ក្រុមសាមគ្គីបង្កបង្កើនផលមានជាង ៥០.០០០ក្រុម ៖ ប្រភេទទី១មាន៣% ប្រភេទទី២មាន២៧% និងប្រភេទទី៣ មាន ៧០%។ នៅឆ្នាំ១៩៨៤ ក្រុមសាមគ្គីបង្កបង្កើនផលទាំងអស់មានចំនួន១០២.៩៥០ក្រុម ៖ ប្រភេទទី១មាន ១០.២៥០ក្រុម (១០%) ប្រភេទទី២មាន ៥៦.៦២៣ក្រុម (៥៥%) ប្រភេទទី៣មាន ៣៦.០៣២ក្រុម (៣៥%)។ រីឯសេដ្ឋកិច្ចឯកជន ទោះជាពេលនោះរដ្ឋអំណាចមិនបានកំណត់ឱ្យមានក៏ដោយតែ សេដ្ឋកិច្ចនេះកើតមានជាសន្សឹមៗតាំងពីគ្រាដំបូងក្នុងចំណោមប្រជាជន ដើម្បីដោះស្រាយជាបន្ទាន់នូវការអត់ឃ្លាននិងតម្រូវការក្នុងជីវភាពរស់នៅ ដោយផ្តើមចេញពីការព្រមព្រៀងគ្នាទៅវិញទៅមករបស់ប្រជាជន ក្នុងការដោះដូរស្បៀង

---

[៤៤] កាសែតកម្ពុជា លេខ ៥៧ ថ្ងៃទី០៥ ខែ០២ ឆ្នាំ១៩៨០

[៤៥] ហ្វ.អង់ហ្គែល្ស, បញ្ហាកសិកម្មនៅក្នុងបស្ចិមប្រទេស, ដកស្រង់ចេញពីសៀវភៅ ៖ ឡេនីន, ស្នាដៃនិពន្ធន៍ជ្រើសរើសរែ១២ក្បាល, ក្បាលទី១, ប្រូហ្គេស្ស, ម៉ូស្គូ, ១៩៨៧, ទំព័រ ៥៦ (បកប្រែដោយ ងួន នន្ទ)

អាហារថ្នាំសង្កូវ និងរបស់ប្រើប្រាស់ផ្សេងៗ ដូចប្រសាសន៍របស់លោក ហ៊ុន សែន " ... សេដ្ឋកិច្ចឯកជនបានកើតមានឡើងតាំងពីជំហានដំបូង ហើយបានរីកដុះដាលជាបណ្តើរៗក្នុងវិស័យកសិកម្ម វិស័យសិប្បកម្ម វិស័យសេវាកម្មលក់ដូរ ដឹកជញ្ជូន[៤៦]។ល។"

តាមទ្រឹស្តីរបស់លោក កាល់ ម៉ាក្ស នៅក្នុងស្ថានភាពសមស្របកម្លាំងផលិតកម្មមានការរីកចម្រើនជាលំដាប់ ក៏ដូចគ្នាដែរកម្លាំងផលិតកម្មនៅកម្ពុជាមានការរីកចម្រើនក្រោយពីចាកផុតពីគ្រោះអត់ឃ្លាននិងមានសេរីភាពនៅលើរាងកាយរបស់ខ្លួន ម្ល៉ោះហើយវាទាមទារឱ្យទំនាក់ទំនងផលិតកម្មត្រូវកែប្រែឱ្យសមស្របនឹងកម្លាំងផលិតកម្មដែរ ប្រៀបដូចជារាងកាយនិងសម្លៀកបំពាក់គឺនៅពេលដែលរាងកាយកាន់តែធំ វាទាមទារឱ្យមានសម្លៀកបំពាក់ធំល្មមនឹងខ្លួនវា វាមិនអាចបន្តពាក់អាវដែលតូចជាងខ្លួនបានឡើយ បើនៅបន្តពាក់អាវនោះនឹងរហែក។ ករណីនេះហើយទើបសន្និបាតកម្មាភិបាលទូទាំងប្រទេសរបស់បក្សពីថ្ងៃទី២ដល់ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៨៤ បានឱ្យសច្ចាប័នទទួលស្គាល់សមាសភាពសេដ្ឋកិច្ចឯកជន ដើម្បីប្រើប្រាស់ឱ្យអស់ប្រភពទុន បច្ចេកទេសនិងពលកម្មរបស់ប្រជាជនក្នុងការកសាងប្រទេស ហើយមហាសន្និបាតបក្សលើកទី៥ ក៏បានឱ្យសច្ចាប័នទទួលស្គាល់សមាសភាពសេដ្ឋកិច្ចនេះដែរ។ ម្យ៉ាងទៀត កម្មាភិបាលជំនាញសេដ្ឋកិច្ច និងកម្មាភិបាលមូលដ្ឋានមួយចំនួនមានសមត្ថភាពខាងសេដ្ឋកិច្ចនៅមានកម្រិតទាបនិងជួនកាលមានការអនុវត្តជ្រុលហួសហេតុផង បានបង្កឱ្យមានការលំបាកនិងរាំងស្ទះដល់ការផលិតរបស់ប្រជាជន "...ពេលកម្មាភិបាលនៅមូលដ្ឋានមួយចំនួនអនុវត្តវិធានការគ្រប់គ្រងទីផ្សារនៅមូលដ្ឋានហួសហេតុក៏បានបង្កឡើងនូវការលំបាកសម្រាប់តំបន់ទាំងពីរហើយក៏ជះឥទ្ធិពលមិនល្អដល់ផលិតកម្មនៃតំបន់ទាំងពីរទៀត" (តំបន់ផលិតកសិផល និងតំបន់ដំណាំឧស្សាហកម្ម)។ កាសែតកម្ពុជាបានគូស បញ្ជាក់ថា "បុគ្គលិក កម្មាភិបាលដឹកនាំរបស់យើងមានកម្រិតវប្បធម៌នៅទន់ទាប ពុំមានបទពិសោធដឹកនាំច្បាស់លាស់ ហេតុដូច្នេះ គេពិបាកដឹកនាំវឌ្ឍនភាពផលិតកម្មកសិកម្ម" រួមជាមួយការណែនាំរបស់ថ្នាក់លើចំពោះថ្នាក់ ក្រោមមិនបានគ្រប់គ្រាន់ផង បានចាត់តាំងរៀបចំក្រុម សាមគ្គីបង្កបង្កើនផលដំណើរការមិនបានល្អ ដូចជា ទំហំក្រុមសាមគ្គីធំពេកនាំឱ្យការគ្រប់គ្រងកម្លាំងពលកម្ម ការបែងចែកផលមិនទាន់បានត្រឹមត្រូវ ប្រធានក្រុម សាមគ្គីខ្លះមិនទាន់យល់ពីគោលបំណងនៃការធ្វើសមូហភាពនីយកម្ម បណ្តាលឱ្យការដឹកនាំគ្រប់គ្រងជួបការខុសឆ្គងដូចជាប្រើ "បទបញ្ជា" ជំនួស "ការអប់រំផ្សព្វផ្សាយ" "ការមិនប្រមូលមតិពីសមាជិកក្នុងក្រុម" "ការមិនទទួលស្គាល់នូវអសមត្ថភាពរបស់ខ្លួន" (ការជ្រើសរើសប្រធានក្រុមដោយផ្អែកលើប្រវត្តិរូប "ល្អ" បានធ្វើឱ្យសមាជិកក្រុមខ្លះមានការយល់ដឹងពីការងារបង្កបង្កើនផលច្រើនជាងមេក្រុម) ការពុករលួយនៅក្នុងក្រុមសាមគ្គី និងការលួចទ្រព្យសម្បត្តិក្រុមសាមគ្គីជាដើម។ កំហុសឆ្គងទាំងអស់នេះមានដូចការបង្ហាញក្នុងកិច្ចប្រជុំរដ្ឋសភា នៅឆ្នាំ១៩៨៤ថា «អំណាចមូលដ្ឋានត្រូវតែផ្លាស់ប្តូរប្រធានក្រុមសាមគ្គី ១ ឱ្យបានញឹកញាប់ ព្រោះពួកគេមិនត្រឹមតែគ្មានសមត្ថភាពដឹកនាំការងារពលកម្មនោះទេ ហើយថែមទាំងប្រឹងប្រែងដើម្បីខ្លួនឯងតែប៉ុណ្ណោះ កាយវិការនេះធ្វើឱ្យខូចអត្ថប្រយោជន៍បដិវត្តន៍" ដែលធ្វើឱ្យសតិអារម្មណ៍របស់ប្រជាជនមិនយកចិត្តទុកដាក់ដល់ការងាររបស់ក្រុមសាមគ្គី ហើយបែរជាយកចិត្តទុកដាក់សេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចឯកជនវិញ។ នេះក៏ជាមូលហេតុមួយដែលធ្វើឱ្យសេដ្ឋកិច្ចសមូហភាពនៅនឹង ឬ មានការថយចុះជា

[៤៦] ហ៊ុន សែន ១០ឆ្នាំនៃដំណើរកម្ពុជា(១៩៧៩-១៩៨៩), ទំព័រ ២៣៦-២៣៧

លំដាប់។ ដូច្នេះហើយ ទើបគណៈកម្មាធិការមជ្ឈិមបក្សប្រជាជនបដិវត្តន៍កម្ពុជាបានអនុម័តិនូវសេចក្តីសម្រេចចិត្តស្តីអំពី ការរំសាយក្រុមសាមគ្គីប្រភេទទីមួយ នាខែធ្នូ ឆ្នាំ១៩៨៣។

ម្យ៉ាងទៀត ជំនួយមនុស្សធម៌ ពិសេសស្បៀងអាហារនៃអង្គការអន្តរជាតិផ្សេងៗមាន យូនីសេហ្វ កាកបាទក្រហម កម្មវិធីស្បៀងអាហារពិភពលោក OXFAM និង FAO បានផ្តល់មកបន្ថែមលើជំនួយរបស់សហភាពសូវៀត និងវៀតណាម ដើម្បីជួយប្រជាជនខ្មែរឱ្យផុតពីគ្រោះទុរ្ភិក្ស។ ក្រៅពីការជួយឧបត្ថម្ភដ៏ធំធេង ជំនួយទាំងអស់នេះ ក៏បានជះឥទ្ធិពលមកដល់សមាសភាពសេដ្ឋកិច្ចផ្សេងៗនៅកម្ពុជាដែរ ពីព្រោះជំនួយទាំងនោះបានក្លាយទៅជាទំនិញនៅលើទីផ្សារពាសពេញប្រទេសដោយឥតគ្រោងទុកដែលក្នុងនោះ គេបានយកមាសនិងអង្ករជាវត្ថុគោលសម្រាប់ដោះដូរទំនិញផ្សេងទៀត។ ស្ថានភាពជាក់ស្តែងក្នុងសង្គមកម្ពុជានាពេលនោះ បានរួមចំណែកធ្វើឱ្យសមាសភាពសេដ្ឋកិច្ចទាំងអស់ដែលរដ្ឋអំណាចបានកំណត់មានការប្រែប្រួលជាបន្តបន្ទាប់។ ការរំសាយក្រុមសាមគ្គីប្រភេទទីមួយ និងការទទួលស្គាល់សមាសភាពសេដ្ឋកិច្ចឯកជនរបស់គណៈកម្មាធិការមជ្ឈិមបក្សប្រជាជនបដិវត្តន៍កម្ពុជា ជាមូលដ្ឋានដល់ការលេចឡើង ការធ្វើដំណើរ និងអត្ថិភាពនៃទំនាក់ទំនងសេដ្ឋកិច្ចទីផ្សារនៅកម្ពុជា។

ឆ្លងតាមស្ថានភាពជាក់ស្តែងនៃជនបទស្រែចំការក្នុងប្រទេសកម្ពុជា យើងឃើញថា ទំនាក់ទំនងផលិតកម្ម ប្រែប្រួលមិនទាន់តម្រូវការចាំបាច់របស់កម្លាំងផលិតកម្ម ហេតុនេះហើយបានជាគណៈកម្មាធិការមជ្ឈិមបក្សប្រជាជនបដិវត្តន៍កម្ពុជាបានចេញសេចក្តីសម្រេចចិត្តជាបន្តបន្ទាប់ដោយផ្អែកលើទស្សនវិជ្ជាម៉ាក្សលេនីនគឺក្រឹត្យក្រមសេដ្ឋកិច្ច ផ្អែកលើលក្ខណសម្បត្តិជាក់ស្តែងរបស់កម្ពុជា និងនិន្នាការរបស់ពិភពលោក។

សរុបមក ក្រោយថ្ងៃ ៧ មករា ១៩៧៩ កម្ពុជាត្រូវការរបបមួយដែលអាចជួយប្រជាជនខ្មែរទាំងអស់ឱ្យចេញផុតពីការកាប់សម្លាប់នៃរបបប៉ុល ពត និងការអត់ឃ្លានចំពោះមុខនាពេលនោះ។ ក្នុងស្ថានភាពសង្គមច្របូកច្របល់មិនទាន់មានការគ្រប់គ្រងច្បាស់លាស់ ទាំងនយោបាយ សេដ្ឋកិច្ចសង្គមនិងសតិអារម្មណ៍មនុស្ស និង ចំណោទបញ្ហាចំពោះមុខខាងគ្រោះទុរ្ភិក្ស សុខភាពរាងកាយ និងផ្លូវចិត្តបានជំរុញប្រជាជនកម្ពុជា ត្រូវដើរតាមមាគ៌ាចែកគ្នារស់សិន និងទប់ស្កាត់ការវិលមកវិញនូវរបបកាប់សម្លាប់។ អ្នកដែលបានមកជួយប្រជាជនកម្ពុជាបាន ទាន់ពេលវេលាគឺកម្លាំងដែលដើរតាមលទ្ធិម៉ាក្ស-លេនីន។ ដូច្នេះការដើរតាមលទ្ធិម៉ាក្ស លេនីន របស់រដ្ឋអំណាចថ្មីគឺ សមស្របទៅតាមស្ថានភាពជាក់ស្តែង ព្រោះដើម្បីដោះស្រាយភាពច្របូកច្របល់ក្នុងសង្គម និងទប់ស្កាត់ការវិលមកវិញនៃរបប ប៉ុល ពតនាពេលនោះ ដែលទាមទារត្រូវមានបក្សតែមួយប្រកបដោយឆន្ទៈរឹងមាំដឹកនាំ ដើម្បីដោះស្រាយបាននូវគ្រោះអត់ឃ្លានចំពោះមុខរបស់ប្រជាជនក្នុងសភាពដែលកម្លាំងផលិតកម្មសង្គមខ្ទេចខ្ទាំ និងខ្វះខាត ហើយមធ្យោបាយផលិតកម្មបានក្លាយទៅជាកម្មសិទ្ធរួមទៅហើយ ហេតុនេះវាសមស្របនឹងគោលនយោបាយសមូហភាពនីយកម្ម ដោយឱ្យប្រជាជនរួបរួមជាក្រុមសាមគ្គី បង្កបង្កើនផលប៉ុណ្ណោះទើបអាចជួយគ្នាបាន។

ក្នុងគ្រាដំបូងទោះបីជានៅជួបការលំបាក ការខ្វះខាតផ្នែកសម្ភារៈ និងសេចក្តីអត់ឃ្លានក៏ដោយ តែវាគ្រាន់បើជាងការរស់នៅប្រកបដោយភាពភ័យខ្លាចក្នុងរបបប៉ុលពតដែរ ហើយប្រជាជនខ្មែរគ្រប់រូបមានសេរីភាពក្នុងការដាំដុះ ការហូបចុក ការដើរហើរ ការជួបជុំគ្រួសារ តាមលទ្ធភាពរបស់គ្រួសារនីមួយៗ។ ទាំងអស់នេះជាតម្រូវការចំពោះមុខរបស់ប្រជាជនខ្មែរនាពេលនោះ។ សេរីភាពនេះបាននាំទៅដល់ការកើតឡើងដោយស្វ័យប្រវត្តិនូវទំនាក់ទំនងទីផ្សារតាំងពីឆ្នាំ១៩៧៩ គ្រាន់តែស្ថិតនៅក្នុងទ្រង់ទ្រាយតូចតាចជាលក្ខណៈគ្រួសារប៉ុណ្ណោះ។

ការហ៊ុមព័ទ្ធសេដ្ឋកិច្ចពីសំណាក់ប្រទេសមួយចំនួន ការប្រឆាំងរបស់រដ្ឋាភិបាលចម្រុះត្រីភាគីដែលមានការគាំទ្រពីសហរដ្ឋអាម៉េរិក និងចិន ព្រមទាំងបណ្តាប្រទេសអាស៊ានផងនោះ បានធ្វើឱ្យរដ្ឋអំណាចថ្មីនៃកម្ពុជារិះរកគ្រប់វិធីគ្រប់លទ្ធភាព ដើម្បីដោះស្រាយទំនាស់និងកសាងប្រទេសឡើងវិញ។ ប្រការនេះហើយដែលធ្វើឱ្យគោលនយោបាយផ្សេងៗរបស់រដ្ឋាភិបាលកម្ពុជា តែងតែកែសម្រួលជាបន្តបន្ទាប់ឱ្យសមស្របទៅតាមការវិវត្តនៃសភាពការណ៍ជាក់ស្តែងរបស់កម្ពុជា និងបានទទួលការគាំទ្រពីប្រជាជន។ ម្យ៉ាងទៀត ទស្សនវិជ្ជាម៉ាក្ស ក៏បានលើកឡើងថា បញ្ហាជោគជ័យឬបរាជ័យក៏អាស្រ័យមួយចំណែកនៃតួនាទីរបស់បុគ្គលមគ្គុទ្ទេសក៍ដែរ។

ពេលខ្លះទៀត ឥទ្ធិពលទស្សនវិជ្ជានេះហាក់ដឹកនាំ ប្រទេសកម្ពុជាឱ្យធ្លាក់ទៅក្នុងភ្លក់ភ្លើងសង្គ្រាមទៅវិញ ប៉ុន្តែបើយើងពិនិត្យទៅលើការប្រតិបត្តិជាក់ស្តែង យើងនឹងឃើញថា ទស្សនវិជ្ជាជាមូលដ្ឋានសម្រាប់យើងពិចារណា ស្វែងយល់និងវិនិច្ឆ័យ ហើយក៏បង្ហាញនូវបទពិសោធន៍ដល់អ្នកសិក្សាមិនមែនជាបទបញ្ជាឱ្យយើងអនុវត្តនោះឡើយ ពីព្រោះទស្សនៈមួយទៅជាទស្សនវិជ្ជាបានលុះត្រាតែត្រូវបានគេទទួលស្គាល់ថាមានហេតុផលត្រឹមត្រូវដែលអាចទទួលយកបាន។ ចំពោះព្រឹត្តិការណ៍ទាំងឡាយតែងខុសៗគ្នាទៅតាមទីកន្លែង និងពេលវេលា ពោលគឺជាលក្ខណៈពិសេសនៃព្រឹត្តិការណ៍ និងទៅតាមឆន្ទៈរបស់អ្នកអនុវត្តផងដែរ។ នៅក្នុងកំលុងទសវត្សទី៦០នៃសតវត្សទី២០ កម្ពុជាបានធ្លាក់ទៅក្នុងភ្នក់ភ្លើងសង្គ្រាមត្រជាក់រវាងគូបដិបក្ខទាំងពីររបស់ពិភពលោកគឺ លោកសេរី និង លោកកុម្មុយនីស្ត ដោយសារទីតាំងនៃប្រទេសកម្ពុជាដែលស្ថិតនៅចន្លោះនៃប្រព័ន្ធទាំងពីរគឺ ប្រទេសថៃ ដែលដើរតាមលោកសេរី និងប្រទេសវៀតណាមដែលដើរតាមលោកកុម្មុយនីស្ត។ វិបត្តិសេដ្ឋកិច្ចក្នុងប្រទេសនាពាក់កណ្តាល ខាងចុងនៃទសវត្សទី៦០ បានជំរុញឱ្យប្រទេសកម្ពុជាត្រូវតែដើរតាមភាគីណាមួយ មិនអាចរក្សាអព្យាក្រឹតភាពរបស់ខ្លួនបានឡើយ ដូចក្នុងគោលការណ៍មិនផ្ទុយនៃអស្តិរូបវិជ្ជាបានលើកឡើងថា "គ្មានទេភាពកណ្តាលនៃភាវៈពីរ"។ ការជ្រើសរើសយកផ្លូវណាមួយ គឺអាស្រ័យទៅតាមកម្លាំងណាដែលខ្លាំងជាង និងស្របតាមនិន្នាការរបស់ពិភពលោកនាពេលនោះ។ ម្យ៉ាងទៀត ទស្សនវិជ្ជាម៉ាក្សក៏បានលើកឡើងថា បញ្ហាជោគជ័យ ឬបរាជ័យក៏អាស្រ័យមួយចំណែកនៃតួនាទីរបស់បុគ្គលមគ្គុទ្ទេសក៍ដែរ។

# វិស័យឯកជន និងការងារ



សួង ម៉េងឡុង
បេក្ខជនបណ្ឌិតវគ្គទី២ ផ្នែកវិទ្យាសាស្ត្រនយោបាយ
នៃរាជបណ្ឌិត្យសភាកម្ពុជា

រដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ និងឯកភាពលើចំណុចមួយដ៏សំខាន់ដែលថា ផ្នែកឯកជនជាកម្លាំងដ៏សំខាន់សម្រាប់ការវិនិយោគ និងកំណើនក្នុងប្រទេស។ តួនាទីរបស់រាជរដ្ឋាភិបាល គឺជាអ្នកជំរុញអ្នកលើកទឹកចិត្ត អ្នកជួយបង្កលក្ខណៈ អ្នកជួយសម្របសម្រួល និងជានិយ័តករ។ កម្រិតដ៏ធំនៃការវិនិយោគ គឺជាតម្រូវការចាំបាច់ ដើម្បីថែរក្សា និងបង្កើនល្បឿនសន្ទុះនៃកំណើនសេដ្ឋកិច្ច ដែលត្រូវផ្អែកលើមូលដ្ឋានច្រើន។ ផ្នែកឯក-ជនដែលមានកំណើនដ៏រឹងមាំ បំពេញបន្ថែមវិនិយោគសាធារណៈក្នុងវិស័យសង្គមកិច្ចបានទាក់ទាញអ្នកចូលរួមក្នុងកម្លាំងពលកម្មដែលចេះតែកើនឡើង និងបង្កើតជំនាញផ្សេងៗជាច្រើន។ មុំទាំង៤ នៃចតុកោណនេះគឺ (១) ការពង្រឹងវិស័យឯកជន និងការទាក់ទាញការវិនិយោគ (មានវិស័យកាត់ដេរសម្លៀកបំពាក់ និងទេសចរណ៍) (២) ការបង្កើតការងារ និងការធានាលក្ខខណ្ឌការងារល្អប្រសើរជូនដល់កម្មករ និងនិយោជិត (៣) ការលើកស្ទួយសហគ្រាសធុនតូច និងមធ្យម និង (៤) ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គម សម្រាប់មន្ត្រីបុគ្គលិកកម្មករ។ រាជរដ្ឋាភិបាលកម្ពុជា បានកាត់បន្ថយចំណាយក្នុងការធ្វើធុរកិច្ច បានពង្រីកលទ្ធភាពប្រើប្រាស់ទីផ្សារ បានកាត់បន្ថយចំណាយក្នុងការដឹកជញ្ជូនក្នុងស្រុក ហើយបានលើកកម្ពស់សុវត្ថិភាព តាមរយៈការកែលម្អហេដ្ឋារចនា-សម្ព័ន្ធជាមូលដ្ឋាន ដែលជំរុញឱ្យមានផងដែរនូវការបញ្ចូលគ្នារវាងសេដ្ឋកិច្ចទីប្រជុំជននិងសេដ្ឋកិច្ចជនបទ។ វឌ្ឍនភាពដែលធ្វើឱ្យកើតមានឡើងមកទល់ពេលនេះ ដើម្បីឈានទៅសម្រេចបានអាទិភាពទាំងនេះ បានចូលរួមចំណែកយ៉ាងធំធេង ចំពោះការអភិវឌ្ឍថ្មីៗក្នុងវិស័យជាច្រើនផ្សេងទៀត និងចំពោះការពង្រឹងស្ថានភាពសេដ្ឋ-កិច្ច សង្គមកិច្ចរបស់ប្រជាជនជនបទ ជាពិសេសអ្នកក្រីក្រ។

ការវិនិយោគក្នុងវិស័យឯកជន កំពុងមានការកើនឡើងយ៉ាងឆាប់រហ័សដែលអាចពិនិត្យឃើញនៅក្នុងសូចនាករម៉ាក្រូសេដ្ឋកិច្ច និងរូបិយវត្ថុ ដោយតាមរយៈនេះបានបង្កើនការជឿជាក់ និងភាពកក់ក្តៅក្នុងចំណោមអ្នកវិនិយោគឯកជនជាតិ និងអន្តរជាតិនានាក្នុងសេដ្ឋកិច្ចកម្ពុជា។ ប្រការនេះ គឺជាភស្តុតាងដ៏ធំនៃជោគជ័យរបស់គោលនយោបាយ ដែលជួយជំរុញឱ្យមានលទ្ធផលវិជ្ជមាន និងដែលមានលក្ខណៈជឿនលឿនរបស់រាជ-រដ្ឋាភិបាលកម្ពុជា (ការធានាឱ្យមានសន្តិភាព ស្ថិរភាពគោលនយោបាយ ច្បាប់ និងសណ្តាប់ធ្នាប់ ការគ្រប់គ្រងដោយច្បាប់ កំណើនម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយរូបិយវត្ថុ និងការបង្កើតនូវបរិយាកាសអំណោយផលមួយ សម្រាប់ការអភិវឌ្ឍវិស័យឯកជន។ រាជរដ្ឋាភិបាលកម្ពុជា បានជំរុញយុទ្ធសាស្ត្រកំណើនដែលនាំមុខដោយការនាំចេញ និងដែលសម្រាប់គាំទ្រប្រជាជនក្រីក្រដោយផ្តោតលើការធ្វើពិពិធកម្ម និងការពង្រីកឱ្យបានទូលំ-ទូលាយនូវមូលដ្ឋានសេដ្ឋកិច្ច ហើយបានលើកទឹកចិត្ត ជួយសម្រួល និងផ្តល់ការគាំទ្រដល់ការវិនិយោគ របស់វិស័យឯកជនក្នុងវិស័យអាទិភាពមួយចំនួន។

វេទិកាពិភាក្សារវាងផ្នែកឯកជន និងរាជរដ្ឋាភិបាលកម្ពុជា ហៅថាវេទិការាជរដ្ឋាភិបាល-វិស័យឯកជន ដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលប្រារព្ធធ្វើឡើងជារៀងរាល់ ៦ខែម្តង និងការងាររបស់គណៈកម្មាធិការពិគ្រោះយោបល់ និងគណៈកម្មាធិការផ្សេងៗទៀត បាន

ផ្តល់នូវយុត្តាធិការយ៉ាងសំខាន់ សម្រាប់កិច្ចសហប្រតិបត្តិការដ៏មានអត្ថន័យ និងការយល់ដឹងគ្នាទៅវិញទៅមករវាងរាជរដ្ឋាភិបាលកម្ពុជា និងវិស័យឯកជន។ ក្រុមការងារមួយផ្សេងទៀតសម្រាប់ធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនង រវាងនិយោជិត និងនិយោជក ត្រូវបានរៀបចំឡើង។ ការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ និងការពង្រឹង និងការលើកកម្ពស់សកម្មភាពពាណិជ្ជកម្ម ត្រូវបានបញ្ចូលក្នុងវិស័យអាទិភាពសម្រាប់ពិចារណាផងដែរ។

ដើម្បីកាត់បន្ថយនូវរបាំងក្នុងការស្វែងរកសេចក្តីអនុម័តិនានា ពីបណ្តាក្រសួង និងភ្នាក់ងារពាក់ព័ន្ធផ្សេងៗ រដ្ឋាភិបាលកម្ពុជាបានបង្កើតនូវយន្តការច្រកចេញ-ចូលតែមួយ ដែលអនុញ្ញាតឱ្យបណ្តាអ្នកវិនិយោគអាចទទួលបានការអនុម័តិជាកញ្ចប់ ក្នុងការស្នើសុំការវិនិយោគ។ គណៈកម្មការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាអ្នកគ្រប់គ្រងលើការអនុវត្តយន្តការច្រកចេញ-ចូលតែមួយនេះ។ ក្នុងស្មារតីកាត់បន្ថយពេលវេលា សម្រាប់ការអនុម័តិលើការស្នើសុំការវិនិយោគ និងបង្កលក្ខណៈឱ្យកាន់តែងាយស្រួលថែមទៀតដល់ អ្នកវិនិយោគ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចផ្តល់សិទ្ធិជូនអនុគណៈកម្មការ រាជធានី-ខេត្ត ពិនិត្យសម្រេចលើគម្រោងវិនិយោគនានា ដែលមានទុនវិនិយោគតិចជាង២លានដុល្លារអាមេរិក។

គណៈកម្មការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានបង្កើតនូវយន្តការ "ការយកចិត្តទុកដាក់ចំពោះវិនិយោគិន" និង "ប្រព័ន្ធតាមដាន និងត្រួតពិនិត្យការវិនិយោគ" ដើម្បីដោះស្រាយបញ្ហាប្រឈមនានារបស់វិនិយោគិន និងដើម្បីតាមដានពិនិត្យវឌ្ឍនភាពនៃការអនុវត្តគម្រោងវិនិយោគនានា ដែលទទួលបានការអនុម័តិរួចហើយ។ រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាធានានូវតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពក្នុងការផ្តល់នូវសេវាកម្មទាំងឡាយដល់វិនិយោគិន។ ទន្ទឹមនេះដែរអាទិភាពចម្បងមួយរបស់រដ្ឋាភិបាល គឺបន្តធ្វើឱ្យមានប្រសិទ្ធភាព និងធ្វើឱ្យប្រសើរឡើងក្នុងការផ្តល់សេវាកម្មដល់វិនិយោគិនតាមរយៈការពង្រឹងសមត្ថភាពបច្ចេកទេសរបស់មន្ត្រី ជាពិសេសមន្ត្រីថ្នាក់មធ្យមនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

រាជរដ្ឋាភិបាលបានចុះហត្ថលេខាទ្វេភាគី លើកិច្ចព្រមព្រៀងស្តីពីការជំរុញ និងការការពារការវិនិយោគចំនួន២៤ និងកំពុងបន្តការចរចាជាបន្តបន្ទាប់ទៀត ជាមួយបណ្តាប្រទេសផ្សេងៗក្នុងក្របខ័ណ្ឌអាស៊ានអេប៉ិកសហរដ្ឋអាម៉េរិក អឺរ៉ុប និងតំបន់មជ្ឈិមបូព៌ា ដើម្បីជំរុញការអភិវឌ្ឍវិស័យឯកជនឱ្យបានទូលំទូលាយជាងមុននិងកិច្ចព្រមព្រៀងចំនួន១៧ផ្សេងទៀត ជាមួយបណ្តាប្រទេសក្នុងតំបន់មជ្ឈិមបូព៌ា អាស៊ីខាងកើត និងអឺរ៉ុប។

ក្រសួងពាណិជ្ជកម្មកំពុងបន្តធ្វើការងារ លើការធ្វើឱ្យមានប្រសិទ្ធភាពនូវដំណាក់កាល សម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម ការផ្តល់ព័ត៌មានទីផ្សារ ការរៀបចំសហគមន៍ផលិតផល ការអនុវត្តកម្មវិធីរោងចក្រល្អប្រសើរ ការសម្របសម្រួល និងជំរុញពាណិជ្ជកម្ម និងការពង្រឹងឡើងវិញនូវច្បាប់កម្មសិទ្ធិបញ្ញាទាំងឡាយ។ ដូច្នេះដើម្បីសម្រួលដល់ការចុះបញ្ជីពាណិជ្ជកម្ម នៅក្នុងខែកញ្ញា ឆ្នាំ២០០៧ ក្រសួងពាណិជ្ជកម្មបានបង្កើតការិយាល័យ ចុះបញ្ជីពាណិជ្ជកម្មនៅតាមសាខាថ្នាក់ខេត្ត ដូចជា សាខាខេត្តបាត់ដំបងជាដើម សម្រាប់សម្រួលដល់កិច្ចការពាណិជ្ជកម្ម ដល់ខេត្តបាត់ដំបងផ្ទាល់ ខេត្តពោធិ៍សាត់ ខេត្តប៉ៃលិន និងខេត្តបន្ទាយមានជ័យ។ ទន្ទឹមនេះក្រសួងពាណិជ្ជកម្ម នៅមានផែនការក្នុងការបើកការិយាល័យ ចុះបញ្ជីពាណិជ្ជកម្មបន្ថែមទៀត នៅក្នុងខេត្តមួយចំនួនទៀតដូចជា៖

- ក្នុងឆ្នាំ២០១០ ការិយាល័យចុះបញ្ជីពាណិជ្ជកម្មមួយ នឹងត្រូវបង្កើតក្នុងសាខាខេត្តព្រះសីហនុសម្រាប់សម្រួលដល់កិច្ចការពាណិជ្ជកម្ម ក្នុងខេត្តព្រះសីហនុផ្ទាល់ ខេត្តតាកែវ ខេត្តកំពត និងខេត្តកោះកុង។

- ក្នុងឆ្នាំដដែលនេះដែរ ការិយាល័យចុះបញ្ជីពាណិជ្ជកម្មមួយ នឹងត្រូវបង្កើតក្នុងសាខាខេត្តក្រចេះ សម្រប សម្រួលដល់កិច្ចការពាណិជ្ជកម្មខេត្តក្រចេះផ្ទាល់ ខេត្តស្ទឹងត្រែង ខេត្តមណ្ឌលគិរី និងខេត្តរតនគិរី។
- នៅក្នុងឆ្នាំ២០១២ ការិយាល័យចុះបញ្ជីពាណិជ្ជកម្មមួយ នឹងត្រូវបង្កើតក្នុងសាខាខេត្តសៀមរាបសម្រាប់ សម្រួលដល់កិច្ចការពាណិជ្ជកម្ម ដល់ខេត្តសៀមរាបផ្ទាល់ និងឧត្តរមានជ័យ។
- ដោយឡែកសម្រាប់ឆ្នាំ២០១៣ ក្រសួងពាណិជ្ជកម្មនឹងរៀបចំប្រព័ន្ធអេឡិចត្រូនិក សម្រាប់ផ្តល់ ការងាយស្រួល ក្នុងការចុះបញ្ជីពាណិជ្ជកម្ម។

រហូតមកដល់ពេលបច្ចុប្បន្ន ក្រសួងពាណិជ្ជកម្មបានផ្តល់ព័ត៌មានទីផ្សារពាណិជ្ជកម្ម តាមរយៈព្រឹត្តិប័ត្រ និងទូរទស្សន៍តែប៉ុណ្ណោះ។ ដូច្នេះក្នុងឆ្នាំ២០០៨ ដើម្បីជំរុញការលើកកម្ពស់ព័ត៌មានទីផ្សារពាណិជ្ជកម្ម ក្រសួង បានរៀបចំប្រព័ន្ធទំនាក់ទំនងទីផ្សារអេឡិចត្រូនិក ដែលនឹងសង្ឃឹមថាអាចផ្តល់នូវព័ត៌មានលឿន និងប្រសើរជាង មុន។ គ្រប់ព័ត៌មានដែលមានក្នុងប្រព័ន្ធទំនាក់ទំនង ទីផ្សារអេឡិចត្រូនិក អាចទទួលបានតារយៈការប្រើប្រាស់ ជាមួយនឹងទូរស័ព្ទចល័តដូចជា ព័ត៌មានអំពីតម្លៃកសិផល ផលិតផលម្ហូបអាហារ អត្រាប្តូរប្រាក់ និងតម្រូវការ ផ្សេងៗរបស់ទីផ្សារ។

ក្រសួងពាណិជ្ជកម្មក៏បានផ្តល់ជំនួយផងដែរ ក្នុងការរៀបចំសមាគមអាជីវកម្មដើម្បីលើកកម្ពស់ សមត្ថ-ភាពផលិតកម្ម និងដើម្បីធ្វើសមាហរណកម្មផលិតផលទំនិញ ចូលទៅក្នុងទីផ្សារក្នុងស្រុកទីផ្សារផលិតផល ពិសេស និងទីផ្សារពិភពលោក។ ជាក់ស្តែងរវាងឆ្នាំ២០០៧-២០០៩ ក្រសួងបានជួយរៀបចំសមាគមអាជីវកម្ម ក្នុងនោះរួមមានសមាគមអភិវឌ្ឍន៍សម្រេច សមាគមអភិវឌ្ឍន៍ស្ករត្នោត សមាគមអភិវឌ្ឍន៍កសិកម្មតំបន់ពាយ័ព្យ និងសមាគមអភិវឌ្ឍន៍ប្រហុកអប់នៅកំពង់ឃ្លាំង។ បច្ចុប្បន្ននេះ ក្រសួងកំពុងជួយរៀបចំសមាគមអាជីវកម្ម ស្វាយចន្ទី នៅខេត្តកំពង់ចាម និងខេត្តកំពង់ធំ ថែមទៀតផង។ ដូច្នេះការរៀបចំសមាគមអាជីវកម្ម អាចជួយ ប្រែក្លាយពីការធ្វើពាណិជ្ជកម្មគ្រួសារឱ្យទៅជាការធ្វើពាណិជ្ជកម្ម ដោយមានយុទ្ធសាស្ត្រសម្រាប់ទីផ្សារ ដែល មានចីរភាព និងមានសមត្ថភាពប្រកួតប្រជែងខ្ពស់ក្នុងទីផ្សារពិភពលោក។

ដើម្បីសម្រួលដល់ការជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្មបានអនុវត្តយ៉ាងសកម្មនូវអនុក្រឹត្យ ស្តីពី កិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ ដែលត្រូវបានអនុម័តិក្នុងខែមីនា ឆ្នាំ២០០៦ និង អនុវត្តមូលនិធិបើកច្រកទីផ្សារនាំចេញ ដែលគាំទ្រដោយធនាគារពិភពលោក។ ដោយឡែកក្រសួង បានរៀបចំ "ពិព័ណ៌ពាណិជ្ជកម្ម" និងបានរៀបចំកិច្ចប្រជុំជំនួញពាណិជ្ជកម្មជាច្រើនលើកច្រើនសារ ជាមួយដៃគូបរទេស ដើម្បីជំរុញឱ្យអាជីវកម្មក្នុងស្រុក ដាក់តាំងបង្ហាញនូវផលិតផលរបស់ខ្លួន ក្នុងន័យរកដំណោះស្រាយនូវការ រាំងស្ទះផលិតផល និងសម្រួលដល់លំហូរទំនិញទៅកាន់ទីផ្សារបរទេស។

ដើម្បីពង្រឹងវិស័យឯកជន សម្រាប់ការអភិវឌ្ឍន៍ពាណិជ្ជកម្មសេដ្ឋកិច្ច និងការជំរុញសកម្មភាពពាណិជ្ជ-កម្មក្នុងស្រុក ក្រសួងពាណិជ្ជកម្មបានរៀបចំបង្កើតសភាពាណិជ្ជកម្មខេត្តបានចំនួន១១ ចាប់ពីឆ្នាំ២០០៦ ដល់ ឆ្នាំ២០០៧ ដែលមានទីតាំងនៅក្នុងខេត្តបាត់ដំបង សៀមរាប ពោធិ៍សាត់ បន្ទាយមានជ័យ កណ្តាល តាកែវ កំពត ព្រះសីហនុ កោះកុង កំពង់ស្ពឺ និងកំពង់ចាម។ នៅឆ្នាំ២០០៨ សភាពាណិជ្ជកម្មកម្ពុជាមានតួនាទីធ្វើជា តំណាងវិស័យឯកជនកម្ពុជាក្នុងការចរចា អំពីការធ្វើពាណិជ្ជកម្មនិងការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស មកកម្ពុជា។ ដោយឡែកសភាពាណិជ្ជកម្មរាជធានីភ្នំពេញដែលបានបង្កើតឡើងចាប់តាំងពីឆ្នាំ១៩៩៥ មកកំពុង

មានតួនាទីដ៏ខំខាន់ជួយដល់ការបណ្តុះបណ្តាល និងការជួយជ្រោមជ្រែងដល់សភាពាណិជ្ជកម្មខេត្តផ្សេងៗទៀតឱ្យដំណើរការបានល្អប្រសើរ។

ក្រសួងពាណិជ្ជកម្មក៏បានខិតខំផងដែរ ក្នុងការពង្រឹងការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា ដើម្បីទប់ស្កាត់ការផលិត ការនាំចូល និងការចែកចាយផលិតផលក្លែងក្លាយ។ មន្ត្រីកាំកុងត្រូលបានត្រួតពិនិត្យជាប្រចាំតាមច្រកចេញ-ចូល ដើម្បីទប់ស្កាត់ឱ្យបានទាន់ពេលវេលារាល់ចរាចរណ៍ ទិញ-លក់ ទំនិញខូចគុណភាពដែលអាចធ្វើឱ្យប៉ះពាល់ដល់សុខភាពរបស់អ្នកប្រើប្រាស់។

ដើម្បីរក្សាការប្រកួតប្រជែងវិស័យកាត់ដេរសម្លៀកបំពាក់ ក្នុងទីផ្សារអន្តរជាតិ ក្រសួងពាណិជ្ជកម្មដោយមានកិច្ចសហការណ៍ជាមួយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបាននឹងកំពុងអនុវត្តកម្មវិធី "រោងចក្រល្អប្រសើរជាងមុន" ដើម្បីជានាលក្ខខណ្ឌការងារឱ្យកាន់តែល្អប្រសើរជាងមុន ស្របតាមស្តង់ដាអន្តរជាតិ និងផ្តល់ការអប់រំបណ្តុះបណ្តាលកម្មករនិងសហជីព អំពីច្បាប់ស្តីការងារ ដោយផ្សារភ្ជាប់នឹងលក្ខខណ្ឌពាណិជ្ជ-កម្ម ហើយលើកទឹកចិត្តឱ្យមានការកែច្នៃម៉ូត ដើម្បីជំរុញការផលិតទំនិញកែច្នៃនៅប្រទេសកម្ពុជា។

ដើម្បីជំរុញការធ្វើសមាហរណកម្មក្នុងតំបន់ ក្នុងឆ្នាំ២០០៨ គណៈកម្មការគ្រប់គ្រងផ្សារគំរូព្រំដែនកម្ពុជា-វៀតណាម បានរៀបចំអភិវឌ្ឍន៍ប្លង់មេសាងសង់ផ្សារតាមព្រំដែនកម្ពុជា-វៀតណាមនៅមេមត់ និងរៀបចំចុះកិច្ចព្រមព្រៀងអនុគ្រោះពន្ធគយ លើការនាំចេញផលិតផលកសិផលរបស់កម្ពុជាទៅលើទីផ្សារវៀតណាម។ ក្រសួងពាណិជ្ជកម្មបានកត់សម្គាល់នូវបញ្ហាប្រឈមមួយចំនួន លើការនាំចេញកសិផលរបស់កម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ។ បញ្ហាទាំងនោះមានដូចជា៖

- ទំនិញភាគច្រើនមិនអាចឆ្លើយតបបានតាមស្តង់ដារបស់អ្នកបញ្ជាទិញ ដោយហេតុថា ម៉ាស៊ីនកែច្នៃជាពិសេសម៉ាស៊ីនកិនអង្ករភាគច្រើនជាម៉ាស៊ីនចាស់ៗ មិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។ នាពេលបច្ចុប្បន្នមានម៉ាស៊ីនកែច្នៃអង្ករតាមស្តង់ដាចំនួន២ ប៉ុណ្ណោះ ដែលមានសមត្ថភាពអាចកែច្នៃបានពី១២ ០០០តោនទៅ ១៥ ០០០តោនក្នុងមួយឆ្នាំ។
- ថ្លៃដើមរបស់ទំនិញខ្ពស់ ដោយបណ្តាមកពីការចំណាយផ្លូវការ និងក្រៅផ្លូវការខ្ពស់ មានតម្លៃនៃការដឹកជញ្ជូនខ្ពស់ ដែលមកពីតម្លៃខ្ពស់របស់ប្រេង និងថាមពល និងការចំណាយក្រៅផ្លូវការជាច្រើនដំណាក់។

ច្បាប់ពាណិជ្ជកម្មដូចដែលមានរៀបរាប់ខាងក្រោមត្រូវបានបង្កើតឡើង និងកំពុងត្រូវអនុវត្តដោយក្រសួងពាណិជ្ជកម្ម ដើម្បីទទួលបានទំនុកចិត្តពីអ្នកវិនិយោគ និងសហគមន៍ពាណិជ្ជកម្ម៖

- ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម។
- ច្បាប់ស្តីពី ការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវា។
- ច្បាប់ស្តីពី ម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់។
- ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម។
- ច្បាស់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម។
- ច្បាប់ស្តីពី ប្រតិបត្តិការដែលមានកិច្ចធានា។
- ច្បាប់ស្តីពី ក្ស័យធន។

ការវិនិយោគវិស័យឯកជនដែលមានប្រភពមកពីបរទេស និងក្នុងស្រុក បានក្លាយទៅជាយានដ៏សំខាន់មួយនៃនិរន្តរភាពអត្រាខ្ពស់នៃកំណើនសេដ្ឋកិច្ច ដែលសម្រេចបាននាចុងទសវត្សរ៍នេះ។ វិស័យសេដ្ឋកិច្ចដែល

ភាគច្រើនទទួលបានមកពីការវិនិយោគឯកជនទាំងអស់នេះមួយមាន៖ វិស័យទេសចរណ៍ វិស័យកាត់ដេរ វិស័យសំណង់ និងការរុករកប្រេងឧស្ម័ន និងធនធានរ៉ែ នាពេលប៉ុន្មានឆ្នាំថ្មីៗនេះ។ ម៉្យាងវិញទៀត វិបត្តិហិរញ្ញវត្ថុសាកលលោក និងការធ្លាក់ចុះនៃសេដ្ឋកិច្ចដែលបានចាប់ផ្តើមឡើងនៅចុងឆ្នាំ២០០៧ បានបង្កឱ្យមានផលប៉ះពាល់ជាអវិជ្ជមានយ៉ាងធ្ងន់ធ្ងរ មិនត្រឹមតែលំហូរនៃការវិនិយោគផ្ទាល់ពីបរទេសប៉ុណ្ណោះទេ ថែមទាំង ការវិនិយោគវិស័យឯកជនក្នុងស្រុកផងដែរ។ រាជរដ្ឋាភិបាលកំពុងអនុវត្តកញ្ចប់ជំរុញសារពើពន្ធមួយ ដើម្បីគាំទ្រដល់កំណើនសេដ្ឋកិច្ចពិត ក៏ដូចជាការចាត់វិធានការ ដើម្បីជួយសម្រាលនូវផលប៉ះពាល់អវិជ្ជមាននៃវិបត្តិទាំងឡាយនេះ មកលើប្រជាជនក្រីក្រ និងជនងាយរងគ្រោះ។ រាជរដ្ឋាភិបាលកម្ពុជាបន្តបង្កើតនូវបរិយាកាសមួយដែលជួយជំរុញនិងលើកទឹកចិត្តដល់ការវិនិយោគក្នុងស្រុក និងការវិនិយោគបរទេសនៅក្នុងគ្រប់វិស័យអាទិភាព ដើម្បីពង្រីកនិងធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច។ ការរំលេចឡើងនូវការងារ និងបញ្ហាប្រឈមទាំងឡាយដែលបានកើតមាននៅក្នុងវិស័យអាទិភាពនានា ដែលបានទាក់ទាញការវិនិយោគក្នុងស្រុកនិងបរទេសក្នុងពេលប៉ុន្មានឆ្នាំថ្មីៗនេះត្រូវបានសង្ខេបដូចខាងក្រោម។

**វិស័យទេសចរណ៍៖** ទេសចរណ៍គឺជាវិស័យអាទិភាពមួយ ក្នុងចំណោមវិស័យអាទិភាពទាំងឡាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានរួមចំណែកក្នុងការកសាងសេដ្ឋកិច្ច និងសង្គមកិច្ច ការបង្កើតឱកាសការងារ និងប្រាក់ចំណូល ការលើកកម្ពស់ជីវភាពរស់នៅ និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ជាពិសេសរួមចំណែកក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងការជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចបៃតង។ ទេសចរណ៍នៅកម្ពុជាជាទេសចរណ៍ "វប្បធម៌ និងធម្មជាតិ" ដែលបានរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍន៍ ការថែរក្សាការពារ និងការអភិរក្សសម្បត្តិវប្បធម៌-ប្រវត្តិសាស្ត្រ និងធនធានធម្មជាតិ ក៏ដូចជាការប្រើប្រាស់សក្តានុពលនៃធនធានទាំងនេះ ប្រកបដោយនិរន្តរភាព។ សមិទ្ធផលសំខាន់ៗមួយចំនួន ដែលបានគាំទ្រដល់ការអភិវឌ្ឍន៍វិស័យទេសចរណ៍ មាន៖

- គោលនយោបាយបើកចំហជើងមេឃរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីបង្កលក្ខណៈងាយស្រួលនិងជំរុញលើកទឹកចិត្តភ្ញៀវទេសចរឱ្យធ្វើដំណើរតាមផ្លូវអាកាស បានជួយជំរុញឱ្យមានការកែលម្អអាកាសយានដ្ឋានឱ្យកាន់តែមានភាពប្រសើរឡើង ហើយបច្ចុប្បន្ននេះអាកាសយានដ្ឋានខេត្តព្រះសីហនុ ត្រូវបានដាក់ឱ្យដំណើរការហោះហើរ។ ក្នុងឆ្នាំ២០០៩ ក្រុមហ៊ុនអាកាសចរណ៍ជាតិមួយបានបង្កើតឡើងហើយបានចាប់ផ្តើមដំណើរការជើងហោះហើររបស់ខ្លួនរវាងទីក្រុងភ្នំពេញ និងខេត្តសៀមរាប។
- ការផ្តល់ទិដ្ឋាការត្រូវបានបង្កឱ្យមានលក្ខណៈងាយស្រួល នៅគ្រប់ច្រកទ្វារអន្តរជាតិទាំងអស់។ ទិដ្ឋាការត្រូវបានផ្តល់ជូនភ្ញៀវទេសចរនៅពេលមកដល់ ជាពិសេសទិដ្ឋាការអេឡិចត្រូនិក ក៏ត្រូវបានដាក់ឱ្យប្រើប្រាស់ដែរ។ នៅក្នុងក្របខ័ណ្ឌអាស៊ាន រាជរដ្ឋាភិបាលកម្ពុជាបានចុះកិច្ចព្រមព្រៀងជាមួយប្រទេសសិង្ហបុរី ម៉ាឡេស៊ី ហ្វីលីពីន ឡាវ និងប្រទេសវៀតណាម ក្នុងការលើកលែងទិដ្ឋាការ ចំពោះប្រជាពលរដ្ឋកម្ពុជា និងប្រជាពលរដ្ឋប្រទេសទាំ៥នេះ។ ក្នុងក្របខ័ណ្ឌនៃយុទ្ធសាស្ត្រសហប្រតិបត្តិការសេដ្ឋកិច្ចអាយ៉េយ៉ាវ៉ាឌី-ចាប្រាយ៉ា-មេគង្គ កិច្ចព្រមព្រៀងមួយត្រូវបានចុះហត្ថលេខា សម្រាប់ការប្រើប្រាស់ទិដ្ឋាការទោល សម្រាប់ពលរដ្ឋនៃប្រទេសទី៣ ដែលធ្វើដំណើរមកប្រទេសកម្ពុជា និងទៅប្រទេសថៃ។ បញ្ជរព័ត៌មានទេសចរណ៍ត្រូវបានរៀបចំបង្កើតឡើងនៅរាជធានី និងខេត្តចំនួន១៣ ជាពិសេសខេត្តដែលមានច្រកទ្វារព្រំដែនអន្តរជាតិដើម្បីផ្តល់ព័ត៌មានជូនភ្ញៀវទេសចរ ក៏ដូចជាការផ្សព្វផ្សាយអំពីគោល

ដៅទេសចរណ៍នៅកម្ពុជា។ ក្រសួងទេសចរណ៍បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការទេសចរណ៍ជាមួយរដ្ឋគូវ៉េត ដើម្បីទាក់ទាញភ្ញៀវទេសចរ និងអ្នកវិនិយោគរបស់រដ្ឋគូវ៉េត។

- សកម្មភាពប្រឆាំងនឹងទេសចរណ៍ផ្លូវភេទកុមារ កំពុងត្រូវបានតាមដានត្រួតពិនិត្យ ហើយវិធានការជាច្រើនកំពុងត្រូវបានអនុវត្តប្រឆាំងនឹងជនល្មើស ដោយគណៈកម្មាធិការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍របស់ក្រសួងទេសចរណ៍ ដោយមានកិច្ចសហការល្អជាមួយក្រសួង-ស្ថាប័ន អង្គការជាតិ និង អង្គការអន្តរជាតិពាក់ព័ន្ធនានា។ បច្ចុប្បន្ននេះសម្ភារផ្សព្វផ្សាយអំពីទេសចរណ៍ជាច្រើនត្រូវបានផលិតវីដេអូខ្លីៗ កម្មវិធីអប់រំតាមវិទ្យុ រូបភាពបិទផ្សព្វផ្សាយ ប័ណ្ណផ្ទត់ផ្ទាំងរូបភាពតូច-ធំ សារព័ត៌មាន និងទស្សនាវដ្តី ក្នុងគោលបំណងអប់រំផ្សព្វផ្សាយ លើកកម្ពស់ការយល់ដឹងអំពីសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ និងធានាឱ្យមានសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍។
- វិស័យទេចរណ៍នៅកម្ពុជាធ្លាប់មានកំណើនខ្ពស់លើសពី ២០ភាគរយ នៅចន្លោះពី ឆ្នាំ២០០០-២០០៧ និងមានការកើនឡើង ៥,៥ភាគរយនៅឆ្នាំ២០០៨។ទោះជាយ៉ាងណាក៏ដោយក៏ការអភិវឌ្ឍន៍វិស័យទេសចរណ៍នៅកម្ពុជា ជួបបញ្ហាប្រឈមជាច្រើនដូចជា៖
- កញ្ចប់ទស្សនកិច្ចនៅកម្ពុជាមានថ្លៃខ្ពស់។
- ការប្រកួតប្រជែងក្នុងទីផ្សារសេវាទេសចរណ៍ នៅពុំទាន់មានគ្រប់គ្រាន់នៅឡើយ (ឧ.សេវាស្នាក់នៅ មធ្យោបាយធ្វើដំណើរ ការឃោសនាផ្សព្វផ្សាយទេសចរណ៍ជាដើម)។
- គុណភាពរបស់រមណីយដ្ឋាន សម្បទា និងសេវាកម្មទេសចរណ៍មួយចំនួន ពុំទាន់មានលក្ខណៈស្តង់ដារសមស្របតាមតម្រូវការនៅឡើយ ដែលទាមទារឱ្យមានការកែលម្អ។
- ការអភិវឌ្ឍន៍ទេសចរណ៍ ត្រូវបានផ្តោតការយកចិត្តទុកដាក់តែនៅតំបន់ទីប្រជុំជន ដែលជាហេតុធ្វើឱ្យប្រជាជនក្រីក្រដែលរស់នៅតំបន់ដាច់ស្រយាល ពុំបានទទួលផលប្រយោជន៍ពីការអភិវឌ្ឍន៍ នេះ។
- ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត (ជាពិសេស ផ្លូវថ្នល់ ការផ្គត់ផ្គង់ អគ្គិសនី និងទឹកស្អាត និងប្រព័ន្ធគ្រប់គ្រងកាកសំណល់រឹង និងរាវ) ដែលចាំបាច់សម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍ ពុំទាន់មានលក្ខណៈសមស្របនៅឡើយ ដែលទាមទារឱ្យមានការកែលម្អបន្ថែមទៀត។
- ចំណូលដែលទទួលបានពីវិស័យទេសចរណ៍ ពុំបានរួមចំណែកឱ្យបានខ្លាំងក្លាក្នុងការជំរុញឱ្យផលិតកម្ម និងការប្រើប្រាស់ផលិតផលក្នុងស្រុក ដោយហេតុថាចំណូលមួយភាគធំ ត្រូវបានចំណាយសម្រាប់ការនាំចូលនូវទំនិញ និងសេវាកម្មពីបរទេស។
- ការអនុវត្តន៍គម្រោងអភិវឌ្ឍវិស័យទេសចរណ៍ របស់ក្រុមហ៊ុនវិនិយោគឯកជនមួយចំនួន ដែលទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា រួចហើយមានភាពយឺតយ៉ាវ ហើយគម្រោងមួយចំនួនទៀតគ្មានសកម្មភាព។
- កលិយុគហិរញ្ញវត្ថុ និងឱនភាពសេដ្ឋកិច្ចសកល វិបត្តិនយោបាយនៅប្រទេសថៃ និងការរីករាលដាលនៃជំងឺគ្រុនផ្តាសាយថ្មី បានជះឥទ្ធិពលអវិជ្ជមានមកលើវិស័យទេសចរណ៍ នៅកម្ពុជា។
- គុណភាពធនធានមនុស្ស ដែលបម្រើការងារនៅក្នុងវិស័យទេសចរណ៍ទាំងផ្នែកឯកជន និងផ្នែកសេវាសាធារណៈនៅមានកម្រិតទាបនៅឡើយ។

ការអភិរក្ស និងការជំរុញលើកកម្ពស់នូវមរតកវប្បធម៌ខ្មែដ៏រុងរឿង និងទំនៀមទម្លាប់ប្រពៃណី គឺជាអាទិភាពខ្ពស់មួយរបស់រដ្ឋាភិបាល។ ប្រាសាទបុរាណ សារមន្ទីរ និងស្នាដៃដ៏ប៉ិនប្រសប់ផ្សេងៗទៀត រួមមានការបង្ហាញនូវរបាំ ប្រពៃណីខ្មែរ ចម្រៀង និងគំនូរ បានរួចចំណែក និងគាំទ្រដល់ការអភិវឌ្ឍន៍វិស័យទេសចរណ៍។ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានរួមចំណែកយ៉ាងសកម្មក្នុងការធានាឱ្យបាននូវការការពារតំបន់មរតកវប្បធម៌ និងការជំរុញនូវគ្រប់សកម្មភាព ដែលគ្របដណ្តប់លើទិដ្ឋភាពខុសៗគ្នានៃវិចិត្រសិល្បៈ។

**វិស័យកាត់ដេរ៖** ជាកត្តាសំខាន់មួយដែលរួមចំណែកក្នុងកំណើនសេដ្ឋកិច្ច និងភាពមានការងារធ្វើ កំពុងបង្ហាញជាសញ្ញានៃការបាត់បង់ភាពប្រកួតប្រជែង របស់ខ្លួនដោយសារតែប្រាក់ឈ្នួលកម្មករមានកម្រិតខ្ពស់ (ត្រូវបានធ្វើឱ្យមានបញ្ហាកាន់តែធ្ងន់ធ្ងរ ដោយសារវិបត្តិអតិផរណាក្នុងពេលកន្លងមកថ្មីៗនេះ) ធៀបជាមួយនឹងប្រាក់ឈ្នួលកម្មករក្នុងបណ្តាប្រទេសដែលផលិត ផលិតផលដូចគ្នា ហើយថ្លៃដឹកជញ្ជូនខ្ពស់ និងការកើនឡើងនៃភាពប្រកួតប្រជែង នៅខណៈពេលដែលតម្រូវការក្នុងទីផ្សារពិភពលោកកំពុងធ្លាក់ចុះ។ ម៉្យាងទៀតនៅមានកត្តាជាច្រើន ដែលមានឥទ្ធិពលទៅលើកំណើនជាបន្តទៀតក្នុងវិស័យនេះ ជាឧទាហរណ៍៖ ភាពមានកម្រិតក្នុងការចូលរួមនៃវិស័យដទៃទៀត ទៅក្នុងការប្រែប្រួលអនុក្រមតម្លៃនៃវិស័យកាត់ដេរ និងការកើនឡើងនៃចំនួនសហជីពកម្មករក្នុងរោងចក្រ ដោយសារភាពមិនច្បាស់លាស់នៅក្នុងច្បាប់ស្តីពីការងារ។ ដើម្បីបន្ធូរបន្ថយដល់វិស័យនេះ រដ្ឋាភិបាលកម្ពុជាបានផ្តល់ការលើកលែងពន្ធ និងបានចាប់ផ្តើមផ្តល់ប្រាក់ឧបត្ថម្ភធនបន្ថែមពីលើប្រាក់ខែរបស់កម្មករចំនួន ៦ដុល្លារអាម៉េរិកក្នុងមួយខែ ចាប់ពីចុងខែមេសាឆ្នាំ២០០៨ មក។

វិស័យសំណង់៖ ដែលជាកត្តាសំខាន់មួយផ្សេងទៀត ដែលជួយជំរុញដល់កំណើនសេដ្ឋកិច្ច ក៏ត្រូវបានទទួលរងនូវផលប៉ះពាល់ជាអវិជ្ជមាន ដោយសារវិបត្តិហិរញ្ញវត្ថុពិភពលោក ក៏ដូចជាការប្រែប្រួលខ្លាំងនៃតម្លៃសម្ភារសំណង់នាំចូលដែរ ដូចជា ស៊ីម៉ង់ត៍ និងដែកជាដើម។ ដើម្បីទប់ទល់នឹងបញ្ហាប្រឈម និងឥទ្ធិពលនៃវិបត្តិទាំងនេះ ក៏ដូចជាដើម្បីទាក់ទាញការវិនិយោគលើទីផ្សារសំណង់ រដ្ឋាភិបាលកម្ពុជាបាននឹងកំពុងជំរុញរៀបចំសេចក្តីព្រាងច្បាប់ថ្មី មាន ច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស ច្បាប់ស្តីពីការរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងពង្រឹងការរៀបចំច្រកចេញចូលតែមួយលើការងារផ្តល់សេវាសុំការអនុញ្ញាតសាងសង់។

ការរុករក ប្រេង ឧស្ម័ន និងរ៉ែ៖ នៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ការរុករកប្រេងកាត ឧស្ម័នធម្មជាតិ និងរ៉ែ បានទាក់ទាញចំណាប់អារម្មណ៍អ្នកវិនិយោគបរទេសជាច្រើន។ បច្ចុប្បន្នការងាររុករកប្រេង និងឧស្ម័នបម្រុងមានដំណើរការវិវត្តបានយ៉ាងល្អ ហើយការងារនេះក៏ត្រូវបានរំពឹងទុកថានឹងឈានទៅដល់ដំណាក់កាលនៃការផលិតមួយ ដែលនឹងបង្កើតជាចំណូលថ្មីសម្រាប់រដ្ឋនាពេលអនាគត។ ការស្វែងរុករករ៉ែដែក មាស បុកស៊ីត ត្បូងថ្ម ត្បូងថ្មមានតម្លៃ ។ល។ ដែលនឹងអាចក្លាយជាសក្តានុពលរ៉ែដ៏សំខាន់មួយសម្រាប់អភិវឌ្ឍន៍ប្រទេសជាតិ កំពុងតែដំណើរការនៅតាមតំបន់សម្បទានរ៉ែនានា នៅតាមបណ្តាខេត្តដែលស្ថិតនៅក្នុងភាគឧត្តរ និងភាគឦសាន។ ទន្ទឹមនឹងនេះ ការធ្វើអាជីវកម្មរ៉ែថ្មកំបោរ សម្រាប់ប្រើប្រាស់ជាវត្ថុធាតុដើម ក្នុងការផលិតស៊ីម៉ង់ត៍នៅកម្ពុជាកំពុងតែដំណើរការនិងបានចូលរួមយ៉ាងសកម្មក្នុងការកាត់បន្ថយការនាំចូលផលិតផលស៊ីម៉ង់ត៍ពីក្រៅប្រទេស។ បទប្បញ្ញត្តិ និងនីតិវិធីនានាត្រូវរៀបចំឡើងដោយប្រុងប្រយ័ត្ន ដើម្បីធានាឱ្យមានចីរភាពបរិស្ថាន ការកែច្នៃនៅក្នុងស្រុកដែលបង្កើតឡើងនូវតម្លៃបន្ថែម និងការបង្កើនជាអតិបរមានូវចំណូលរដ្ឋ។ រដ្ឋាភិបាលកម្ពុជា នឹងបន្តជំរុញយ៉ាងសកម្មលើការវិនិយោគវិស័យឯកជន សម្រាប់ការពង្រីក និងការធ្វើពិពិធកម្មនៃកម្មន្តសាល និងផលិត

កម្មឧស្សាហកម្ម ដើម្បីទាញយកប្រយោជន៍ពីធនធានធម្មជាតិក្នុងប្រទេស។ ឧស្សាហកម្មដែលផ្អែកលើធនធានធម្មជាតិជាមូលដ្ឋាន ជាពិសេសឧស្សាហកម្មដែលប្រើប្រាស់វត្ថុធាតុដើមពីរ៉ែ អលោហៈត្រូវបានពង្រីក និងអភិវឌ្ឍ ដើម្បីផលិតនូវមុខទំនិញឧស្សាហកម្មថ្មីៗ ហើយឧស្សាហកម្មដែលមានប្រភពធនធានពីកសិកម្ម គឺជាឧស្សាហកម្មដែលមានសក្តានុពលខ្ពស់ក្នុងការអភិវឌ្ឍន៍ ដោយជំនួសឱ្យវិស័យឧស្សាហកម្មផ្សេងទៀតដែលងាយទទួលរងផលប៉ះពាល់។

# ការគ្រប់គ្រងការងារគយនៅទីស្នាក់ការគយ និង រដ្ឋាករភ្នំដិន




ចិន្តា បណ្ឌិត

បេក្ខជនបណ្ឌិតជំនាន់ទី៣ ផ្នែកគ្រប់គ្រង

សាកលវិទ្យាល័យឯកទេសនៃកម្ពុជា


## ១- សេចក្ដីផ្ដើម

ការសិក្សាស្រាវជ្រាវលើប្រធានបទស្ដីពី ការគ្រប់គ្រងការងារគយនិងរដ្ឋាករនៅទីស្នាក់ការគយ និង រដ្ឋាករភ្នំដិន ដោយហេតុថា កន្លងមកបានសង្កេតឃើញថាការគ្រប់គ្រងការងារគយនិងរដ្ឋាករនៅមានចំណុចខ្វះខាតមួយចំនួនដូចជា ចំនួនធនធានមនុស្សមិនទាន់សមស្របទៅនឹងទំហំការងារជាក់ស្ដែង ការគ្រប់គ្រងប្រមូលពន្ធអាករ និង កម្រៃផ្សេងៗមិនទាន់បានអស់លទ្ធភាពតាមច្បាប់បានកំណត់ ការទប់ស្កាត់និងបង្ក្រាបអំពើគេចពន្ធនៅពុំទាន់មានប្រសិទ្ធភាព ហើយរបាំងមិនមែនពន្ធក៏មិនទាន់ត្រូវបានលុបបំបាត់នៅឡើយ ។

ការសិក្សាស្រាវជ្រាវលើប្រធានបទនេះក្នុងគោលបំណងដើម្បីសិក្សាពីដំណើរការគ្រប់គ្រងទូទៅនៃទីស្នាក់ការគយ និងរដ្ឋាករភ្នំដិនស្វែងយល់ពីកត្តារាំងស្ទះដល់ការអនុវត្តនូវតួនាទីភារកិច្ចក្នុងការគ្រប់គ្រងការងារគយនិងរដ្ឋាករនៃទីស្នាក់ការគយនិងរដ្ឋាករភ្នំដិន និង វិភាគលើចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងចំណុចខ្វះខាតក្នុងការគ្រប់គ្រងទីស្នាក់ការគយ និងរដ្ឋាករភ្នំដិន(SWOT analysis)។

## ២- វិធីសាស្ត្រស្រាវជ្រាវ

### ២.១. ការជ្រើសរើសសំណាក

ទីកន្លែងសម្រាប់ការសិក្សាស្រាវជ្រាវគឺ ទីស្នាក់ការគយនិងរដ្ឋាករភ្នំដិន ដែលស្ថិតនៅក្នុងភូមិផ្សារ ឃុំភ្នំដិន ស្រុកគីរីវង់ ខេត្តតាកែវ ភាគខាងត្បូងនៃព្រះរាជាណាចក្រកម្ពុជា ជាប់ព្រំដែននៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលមានចម្ងាយប្រហែល១២៧គីឡូម៉ែត្រពីរាជធានីភ្នំពេញ និងមានចម្ងាយប្រហែល៤៧គីឡូម៉ែត្រពីទីរួមខេត្តតាកែវតាមបណ្ដោយផ្លូវជាតិលេខ២ ។

ការសិក្សាស្រាវជ្រាវនេះបានធ្វើឡើងចំពោះតែទីស្នាក់ការគយនិងរដ្ឋាករភ្នំដិន ដូច្នេះសកលស្ថិតិទាំងមូលគឺជាមន្ត្រីរាជការគយនិងរដ្ឋាករនៃទីស្នាក់ការគយនិងរដ្ឋាករភ្នំដិនដែលមានចំនួនសរុបទាំងអស់៩នាក់។

ការជ្រើសរើសចំនួនសំណាកចេញពីសកលស្ថិតិ មិនត្រូវបានអនុវត្តតាមរបៀបជ្រើសរើសដោយចៃដន្យទេ (Random Sampling) តែត្រូវអនុវត្តដោយការជ្រើសរើសយកទាំងអស់គឺ១០០%(មួយរយភាគរយ)។ ដូច្នេះទំហំសំណាកដែលបានជ្រើសរើសយកចេញពីសកលស្ថិតិមានចំនួនសរុបទាំងអស់៩នាក់ (n=៩នាក់)។

### ២.២. ការប្រមូលទិន្នន័យបឋម (Primary Data)

ទិន្នន័យបឋមគឺជាទិន្នន័យសំខាន់បំផុតដែលប្រមូលបានពីសំណាកតាមរយៈការប្រើប្រាស់ឧបករណ៍ប្រមូលទិន្នន័យសំខាន់ៗ មានកម្រងសំណួរ ការសម្ភាសន៍ និង ការសង្កេត។

### ២.៣. ការប្រមូលទិន្នន័យមានស្រាប់ (Secondary Data)

ទិន្នន័យមានស្រាប់គឺជាទិន្នន័យគួបផ្សំបន្ថែម ដែលប្រមូលបានពីប្រភពផ្សេងៗជាច្រើនមានៈ អ៊ិនធើណែត (Internet)និងឯកសារនានាដែលពាក់ព័ន្ធ។

## ២.៤. វិធីសាស្រ្តវិភាគទិន្នន័យ (Method of Analysis Used)

ទិន្នន័យដែលប្រមូលបាន ត្រូវវិភាគរកតម្លៃភាគរយ(%) មធ្យមភាគ និង ឈីខ្វែរ(Chi-square Test) តាមកម្មវិធី SPSS (Social Package of Social Science)។

# ៣. លទ្ធផលនៃការស្រាវជ្រាវ

១. លទ្ធផលឱ្យដឹងថា មន្ត្រីគយនៃទីស្នាក់ការគយនិងរដ្ឋាករភ្នំដិនជាទូទៅបានបញ្ចប់ការសិក្សាកម្រិតបរិញ្ញាបត្រនិងបរិញ្ញាបត្រជាន់ខ្ពស់ p>0.០៥។

២. មន្ត្រីរាជការគយនៃទីស្នាក់ការគយនិងរដ្ឋាករភ្នំដិន បានទទួលការបណ្តុះបណ្តាលមុខវិជ្ជាជំនាញបច្ចេកទេសគយនិងរដ្ឋាករគ្រប់ៗគ្នាទាំងអស់ មុននឹងត្រូវបានចាត់តាំងមកបំពេញភារកិច្ច នៅទីស្នាក់ការគយនិងរដ្ឋាករភ្នំដិន។

៣. រចនាសម្ព័ន្ធការងារត្រូវបានរៀបចំជាទម្រង់បែបមុខងារ ពុំមែនតាមទម្រង់បែបណាមួយនោះឡើយ។ បរិមាណមន្ត្រីគយនិងរដ្ឋាករចំនួន៩រូប មិនមានលក្ខណៈសមស្របទៅនឹងទំហំនៃការងារគយជាក់ស្តែងនោះទេ។

៤. ការចាត់តាំងមន្ត្រីគយក្រោមឱវាទដោយឈរលើមូលដ្ឋានគ្រឹះសំខាន់ៗទាំងបួន មានកម្រិតវប្បធម៌បទពិសោធន៍ការងារ ជំនាញឯកទេស និង សីលធម៌រស់នៅ។

៥. ទីស្នាក់ការគយនិងរដ្ឋាករភ្នំដិន បានរៀបចំធ្វើផែនការសកម្មភាពសម្រាប់រយៈពេលមួយត្រីមាសម្តងដើម្បីត្រួតពិនិត្យ តាមដាននូវរាល់កិច្ចការសំខាន់ៗរបស់អង្គភាពចាប់ពីឆ្នាំ២០០១ រហូតដល់ពាក់កណ្តាលឆ្នាំ២០០៨ ប៉ុន្តែចាប់ពីពេលនោះមក រហូតដល់ឆ្នាំ២០១១ ពុំឃើញមានឯកសារណាមួយបង្ហាញពីការរៀបចំធ្វើផែនការសកម្មភាពនោះទេ។

៦. ទីស្នាក់ការគយនិងរដ្ឋាករភ្នំដិនបានត្រួតពិនិត្យមើលនូវកត្តាសំខាន់ៗ នៃបរិយាកាសខាងក្នុង ដែលមានសីលធម៌រស់នៅ សាមគ្គីភាពផ្ទៃក្នុង កិច្ចសហការណ៍ក្នុងការបំពេញភារកិច្ច ការគ្រប់គ្រងនិងដឹកនាំទីស្នាក់ការគយនិងភារកិច្ចដែលបានប្រគល់ឱ្យ។ កត្តាសំខាន់ៗ មួយចំនួននៃបរិយាកាសខាងក្រៅ ដែលមានទំនាក់-ទំនងនិងកិច្ចសហការណ៍ជាមួយអង្គភាពខាងក្រៅ ជាមួយអាជ្ញាធរមូលដ្ឋាននិងអង្គភាពសមភាគីបរទេសហើយមានសាមគ្គីភាពជាមួយអង្គភាពទាំងនេះ។

៧. របាំងមិនមែនពន្ធ ដែលបាននិងកំពុងកើតមានឡើងនៅមាត់ច្រកអន្តរជាតិភ្នំដិនគឺមាន ប៉ុស្តិ៍ត្រួតពិនិត្យក្រៅច្បាប់ ការិយាធិបតេយ្យនិងការបង្ខាំងទុកឯកសារយូរដើម្បីផលប្រយោជន៍អ្វីមួយ។ ប៉ុស្តិ៍ត្រួតពិនិត្យក្រៅច្បាប់មានចាប់ពី៣កន្លែងរហូតដល់៨កន្លែង ដែលឈរជើងពីមាត់ច្រកចូលរហូតដល់ក្នុងភូមិសាស្ត្រខេត្តតាកែវ។

តារាងទី១: របាំងមិនមែនពន្ធ

| ល.រ. | កត្តាសំខាន់ៗ | ចំនួនអ្នកឆ្លើយតប(F) | Chi-Square | Probability |
|---|---|---|---|---|
| ០១ | ការិយាធិបតេយ្យ | ៤នាក់ | | |
| ០២ | អាកប្បកិរិយានិងសម្តីមន្ត្រីមិនសមរម្យ | 0 | | |
| ០៣ | ប៉ុស្តិ៍ត្រួតពិនិត្យក្រៅច្បាប់ | ៥នាក់ | ១.២៧ | >0.០៥ |

| | | | | |
|---|---|---|---|---|
| ០៤ | ការបង្ខាំងទុកឯកសារដើម្បីផលប្រយោជន៍ | ០ | | |
| ០៥ | ទាំងអស់ | ២នាក់ | | |
| | សរុប | ១១នាក់ | | |

៨. មធ្យោបាយមានប្រសិទ្ធភាពមួយចំនួន ដែលគួរប្រើប្រាស់ ដើម្បីលុបបំបាត់មូលហេតុឫសគល់ធ្វើឱ្យចំណូលពន្ធគយធ្លាក់ចុះគឺ ត្រូវសម្រួលបែបបទគយឱ្យបានឆាប់រហ័សដល់ធុរជន រឹតបន្តឹងច្រករបៀង បង្ក្រាបទំនិញក្លែងក្លាយដែលផលិតនៅក្នុងប្រទេស លុបបំបាត់របាំងមិនមែនពន្ធ ណែនាំធុរជនឱ្យបានយល់ដឹងអំពីការជាប់កាតព្វកិច្ចពន្ធ បំពេញបែបបទគយឱ្យបានគ្រប់គ្រាន់ និងត្រូវមានទំនាក់ទំនងល្អជាមួយអាជ្ញាធរមូលដ្ឋានជាប្រចាំ p>0.0៥។

៩. ការបំពេញបែបបទរបស់អង្គភាពគយកម្ពុជា នៅមាត់ច្រកអន្តរជាតិភ្នំដិនមានលក្ខណៈប្រហាក់ប្រហែលគ្នាជាមួយនិងមន្ត្រីគយនៃប្រទេសវៀតណាម។ នៅពេលខ្លះ មន្ត្រីគយកម្ពុជាអាចមានលទ្ធភាពបំពេញបែបបទបានលឿនជាង។

តារាងទី២:ការបំពេញបែបបទគយកម្ពុជានៅមាត់ច្រកប្រៀបធៀបជាមួយគយនៃប្រទេសជិតខាង(វៀតណាម)

| ល.រ. | កម្រិតនៃភាពខុសគ្នា | ចំនួនអ្នកឆ្លើយតប(F) | Chi-Square | Probability |
|---|---|---|---|---|
| ០១ | រហ័សជាងខ្លាំង | ០ | ២.៦៦ | >0.0៥ |
| ០២ | រហ័សជាង | ៣នាក់ | | |
| ០៣ | ប្រហាក់ប្រហែលគ្នា | ៥នាក់ | | |
| ០៤ | រហ័សជាងល្មម | ០ | | |
| ០៥ | យឺតជាង | ១នាក់ | | |
| | សរុប | ៩នាក់ | | |

១០. ការងារមិនចាំបាច់និងប៉ះពាល់ដល់សាមញ្ញកម្មនីតិវិធីគយនៅតែមាន ដូចជាការិយាធិបតេយ្យការបំពេញបែបបទដោយដៃនិងការយកកម្រៃក្រៅផ្លូវការ។

តារាងទី៣: វិធានការផ្តល់សេវាកម្មគយបានរហ័ស ពេញចិត្ត និង គួរឱ្យទុកចិត្តដល់ធុរជន

| ល.រ. | វិធានការផ្តល់សេវា | ចំនួនអ្នកឆ្លើយតប(F) | Chi-Square | Probability |
|---|---|---|---|---|
| ០១ | ត្រូវបំពាក់ប្រព័ន្ធស្វ័យប្រវត្តិកម្ម | ២នាក់ | 0.៤០ | >0.0៥ |
| ០២ | បង្កលក្ខណៈងាយស្រួលដល់ធុរជន | ៣នាក់ | | |
| ០៣ | សម្រួលបែបបទឱ្យបានឆាប់រហ័ស | ៣នាក់ | | |
| ០៤ | គ្មានចម្លើយ | ២នាក់ | | |
| | សរុប | ១០នាក់ | | |

## ៤-ការពិភាក្សាលើលទ្ធផលនៃការស្រាវជ្រាវ

### ៤.១. ចំណុចខ្លាំង

១.កម្រិតវប្បធម៌ខ្ពស់របស់មន្ត្រីរាជការគយនៃទីស្នាក់ការគយនិងរដ្ឋាករភ្នំដិន។

២.បានទទួលការបណ្តុះបណ្តាលជំនាញបច្ចេកទេសគយនិងរដ្ឋាករ ដូចជាការធ្វើបែបបទគយ ការបំពេញប្រតិវេទន៍គយ (ឯកសាររដ្ឋបាលតែមួយ) ការងារគណនេយ្យ ការកំណត់តម្លៃគិតពន្ធគយ ចំណាត់ថ្នាក់ទំនិញ បច្ចេកទេសក្នុងការទប់ស្កាត់និងបង្ក្រាបបទល្មើសគយ និង បទល្មើសពាក់ព័ន្ធ ការធ្វើកំណត់ហេតុបទល្មើសគយការងាររដ្ឋបាល ច្បាប់ស្តីពីគយ និង បទប្បញ្ញត្តិ។

៣.ការត្រួតពិនិត្យមើលបរិយាកាសខាងក្នុងនិងខាងក្រៅជាមួយអាជ្ញាធរមូលដ្ឋាននិងអង្គភាពសមភាគីបរទេសនិងមានសាមគ្គីភាពជាមួយអង្គភាពទាំងនេះ។

៤.មធ្យោបាយមានប្រសិទ្ធភាពដែលធ្វើឱ្យចំណូលពន្ធគយកើននោះ ត្រូវសម្រួលបែបបទគយឱ្យបានឆាប់រហ័សដល់ធុរជន រឹតបន្តឹងច្រករបៀង បង្ក្រាបទំនិញក្លែងក្លាយដែលផលិតនៅក្នុងប្រទេស លុបបំបាត់របាំងមិនមែនពន្ធ ណែនាំធុរជនឱ្យបានយល់ដឹងអំពីការជាប់កាតព្វកិច្ចពន្ធ បំពេញបែបបទគយឱ្យបានគ្រប់គ្រាន់ ទប់ស្កាត់និងបង្ក្រាបគ្រប់ទម្រង់នៃបទល្មើសគយនិងបទល្មើសពាក់ព័ន្ធ។

៥.ការបំពេញបែបបទគយកម្ពុជាបានលឿនជាងមន្ត្រីគយនៃប្រទេសវៀតណាមទៀតផង។

៦.វិធានការផ្តល់សេវាកម្មគយបានរហ័ស ពេញចិត្តនិងគួរឱ្យទុកចិត្តដល់ធុរជន។

### ៤.២. ចំណុចខ្សោយ

១. រចនាសម្ព័ន្ធការងារនៃទីស្នាក់ការគយនិងរដ្ឋាករភ្នំដិន

រចនាសម្ព័ន្ធការងារមានទម្រង់ផ្សេងៗគ្នា ដូចជា ទម្រង់បែបមុខងារ ម៉ាទ្រីស នាយកដ្ឋាន ផ្នែក តំបន់ផលិតផលនិងផ្សេងទៀត។

២.ការរៀបចំធ្វើផែនការសកម្មភាពដើម្បីត្រួតពិនិត្យនិងវាយតម្លៃការងារប្រចាំថ្ងៃចាប់ពីឆ្នាំ២០០៨ មករហូតដល់ឆ្នាំ២០១១ ពុំឃើញមានឯកសារណាមួយបង្ហាញពីការរៀបចំធ្វើផែនការសកម្មភាពនោះទេ។

៣.របាំងមិនមែនពន្ធ

លទ្ធផលស្រាវជ្រាវបានបង្ហាញឃើញថា របាំងមិនមែនពន្ធដែលបាននិងកំពុងកើតមានឡើងនៅមាត់ច្រកអន្តរជាតិភ្នំដិន គឺមាន ប៉ុស្តិ៍ត្រួតពិនិត្យក្រៅច្បាប់ ការិយាធិបតេយ្យនិងការបង្ខាំងទុកឯកសារយូរដើម្បីផលប្រយោជន៍អ្វីមួយ $p>0.05$ ។

៤. ប៉ុស្តិ៍ត្រួតពិនិត្យក្រៅច្បាប់មានចាប់ពី៣កន្លែងទៅ៨កន្លែង ដែលបោះទីតាំងនៅតាមដងផ្លូវជាតិចាប់ពីមាត់ច្រកចូលរហូតដល់ក្នុងភូមិសាស្ត្រខេត្តតាកែវ។ ចំណុចនេះ ទីស្នាក់ការគយនិងរដ្ឋាករភ្នំដិនបានខិតខំរកមធ្យោបាយដោះស្រាយ តែទទួលបានលទ្ធផលតិចតួចណាស់។

៥. ការងារមិនចាំបាច់និងប៉ះពាល់ដល់សាមញ្ញកម្មនិតិវិធីគយ

ទិន្នន័យបានបង្ហាញថា ការងារមិនចាំបាច់និងប៉ះពាល់ដល់សាមញ្ញកម្មនីតិវិធីគយនៅតែមាន ដូចជាការិយាធិបតេយ្យ ការបំពេញបែបបទដោយដៃនិងការយកកម្រៃក្រៅផ្លូវការ $p>0.05$។

ចំពោះការបំពាក់ប្រព័ន្ធស្វ័យប្រវត្តិកម្មគយ (ASYCUDA) ដើម្បីធ្វើឱ្យការផ្តល់សេវាកម្មគយបានឆាប់រហ័ស ងាយស្រួលពេញចិត្តនិងគួរឱ្យទុកចិត្តបាន។

### ៤.៣ ឱកាស

ម៉ូដែលឬទ្រឹស្តីនៃការដឹកនាំ ដើម្បីឱ្យការគ្រប់គ្រងមានប្រសិទ្ធភាព

ចំណុចសំខាន់ៗរបស់អ្នកគ្រប់គ្រងមានប្រសិទ្ធភាពដែលមន្ត្រីគយយល់ឃើញ មានដូចជា អ្នកគ្រប់គ្រងត្រូវប្តេជ្ញាចិត្តក្នុងការងារជាមួយបុគ្គលិក ត្រូវធ្វើជាគំរូល្អដល់អ្នកដទៃនិងត្រូវស្វែងយល់ពីសុខទុក្ខនិងតម្រូវការរបស់អ្នកក្រោមឱវាទ ហើយត្រូវលប់បំបាត់ចោលនូវភាពមិនចុះសម្រុងគ្នារវាងថ្នាក់ដឹកនាំនិងនិយោជិត ត្រូវដឹកនាំអ្នកក្រោមបង្គាប់អនុវត្តតាមគោលដៅរបស់អង្គភាព មានវិន័យល្អ មានសីលធម៌ល្អ មានទំនាក់ទំនងល្អ និងចេះគ្រប់គ្រងពេលវេលាបានល្អ $p>0.05$។

**៤.៤ ឧបសគ្គ**

-គ្រោះធម្មជាតិរាំងស្ងួតឬទឹកជំនន់បណ្តាលឱ្យខូចកសិផលដែលធ្វើឱ្យចំណូលថវិកាមានការថយចុះ

-តម្លៃធ្លាក់ចុះនៅពេលមានកំណើនផលិតផលកសិកម្មធ្វើឱ្យការនាំចេញចុះខ្សោយ

-មានច្រករបៀងតាមព្រំដែនច្រើនដើម្បីនាំទំនិញចេញនិង/ឬចូលគេចពន្ធ

-នៅមានប៉ុស្តិ៍ត្រួតពិនិត្យក្រៅច្បាប់ចាប់ពី៧កន្លែងទៅ៨កន្លែងដែលជាឧបសគ្គធ្វើឱ្យចំណូលពន្ធគយធ្លាក់ចុះ។

## ៥. សន្និដ្ឋាន

លទ្ធផលនៃការសិក្សាស្រាវជ្រាវ បានបញ្ជាក់ឱ្យដឹងថា ការគ្រប់គ្រងការងារគយជាក់ស្តែងនៅទីស្នាក់ការគយនិងរដ្ឋាករភ្នំដិន មានទាំងគុណសម្បត្តិនិងគុណវិបត្តិដូចខាងក្រោម៖

**គុណសម្បត្តិ៖** មន្ត្រីរាជការគយនិងរដ្ឋាករ នៃទីស្នាក់ការគយនិងរដ្ឋាករភ្នំដិន មានកម្រិតវប្បធម៌ឧត្តមសិក្សានិងក្រោយឧត្តមសិក្សា ហើយបានចូលរួមវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសគយមុននឹងបានចាត់តាំងឱ្យមកបម្រើការងារនៅទីស្នាក់ការគយនិងរដ្ឋាករភ្នំដិន។ ការចាត់តាំងភារកិច្ចដល់មន្ត្រីគយ ដោយផ្អែកលើកត្តាសំខាន់ៗបួនយ៉ាងគឺ កម្រិតវប្បធម៌ បទពិសោធន៍ការងារ ជំនាញបច្ចេកទេសនិងសីលធម៌រស់នៅ $p<0.001$។ ទីស្នាក់ការគយនិងរដ្ឋាករភ្នំដិន បានត្រួតពិនិត្យមើលបរិយាកាសខាងក្នុងនិងខាងក្រៅ។ កត្តាសំខាន់ៗនៃបរិយាកាសខាងក្នុងមាន សីលធម៌រស់នៅ សាមគ្គីភាពផ្ទៃក្នុង ការសហការគ្នាក្នុងពេលបំពេញភារកិច្ចគយ ការគ្រប់គ្រងដឹកនាំនិងកិច្ចការដែលប្រគល់ឱ្យ $p<0.05$។ កត្តាសំខាន់ៗនៃបរិយាកាសខាងក្រៅមានទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាននិងអង្គភាពសមភាគីបរទេសនិងមានសាមគ្គីភាពជាមួយអង្គភាពខាងក្រៅ $p<0.001$។

ទន្ទឹមនឹងនេះ ទីស្នាក់ការគយនិងរដ្ឋាករភ្នំដិន ក៏បានចាត់វិធានការសមស្របមួយចំនួន ដើម្បីធ្វើឱ្យការគ្រប់គ្រងប្រមូលចំណូលពន្ធគយមានកំណើន ដោយលុបបំបាត់នូវភាពអសកម្មក្នុងការបំពេញបែបបទគយត្រូវមានក្រមសីលធម៌ក្នុងការងារ ទំនាក់ទំនងល្អជាមួយនឹងធុរជន គ្រប់គ្រងប្រមូលពន្ធនិងអាករឱ្យបានត្រឹមត្រូវតាមផែនការបានដាក់ចុះនឹងត្រូវបង្ក្រាបបទល្មើសគយគ្រប់រូបភាពនិងបទល្មើសដែលពាក់ព័ន្ធ $p<0.05$។

មន្ត្រីគយនិងរដ្ឋាករ បានបំពេញបែបបទនិងទម្រង់ការគយផ្សេងៗជូនធុរជនបានរហ័សដោយបានប្រើប្រាស់នូវរយៈពេលចាប់ពីក្រោម ៣០នាទីរហូតដល់ត្រឹម៣០នាទីនិងត្រឹម៣០នាទីរហូតដល់៦០នាទី $p<0.05$។ ការបំពេញបែបបទនៃមន្ត្រីគយនិងរដ្ឋាករកម្ពុជាមានលក្ខណៈប្រហាក់ប្រហែលគ្នា បើប្រៀបធៀបជាមួយនឹងអង្គភាពគយនៃប្រទេសវៀតណាម ហើយការបំពេញបែបបទនិងទម្រង់ការគយផ្សេងៗនេះ ទទួលបានការពេញចិត្តពីធុរជនទៀតផង $p>0.05$។

**គុណវិបត្តិ:** បរិមាណមន្ត្រីគយនិងរដ្ឋាករចំនួន៩រូប មិនមានលក្ខណៈសមស្របទៅនឹងទំហំការងារគយជាក់ស្តែង។ ទន្ទឹមនឹងនេះ ទីស្នាក់ការគយនិងរដ្ឋាករភ្នំដិនមិនបានរៀបចំធ្វើផែនការសកម្មភាពការងារ ប្រចាំត្រីមាសឬឆមាស ដើម្បីត្រួតពិនិត្យនិងវាយតម្លៃសកម្មភាពការងារប្រចាំថ្ងៃនោះទេ។

ការប្រមូលចំណូលពន្ធគយវិញមានការធ្លាក់ចុះ ដោយសារមានការរត់គេចពន្ធច្រករបៀងច្រើន ទំនិញឡើងថ្លៃនៅលើទីផ្សារក្នុងស្រុកនិងមានការផលិតទំនិញក្លែងក្លាយនៅក្នុងប្រទេស $p<0.05$។

របាំងមិនមែនពន្ធដែលនៅក្នុងនោះមានជាអាទិ៍ ការិយាធិបតេយ្យ ការបង្ខាំងទុកឯកសារយូរដើម្បីប្រយោជន៍អ្វីមួយ ប៉ុស្តិ៍ត្រួតពិនិត្យក្រៅច្បាប់មានចំនួនចាប់ពី៣កន្លែងទៅ៨កន្លែង ដែលឈរជើងពីមាត់ច្រកចូលរហូតដល់ក្នុងភូមិសាស្រ្តខេត្តតាកែវ $p>0.05$។

សរុបសេចក្តីមក ការគ្រប់គ្រងការងារគយនិងរដ្ឋាករនៅមាត់ច្រកអន្តរជាតិភ្នំដិនមានចំណុចល្អលើកត្តាខាងក្នុងនិងខាងក្រៅ មានកម្រិតវប្បធម៌ខ្ពស់បង្ក្រាបបទល្មើសគយបានទាន់ពេលវេលានិងមានការពេញចិត្តពីធុរជនលើការផ្តល់សេវាកម្មគយ។ ចំពោះចំណុចខ្សោយវិញមានដូចជា ច្រករបៀងច្រើន ប៉ុស្តិ៍ត្រួតពិនិត្យក្រៅច្បាប់ច្រើនដែលនាំឱ្យមានការចំណាយច្រើន សេវាកម្មមិនទាន់សូវល្អ ខ្វះផែនការត្រួតពិនិត្យសកម្មភាពនិងទីតាំងមិនអំណោយផល។

## គន្ថនិទ្ទេស


១- ជួន ណាត *វចនានុក្រមខ្មែរ* ភាគ១-២ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពគ្រាទី៥ ឆ្នាំ១៩៦៧

២-តារាង*កំណត់ប្រភេទទីកន្លែងធ្វើការទី១,ទី២និងទី៣ ដើម្បីសម្រួលតាមសេចក្តីសម្រេច លេខ ០០៥ សហវ. ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៤* ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៥ របស់ទីចាត់ការគយ និងរដ្ឋាករ

៣-សេចក្តីណែនាំ លេខ ៦២៩ គ.រ. ស្តីពី *ការសម្រួលនីតិវិធីនាំចូលនិងនាំចេញ តាមមាត់ច្រកអន្តរជាតិនិងតំបន់* ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៣ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករ

៤-លិខិត លេខ ២៨៦ អ.គ.រ. ស្តីពី*ការកែសម្រួល និងការកំណត់បន្ថែមមួយចំនួនលើនីតិវិធីគយដើម្បីបង្កភាពងាយស្រួលបន្ថែមទៀតដល់វិនិយោគិននិងធុរជនពាក់ព័ន្ធ* ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១០ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករ

៥-លិខិត លេខ ៤៧៩ គរ.ភដ. ស្តីពី *ផែនការសកម្មភាពប្រចាំឆមាសទី១ ឆ្នាំ២០០៨* ចុះថ្ងៃទី......... ខែធ្នូ ឆ្នាំ២០០៨ របស់ទីស្នាក់ការគយនិងរដ្ឋាករភ្នំដិន

៦-The United Nations Conference on Trade and Development (UNCTAD), Technical Note N° 21, *Automated System for Customs Data (ASYCUDA).*

៧-WTO : TRADE FACILITATION MEASURE,CASE STUDY, ***SAINT LUCIA'S,*** *Implementation of Automated System for Customs Data (ASYCUDA)*, June 2006.

# ផលវិបាក និងដំណោះស្រាយនៃវិធីសាស្ត្របង្រៀនភាសាខ្មែរ នៅបឋមសិក្សា
## (១៩៥៣-២០១១)



សូ សុធីរ
បេក្ខជនបណ្ឌិតវគ្គទី២ ផ្នែកវិទ្យាសាស្ត្រអប់រំ
នៃរាជបណ្ឌិត្យសភាកម្ពុជា

### ១-ការសម្ភាស

១.១-នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ

១.២-នាយកដ្ឋានបឋមសិក្សា

១.៣-អធិការបឋមសិក្សានិងគ្រូឧទ្ទេស

១.៤-នាយកសាលាបឋមសិក្សា

១.៥-ប្រធានក្រុមបច្ចេកទេស។

### ២-ការអង្កេត

ការអង្កេតលើកម្រងសំណួរគ្រូបឋមសិក្សានិងសិស្សបឋមសិក្សា។

### ៣-ការសង្កេតការបង្រៀនភាសាខ្មែរនៅបឋមសិក្សា

តាមការសិក្សាស្រាវជ្រាវខាងលើនេះ អ្នកស្រាវជ្រាវបានរកឃើញថា៖

វិធីសាស្ត្របង្រៀនភាសាខ្មែរ ពីឆ្នាំ១៩៥៣-២០១១នេះ បានវិវត្តចាប់ផ្តើមឡើងពីភាពជោគជ័យក្នុងសម័យឯករាជ្យនិងវិវត្តទៅរកភាពបរាជ័យ នៅក្នុងពេលដែលប្រទេសខ្មែរស្ថិតក្នុងសង្គ្រាមស៊ីវិលនិងក្រោយពេលដែលខ្មែរបានបញ្ចប់សង្គ្រាមស៊ីវិល។ ភាពបរាជ័យដែលកើតមានក្រោយខ្មែរបានបញ្ចប់សង្គ្រាមស៊ីវិលនោះ បណ្តាលមកពីធនធានមនុស្សនិងធនធានសម្ភារៈស្ទើរទាំងស្រុងត្រូវបំផ្លាញនៅក្នុងពេលសង្គ្រាម។ ការកសាងសង្គមទៅរកភាពជោគជ័យឡើងវិញ បានចាប់ផ្តើមដោយការតស៊ូការព្យាយាមនឹងឧបសគ្គ។ វិធីសាស្ត្របង្រៀនភាសាខ្មែរក៏ត្រូវបានអភិវឌ្ឍឡើងវិញដោយសន្សឹមៗនិងប្រកបដោយការលំបាកៗនិងឧបសគ្គជាច្រើនផងដែរ។ វាបានវិវត្តនិងអភិវឌ្ឍពីគោលវិធីគ្រូមជ្ឈមណ្ឌលទៅរកគោលវិធីសិស្សមជ្ឈមណ្ឌល។ ការលំបាកៗនិងឧបសគ្គទាំងឡាយបណ្តាលមកពីកត្តាទាំងឡាយដូចជា៖

-នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ មិនបានបណ្តុះបណ្តាលគ្រូឧទ្ទេសថ្មីៗដែលចូលទៅបម្រើការងារនៅសាលាគរុកោសល្យនិងវិក្រឹតការ

-នាយកដ្ឋានបឋមសិក្សា ការងារអធិការកិច្ចគរុកោសល្យនិងការងារគ្រប់គ្រងសាលារៀនបឋមសិក្សាមិនទាន់អនុវត្តបានល្អ ដោយមិនបានយកពីផលវិបាករបស់ខ្លួនលើផ្នែកវិធីសាស្ត្របង្រៀនទៅឱ្យនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ ដើម្បីកែលម្អការងារបណ្តុះបណ្តាលនិងវិក្រឹតការរបស់ខ្លួនឡើងវិញ

-អធិការនិងគ្រូឧទ្ទេស មិនទាន់សហការគ្នារវាងការងារបណ្តុះបណ្តាលនិងអធិការកិច្ច

-នាយកមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ ទោះបីជាមានបទពិសោធនិងបានបណ្តុះបណ្តាលច្រើនឆ្នាំក្តី

-ប្រធានក្រុមបច្ចេកទេសអសមត្ថភាព ផលនៃការប្រជុំមិនបានយកទៅប្រើប្រាស់ជាផ្លូវការ

-គ្រូមិនទាន់យល់ច្បាស់វិធីសាស្រ្តបង្រៀនភាសាខ្មែរ ដោយអនុវត្តតាមគោលវិធីសិស្សមជ្ឈមណ្ឌល និង កង្វះមនសិការវិជ្ជាជីវៈ។

សិស្ស ថ្នាក់រៀនខ្លះ មានសិស្សច្រើនលើសនិយាមគរុកោសល្យ និងកង្វះឯកសារសិក្សា សិស្ស ខ្សោយ - មិនសូវមានសកម្មភាព ពឹងផ្អែកលើសិស្សពូកែ។ សិស្សខ្សោយ បណ្តាលមកពីការឡើងថ្នាក់តាមផែន ការមិនមែនតាមចំណេះ។ សិស្សចូលរៀនមិនបានឆ្លងកាត់មត្តេយ្យសិក្សា

ផ្នែកហេដ្ឋារចនាសម្ព័ន្ធ អគារ បន្ទប់រៀន តុសិស្សវែងជាប់គ្នាពិបាករើចុះឡើង កៅអីជាប់នឹង តុសិស្ស - ក្តារខៀនតូចចង្អៀត មិនត្រឹមត្រូវតាមគរុកោសល្យ កង្វះសម្ភារឧបទេស សម្ភារសិក្សាទំនើប បណ្ណា- ល័យមិនមានបណ្ណារក្សនិងសៀវភៅគ្រប់គ្រាន់ ព្រមទាំងអសមត្ថភាព។

សិក្សាតិច មេរៀនច្រើន សម័យសង្គមរាស្រ្តនិយម ម៉ោងសិក្សាច្រើនកម្មវិធីសិក្សា ម៉ោង- សៀវភៅសិក្សា មានសៀវភៅសិស្ស គ្មានសៀវភៅគ្រូ និងផ្លាស់ប្តូរញឹកញាប់ មិនជាក់លាក់- ការមិនបានបន្តនិន្តរភាពនៃកម្មវិធីសិក្សា សៀវភៅសិក្សា និងវិធីសាស្រ្តបង្រៀនភាសាខ្មែរ-

## ដើម្បីឆ្លើយតបទៅនឹងការលំបាកខាងលើ គេក៏ត្រូវចាប់ផ្តើមពីការអភិវឌ្ឍ វិធីសាស្រ្តបង្រៀនភាសាខ្មែរ កម្មវិធីសិក្សាសិក្សាភាសាខ្មែរនិងសៀវភៅសិក្សាភាសាខ្មែរ ទៅតាមផ្នែកដែលមានការពាក់ព័ន្ធនឹងនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ

-គួរបណ្តុះបណ្តាលបុគ្គលិកទទួលបន្ទុកផ្នែកបច្ចេកទេសនៃវិធីសាស្រ្តបង្រៀនគ្រប់ផ្នែក ជាពិសេស វិធី សាស្រ្តបង្រៀនភាសាខ្មែរនិងសមត្ថភាពផ្នែកកម្មវិធីសិក្សាភាសាខ្មែរបន្ថែមទៀត។

-ត្រូវបណ្តុះបណ្តាលសមត្ថភាពគ្រូឧទ្ទេសឡើងវិញ ព្រោះគ្រូឧទ្ទេសដែលបានបណ្តុះបណ្តាលមុន ឆ្នាំ២០០៤ បានចូលនិវត្តន៍និងផ្លាស់ចេញជាច្រើន។

-ត្រូវសិក្សាស្វែងយល់ឱ្យបានច្បាស់លាស់បន្ថែមទៀត ទៅលើវិធីបង្រៀនសមត្ថភាពភាសាខ្មែរទាំង៤ មានសមត្ថភាពស្តាប់ សមត្ថភាពនិយាយ សមត្ថភាពអាននិងសមត្ថភាពសរសេរ ដែលបានបោះពុម្ពផ្សាយ នា ពេលកន្លងមកថា តើការអនុវត្តនៅឯមូលដ្ឋានសាលារៀនមានការលំបាកអ្វីខ្លះ ចំពោះគ្រូនិងសិស្ស អំពីខ្លឹមសារ និងវិធីបង្រៀន រួចស្វែងរកមូលហេតុដែលបណ្តាលឱ្យមានការលំបាកទាំងនោះនិងចុងក្រោយត្រូវស្វែងរកដំណោះ ស្រាយទៅនឹងការលំបាកទាំងឡាយនោះជាបន្ទាន់។ គេក៏ត្រូវតាមដាននិងសិក្សាអំពីដំណោះស្រាយទាំងនោះ ផងដែរ តើគ្រប់គ្រាន់ដែរឬទេ ចំពោះការលំបាកដែលបានកើតឡើង។

## នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ និង នាយកដ្ឋានបឋមសិក្សា

គេគួរធ្វើសហការគ្នាឱ្យបានស្អិតរមួតលើការអភិវឌ្ឍវិធីបង្រៀនភាសាខ្មែរ។ នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការជាអ្នកទទួលខុសត្រូវចំពោះការបណ្តុះបណ្តាលគ្រូបឋមសិក្សា នៅសាលាគរុកោសល្យនិងវិក្រឹតការ ដែលជាកន្លែងគ្រូត្រូវបណ្តុះបណ្តាលដំបូង។ ក្រោយពេលគ្រូបឋមសិក្សាបានចាកចេញពីសាលាគរុកោសល្យ និងវិក្រឹតការហើយ នាយកដ្ឋានបឋមសិក្សា ជាពិសេស ផ្នែកអធិការកិច្ច ជាអ្នកតាមដានពិនិត្យចំពោះការ បង្រៀនរបស់គាត់ដែលក្នុងនោះមានវិធីបង្រៀនផងដែរ។ ក្រោយពេលពិនិត្យតាមដានហើយ បានរកឃើញពី កង្វះខាតផ្សេងៗដែលបណ្តាលមកពីការបណ្តុះបណ្តាលនៅសាលាគរុកោសល្យនិងវិក្រឹតការ គេត្រូវធ្វើសំណូម ពរទៅនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ ឬ សាលាគរុកោសល្យនិងវិក្រឹតការ ដើម្បីឱ្យជួយកែលម្អឡើង

វិញ។ ម្យ៉ាងទៀត ពេលធ្វើអធិការកិច្ច គេគួរសហការគ្នារវាងអធិការនិងគ្រូឧទ្ទេសតែម្តង ដើម្បីស្វែងរកគុណវិបត្តិនៃវិធីបង្រៀនភាសាខ្មែរ ដើម្បីកែលម្អភ្លាមបានទាន់ពេលវេលា គេក៏គួរស្វែងរកគុណសម្បត្តិល្អ ទុកជាបទពិសោធន៍នាពេលអនាគត។

នាយកដ្ឋានទាំង២ខាងលើ ត្រូវបើកវគ្គបណ្តុះបណ្តាលឬវគ្គតម្រង់ទិសនៅពេលមានការផ្លាស់ប្តូរសៀវភៅភាសាខ្មែរថ្មីនិងកម្មវិធីសិក្សាភាសាខ្មែរថ្មី ដូចដែលបានធ្វើនៅចន្លោះឆ្នាំ១៩៩៦-២០០២។ នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ គួរបណ្តុះបណ្តាលគ្រូបឋមសិក្សាឱ្យបង្រៀនទៅតាមឯកទេស ដូចជាភាសាខ្មែរ គណិតវិទ្យា សិក្សាសង្គមនិងវិទ្យាសាស្ត្រអនុវត្ត ដូចនៅឯមធ្យមសិក្សាឬដូចការបង្រៀននៅសាលាបឋមសិក្សាអង្គរខេមរា (ឯកជន) បានអនុវត្តរួចមកហើយ ពីព្រោះពួកគាត់មានភាពងាយស្រួលក្នុងកការធ្វើកិច្ចតែងការបង្រៀននិងអាចមានចំណេះដឹងច្បាស់លាស់លើមុខវិជ្ជារបស់ខ្លួនបានប្រសើរជាងមុន។

**នាយកសាលារៀន**

គាត់គឺជាអធិការអចិន្ត្រៃយ៍ដែលធ្វើអធិការកិច្ចនៅតាមថ្នាក់រៀនទាំងឡាយ ជាមួយប្រធានក្រុមបច្ចេកទេស ដើម្បីស្វែងយល់តាមដាន វាយតម្លៃនិងជួយដល់ការងារបង្រៀនរបស់គ្រូនិងសកម្មភាពរៀនសូត្ររបស់សិស្សតាមកម្រិតថ្នាក់។ ក្រោយពេលចុះធ្វើរួច នាយកសាលារៀន ជាមួយប្រធានក្រុមបច្ចេកទេស ត្រូវពិភាក្សារៀបចំវិធានការនានា សម្រាប់ជួយគ្រូដែលមានសមត្ថភាពខ្សោយ ដូចជា ការប្រជុំគរុកោសល្យធ្វើថ្នាក់និទស្សន៍ ... ដើម្បីកែលម្អគុណភាពនៃការបង្រៀននិងរៀនឱ្យបានទាន់ពេលវេលា។

**ការប្រជុំក្រុមបច្ចេកទេស**

ការប្រជុំក្រុមបច្ចេកទេសត្រូវតែធ្វើឱ្យមានប្រសិទ្ធភាពនិងប្រកបដោយគុណភាព។ ការធ្វើដូច្នេះបាន គេត្រូវជ្រើសរើសប្រធានក្រុមបច្ចេកទេសដែលមានសមត្ថភាពចំណេះដឹងទូទៅល្អ មានបទពិសោធន៍ក្នុងការងាររយៈពេលយូរឆ្នាំ ជាពិសេស សមត្ថភាពផ្នែកវិធីសាស្ត្របង្រៀន។ ចំពោះការធ្វើថ្នាក់និទស្សន៍ គួរផ្លាស់ប្តូររវាងគ្រូល្អនិងគ្រូខ្សោយ ដើម្បីកេឱ្យឃើញគុណសម្បត្តិនិងគុណវិបត្តិនៅក្នុងវិធីសាស្ត្របង្រៀន។ ចំណែកឯការប្រជុំក្រុមបច្ចេកទេសត្រូវធ្វើឱ្យមានប្រយោជន៍ចំពោះគ្រូបឋមសិក្សា កម្ចាត់ចោលនូវភាពអវិជ្ជមានទាំងឡាយដែលធ្លាប់កើតមានឡើងនាពេលកន្លងមក។

ប្រធានក្រុមបច្ចេកទេសត្រូវចេះតាមដានការងារដែលសម្រេចបាននៅក្នុងការប្រជុំបច្ចេកទេស តើគ្រូបឋមសិក្សាបានអនុវត្តតាមឬទេ? ពេលខ្លះការប្រជុំក្រុមបច្ចេកទេសទទួលបានផលល្អ ប៉ុន្តែ លទ្ធផលដែលសម្រេចបាននោះមិនត្រូវបានគ្រូយកទៅអនុវត្តទេ។

**គ្រូបឋមសិក្សា**

នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការត្រូវរៀបចំបណ្តុះបណ្តាលគ្រូបឋមសិក្សាឡើងវិញ អំពីការប្រើប្រាស់សៀវភៅភាសាខ្មែរថ្មី កម្មវិធីសិក្សាភាសាខ្មែរថ្មី នៅពេលមានការផ្លាស់ប្តូរសៀវភៅភាសាខ្មែរថ្មីនិងកម្មវិធីភាសាខ្មែរថ្មី។ នៅពេលកម្មវិធីសិក្សាថ្មីនិងសៀវភៅសិក្សាថ្មីដែលមានសៀវភៅសិស្សនិងសៀវភៅគ្រូ មានការផ្លាស់ប្តូរចន្លោះឆ្នាំ១៩៩៦-២០០២ នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ បានបោះពុម្ពសៀវភៅវគ្គសិក្សាតម្រង់ទិសដល់គ្រូបង្រៀនបឋមសិក្សានិងនាយកសាលាបឋមសិក្សា ព្រមទាំងមានបើកវគ្គសិក្សាតម្រង់ទិសផង។ ប៉ុន្តែ កម្មវិធីសិក្សាថ្មីនិងសៀវភៅសិក្សាថ្មីដែលបានបោះពុម្ពតាមកម្មវិធីសិក្សាថ្មីឆ្នាំ២០០៦នោះ នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការមិនបានបោះពុម្ពសៀវភៅវគ្គសិក្សាតម្រង់ទិសនិងវគ្គបណ្តុះបណ្តាលទៀតទេ។

សៀវភៅគ្រូក៏គ្មាន សៀវភៅសិស្សផ្លាស់ប្តូរញឹកញាប់ធ្វើឱ្យគ្រូបឋមសិក្សាមានការលំបាកជាខ្លាំង។ គ្រូគួរត្រៀមគំនិតឱ្យបានគ្រប់គ្រាន់ មុននឹងសរសេរកិច្ចតែងការបង្រៀន។ ការត្រៀមគំនិតទាំងនោះមានៈ

ពិនិត្យកម្មវិធីសិក្សា កាលវិភាគនិងរយៈពេល វត្ថុបំណង សម្ភារៈឧបទេស បរិស្ថានសិក្សា សកម្មភាពសិក្សា ខ្លឹមសារមេរៀន សមត្ថភាពមានស្រាប់និងសមត្ថភាពចាំបាច់ រង្វាយតម្លៃនិងការដាក់កិច្ចការផ្ទះសម្រាប់សិស្សធ្វើ។ ក្រោយពេលត្រៀមគំនិតហើយ គ្រូត្រូវសរសេរកិច្ចតែងការបង្រៀនឱ្យបានគ្រប់ពេល ព្រោះវាជាជំនួយស្មារតីរបស់គ្រូបង្រៀន។

គ្រូបឋមសិក្សាត្រូវណែនាំសិស្សឱ្យយល់ពីសារៈសំខាន់នៃមុខវិជ្ជាភាសាខ្មែរ ព្រោះភាសាខ្មែរជាមូលដ្ឋានគ្រឹះនៃការសិក្សាមុខវិជ្ជាផ្សេងៗទៀត បើសិស្សខ្សោយខាងភាសាខ្មែរនោះ សិស្សពិបាកនឹងរៀនមុខវិជ្ជាផ្សេងៗទៀតឱ្យបានពូកែណាស់។ គាត់ក៏ត្រូវណែនាំសិស្សផងដែរថា មុខវិជ្ជាផ្សេងៗទៀតក៏មានសារៈសំខាន់ស្មើៗគ្នាដែរ។

**សិស្ស**

នាយកនិងគ្រូត្រូវរៀបចំសិស្សឱ្យត្រឹមត្រូវតាមនិយាមគរុកោសល្យនិងដោះស្រាយបញ្ហាកង្វះឯកសារសិក្សា ដូចជា សៀវភៅភាសាខ្មែរនិងសម្ភារៈសិក្សា ដូចជា សៀវភៅសរសេរ ដីស ក្តារឆ្នួន ហ្វឺត ប៊ិក បន្ទាត់ ប្រដាប់លុបឱ្យបានគ្រប់គ្រាន់។ សិស្សខ្សោយមិនសូវមានសកម្មភាព ពឹងផ្អែកលើសិស្សពូកែ ត្រូវឱ្យគេធ្វើសកម្មភាពច្រើន ដូចជាអាន សរសេរនិងដោះស្រាយលំហាត់។

សិស្សខ្សោយបណ្តាលមកពីការឡើងថ្នាក់តាមផែនការ មិនមែនតាមចំណេះ ជាបញ្ហាដល់គ្រូបង្រៀន។ សិស្សចូលរៀនមិនបានឆ្លងកាត់មត្តេយ្យសិក្សានិងបានឆ្លងកាត់មត្តេយ្យសិក្សា សុទ្ធតែមានសិទ្ធិចូលរៀននៅសាលាបឋមសិក្សា។ គេគួរពិចារណាឡើងវិញថា សិស្សដែលឆ្លងកាត់សាលាមត្តេយ្យ រយៈពេល៣ឆ្នាំ មានចំណេះខុសពីសិស្សមិនបានឆ្លងកាត់មត្តេយ្យសិក្សាឬទេ? គ្រូបង្រៀននៅសាលាបឋមសិក្សា ជាពិសេស គ្រូនៅថ្នាក់ទី១ នឹងមានភាពងាយស្រួលក្នុងការបង្រៀនសិស្ស ប្រសិនសិស្សរបស់គាត់បានឆ្លងកាត់មត្តេយ្យសិក្សា។

**ផ្នែកហេដ្ឋារចនាសម្ព័ន្ធ**

ក្រសួងអប់រំ យុវជននិងកីឡា គួរកែលម្អអគារសិក្សាឱ្យមានស្តង់ដាប្រសើរជាងមុន។ បន្ទប់រៀនគួរបំពាក់ឱ្យមានភ្លើងអគ្គីសនីឱ្យបានគ្រប់គ្រាន់ កែលម្អតុសិស្ស តុសិស្សកុំវែងជាប់គ្នាពិបាករើចុះឡើង កៅអីកុំជាប់នឹងតុសិស្ស ក្តារខៀនតូចធំទូលាយត្រឹមត្រូវតាមគរុកោសល្យ សម្ភារៈឧបទេសនិងសម្ភារៈសិក្សាទំនើប ដូចជា កុំព្យូទ័រ អ៊ីនធឺណិត ផែនទីខ្មែរនិងសកលលោក ឧបករណ៍បញ្ចាំងរូបភាពឬស្លាយ មានរូបភាពសម្បូរបែបប្រកបដោយពណ៌ធម្មជាតិ មានមីក្រូហ្វូន មានកង្ហារពិតាន ម៉ាញេ ទូរទស្សន៍ វីដេអូ ម៉ាស៊ីនថតចម្លង (Photocopier) ម៉ាស៊ីនបោះពុម្ព (Printer) បណ្ណាល័យ មានបណ្ណារក្សនិងសៀវភៅគ្រប់គ្រាន់ ព្រមទាំងមានសមត្ថភាព។ លើសពីនេះទៅទៀត គេគួរកែលម្អសាលារៀនបឋមសិក្សាឱ្យក្លាយជាសាលារៀននិងថ្នាក់រៀនកុមារមេត្រី។

**កម្មវិធីសិក្សា**

សព្វថ្ងៃនេះកម្មវិធីសិក្សាតម្រូវឱ្យមានម៉ោងសិក្សាតិច មេរៀនច្រើន ខ្លឹមសារវែង ពិបាកយល់ហួសសមត្ថភាពសិស្សបឋមសិក្សានិងគ្រូបឋមសិក្សា។ គេគួរបន្ថែមម៉ោងសិក្សាឱ្យសិស្សបានរៀនទាំងពេលព្រឹក ទាំង

ពេលរសៀល ដូចនៅក្នុងសម័យសង្គមរាស្ត្រនិយម ពោលគឺមួយសប្តាហ៍សិស្សរៀនរហូតដល់ទៅ៣០ម៉ោង។ ពេលមានការផ្លាស់ប្តូរកម្មវិធីសិក្សា គេគួរបើកវគ្គបណ្តុះបណ្តាលដល់ភាគីពាក់ព័ន្ធផង។

គេគួរពិចារណាឡើងវិញ អំពីឈប់ច្រើន ដើម្បីប្រជុំ ពិធីបុណ្យទាន ពិធីការ យកសាលាទៅធ្វើជាមណ្ឌលប្រឡងនិងការឈប់ផ្សេងៗទៀតដែលមិនចាំបាច់ ដែលធ្វើឱ្យគ្រូបឋមសិក្សាបង្រៀនមិនបានចប់ទៅតាមកម្មវិធីសិក្សា ជាពិសេស កម្មវិធីសិក្សាភាសាខ្មែរនិងសិស្សមិនទទួលបានចំណេះដឹងទៀតផង។

**សៀវភៅសិក្សាភាសាខ្មែរ**

ការផ្លាស់ប្តូរសៀវភៅសិក្សា គួរតែមានភាពជាក់លាក់ មិនគួរនិយមបរទេសពេកទេ។ សៀវភៅសិក្សាភាសាខ្មែរមិនគួរផ្លាស់ប្តូរញឹកញាប់ពេកទេ។ ការចេញសៀវភៅភាសាខ្មែរថ្មី ត្រូវមានសៀវភៅគ្រូផង ពីព្រោះ គ្រូបឋមសិក្សាមួយចំនួនមានការលំបាក ជាពិសេស ការបង្រៀនសមត្ថភាពស្តាប់ អំពីការស្តាប់រឿងនិទាន មានគ្រូខ្លះ គាត់មិនចេះរឿងនិទាន ដែលមាននៅក្នុងសៀវភៅនោះផង។

សៀវភៅគ្រូ គួររៀបចំសរសេរវត្ថុបំណងឱ្យបានច្បាស់លាស់ ដូចជាផ្នែកចំណេះដឹង បំណិននិងឥរិយាបថ ព្រមទាំងរៀបចំឱ្យមានផ្នែកសកម្មភាព លក្ខខណ្ឌនិងកម្រិតលទ្ធផល។

ជារួមមក ការនិពន្ធសៀវភៅសិក្សាភាសាខ្មែរ ទាំងផ្នែកសៀវភៅសិស្ស ទាំងផ្នែកសៀវភៅគ្រូ បានល្អ វានឹងជួយជំរុញដល់ការអនុវត្តវិធីបង្រៀនភាសាខ្មែរបានល្អ ព្រមទាំងគុណភាពសិក្សាក៏ទទួលបានលទ្ធផលល្អប្រសើរដែរ។

ចំពោះសៀវភៅសិស្ស ត្រូវរៀបចំបោះពុម្ពឱ្យមានរចនាថល្អ មានរូបភាព រូបថតពណ៌ធម្មជាតិល្អៗដែលធ្វើឱ្យសិស្សមានចំណូលចិត្តចង់អាននិងចង់សិក្សា។ គេត្រូវពិនិត្យអក្ខរាវិរុទ្ធឱ្យបានច្បាស់លាស់មុននឹងបោះពុម្ពផ្សាយ។ ចំពោះបទានុក្រមនៅផ្នែកខាងក្រោយនៃសៀវភៅសិស្ស គួរបន្ថែមពាក្យឱ្យបានច្រើននិងគ្រប់គ្រាន់ដែលអាចប្រើបានទាំងគ្រូទាំងសិស្ស ហើយត្រូវប្រាប់ពីវិធីអានពាក្យ ថ្នាក់ពាក្យ ឬ ប្រភេទពាក្យនិង ពន្យល់ន័យឱ្យបានត្រឹមត្រូវផង។ គេក៏គួរតែបញ្ចូលសទិសសូរឬសូរដូច សទិសន័យឬន័យដូច ពាក្យផ្ទុយនិងតែងសេចក្តីទៅក្នុងសៀវភៅភាសាខ្មែរឡើងវិញផង។

**គេត្រូវប្រើល្បិចបង្រៀន ដើម្បីជំនះនូវការលំបាកទាំងនេះ៖**

-**ចំពោះគ្រូ៖** ល្បិចបង្រៀនលើសមត្ថភាពទាំង៤ គឺ ស្តាប់ និយាយ អាន និង សរសេរ។

-**ចំពោះសិស្ស៖** ល្បិចបង្រៀនលើសមត្ថភាពទាំង៤ គឺ ស្តាប់ និយាយ អាន និង សរសេរ។

សរុបសេចក្តីមក ការអភិវឌ្ឍវិធីសាស្ត្របង្រៀនភាសាខ្មែរ នៅបឋមសិក្សា បានទទួលជោគជ័យនោះមិនមែនអ្នកណាតែម្នាក់ឬមួយក្រុម អាចធ្វើទៅបានទេ គេត្រូវរួមសហការគ្នា នៅក្នុងក្រសួងអប់រំ យុវជន និងកីឡា តាំងពីថ្នាក់លើរហូតដល់ថ្នាក់មូលដ្ឋានសាលារៀន។ គេត្រូវសិក្សាឱ្យបានស៊ីជម្រៅនិងឱ្យបានច្បាស់លាស់អំពីការលំបាកនិងមូលហេតុនៃការលំបាកដែលកើតមាននៅក្នុងវិធីសាស្ត្របង្រៀនភាសាខ្មែរ ព្រមទាំងស្វែងរកដំណោះស្រាយឱ្យបានទាន់ពេលវេលា។

# របបសន្តិសុខសង្គមនៅក្នុងសហគ្រាសកាត់ដេរ, ភ្នំពេញ



សុខ បូរី
បេក្ខជនបណ្ឌិតជំនាន់ទី១ ផ្នែកនីតិសាស្ត្រ
សាកលវិទ្យាល័យឯកទេសនៃកម្ពុជា

**១-សេចក្តីផ្តើម**

នៅដើមឆ្នាំ២០០០ ឧស្សាហកម្មវាយនភណ្ឌនិងសម្លៀកបំពាក់មានសន្ទុះកើនឡើងគួរឱ្យកត់សម្គាល់។ តាមតួលេខរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានឱ្យដឹងថា នៅឆ្នាំ២០០៦[១] កម្ពុជាមានរោងចក្រវាយនភណ្ឌសម្លៀកបំពាក់និងស្បែកជើងចំនួន៤៩២ និងមានកម្មករ-និយោជិតចំនួន៤០៣ ៧៤៣នាក់ ឯសហគ្រាស ក្រៅពីកាត់ដេរមានចំនួន៧៧២និងមានកម្មករ-និយោជិតសរុប១៧ ៧៧៨នាក់។ ឆ្នាំ២០០៧ កម្ពុជាមានរោងចក្រវាយនភណ្ឌ សម្លៀកបំពាក់និងដេរស្បែកជើង៥០៥ មានកម្មករ-និយោជិតសរុប៣៦៦-២៩៩នាក់។ ក្រៅពីសហគ្រាសកាត់ដេរ មានសហគ្រាសចំនួន១ ៨៦៣ ដែលមានកម្មករ-និយោជិតសរុបចំនួន៧៤ ២១២នាក់។ ឆ្នាំ២០០៨ សហគ្រាសនិងគ្រឹះស្ថានកាត់ដេរមានចំនួន៤៣២ ដែលមានកម្មករ-និយោជិតសរុបចំនួន២៨០ ៦០១នាក់ និង សហគ្រាសក្រៅពីកាត់ដេរចំនួន៨៤១ ដែលមានកម្មករ-និយោជិត សរុបចំនួន២៥ ៩៨៨នាក់។ ចំនួនកម្មករ-និយោជិតទាំងនោះ ៨០% ជានារីក្មេងៗដែលមានអាយុពី១៨ឆ្នាំទៅ២៥ឆ្នាំ។ ការរីកលូតលាស់ផ្នែកឧស្សាហកម្មធុនស្រាលទាំងនេះ គឺជាកត្តាជំរុញឱ្យមានការប្តូរកម្លាំងពលកម្មពីជនបទមកទីក្រុង ឬ ទីប្រជុំជនយ៉ាងគំហុក។ ការឃ្លាតឆ្ងាយពីគ្រួសារនៅទីជនបទមករស់នៅនិងស្វែងរកការងារធ្វើនៅទីក្រុង ឬ ទីប្រជុំជន តម្រូវឱ្យពួកគេប្រឈមមុខទៅនឹងបញ្ហាលំបាកជាច្រើនដូចជា ជម្រកស្នាក់នៅ, បញ្ហាហូបចុក, សម្លៀកបំពាក់និងការថែទាំសុខភាព។ ជាងនេះទៅទៀត ពួកគេប្រឈមទៅនឹងបញ្ហាមួយចំនួន ដែលគេពុំដែលជួបប្រទះ ដូចជា ហានិភ័យការងារ និងជម្ងឺវិជ្ជាជីវៈ ការកេងប្រវ័ញ្ចកម្លាំងពលកម្មពីសំណាក់ជនឱកាសនិយម, ការរំលោភបំពានលើរាងកាយ, អនាចារនានា និង ការរីករាលដាលនៃជំងឺអេដស៍ជាដើម។ បញ្ហាទាំងអម្បាលមានខាងលើនេះ តម្រូវឱ្យរាជរដ្ឋាភិបាលរៀបចំវិធានការការពារសង្គម ដើម្បីឱ្យកម្លាំងពលកម្មត្រូវបានធានាប្រឆាំងទល់នឹងការបាត់បង់ប្រាក់ឈ្នួល ការថមថយនៃប្រាក់ចំណូលដែលបណ្តាលមកពីហានិភ័យសង្គមនានាដូចជាគ្រោះថ្នាក់ការងារ, ជំងឺវិជ្ជាជីវៈ, ការសម្រាលកូន, ជរាភាព, ទុព្វលភាព និង មរណភាពជាដើម។

ដោយយល់ឃើញថាកម្មករ-និយោជិតពីមួយឆ្នាំទៅមួយឆ្នាំ ដែលកំពុងធ្វើការនៅក្នុងរោងចក្រ សហគ្រាសឯកជនកាន់តែមានចំនួនកើនឡើងឥតឈប់ឈរ ទទួលរងនូវហានិភ័យការងារ ដូចជា គ្រោះថ្នាក់នៅនឹងកន្លែងធ្វើការ បណ្តាលមកពីមូលហេតុជាច្រើនដូចជា ដួលសន្លប់នៅនឹងកន្លែង ដោយពុលនឹងជាតិគីមីនៅនឹងក្រណាត់ ឬ សម្លៀកបំពាក់កំពុងកាត់ដេរ កន្លែងហាប់ពុំមានខ្យល់អុកស៊ីសែនគ្រប់គ្រាន់ ពន្លឺបំភ្លឺពុំគ្រប់គ្រាន់នៅពេលធ្វើការ។ នៅពេលធ្វើដំណើរពីលំនៅដ្ឋានទៅកន្លែងធ្វើការនិងការវិលត្រឡប់ពីកន្លែងធ្វើការមកលំនៅដ្ឋាន កម្មករ-និយោជិតតែងតែជួបប្រទះគ្រោះថ្នាក់ចរាចរណ៍មិនមានចំនួនតិចទេរហូតដល់ស្លាប់, រងរបួសធ្ងន់រហូតដល់បាត់បង់សមត្ថភាពការងារបណ្តោះអាសន្ននិងទាំងស្រុងដែលនិយោជក ឬ ម្ចាស់សហគ្រាសមួយចំនួនបានបដិសេធការទទួលខុសត្រូវរបស់ខ្លួនចំពោះហានិភ័យទាំងនេះ។ ជំងឺវិជ្ជាជីវៈដែលច្បាប់បានចាត់ទុកថាជាគ្រោះ

[១] ឆ្នាំ២០០៦ និង ឆ្នាំ២០០៨ ដកស្រង់ពីរបាយការណ៍ប្រចាំឆ្នាំ២០០៧ របស់ក្រសួងការងារនិបណ្តុះបណ្តាលវិជ្ជាជិវៈ

ថ្នាក់ការងារ និយោជក ឬ ម្ចាស់សហគ្រាស ពុំបានយកចិត្តទុកដាក់អនុវត្តតាមប្រកាសណែនាំរបស់ក្រសួងឡើយ[២]។

គោលបំណងនៃការស្រាវជ្រាវៈ

១- សិក្សាលើរបបហានិភ័យការងារដែលកំពុងអនុវត្តក្នុងរោងចក្រ-សហគ្រាស។

២- ស្វែងយល់ពីការឧបត្ថម្ភប្រាក់តាវកាលិកដល់កម្មករ-និយោជិតដែលទទួលរងគ្រោះថ្នាក់ក្នុងម៉ោង និង ក្រៅម៉ោងការងារ។

## ២-វិធីសាស្ត្រស្រាវជ្រាវ

### ២.១ ការជ្រើសរើសសំណាក

សំណាកបានជ្រើសរើសដោយចៃដន្យតាមគោលបំណងនៃការស្រាវជ្រាវ ដោយជ្រើសរើសយកតែកម្មករ-និយោជិតណាដែលធ្វើការងារនៅក្នុងសហគ្រាសកាត់ដេរតែប៉ុណ្ណោះ។

ទំហំសំណាកវិញបានជ្រើសរើសយក ១០០% នៃចំនួននិយោជិត-កម្មករក្នុងរោងចក្រទាំងអស់។

n =113នាក់

n = ចំនួននិយោជិត-កម្មករដែលត្រូវសម្ភាស

### ២.២ ការប្រមូលទិន្នន័យបឋម (Primary Data)

គឺជាការរៀបចំកម្រងបញ្ជីសំណួរ ដែលបានធ្វើឡើងដោយមានការកែតម្រូវនិងឯកភាពពីសាស្ត្រាចារ្យដឹកនាំ។

ការប្រមូលទិន្នន័យ ត្រូវធ្វើឡើងតាមការចុះទៅសម្ភាសផ្ទាល់យកព័ត៌មាននៅទីកន្លែងជាក់ស្តែង តាមរយៈបញ្ជីសំណួរ (Questionnaires) ដើម្បីប្រមូលព័ត៌មានដែលទាក់ទងទៅនឹងប្រធានបទខាងលើ។

### ២.៣ ការប្រមូលទិន្នន័យទី២ (Secondary Data)

គឺទិន្នន័យដែលមានស្រាប់ ដូចជា ឯកសារស្នាដៃអ្នកនិពន្ធកម្រិតជាតិ ស្នាដៃអ្នកនិពន្ធបរទេស ច្បាប់ជាតិ ច្បាប់អន្តរជាតិ និង លិខិតបទដ្ឋានក្រោមច្បាប់នានា។ បន្ថែមក្រៅពីនេះទៀត មានឯកសារតាមប្រព័ន្ធអ៊ីនធឺណែត ព្រឹត្តិបត្រព័ត៌មាន និង ឯកសារមកពីប្រភពផ្សេងៗទៀត។

វិធីសាស្ត្រប្រមូលទិន្នន័យសម្រាប់ការស្រាវជ្រាវនេះ មានពីរបែប គឺ ៖

**១. វិធីសាស្ត្របែបគុណភាព និង បែបបរិមាណ**

វិធីសាស្ត្រនេះតម្រូវឱ្យមានព័ត៌មានចាំបាច់ ដូចជា ៖

ទិន្នន័យទី ១ ៖ សាកសួរផ្ទាល់តាមរយៈកម្រងសំណួរ

ទិន្នន័យទី២ ៖ ប្រមូលឯកសារដែលមានស្រាប់ដូចជា ព្រះរាជក្រឹត្យ អនុក្រឹត្យ ឯកសារនានាដែលពាក់ព័ន្ធ Internet ច្បាប់សារាចរ របាយការណ៍ ។ល។

**២. វិធីសាស្ត្រវិភាគ**

ទិន្នន័យដែលប្រមូលបាន ត្រូវបានធ្វើការវិភាគតាមបែបគុណភាពតាម Chi square Test នៃកម្មវិធី SPSS (Statistic Package of Social Science) ។

## ៣-លទ្ធផលនៃការស្រាវជ្រាវនិង ការពិភាក្សា

តារាងទី៤-៣ កម្រិតវប្បធម៌ទូទៅរបស់ប្រជាជន

[២] ប្រកាស លេខ ៣៤៣ សកបយ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០២ របស់ក្រសួងទទួលបន្ទុកវិស័យការងារ

| បឋម | មធ្យមបឋមភូមិ | មធ្យមទុតិយភូមិ | ឧត្តមសិក្សា | Chi-square | Probability |
|---|---|---|---|---|---|
| ៤១ | ៥៣ | ១៩ | ១ | ៥៦.២៤ | <0.00១ |

បកស្រាយ ៖ លទ្ធផលតារាងទី៤-៣ ខាងលើនេះ បានបញ្ជាក់ឱ្យដឹងថាៈ កម្រិតវប្បធម៌ទូទៅរបស់កម្មករភាគច្រើនមានកម្រិតទាប ត្រឹមតែបឋមនិងមធ្យមសិក្សាប៉ុណ្ណោះ (p<0.001) រីឯកម្រិតមធ្យមទុតិយភូមិក៏មានបរិមាណតិចដែរ។

តារាងទី៤-៦ ប្រាក់បំណាច់ប្រចាំខែរបស់កម្មករ-និយោជិត

| Mean | Std. Deviation | អប្បបរិមា (រៀល) | អតិបរមា (រៀល) |
|---|---|---|---|
| ៥១៦ ៤០៨.៥ | ២៩៨ ៩០៦.៩៩ | ១២៣ ៦០០ | ១ ៩៣៧ ៩៤០ |

បកស្រាយៈ លទ្ធផលតារាងទី៤-៦ ខាងលើនេះ បានបញ្ជាក់ឱ្យដឹងថាៈ មធ្យមភាគប្រាក់បំណាច់ ប្រចាំខែរបស់កម្មករ-និយោជិត ៥១៦៤០៨,៥០រៀល។

តារាងទី៤-៧ កម្មករធ្លាប់ទទួលរងគ្រោះថ្នាក់នៅកន្លែងធ្វើការ

| មាន | គ្មាន | Chi-square | Probability |
|---|---|---|---|
| ៧៣ | ៤១ | ៨.៩៨ | <0.00១ |

បកស្រាយៈ លទ្ធផលតារាងទី៤-៧ ខាងលើនេះ បានបញ្ជាក់ឱ្យដឹងថាៈ ជាទូទៅកម្មករធ្លាប់ទទួលរងគ្រោះថ្នាក់នៅកន្លែងធ្វើការស្ទើរតែទ្វេដងជាងអ្នកពុំដែលមានគ្រោះថ្នាក់ ដោយ p<0.001 ។

តារាងទី៤-៩ ប្រភេទគ្រោះថ្នាក់ដែលកើតឡើងនៅនឹងកន្លែងធ្វើការ

| សន្លប់ | ផ្សេងៗ | Chi-square | Probablility |
|---|---|---|---|
| ៧១ | ១ | ៦៨.០៥ | <0.00១ |

បកស្រាយៈ លទ្ធផលតារាងទី៤-៩ ខាងលើនេះ បានបញ្ជាក់ឱ្យដឹងថាៈ ប្រភេទគ្រោះថ្នាក់ដែលកើតឡើងញឹកញាប់ជាងគេ គឺសន្លប់នៅនឹងកន្លែងដោយ p<0.001 ។

តារាងទី៤-១០តើនិយោជកមានដែលឧបត្ថម្ភប្រាក់តាវកាលិកដល់កម្មកររងគ្រោះដែរឬទេ?

| មាន | គ្មាន | Chi-square | Probability |
|---|---|---|---|
| ៧០ | ១០៤ | ៨៩.៩១ | <0.00១ |

បកស្រាយៈ លទ្ធផលតារាងទី៤-១០ ខាងលើនេះ បានបញ្ជាក់ឱ្យដឹងថាៈ ជាទទូទៅនិយោជកមានការជួយឧបត្ថម្ភប្រាក់តាវកាលិកដល់កម្មករដែលរងគ្រោះដោយ p<0.001 ។

តារាងទី៤-២០ តើនិយោជកមានបានផ្តល់សំណងដល់កម្មករ-និយោជិតពេលបញ្ឈប់ពីការងារដែរ ឬទេ?

| មាន | គ្មាន | Chi-square | Probability |
|---|---|---|---|
| ៥ | ១០៤ | ៨៩.៩១ | <0.00១ |

បកស្រាយៈ លទ្ធផលតារាងទី៤-២០ ខាងលើនេះ បានបញ្ជាក់ឱ្យដឹងថាៈ ជាទូទៅពេលបញ្ឈប់កម្មករ-និយោជិត ពីការងារ និយោជកពុំដែលផ្តល់សំណងដល់កម្មករទេ p.<.0.001។

តារាងទី៤-២១ និយោជកមានដែលកាត់ប្រាក់បំណាច់ប្រចាំខែរបស់កម្មករ-និយោជិតសម្រាប់ធានារ៉ាប់រងទៅលើហានិភ័យការងារដែរឬទេ មុនបេឡាជាតិបង្កើត?

| គ្មាន | Chi-square | Probabililty |
|---|---|---|
| ១១១ | | <0.00១ |

បកស្រាយៈ លទ្ធផលតារាងទី ៤-២១ ខាងលើនេះ បានបញ្ជាក់ឱ្យដឹងថាៈ និយោជកមិនមានកាត់ប្រាក់បំណាច់ប្រចាំខែរបស់កម្មករ សម្រាប់ធានារ៉ាប់រងទៅលើហានិភ័យការងារទេ មុនបេឡាជាតិបង្កើត $p<0.001$។

តារាងទី៤-២៤ យោបល់ចំពោះរបបហានិភ័យការងារនាពេលបច្ចុប្បន្ន

| ជួយសម្រាលបន្ទុកកម្មករពេលទទួលរងគ្រោះថ្នាក់ | Chi-square | Probability |
|---|---|---|
| ១១៣ | | <0.00១ |

បកស្រាយៈ លទ្ធផលតារាងទី៤-២៤ ខាងលើនេះ បានបញ្ជាក់ឱ្យដឹងថាៈ ជាទទូទៅនិយោជិតមានបំណងទាំងអស់គ្នាឱ្យមានរបបហានិភ័យការងារ ដើម្បីជួយសម្រាលបន្ទុកកម្មករ ពេលទទួលរងគ្រោះថ្នាក់ម្តងៗ $p<0.001$។

ទន្ទឹមនឹងគ្រោះថ្នាក់នៅនឹងកន្លែងធ្វើការ ក៏មានគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកជាច្រើនបន្ថែមទៀតក្រៅម៉ោងធ្វើការ ដោយគ្រាន់តែក្នុងរយៈពេល៨ឆ្នាំ គឺពីឆ្នាំ២០០០ រហូតដល់ឆ្នាំ២០០៧ មានជនរងគ្រោះដោយគ្រោះថ្នាក់ចរាចរណ៍ចំនួន៨៣ ៦៥៧នាក់ ដែលក្នុងនោះមានមនុស្សស្លាប់ ៧ ០០២នាក់, របួសធ្ងន់ ២៨ ៨៦០នាក់ របួសស្រាល ៤៧ ៧៩៥នាក់[៣] ដែលត្រូវចំណាយថវិកា រាប់រយលានដុល្លារក្នុងមួយឆ្នាំៗ ហើយអ្នករងគ្រោះមួយចំនួនត្រូវពិការនិងបាត់បង់សមត្ថភាពពលកម្មអស់មួយជីវិត។

## ៤-សន្និដ្ឋាន

លទ្ធផលនៃការស្រាវជ្រាវបានបញ្ជាក់ឱ្យដឹងថា កម្មករដែលទទួលរងគ្រោះថ្នាក់ការងារ និយោជកក៏មានការជួយឧបត្ថម្ភប្រាក់តាវកាលិកដល់កម្មករដែលរងគ្រោះដោយ $p<0.001$។ រីឯប្រាក់តាវកាលិកដែលបានឧបត្ថម្ភដល់កម្មកររងគ្រោះមានចំនួនជាមធ្យម ១២៩.៤២ដុល្លាអាមេរិកតែប៉ុណ្ណោះ។ ប្រាក់ឧបត្ថម្ភនេះមានចំនួនតិចតួចណាស់សម្រាប់ការព្យាបាលជំងឺ។ ចំពោះសុវត្ថិភាពកម្មករពេលបំពេញការងារ និយោជកពុំបានតម្រូវឱ្យបង់ភាគទានហានិភ័យការងារទេ $p<0.001$។ ការដោះស្រាយរបបហានិភ័យការងារ ដោយបេឡាជាតិរបបសន្តិសុខសង្គមទើបបានចាប់ផ្តើមអនុវត្តនៅចុងឆ្នាំ២០០៨។

សរុបសេចក្តីមក របបធានារ៉ាប់រងសង្គមដែលមានចែងក្នុងគោលនយោបាយនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដឹកនាំដោយភាគីចម្រុះត្រីភាគីគឺក្រុមប្រឹក្សាភិបាលនៃប.ស.ស.អាចនាំមកនូវក្តីសេចក្តីសង្ឃឹមនាពេលបច្ចុប្បន្ននិងទៅអនាគតចំពោះកម្មករ-និយោជិតទាំងអស់ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ ស្តីពីការងារនិងច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ។

# គន្ថនិទ្ទេស

១- ច្បាប់ស្តីពីការងារ

២- ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

៣- អនុក្រឹត្យ លេខ១៦ អនក្រ. ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិ របបសន្តិសុខសង្គម។

៤- របាយការណ៍របស់ក្រសួងសាធារណការ និងដឹកជញ្ជូនឆ្នាំ២០០៤ ដល់ឆ្នាំ២០០៧។

៥- របាយការណ៍ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ឆ្នាំ២០០០, ២០០១, ២០០៤, ២០០៦, ២០០៧, ២០០៨។

៦- របាយការណ៍របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រចាំឆ្នាំ២០០៧

៧- ប្រកាស លេខ ២៤៣ សកបយ. របស់ក្រសួងទទួលបន្ទុកវិស័យការងារ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០២។

# កត្តាដែលនាំឱ្យការគ្រប់គ្រងរដ្ឋបាលមូលដ្ឋានមានប្រសិទ្ធភាព

ជួន រក្សា
បេក្ខជនបណ្ឌិតជំនាន់ទី១ ផ្នែកគ្រប់គ្រង
សាកលវិទ្យាល័យឯកទេសនៃកម្ពុជា

## ១-មូលសង្ខេប

បច្ចុប្បន្នមានប្រទេសជាច្រើននៅលើសកលលោក បានធ្វើការផ្លាស់ប្តូរការងារគ្រប់គ្រងរដ្ឋបាលមូលដ្ឋានរបស់ខ្លួនពីមជ្ឈការទៅកាន់វិមជ្ឈការដើម្បីឱ្យការងារអភិវឌ្ឍនៅក្នុងមូលដ្ឋានមានប្រសិទ្ធភាពកាន់តែខ្ពស់ ។ ការផ្លាស់ប្តូរនេះមានបំណងឆ្លើយតបតាមតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានគិតទាំងការអភិវឌ្ឍ និងការបញ្ចេញមតិតាមលទ្ធិប្រជាធិបតេយ្យបែបវិមជ្ឈការ។ ប្រទេសកំពុងប្រកាន់ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលមូលដ្ឋានតាមបែបវិមជ្ឈការមានដូចជាប្រទេស ជប៉ុន ចិន អង់គ្លេស បារាំង ឥណ្ឌូនេស៊ី តៃវ៉ាន់ អាឡឺម៉ង់ កាសាកស្ថាន និងមានបណ្តាប្រទេសជាច្រើនទៀតនៅលើពិភពលោក។

ការប្រតិបត្តិគោលនយោបាយវិមជ្ឈការមានប្រសិទ្ធភាពទៅបាន លុះត្រាតែអនុវត្តទៅតាមអ្វីដែលច្បាប់បានកំណត់និងមានការចូលរួមពីប្រជាជននូវគ្រប់កិច្ចការអភិវឌ្ឍក្នុងមូលដ្ឋាន។ នៅក្នុងកាលៈទេសៈនេះ ប្រទេសកម្ពុជាបានកំពុងធ្វើកំណែទម្រង់បែបបទរដ្ឋបាលជាច្រើន ជាពិសេសប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៅថ្នាក់មូលដ្ឋានក្នុងគោលដៅជម្រុញការអភិវឌ្ឍឱ្យមានប្រសិទ្ធភាពដោយធ្វើការសិក្សាពីបណ្តាប្រទេស ដែលកំពុងទទួលជោគជ័យក្នុងកិច្ចអភិវឌ្ឍតាមបែបវិមជ្ឈការ។

## ២-សេចក្តីផ្តើម

ការគ្រប់គ្រងរដ្ឋបាលមូលដ្ឋានមានប្រសិទ្ធភាព ជាកិច្ចការដ៏សំខាន់ឈានទៅរកភាពជោគជ័យធំៗ និងជាគ្រឹះនៃកិច្ចអភិវឌ្ឍប្រកបដោយនិរន្តរភាព ប៉ុន្តែនៅក្នុងការអនុវត្តតែងជួបប្រទះនឹងបញ្ហាប្រឈមជាច្រើន ដែលទាមទារឱ្យមានការ កែលម្អនិងរកដំណោះស្រាយ។ ការសិក្សានឹងពិនិត្យការអនុវត្តរបស់ប្រទេសមួយចំនួន ដែលទទួលបានជោគជ័យនៅក្នុងគោលនយោបាយវិមជ្ឈការមកធ្វើជាគំរូក្នុងប្រទេសកម្ពុជា។

វិសាលភាពនេះពិនិត្យមើលជាសំខាន់អំពីស្ថានភាពទូទៅរបស់មូលដ្ឋានថ្នាក់ក្រោមបំផុតនៅក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលបានធ្វើឡើងក្នុងនីតិកាលទី១ ពី ខែកុម្ភៈ ឆ្នាំ ២០០២ នៅកម្ពុជារហូតដល់ ឆ្នាំ ២០១០ នៃនីតិកាលទី២ ក្នុងនោះបានធ្វើការពិនិត្យមើលការវិវត្តជាសារវន្តក្នុងវិស័យកំណែទម្រង់នៃវិមជ្ឈការរបស់គណៈកម្មការជាតិកំណែទម្រង់វិមជ្ឈកា វិសហមជ្ឈការ ដែលបានអនុវត្តចាប់តាំងពីឆ្នាំ ២០០៧ ។

ការសិក្សាស្រាវជ្រាវត្រូវបានធ្វើឡើងដើម្បីបម្រើផលប្រយោជន៍អាជ្ញាធរមូលដ្ឋានឃុំ សង្កាត់ ប្រជាពលរដ្ឋ និងជាការបង្ហាញអំពីសកម្មភាពគ្រប់គ្រងរដ្ឋបាលនៅមូលដ្ឋានតាមប្រព័ន្ធវិមជ្ឈការ ដែលជាកិច្ចការអភិវឌ្ឍមួយនៅតំបន់ជនបទ ឬ មូលដ្ឋានដើម្បីបង្កើនកម្រិតជីវភាពបទដ្ឋានរបស់ប្រជាពលរដ្ឋ។

សារៈប្រយោជន៍នៃការសិក្សានេះជាការជួយជម្រុញដល់អាជ្ញាធរមូលដ្ឋានឃុំ សង្កាត់ ប្រជាពលរដ្ឋនិងដៃគូអភិវឌ្ឍនានានៅមូលដ្ឋានទាំងអស់ដែលកំពុងចូលរួមធ្វើសកម្មភាពអភិវឌ្ឍផ្សេងៗ ដល់កិច្ចការអនុវត្តលទ្ធិប្រជាធិបតេយ្យទៅតាមគោលនយោបាយវិមជ្ឈការ។ ចូលរួមលើកកម្ពស់ការគ្រប់គ្រងរដ្ឋបាលនៅមូលដ្ឋានដើម្បីជួយសម្របសម្រួលដល់ការផ្តល់សេវាកម្មសាធារណៈ បង្កើនកម្រិតជីវភាពរបស់ប្រជាពលរដ្ឋនៅភូមិឃុំ ឱ្យកាន់តែមានភាពប្រសើរឡើង និងមានការគាំទ្រពីប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន។ ជាពិសេសសារៈប្រយោជន៍នេះ នឹងបានជាគន្លឹះដើម្បីជួយដល់ការកែទម្រង់ ជាគោលការណ៍ជាក់លាក់មួយ យកមកធ្វើការវិភាគអំពីផលលំបាកផ្សេងៗរបស់ឃុំ សង្កាត់ផ្សេងៗគ្នានៅលើស្ថានភាពភូមិសាស្ត្រផ្សេងៗគ្នា និងមានសារៈប្រយោជន៍ចំពោះអស់លោកលោកស្រីអ្នកសិក្សាស្រាវជ្រាវ មិត្តអ្នកអានជំនាន់ក្រោយ។

## ៣-កត្តា ដែលនាំឱ្យការគ្រប់គ្រងរដ្ឋបាលមូលដ្ឋានមានប្រសិទ្ធភាព

កត្តាមួយចំនួន ដែលនាំឱ្យការគ្រប់គ្រងរដ្ឋបាលមូលដ្ឋានមានប្រសិទ្ធភាពមានដូចជាៈ ធនធានមនុស្សគ្រប់គ្រាន់ ចំណូលប្រចាំឆ្នាំគិតជាមធ្យមសំរាប់មនុស្សម្នាក់ៗមានភាពសមរម្យបានឆ្លើយតបទៅនឹង ជីវភាពរស់នៅក្នុងប្រទេស ប្រជាពលរដ្ឋភាគច្រើនអាចមានសមត្ថភាព លទ្ធភាពទទួលព័ត៌មាន និងប្រើប្រាស់ប្រព័ន្ធព័ត៌វិទ្យាដែលជាបណ្តាញទំនាក់ទំនងការងារដ៏មាន ប្រសិទ្ធភាព និងជាប្រភពព័ត៌មានយ៉ាងទូលំទូលាយ ។

### ៣. ១-ប្រទេសជប៉ុន

#### ៣.១.១-ធនធានមនុស្ស

បច្ចុប្បន្នប្រទេសជប៉ុនជាប្រទេសមានធនធានមនុស្សដ៏សម្បូរបែបប្រកបទៅដោយការច្នៃប្រឌិតខ្ពស់ពីព្រោះធនធានមនុស្សដែលបានបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេសត្រូវបានវិលចូលប្រទេសវិញ ។

ប្រទេសជប៉ុនប្រកាន់យកលទ្ធិប្រជាធិបតេយ្យ របបសភានិយមអនុវត្តសេដ្ឋកិច្ចទីផ្សារសេរី។ មកដល់បច្ចុប្បន្ននេះប្រទេសជប៉ុនអនុវត្តគោលនយោបាយវិមជ្ឈការអស់រយៈពេល ១១៦ឆ្នាំ កន្លងមកហើយដោយបានធ្វើកំណែទម្រង់ជាច្រើនលើក។ក្រៅពីបោះឆ្នោតជាតិជ្រើសរើសរដ្ឋសភា(របបសភានិយម)រដ្ឋសភាបោះឆ្នោតជ្រើសរើសនាយករដ្ឋមន្ត្រីជាបន្តដើម្បីដឹកនាំប្រទេស ក្រៅពីនេះប្រទេសជប៉ុនមានរៀបចំការបោះឆ្នោតជាច្រើននៅថ្នាក់មូលដ្ឋានការបោះឆ្នោតជ្រើសរើស អភិបាលខេត្តក្រុង ស្រុក មេឃុំ សភាខេត្ត ក្រុង ស្រុក ឃុំ ការបោះឆ្នោតនេះធ្វើឡើងដោយសេរី និងជាសាកលដោយ សម្លេងប្រជាពលរដ្ឋរបស់ខ្លួននៅក្នុងដែនសមត្ថកិច្ចនីមួយៗ។ បន្ទាប់ពីបានទទួលលទ្ធផលជ្រើសរើសតាមសម្លេងប្រជាពលរដ្ឋ រួចពួកគេនឹងចូលកាន់តំណែង

តាមលំដាប់ថ្នាក់នីមួយៗ។ ប្រព័ន្ធរដ្ឋបាលរបស់ប្រទេសជប៉ុនបែងចែកជាបីថ្នាក់សំខាន់ៗ ថ្នាក់កណ្តាល ថ្នាក់ខេត្ត និងថ្នាក់ស្រុក ឃុំ ភូមិ ។

**៣.១.២-កត្តាប្រាក់ចំណូល**

ប្រាក់ចំណូលប្រចាំឆ្នាំគិតជាមធ្យមសម្រាប់មនុស្សម្នាក់ៗរបស់ពលរដ្ឋប្រទេសជប៉ុននៅក្នុង ឆ្នាំ ២០១១ ទទួលបានចំនួន ៤៥ ៨៧០ ដុល្លារអាមេរិក នៅឆ្នាំ២០១២សម្រាប់មនុស្សម្នាក់ៗទទួលបានចំនួន៤៧ ០០០ ដុល្លារអាមេរិក។ប្រាក់ចំណូលនេះបានធ្វើឱ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋជប៉ុនបានល្អប្រសើរបំផុតបើប្រៀបទៅនឹងប្រជាជនកម្ពុជា ជាមូលហេតុធ្វើឱ្យរាល់ការអភិវឌ្ឍនៅប្រទេសនេះមានប្រសិទ្ធភាពខ្ពស់ ។

**៣.១.៣-ប្រព័ន្ធព័ត៌មានវិទ្យា**

ប្រព័ន្ធព័ត៌មានវិទ្យាជាបណ្តាញទំនាក់ទំនងការងារដ៏សំខាន់នៅក្នុងសង្គមប្រជាជនជប៉ុន ស្ទើរទាំងអស់មានសមត្ថភាពប្រើប្រាស់ព័ត៌មានវិទ្យា គិតជាភាគរយមានរហូតដល់ ៧៩.៥៣ ភាគរយ។

**៣.២- ប្រទេសចិន**

**ក-ធនធានមនុស្ស:** បន្ទាប់ពីកំណែទម្រង់ទៅកាន់វិមជ្ឈការនៅមូលដ្ឋាន ជាពិសេសការប្រកាន់យកគោលការណ៍សេដ្ឋកិច្ចទីផ្សារធ្វើឱ្យប្រទេសចិនមានឱកាសកសាងធនធានមនុស្សបានគ្រប់គ្រាន់ឆ្លើយតបតាមតម្រូវការក្នុងការអភិវឌ្ឍប្រទេសជាតិ។ប្រទេសចិន ជាប្រទេសមួយបានធ្វើកំណែទម្រង់តាំងពីឆ្នាំ១៩៧៨មក។ កំណែទម្រង់នេះប្តូរពីមជ្ឈការទៅកាន់វិមជ្ឈការ លើវិស័យពីរជាសំខាន់ក្នុងនោះផ្តោតលើវិមជ្ឈការផែនការអភិវឌ្ឍ និងវិមជ្ឈការសារពើពន្ធ ជាពិសេសធ្វើឱ្យថ្នាក់មូលដ្ឋានក៏ដូចជាថ្នាក់តំបន់នៅក្នុងប្រទេសចិន បានធ្វើឱ្យមានភាពងាយស្រួលក្នុងការផ្លាស់ប្តូរបទពិសោធន៍ទាំងឡាយដែលមានការទាក់ទងដល់ការអភិវឌ្ឍ និងការរីកចម្រើននៅក្នុងមូលដ្ឋាន។ ការអនុវត្តគោលនយោបាយវិមជ្ឈការរបស់ប្រទេសចិនបាន ប្រព្រឹត្តទៅយ៉ាងប្រុងប្រយ័ត្នបំផុតដោយធ្វើការពិនិត្យឡើងវិញភ្លាមៗនៅទសវត្សរ៍ ១៩៨០ មួយឆ្នាំបន្ទាប់ពីការចាប់ផ្តើមនិងទសវត្សរ៍១៩៩០។

គោលបំណងនៃកំណែទម្រង់ដើម្បីពិនិត្យមើលទៅលើការអនុវត្តកិច្ចការជាសំខាន់មានដូចជា: កិច្ចសន្យាទទួលខុសត្រូវប្រព័ន្ធពន្ធដារទៅដល់ថ្នាក់មូលដ្ឋានការអនុវត្តបែបបទរដ្ឋបាលពីថ្នាក់តំបន់ដល់ថ្នាក់មូលដ្ឋានផ្ទាល់ ការងារអភិវឌ្ឍ និង ការប្រើប្រាស់កញ្ចប់ថវិកានៅមូលដ្ឋាន។

**ខ-ផលិតផលសរុបក្នុងស្រុកសំរាប់មនុស្សម្នាក់** (**ផ.ស.ស**) ៖ ឆ្នាំ ២០១១សម្រាប់មនុស្សម្នាក់ៗទទួលបានចំនួន៥ ៤១៧ ដុល្លារអាមេរិក នៅឆ្នាំ ២០១២ សម្រាប់មនុស្សម្នាក់ៗទទួលបានចំនួន ៦ ២០០ ដុល្លារអាមេរិក ។

**គ-ប្រព័ន្ធព័ត៌មានវិទ្យា:** ប៉ុន្មានឆ្នាំចុងក្រោយប្រទេសចិន មានការអភិវឌ្ឍយ៉ាងខ្លាំងក្លាបំផុត ដោយសារប្រព័ន្ធទំនាក់ទំនងព័ត៌មានវិទ្យា ប្រជាជាជនចិនមានសមត្ថភាពប្រើប្រាស់ព័ត៌មានវិទ្យាក្នុងអត្រា៣៨.៣០ ភាគរយ។

**៣.៣-ប្រទេសឥណ្ឌូនេស៊ី**

**ក-ផលិតផលសរុបក្នុងស្រុកសំរាប់មនុស្សម្នាក់:** ឆ្នាំ ២០១១ សម្រាប់មនុស្សម្នាក់ៗមានចំនួន ៣ ៤៩៥ ដុល្លារអាមេរិក នៅឆ្នាំ ២០១២ សម្រាប់មនុស្សម្នាក់ៗ មានចំនួន ៣ ៦០០ ដុល្លារអាមេរិក ។

**ខ-ព័ត៌មានវិទ្យា:** ប្រទេសឥណ្ឌូនេស៊ី ជាប្រទេសប្រជុំទៅដោយកោះតូចធំប្រជាជាជនមានសមត្ថភាពប្រើប្រាស់ព័ត៌មានវិទ្យាក្នុងអត្រា ១៥.៤ ភាគរយ។ ឥណ្ឌូនេស៊ី ជាប្រទេសមួយនៅក្នុងអាស៊ីអាគ្នេយ៍ កំពុងប្រកាន់គោលនយោបាយវិមជ្ឈការ និងបានជំរុញឱ្យប្រទេសមានការរីកចំរើនយ៉ាងខ្លាំងបន្ទាប់ពីប្រទេសនេះធ្វើអន្តរភាពគោលនយោបាយក្នុងអំឡុងខែឧសភាឆ្នាំ១៩៩៨ស្តីពីគម្រោងច្បាប់មួយចំនួនទាក់ទងដល់វិមជ្ឈការ។ ច្បាប់ទាំងនោះមានដូចជា: ការផ្ទេរអំណាចពីថ្នាក់កណ្តាលដល់ថ្នាក់តំបន់ ការផ្ទេរធនធានបច្ចេកវិជ្ជាព័ត៌មានវិទ្យា ការបែងចែកធនធាន ផ្តល់សិទ្ធិសំដែងមតិជាសាធារណៈ ផ្តល់សិទ្ធិស្វ័យភាពលើកម្មសិទ្ធិដីធ្លី។

គោលនយោបាយថ្មីបានកើតមានឡើងចំពោះប្រជាជនរបស់ប្រទេសនេះ។ សិទ្ធិចូលរួមជាសាធារណៈដែលជារឿយៗ នៅក្នុងការចូលរួមនេះបង្កើតឱ្យមាន ការសួរដេញដោលគ្នាយ៉ាងខ្លាំងដើម្បីរកចំណុចល្អៗព្រមទាំងដំណើរការឈានទៅតភ្ជាប់នៃការប្រគល់អំណាចជាបណ្តើរៗនៅក្នុងប្រទេសដើម្បីឱ្យមូលដ្ឋាន មានធនធានថវិកា សម្ភារៈ យកទៅធ្វើការអភិវឌ្ឍសមស្របតាមតំបន់ ឬ មូលដ្ឋានបានល្អប្រសើរ ។

ដូច្នេះប្រសិទ្ធភាពនៅក្នុងការគ្រប់គ្រងរដ្ឋបាលមូលដ្ឋានតាមគោលការណ៍វិមជ្ឈការ ពិតជាត្រូវពឹងផ្អែកលើកម្រិតជីវភាព បច្ចេកវិទ្យាព័ត៌មានទូលំទូលាយ ធនធានមនុស្ស និងពេលវេលាមួយដ៏ជាក់លាក់ ពីព្រោះតាមការស្រាវជ្រាវជាក់ស្តែងបានបង្ហាញថា ប្រសិទ្ធភាពនៃការអភិវឌ្ឍ និងការគ្រប់គ្រងរដ្ឋបាលមូលដ្ឋាន អាចកើតមានបាន ពិតប្រាកដលុះត្រាប្រជាជនក្នុងប្រទេសនោះមានចំណូល ធនធាន និងសមត្ថភាពក្នុងការប្រើប្រាស់ព័ត៌មាន ។

## ៤- សេចក្តីសន្និដ្ឋាន

ប្រសិទ្ធភាពនៃការគ្រប់គ្រងរដ្ឋបាលមូលដ្ឋាន ពីគោលនយោបាយមជ្ឈការទៅកាន់វិមជ្ឈការ ពិតជាមានការប្រែប្រួល គួរឱ្យកត់សំគាល់ទាំងការប្រតិបត្តិ ការអភិវឌ្ឍស្របតាលិខិតបទដ្ឋានគតិយុត្ត និងបទបញ្ញត្តិផ្សេងៗ។ ទន្ទឹមនឹងការប្រតិបត្តិខាងលើនៅមានបញ្ហាប្រឈមសំខាន់ៗ ចំនួនបី ជាគន្លឹះនៅក្នុងចំណោមបញ្ហាជាច្រើន ដែលមិនអាចនាំទៅរកប្រសិទ្ធភាពក្នុង ការគ្រប់គ្រងរដ្ឋបាលមូលដ្ឋានតាមបែបវិមជ្ឈការមានដូចខាងក្រោម ÷

**ក-កត្តាធនធានមនុស្សនៅមូលដ្ឋាន:** ធនធានមនុស្សគឺជាបញ្ហាប្រឈមខ្លាំង ជាពិសេសគឺការបណ្តុះបណ្តាលនៅមន្ត្រីមូលដ្ឋានឃុំ សង្កាត់ និងមន្ត្រីពាក់ព័ន្ធនៅមូលដ្ឋានផ្ទាល់។ ការផ្តល់សេវាកម្ម

សធារណៈប្រកបដោយប្រសិទ្ធភាពបានលុះត្រា មន្ត្រីមូលដ្ឋាន មានសុចន្ទៈនៅក្នុងការងារអភិវឌ្ឍក្នុងមូលដ្ឋានរបស់ខ្លួនឈរលើមូលដ្ឋានច្បាប់មានភាពទទួលខុសត្រូវ តម្លាភាព និងគណនេយ្យភាព ។

**ខ-ការផ្តត់ផ្គង់ធនធាន សម្ភារៈ ថវិកា ៖** ការផ្គត់ផ្គង់ ធនធាន សម្ភារៈ ថវិកា និងផលទុនជាតិសំរាប់មនុស្សម្នាក់ៗ ជាការចាំបាច់សំរាប់ធ្វើការងារគ្រប់គ្រងរដ្ឋបាលនៅ ឃុំ សង្កាត់ អាចបំពេញតាមលក្ខខណ្ឌការងារមួយឈានទៅរកប្រសិទ្ធភាពខ្ពស់ ។ ប្រាក់ខែ និងប្រាក់ឧបត្ថម្ភជូនមន្ត្រីផ្តល់សេវាសាធារណៈនៅមូលដ្ឋានមានកំរិតខ្លាំង ជាក់ស្តែងផលទុនជាតិសំរាប់មនុស្សម្នាក់ៗ ឬ ប្រាក់ចំណូលប្រចាំឆ្នាំរបស់មនុស្សម្នាក់ៗឆ្នាំ២០១១មានចំនួនតែត្រឹម ៩០០ដុល្លារ និង ២០១២ មានចំនួន ១ ០០០ដុល្លារប៉ុណ្ណោះ កម្រិតជីវភាពគ្រួសារពុំបានគ្រប់គ្រាន់បង្កឱ្យមានអំពើពុករលួយគ្រប់រូបភាពនៅស្ទើរពាសពេញផ្ទៃប្រទេស ។

**គ-ការចូលរួមជាសាធារណៈ:** ការចូលរួមពីប្រជាពលរដ្ឋនៅមូលដ្ឋានផ្ទាល់ ជាការចាំបាច់បំផុតសំដៅតម្លាភាព និង គណនេយ្យភាពនៅមូលដ្ឋាន*។ ដរាបណាមានការចូលរួមកាន់តែខ្លាំងពីប្រជាពលរដ្ឋដរាបនោះអំពើពុករលួយនៅមូលដ្ឋានពិត ជាអាចកាត់បន្ថយបាន និងឈានដល់ការលុបបំបាត់បានជាបន្តបន្ទាប់។

សរុបសេចក្តីមកការប្រតិបត្តិប្រព័ន្ធគ្រប់គ្រងរដ្ឋបាលតាមវិមជ្ឈការ មានប្រសិទ្ធភាពបានត្រូវជំរុញការយកចិត្តទុកដាក់លើផ្នែកធនធានមនុស្សការផ្គត់ផ្គង់សម្ភារៈ ថវិកា ផ្តល់ប្រាក់ចំណូលសមរម្យ ដល់ជីវភាពរស់នៅជាក់ស្តែង និងការចូលរួម អភិវឌ្ឍនូវគ្រប់សកម្មភាព។ ដូច្នេះដើម្បីដោះស្រាយបញ្ហាប្រឈម រដ្ឋត្រូវតែលើកទឹកចិត្តខ្ពស់ដល់មន្ត្រីបច្ចេកទេសទៅបំរើការនៅមូលដ្ឋានជាមួយ នឹងការទំលាក់ធនធានសម្រាប់បម្រើការងាររដ្ឋបាល និងថវិកាសំរាប់បម្រើកិច្ចអភិវឌ្ឍនៅតាមមូលដ្ឋានឱ្យបានគ្រប់គ្រាន់ និងធ្វើយ៉ាងណារដ្ឋាភិបាល ត្រូវមានសមត្ថភាពខ្ពស់ក្នុងការប្រមូលថវិកាជាតិ ដោយធ្វើការបែងចែកឡើង វិញនូវចំណូលចំណាយសាធារណៈប្រកបដោយគណនេយ្យភាព តម្លាភាព ដែលអាចឈានដល់ការបង្កើនផលទុនជាតិសម្រាប់ ប្រជាពលរដ្ឋម្នាក់ៗឱ្យបានសមរម្យទៅនឹងជីវភាពរស់ប្រចាំថ្ងៃ ។

© ២០១៣ រាជបណ្ឌិត្យសភាកម្ពុជា

ចំនួន ១០០០ ច្បាប់

រក្សាសិទ្ធិគ្រប់យ៉ាង គ្មានផ្នែកណាមួយនៃទស្សនាវដ្តីនេះនឹងត្រូវបានបោះពុម្ពឡើងវិញ
ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីរាជបណ្ឌិត្យសភាកម្ពុជាឡើយ

---

© 2013 Royal Academy of Cambodia

No. 1000 copies

All rights reserved. No part of this book may be reproduced, in any form, by any means, without permission in writing from Royal Academy of Cambodia.



ប្រាសាទ អង្គរវត្ត


**Royal Academy of Cambodia Review**
Russian Federation Blvd
P.O Box: 531, Phnom Penh
Kingdom of Cambodia
Tel: (855) 23 640 66 22
Fax: (855) 23 890 180
E-mail: magazinerac@yahoo.com
Website: www.rac-academy.edu.com

រាជបណ្ឌិត្យសភាកម្ពុជា
មហាវិថីសហព័ន្ធរុស្ស៊ី
ប្រអប់សំបុត្រលេខ: ៥៣១ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៦៤០ ៦៦ ២២
ទូរសារលេខ: (៨៥៥) ២៣ ៨៩០ ១៨០
អ៊ីម៉ែល / សារអេឡិចត្រូនិច: magazinerac@yahoo.com
គេហទំព័រ: www.rac-academy.edu.com